ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងយុត្តិធម៌

# កំណត់ពន្យល់មាត្រានីមួយៗ
# នៃច្បាប់ស្តីពី
# ការបង្ក្រាបអំពើជួញដូរមនុស្ស
# និង អំពើធ្វើអាជីវកម្មផ្លូវភេទ

ក្រសួងយុត្តិធម៌

unicef
unite for children

បោះពុម្ពលើកទី១: នៅរាជធានីភ្នំពេញឆ្នាំ ២០១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងយុត្តិធម៌

# កំណត់ពន្យល់មាត្រានីមួយៗ

# នៃច្បាប់ស្តីពី

# ការបង្ក្រាបអំពើជួញដូរមនុស្ស

# និង អំពើធ្វើអាជីវកម្មផ្លូវភេទ

## រៀបចំដោយក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា
## រក្សាសិទ្ធិនិពន្ធ និងថតចម្លងដោយក្រសួងយុត្តិធម៌

ការថតចម្លងផ្នែកណាមួយ ឬ ទាំងស្រុងក្នុងគោលបំណងធ្វើអាជីវកម្មត្រូវហាមឃាត់

រាល់ការចម្លងឡើងវិញដោយគ្មានការអនុញ្ញាតិពីក្រសួងយុត្តិធម៌ត្រូវហាមឃាត់ ។

ក្រសួងយុត្តិធម៌ រក្សាសិទ្ធិក្នុងការកែប្រែ និងធ្វើបច្ចុប្បន្នភាពលើឯកសារនេះ ។

## បានធ្វើសមិទ្ធិកម្មសម្រេចកំណត់ពន្យល់មាត្រានីមួយៗ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទនេះដោយៈ

១- លោកជំទាវ **ចាន់ សុខ្ខាវី** រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌

២- លោក **គី ខេមលីន** អគ្គនាយករងនៃក្រសួងយុត្តិធម៌

៣- កញ្ញា **ឡាយ លីនណា** ជំនួយការរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌

៤- លោក **Michael Lerner** ទីប្រឹក្សាផ្នែកច្បាប់

៥- លោកស្រី **Ana Janet Sunga** អ្នកជំនាញផ្នែកការពារកុមាររបស់អង្គការ យូនីសេហ្វ

៦- លោកស្រី **សូ សេរីវឌ្ឍនា** មន្ត្រីទទួលបន្ទុកផ្នែកការពារកុមាររបស់អង្គការ យូនីសេហ្វ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ចំណាប់អារម្មណ៍របស់**

**ឯកឧត្តម អង្គ វង្សវឌ្ឍនា**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាននិងកំពុងបន្តយកចិត្តទុកដាក់ខ្ពស់ ក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ផ្តើមចេញពីការយកចិត្តទុកដាក់ និងស្មារតីទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងបន្ថែមទៀត នូវការការពារសិទ្ធិ-សេរីភាព និងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក្រសួងយុត្តិធម៌ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានខិតខំធ្វើការសិក្សាស្រាវជ្រាវលើបទប្បញ្ញត្តិជាតិ-អន្តរជាតិ ដែលពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្សនេះ ដោយបានធ្វើការកែទម្រង់ច្បាប់ ឱ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

ច្បាប់ ស្តីពី " ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ " ត្រូវបានអនុម័ត ឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ និងប្រកាសឱ្យប្រើនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។

បន្ទាប់ពីច្បាប់នេះ ត្រូវបានអនុវត្ត ក្រសួងយុត្តិធម៌យល់ឃើញថា តម្រូវការចាំបាច់មួយទៀត ក្នុងការធានា និងពង្រឹងប្រសិទ្ធិភាព នៃការអនុវត្តច្បាប់ឱ្យកាន់តែប្រសើរថែមទៀតនោះ គប្បីត្រូវមានកំណត់ពន្យល់ ដើម្បីជាជំនួយផ្នែកស្មារតី សំរាប់ប្រជាពលរដ្ឋ មន្ត្រីអនុវត្តច្បាប់ទាំងអស់ និងអ្នកស្រាវជ្រាវទូទៅ ងាយយល់ ព្រមទាំងអនុវត្តឱ្យបានសមស្រប និងជៀសវាងនូវការភ័ន្តច្រឡំទៅលើខ្លឹមសារនៃបទប្បញ្ញត្តិនីមួយៗរបស់ច្បាប់ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ-សេរីភាព និងការស្វែងរកយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋ ។

ដោយមើលឃើញនូវតម្រូវការចាំបាច់នេះ **ក្រសួងយុត្តិធម៌**បានបង្កើតក្រុមការងារមួយ ដើម្បីរៀបចំកំណត់ពន្យល់នេះ ដោយសហការជាមួយនឹងអង្គការ UNICEF ហើយបច្ចុប្បន្ន **ឯកសារកំណត់ពន្យល់នៃច្បាប់ ស្តីពី " ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ "** នេះ ត្រូវបានរៀបចំរួចរាល់ជាស្ថាពរ ដែលនេះ គឺជាសមិទ្ធិផលថ្មីមួយបន្ថែមទៀត នៃកិច្ចសហការរួមគ្នា ដែលបានប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ខ្ញុំទទួលស្គាល់ថា ការរៀបចំកំណត់ពន្យល់នេះ ពុំមែនជាការងាយស្រួលឡើយ គឺជាការងារមួយដ៏ស្មុគ្រស្មាញ ដែលទាមទារនូវសមត្ថភាពខ្ពស់ ទាក់ទងទៅនឹងចំណេះដឹងផ្នែកច្បាប់ជាតិ និងអន្តរជាតិ រួមទាំងបទពិសោធន៍ជាច្រើនផងដែរ ។

នៅក្នុងដំណើរការនៃការរៀបចំឯកសារកំណត់ពន្យល់នេះ ក្រុមការងារបានរៀបចំតាក់តែង បកស្រាយទៅលើបទប្បញ្ញត្តិនីមួយៗ ស្របជាមួយគោលការណ៍នៃច្បាប់ជាតិ និងអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន និងបានធ្វើការពិនិត្យពិច័យ ប្រកបដោយភាពប្រុងប្រយត្ន័ខ្ពស់ ព្រមទាំងបានលើកយកឧទាហរណ៍ខ្លះៗ មកបញ្ជាក់បន្ថែម ដើម្បីញែកឱ្យដាច់ទៅលើខ្លឹមសារនៃបទប្បញ្ញត្តិនីមួយៗឱ្យបានច្បាស់លាស់ ។

ឯកសារកំណត់ពន្យល់នេះ ក៏ជាជំនួយផងដែរ សម្រាប់ការបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ការយល់ដឹងអំពីខ្លឹមសារនៃច្បាប់នេះ និងបទប្បញ្ញត្តិនៃច្បាប់ផ្សេងៗដែលពាក់ព័ន្ធ ។

វិធានការបន្ត ក្រោយពីបានរៀបចំបញ្ចប់នូវកំណត់ពន្យល់នេះ ក្រសួងយុត្តិធម៌នឹងធ្វើការអប់រំផ្សព្វផ្សាយកំណត់ពន្យល់ ដល់មន្ត្រីអនុវត្តច្បាប់ទាំងអស់ ឱ្យបានទូលំទូលាយនៅទូទាំងប្រទេស ។

ឆ្លៀតឱកាសនេះដែរ ក្នុងនាមក្រសួងយុត្តិធម៌ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរដោយស្មោះអស់ពីចិត្ត ដល់សមាជិក-សមាជិការ នៃក្រុមការងារ ជំនាញការជាតិ និងអន្តរជាតិ ដែលបានខិតខំយកចិត្តទុកដាក់ខ្ពស់ អត់ធ្មត់ តស៊ូ ព្យាយាម យកអស់កំលាំងកាយ និងបញ្ញាស្មារតី ក្នុងការរៀបចំកំណត់ពន្យល់នេះ បានយ៉ាងជោគជ័យ ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា កំណត់ពន្យល់នេះ នឹងក្លាយជាឧបករណ៍ដ៏មានសារៈប្រយោជន៍បំផុតសម្រាប់ជាជំនួយស្មារតី ក្នុងការអនុវត្តច្បាប់ ស្តីពី " ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ " ឱ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត ព្រមទាំងធានា និងការពារបានយ៉ាងពេញលេញនូវសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋកម្ពុជាទូទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១២

អង្គ វង្ស វឌ្ឍនា

# មាតិកា


**អារម្ភកថា** ........................................................ i

**សេចក្ដីផ្ដើម** ........................................................ ១

**និដ្ឋភាពទូទៅ** ........................................................ ១

**គោលការណ៍នៃការបកស្រាយច្បាប់** ........................................................ ៧

**ជំពូកទី ១- បទប្បញ្ញត្តិទូទៅ** ........................................................ ១១

មាត្រា ១ : គោលបំណងនៃច្បាប់នេះ ........................................................ ១១

មាត្រា ២ : ការអនុវត្តច្បាប់នេះនៅក្នុងដែនដី ........................................................ ១៤

មាត្រា ៣ : ការអនុវត្តច្បាប់នេះនៅក្រៅដែនដី ........................................................ ១៦

មាត្រា ៤ : ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ........................................................ ២០

មាត្រា ៥ : ការប្រកាសមូលទោស ........................................................ ២៦

មាត្រា ៦ : បទល្មើសត្រួតគ្នា ........................................................ ២៧

មាត្រា ៧ : និយមន័យនៃអនីតិជន ........................................................ ៣០

**ជំពូកទី ២- អំពើលក់-ដូរមនុស្ស** ........................................................ ៣៣

មាត្រា ៨ : និយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់ ........................................................ ៣៤

មាត្រា ៩ : ការនាំយកអនីតិជន ជាអាទិ៍ ចេញដោយមិនស្របច្បាប់ ........................................................ ៤១

មាត្រា ១០ : ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ........................................................ ៤៥

មាត្រា ១១ : ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ........................................................ ៥៣

មាត្រា ១២ : ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចនី ........................................................ ៥៧

មាត្រា ១៣ : និយមន័យនៃអំពើលក់-ដូរមនុស្ស ........................................................ ៦៣

មាត្រា ១៤ : អំពើលក់-ដូរមនុស្ស ........................................................ ៦៥

មាត្រា ១៥ : អំពើលក់-ដូរមនុស្សដោយមានគោលដៅ ........................................................ ៦៦

មាត្រា ១៦ : អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន ........................................................ ៧១

មាត្រា ១៧ : ការដឹកជញ្ជូនដោយមានគោលដៅ ........................................................ ៧៤

មាត្រា ១៨ : អំពើនាំឆ្លងដែន.......................................................................... ៨០

មាត្រា ១៩ : ការទទួលយកមនុស្សដោយមានគោលដៅ...................................................... ៨៤

មាត្រា ២០ : ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស................................ ៨៩

**ជំពូកទី ៣_ ការបង្ខាំង......................................................................... ៩៣**

មាត្រា ២១ : ការចាប់ពង្រត់ ការឃុំឃាំង ឬ ការបង្ខាំង............................................... ៩៣

មាត្រា ២២ : ស្ថានទម្ងន់ទោស....................................................................... ៩៧

**ជំពូកទី ៤_ អំពើពេស្យាចារ និង អំពើពេស្យាចារកុមារ........................................ ១០១**

មាត្រា ២៣ : និយមន័យនៃអំពើពេស្យាចារ និង អំពើពេស្យាចារកុមារ.................................. ១០២

មាត្រា ២៤ : អំពើអូសទាញ........................................................................... ១០៥

មាត្រា ២៥ : និយមន័យនៃសញ្ជោរកម្ម.................................................................. ១១០

មាត្រា ២៦ : សញ្ជោរកម្ម.............................................................................. ១១៨

មាត្រា ២៧ : ស្ថានទម្ងន់ទោសនៃសញ្ជោរកម្ម........................................................... ១២០

មាត្រា ២៨ : សញ្ជោរកម្មទាក់ទងនឹងពេស្យាចារកុមារ................................................... ១២៣

មាត្រា ២៩ : សញ្ជោរកម្មដោយមានការធ្វើទារុណកម្ម.................................................... ១២៤

មាត្រា ៣០ : ការដឹកនាំពេស្យាចារ.................................................................... ១២៦

មាត្រា ៣១ : ការដឹកនាំគ្រឹះស្ថានពេស្យាចារ.......................................................... ១២៨

មាត្រា ៣២ : ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ.................................................... ១៣២

មាត្រា ៣៣ : បទល្មើសទាក់ទងនឹងពេស្យាចារកុមារ...................................................... ១៣៦

មាត្រា ៣៤ : ការទិញពេស្យាចារកុមារ.................................................................. ១៣៧

មាត្រា ៣៥ : អំពើអូសទាញពេស្យាចារកុមារ............................................................ ១៤១

មាត្រា ៣៦ : ការឱ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ.................... ១៤៤

មាត្រា ៣៧ : កិច្ចសន្យានៃអំពើពេស្យាចារកុមារ........................................................ ១៤៦

**ជំពូកទី ៥_ អនាចារ និង សម្ភារៈអាសអាភាស................................................ ១៤៩**

មាត្រា ៣៨ : និយមន័យនៃរូបភាព និង សម្ភារៈអាសអាភាស.................................... ១៤៩

មាត្រា ៣៩ : រូបភាព និង សម្ភារៈអាសអាភាស.................................... ១៥០

មាត្រា ៤០ : និយមន័យនៃរូបភាព និង សម្ភារៈអាសអាភាសនៃកុមារ.................................... ១៥៣

មាត្រា ៤១ : រូបភាព និង សម្ភារៈអាសអាភាសនៃកុមារ.................................... ១៥៤

**ជំពូកទី ៦~ អំពើអាសគ្រាមប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ.................................... ១៥៩**

មាត្រា ៤២ : អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ.................................... ១៥៩

មាត្រា ៤៣ : អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ.................................... ១៦២

មាត្រា ៤៤ : ការលើកលែងពីការផ្តន្ទាទោស.................................... ១៦៦

**ជំពូកទី ៧~ សំណងរដ្ឋប្បវេណី.................................... ១៦៧**

មាត្រា ៤៥ : កិច្ចសន្យាសម្រាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ.................................... ១៦៧

មាត្រា ៤៦ : សំណងបដិទានលើការទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផល.................................... ១៦៨

មាត្រា ៤៧ : សិទ្ធិជាអាទិភាពក្នុងការទទួលបានទ្រព្យសម្បត្តិ ដែលត្រូវគេរឹបអូស.................................... ១៧០

**ជំពូកទី ៨~ ទណ្ឌបញ្ញត្តិបន្ថែម.................................... ១៧៣**

មាត្រា ៤៨ : ទោសបន្ថែម.................................... ១៧៣

មាត្រា ៤៩ : ការលាក់បាំងនូវអត្តសញ្ញាណនៃជនរងគ្រោះ.................................... ១៧៧

**ជំពូកទី ៩~ អវសានប្បញ្ញត្តិ.................................... ១៨១**

មាត្រា ៥០ : និរាករណ៍នៃច្បាប់ដែលផ្ទុយ.................................... ១៨១

មាត្រា ៥១ : ការជំនួសដោយច្បាប់ព្រហ្មទណ្ឌ.................................... ១៨៤

មាត្រា៥២ : ការអនុវត្តច្បាប់នេះ.................................... ១៨៥

## សេចក្ដីផ្ដើម

ឯកសារនេះ មានកំណត់ពន្យល់អំពីច្បាប់របស់ប្រទេសកម្ពុជា ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

កំណត់ពន្យល់នេះ មានគោលដៅ ដើម្បីប្រាប់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ ឱ្យបានដឹងអំពីគោលបំណង និងអត្ថន័យនៃបទប្បញ្ញត្តិច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ហេតុដូច្នេះ កំណត់ពន្យល់នេះ មានគោលបំណងឱ្យប្រើប្រាស់ជាឯកសារជំនួយផ្នែកស្មារតី សំរាប់មន្ត្រីយុត្តិធម៌ ព្រហ្មទណ្ឌ ឱ្យយល់ និងបញ្ជាក់ឱ្យបានច្បាស់នូវបទប្បញ្ញត្តិរបស់ច្បាប់ និងដើម្បីជួយក្រសួងដែលពាក់ព័ន្ធ ស្ថាប័ន បណ្ដុះបណ្ដាល និងដៃគូរបស់ខ្លួនក្នុងការបង្កើតឯកសារបណ្ដុះបណ្ដាល និងលើកកំពស់ការយល់ដឹងអំពី ច្បាប់ថ្មី នេះ ។

## ទិដ្ឋភាពទូទៅ

នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ព្រះរាជាណាចក្រកម្ពុជា បានប្រកាសឱ្យប្រើច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គោលបំណងនៃច្បាប់នេះ គឺ " ដើម្បី បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ " ។ អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាបទល្មើសធ្ងន់ធ្ងរ ហើយប្រជាពលរដ្ឋកម្ពុជាជាច្រើនបានទទួលរងក្លាយជាជនរងគ្រោះ និងខ្លះទៀត ក៏មានការទាក់ទិនធ្វើជាចារីប្រព្រឹត្តបទល្មើសទាំងនេះដែរ ។ ហេតុផលដូចនេះ ច្បាប់នេះបម្រើជាផលប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលរបស់ខ្លួនក្នុងការហាមឃាត់ និងបង្ក្រាបអំពើល្មើសច្បាប់ព្រហ្មទណ្ឌ បែបនេះ ។

ច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានគោលបំណងបន្ថែមទៀត : " ដើម្បីការពារសិទ្ធិ និងភាពថ្លៃថ្នូររបស់មនុស្ស និងបង្កើន លើកស្ទួយ នូវសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដើម្បីរក្សាការពារ និងលើកកំពស់នូវទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិ និងមានគោលបំណងអនុវត្តឱ្យបានសមស្របផងដែរ តាមពិធីសារអង្គការសហប្រជាជាតិ ស្ដីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្ដន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹង ឧក្រិដ្ឋកម្មឆ្លងដែន...." ។ ពិធីសារនេះ មានឈ្មោះថា ពិធីសារប៉ាឡឺម៉ូ គឺជាឧបករណ៍ច្បាប់អន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងត្រូវបានចុះហត្ថលេខា ដោយប្រទេសកម្ពុជា កាលពី ខែ ធ្នូ ឆ្នាំ ២០០៣ ។

បន្ថែមទៅនឹងការអនុវត្តកាតព្វកិច្ចរបស់ប្រទេសកម្ពុជា អនុលោមតាម ពិធីសារប៉ាឡឺម៉ូ ច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏មានគោលបំណង អនុវត្តកាតព្វកិច្ច យោងតាម " ឧបករណ៍ ឬ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀត ដែលទាក់ទងនឹងការជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានឱ្យសច្ចាប័ន ឬ ចុះហត្ថលេខា " ។ ឧបករណ៍ ឬ កិច្ចព្រមព្រៀងអន្តរជាតិទាំងនេះ រួមមាន ជាពិសេសដូចជា អនុសញ្ញាស្ដីពី សិទ្ធិកុមារ និងពិធីសារតាមជំរើសទាក់ទងនឹងអនុសញ្ញា ស្ដីពី សិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និង

រូបភាព ឬ សម្ភារៈអាសអាភាសកុមារ អនុសញ្ញាស្តីពី ការប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មផ្សេងទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប និងអនុសញ្ញា ស្តីពី ការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងស្ត្រីភេទ ។

ប្រទេសកម្ពុជាក៏ជាភាគី នៃអនុស្សារណៈ នៃការយោគយល់គ្នា ស្តីពី កិច្ចសហប្រតិបត្តិការ ប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់ទន្លេមេគង្គ ក្រោមការសម្របសម្រួល ស្តីពីគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីនៅតំបន់ទន្លេមេគង្គប្រឆាំងនឹងអំពើជួញដូរ ដែលរួមមាន សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពភូមា ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ក៏ជាភាគីដែរ ។

## ប្រវត្តិនៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវរៀបចំឡើងដោយក្រសួងយុត្តិធម៌ ដោយបានចាប់ផ្តើមក្នុងអំឡុង ឆ្នាំ១៩៩៩ ដោយមានការរួមសហការជាមួយ វិទ្យាស្ថានអភិវឌ្ឍន៍ផ្នែកច្បាប់នៃប្រទេសជប៉ុន (Institute of Japanese Legal Development) និងដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពី អង្គការ **យូនីសេហ្វ** ដើម្បីជំនួស "ច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើ មនុស្ស ឆ្នាំ១៩៩៦ " ដោយច្បាប់ថ្មីមួយដែលកែប្រែច្បាប់ចាស់ឱ្យស្របទៅតាមអនុសញ្ញា ស្តីពី សិទ្ធិកុមារ និងពិធីសារតាមជំរើសទាក់ទងនឹងអនុសញ្ញាស្តីពី សិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព ឬ សម្ភារៈអាសអាភាសកុមារ ដែលប្រទេសកម្ពុជា បានចុះហត្ថលេខា កាលពីខែ មិថុនា ឆ្នាំ ២០០០ ។ ប្រទេសកម្ពុជា មានកាតព្វកិច្ចថ្មីបន្ថែមទៀត យោងតាមច្បាប់អន្តរជាតិ ច្បាប់ថ្មីនេះ មានគោលបំណងជាក់លាក់ជាងច្បាប់ ឆ្នាំ ១៩៩៦ ដែលមនុស្សជាច្រើនចាត់ទុកថា មិនច្បាស់ ដោយសារមាននិយមន័យ និងបទល្មើស ទូលំទូលាយពេក ។

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានរៀបចំព្រាងជាដំបូងដោយក្រុមការងារដែលមានសមាសភាព មន្ត្រីក្រសួងយុត្តិធម៌ ០៣ រូប និងទីប្រឹក្សាបច្ចេកទេសផ្នែកច្បាប់អន្តរជាតិ ០១ រូប ។ បន្ទាប់ពីបានរៀបចំជាសេចក្តីព្រាងហើយនោះ ក្រុមការងារក៏បានដាក់សេចក្តីព្រាងនោះ ជូនក្រុមការងារដែលបានបង្កើតថ្មីមួយទៀត ដែលមានសមាសភាពជា : ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីផ្នែកច្បាប់នៃក្រសួងយុត្តិធម៌ តុលាការកំពូល សាលាឧទ្ធរណ៍ សាលាដំបូងក្រុងភ្នំពេញ សាលាដំបូងខេត្តកណ្តាល ចំនួន ១២ រូប ដើម្បីពិភាក្សា និងពិគ្រោះយោបល់ទៅលើសេចក្តីព្រាងដែលបានរៀបចំរួចនោះ ដោយធ្វើការពិនិត្យទៅលើខ្លឹមសារ នៃបទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ មួយមាត្រាម្តងៗ ជាច្រើនលើកច្រើនសារ រហូតបានបញ្ចប់បទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ទាំងមូល ទើបយកសេចក្តីព្រាងនោះ ទៅដាក់ឱ្យផ្តល់មតិយោបល់នៅក្នុងអង្គសិក្ខាសាលាថ្នាក់ជាតិ ស្តីពី " អំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទ " ដែលបានធ្វើឡើង កាលពីខែ សីហា ឆ្នាំ ២០០២ នៅរាជធានីភ្នំពេញ ដោយមានការចូលរួមជាច្រើនដែលអញ្ជើញមកពី រដ្ឋសភា ព្រឹទ្ធសភា ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ជាតិ-អន្តរជាតិ ហើយអនុសាសន៍ដែលបានទទួលពីអង្គសិក្ខាសាលានោះ ត្រូវបានយកមកពិចារណាដើម្បីដាក់បញ្ចូល និងកែសម្រួល នៅក្នុងសេចក្តីព្រាងច្បាប់នេះ ដោយអ្នកជំនាញជាតិ និងអន្តរជាតិចំនួន ៣ រូប គឺលោក **Yoichi Yamada**

ជំនាញការច្បាប់នៃប្រទេសជប៉ុន ឯកឧត្តម ហ៊ី សោភា លោកជំទាវ ចាន់ សុទ្ធាវី និងមានលោក សេង ពុទ្ធី ជាជំនួយការ ។ បន្ទាប់មកទៀត សេចក្តីព្រាងច្បាប់នេះ ត្រូវបានដាក់ឱ្យមានការពិភាក្សាក្នុងក្រុមការងារ ដែលមានសមាសភាព ចំនួន ១២ រូប នោះ ម្តងទៀត ។ ក្រោយពីបានសំរេចពីក្រុមការងារ ទើបបញ្ជូនទៅគណៈរដ្ឋមន្ត្រី ក្នុងខែមីនា ឆ្នាំ ២០០៣ ។

នៅក្នុងកិច្ចប្រជុំអន្តរក្រសួងនៅគណៈរដ្ឋមន្ត្រី ក្នុងអំឡុងឆ្នាំ ២០០៤ មានការស្នើសុំឱ្យបំពេញបន្ថែមនូវចំណុចខ្លះទៀត ហេតុនេះក្រសួងយុត្តិធម៌បានយកសេចក្តីព្រាងច្បាប់នោះមកកែសម្រួលបំពេញបន្ថែម តាមការស្នើសុំ។ បន្ទាប់ពីបានកែសម្រួលតាមការស្នើសុំក្នុងកិច្ចប្រជុំអន្តរក្រសួងនៅគណៈរដ្ឋមន្ត្រីរួចហើយ ក្រសួងយុត្តិធម៌បានរៀបចំសិក្ខាសាលាម្តងទៀត នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៦ នៅរាជធានីភ្នំពេញ ហើយក្រុមការងាររបស់ក្រសួងយុត្តិធម៌ បានធ្វើការពិនិត្យឡើងវិញ ទៅលើសេចក្តីព្រាងទាំងមូល ដោយបានបញ្ចប់ និងបញ្ជូនទៅគណៈរដ្ឋមន្ត្រីដើម្បីដាក់ប្រជុំអន្តរក្រសួងម្តងទៀត ។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានអង្គប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រីសំរេច នាថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ ។

ច្បាប់នេះ ក៏ត្រូវបានអនុម័ត ដោយរដ្ឋសភាជាតិ នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ និងដោយព្រឹទ្ធសភា នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ និងត្រូវបាន ឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើ ដោយព្រះមហាក្សត្រ នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។

បន្ទាប់ពីការអនុម័តច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងឆ្នាំ ២០០៨ រួចមក ក្រសួងយុត្តិធម៌ ( ឯកឧត្តម អង្គ វង្ស វឌ្ឍានា , ឯកឧត្តម ហ៊ី សោភា , លោកជំទាវ ចាន់ សុទ្ធាវី ) មានគំនិតផ្តួចផ្តើមរៀបចំនូវកំណត់ពន្យល់ ដើម្បីជាជំនួយផ្នែកស្មារតី សម្រាប់មន្ត្រីអនុវត្តច្បាប់ទាំងអស់ អនុវត្តឱ្យបានសមស្របទៅតាមខ្លឹមសារនីមួយៗនៃបទប្បញ្ញត្តិច្បាប់ ហើយក៏បានទំនាក់ទំនងធ្វើកិច្ចសហប្រតិបត្តិការ ជាមួយនឹងអង្គការ **យូនីសេហ្វ** ជាបន្តទៀត ក្នុងការរៀបចំកំណត់ពន្យល់នេះ ដោយមានការគាំទ្រយ៉ាងពេញទំហឹងពី លោក Richard Bridle ជាប្រធានអង្គការ **យូនីសេហ្វ** និងលោកស្រី Lesley Miller ប្រធានផ្នែកកិច្ចការពារកុមារ នៃអង្គការយូនីសេហ្វ ប្រចាំកម្ពុជា ។

ដើម្បីឱ្យដំណើរការក្នុងការរៀបចំកំណត់ពន្យល់នេះ ឱ្យបានជោគជ័យ ក្រសួងយុត្តិធម៌បានបង្កើតក្រុមការងារ ដោយមានថ្នាក់ដឹកនាំនៃក្រសួងយុត្តិធម៌ ប្រធានសាលាឧទ្ធរណ៍ ប្រធានតុលាការក្រុងភ្នំពេញ ដែលសុទ្ធតែជាអ្នកមានសមត្ថភាព និងបទពិសោធន៍ខ្ពស់ ធ្វើការពាក់ព័ន្ធទៅនឹងកិច្ចការនេះ និងមានការចូលរួមពីតំណាងក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ផងដែរ ។

ក្រុមការងារនេះ បានបង្កើតតាមប្រកាសលេខ ៤០ កយ.ប្រក/០៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩ ដែលមានសមាសភាព :

១-ឯកឧត្តម **អង្គវង្ស វឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាប្រធាន

២-ឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ អនុប្រធាន

| | | | |
|---|---|---|---|
| ៣-លោកជំទាវ | **ចាន់ សុខន្ធាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធានទទួលបន្ទុកគំរោង |
| ៤-ឯកឧត្តម | **យូ ប៊ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ | សមាជិក |
| ៥-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | | | សមាជិក |
| ៦-រដ្ឋលេខាធិការក្រសួងកិច្ចការនារី | | | សមាជិក |
| ៧-ឯកឧត្តម | **ជីវ កេង** | ប្រធានសាលាដំបូងក្រុងភ្នំពេញ | សមាជិក |
| ៨-លោក | **គី ខេមលីន** | អគ្គនាយករងក្រសួងយុត្តិធម៌ | សមាជិកអចិន្ត្រៃយ៍ |

និងមានការចូលរួមពីជំនាញការផ្នែកច្បាប់អន្តរជាតិ គឺលោក **Yoichi Yamada** ដែលជាអ្នកចូលរួមក្នុងការរៀបចំច្បាប់ ស្តីពី " ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ " តាំងពីដំណាក់កាលដំបូងនៃការរៀបចំសេចក្តីព្រាង ព្រមទាំងមានការចូលរួមពីលោក **Michael Lerner** ទីប្រឹក្សាការពារផ្នែក ច្បាប់ស្តីពីកំណត់ពន្យល់នេះ ការចូលរួមពីកញ្ញា **Ana Janet Sunga** ជាអ្នកជំនាញផ្នែកកិច្ចការពារកុមារ និងលោក **កែវ សុខគា** និងលោកស្រី **សូ សេរីវឌ្ឍនា** ជាមន្ត្រីទទួលបន្ទុកផ្នែកការពារកុមារ និងលោក **ណុប តុងហៃ** ជាអ្នកបកប្រែ ។

## ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅក្នុងក្របខណ្ឌច្បាប់កម្ពុជា

ក្រោយពីច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចូលជាធរមានគេអាចយល់បានយ៉ាងពេញលេញ ប្រសិនបើពិចារណាច្បាប់នេះ នៅក្នុងក្របខណ្ឌច្បាប់កម្ពុជា ដែលឈរលើបរិបទទូលំទូលាយ ។

នៅក្នុងពេលរៀបចំ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពេលនោះក្រមព្រហ្មទណ្ឌ នៅជាសេចក្តីព្រាងនៅឡើយ ហើយពេលនោះ **សេចក្តីព្រាងក្រមព្រហ្មទណ្ឌក៏**សំខាន់ដែរ ទោះបីជាវាគ្រាន់តែជាសេចក្តីព្រាងហើយកំពុងតែ ដំណើរការបង្កើត តែវាមានឥទ្ធិពលយ៉ាងធំធេងទៅលើការធ្វើសេចក្តីព្រាង នៃច្បាប់នេះ ( ឧទាហរណ៍ : នៅក្នុងបទល្មើស ជាច្រើន ដែលទាក់ទងនឹងអំពើធ្វើអាជីវកម្មផ្លូវភេទ ) និងច្បាប់ផ្សេងនានាទៀត ។

ក្រុមរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានធ្វើការពិនិត្យដោយប្រុងប្រយ័ត្នលើសេចក្តីព្រាងច្បាប់ និងច្បាប់ទាំងនេះ និងច្បាប់ផ្សេងៗទៀតរបស់កម្ពុជា ព្រមទាំងបទប្បញ្ញត្តិនៃច្បាប់អន្តរជាតិ ដែលពាក់ព័ន្ធ នឹងច្បាប់នៃប្រទេសនានាមួយចំនួនទៀត ។

គួរកត់សំគាល់ផងដែរថា : ជាការសំខាន់ ច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាផ្នែកមួយនៃច្បាប់ព្រហ្មទណ្ឌ ពោលគឺ ឱ្យនិយមន័យបទល្មើសជាច្រើន ដែលត្រូវគេយល់ថាទាក់ទងទៅនឹងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ហើយបង្កើតឱ្យមានទណ្ឌកម្ម ( ការពិន័យជាប្រាក់ និង/ឬ ទោសជាប់ពន្ធនាគារ ) ចំពោះអ្នកដែលត្រូវបានរកឃើញថា មានទោសពីបទល្មើសទាំងនេះ ។ ចំណែកឯច្បាប់ប្រឆាំងអំពើជួញដូរ

នៅក្នុងប្រទេសផ្សេងខ្លះទៀត មានចែងទូលំទូលាយជាងនេះ ឧទាហរណ៍ : ដូចជាបទប្បញ្ញត្តិ ស្តីពីការការពារជនរងគ្រោះ ករណីនេះមិនមានចែងនៅក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទរបស់ប្រទេសកម្ពុជាឡើយ ។ យ៉ាងណាក៏ដោយ នៅពេលអនាគតប្រទេសកម្ពុជា អាចនឹងរៀបចំច្បាប់ ឬ បទប្បញ្ញត្តិ ស្តីពីការការពារជនរងគ្រោះ ឬ ទិដ្ឋភាពផ្សេងទៀត ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ។ រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្តីសម្រេច និងគោលការណ៍ណែនាំស្តីពីការការពារជនរងគ្រោះ ។

ឧទាហរណ៍ : ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានចេញសេចក្តីសម្រេច ស្តីពី គោលការណ៍ណែនាំសម្រាប់ការការពារសិទ្ធិរបស់កុមារដែលត្រូវជួញដូរ នៃព្រះរាជាណាចក្រកម្ពុជា ( សេចក្តីសម្រេចលេខ ១០៧ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ )។ ឆ្នាំដដែលនោះ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះកិច្ចព្រមព្រៀង ជាមួយអង្គការមិនមែនរដ្ឋាភិបាល ចំនួន ២៤ ស្តីពី គោលការណ៍ណែនាំអនុវត្ត និងកិច្ចសហការរវាង ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និងបណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើររឿងក្តីជួញដូរមនុស្ស ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។ រដ្ឋាភិបាលកម្ពុជា ក៏បានបង្កើតគោលនយោបាយ និងបទដ្ឋានអប្បបរិមា ស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស លេខ ០៦២ ស.វ.យ នាថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ។

ប្រទេសកម្ពុជា ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិ ដែលមានបទប្បញ្ញត្តិ ស្តីពី ការការពារជនរងគ្រោះ ។

ឧទាហរណ៍ : ក្នុងឆ្នាំ ២០០៧ ប្រទេសកម្ពុជាបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងតំបន់អាស៊ាន ស្តីពី ការការពារជនរងគ្រោះកុមារ ដោយអំពើជួញដូរ ។[១]

មុនឆ្នាំ ២០០៧ ប្រទេសកម្ពុជាក៏បានចុះហត្ថលេខាលើ អនុស្សារណៈ នៃការយោគយល់គ្នា ជាមួយប្រទេសថៃឡង់ដ៏[២] និងវៀតណាម[៣] ព្រមទាំងកិច្ចព្រមព្រៀងតំបន់ នៅមហាអនុតំបន់ ទន្លេមេគង្គ ។[៤]

---

[១] គោលការណ៍ណែនាំអាស៊ីអាគ្នេយ៍ សម្រាប់ការការពារសិទ្ធិ របស់ជនរងគ្រោះជាកុមារដោយអំពើជួញដូរ ( ខែ ធ្នូ ឆ្នាំ ២០០៧) ។

[២] អនុស្សារណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៏ ស្តីពី កិច្ចសហប្រតិបត្តិការ ទ្វេភាគី សម្រាប់លុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះ ដោយសារអំពើជួញដូរ ដែលបានចុះហត្ថលេខានៅខេត្តសៀមរាប នៅថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ ២០០៣ ។ កិច្ចព្រម ព្រៀងនេះ ត្រូវបានបន្ថែមដោយគោលការណ៍ណែនាំ សម្រាប់កិច្ចសហប្រតិបត្តិការ រវាងប្រទេសកម្ពុជា និងប្រទេសថៃឡង់ដ៏ ស្តីពី ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ នៃបទល្មើសដែលទាក់ទងនឹងអំពើជួញដូរ ។

[៣] កិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញ ដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះ ដោយសារអំពើជួញដូរ ដែលត្រូវបាន ចុះហត្ថលេខា នៅទីក្រុងហាណូយនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥។

[៤] អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់ទន្លេមេគង្គដែលត្រូវបានចុះហត្ថលេខាដោយ រដ្ឋាភិបាលនៃព្រះរាជាណាចក្រម្ពុជា ក្នុងទីក្រុងរ៉ាំងហ្គូន ប្រទេសភូមា នៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤។

កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពី នីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ដោយសារអំពើជួញដូរ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ។[៥]

នៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គេបានកំណត់និយមន័យបទល្មើសឱ្យស្ថិតក្នុងលក្ខណៈចង្អៀត និងច្បាស់លាស់ (ប្រៀបធៀបទៅនឹងពិធីសារប៉ាឡឺម៉ូ) ។ ឧទាហរណ៍ : ពិធីសារប៉ាឡឺម៉ូ បង្ហាញជាគំនិត " អំពើជួញដូរមនុស្ស " ថាជាបន្សំនៃ *អំពើ មធ្យោបាយ* និង*បំណង* ដ៏ជាក់លាក់ ។ និយមន័យនៃអំពើ ជួញដូរមនុស្ស របស់ពិធីសារនេះ រាប់បញ្ចូលអំពើជាច្រើនទៀត ដូចជា " ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ជម្រក ឬ ការទទួលមនុស្ស " ។ ផ្ទុយទៅវិញ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្យាយាម បែងចែកដោយឡែក នូវអំពើទាំងនេះឱ្យទៅជាបទល្មើសផ្សេងទៀត ។ ហេតុដូច្នេះជំពូកទី ២ នៃច្បាប់នេះ បែងចែក ឱ្យឃើញភាពខុសគ្នា រវាងបទល្មើស ការនាំយកចេញដោយមិនស្របច្បាប់ ការជ្រើសរើស ដោយមិនស្របច្បាប់ អំពើ លក់-ដូរមនុស្ស ការដឹកជញ្ជូនជនរងគ្រោះ ដោយអំពើជួញដូរ និងការទទួលយកជនរងគ្រោះ ដោយអំពើជួញដូរ ។ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដាក់បញ្ចូលឱ្យដាច់ដោយឡែក នូវដំណាក់កាលនីមួយៗនៃនិយមន័យអំពើជួញដូរមនុស្ស របស់ពិធីសារប៉ាឡឺម៉ូ ដោយចែងអំពីបទល្មើសផ្សេងគ្នា និងទណ្ឌកម្មផ្សេងគ្នា ។

ដូចគ្នានេះដែរ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បែងចែកដាច់ដោយឡែកពីគ្នា នូវបទល្មើសធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសរួមភេទជាមួយអនីតិជន ។ យោងតាមច្បាប់ ប្រឆាំងនឹងអំពើជួញដូរ ឆ្នាំ ១៩៩៦ មានតែបទល្មើស អំពើអនាចារជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ តែមួយគត់ ដែលបានចែងអំពី ទណ្ឌកម្មដូចគ្នា ចំពោះជនល្មើសទាំងអស់ ដែលត្រូវផ្តន្ទាទោសពីបទមានទំនាក់ទំនងផ្លូវភេទ ជាមួយអនីតិជនអាយុក្រោម១៥ ឆ្នាំ ដោយមិនគិតពីប្រភេទនៃទំនាក់ទំនងទាំងនោះ ។ ផ្ទុយទៅវិញ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងអំពីបទល្មើសជាក់លាក់មួយចំនួន ដែលទាក់ទងនឹងការរួមភេទ ជាមួយអនីតិជន ដែលរួមមានការទិញពេស្យាចារកុមារ អំពើអាសជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ ហើយបទល្មើសនីមួយៗ មានការដាក់ទណ្ឌកម្មផ្សេងៗគ្នា ជាច្រើន ។

លទ្ធផលមួយនៃការកំណត់ឱ្យបានច្បាស់លាស់ទៅលើបទល្មើស គឺថា នគរបាល ព្រះរាជអាជ្ញា និងចៅក្រមត្រូវតែធ្វើការកំណត់ឱ្យប្រយ័ត្នប្រយែងទាក់ទងទៅនឹងអ្វីដែលជាបទល្មើសដ៏សមរម្យបំផុត ដើម្បីធ្វើការស៊ើបអង្កេត ចោទប្រកាន់ និងកាត់ទោសជនជាប់ចោទ។ យើងសង្ឃឹមថា កំណត់ពន្យល់ទាំងនេះ នឹងជួយបញ្ជាក់ឱ្យបានច្បាស់ នូវបញ្ហាទាំងនោះ ក្នុងចំណោមកិច្ចការផ្សេងទៀត ។

---

[៥] កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណៈរដ្ឋសង្គមនិយមវៀតណាមស្តីពី នីតិវិធីប្រតិបត្តិ បទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ដោយសារអំពើជួញដូរ ខែ ធ្នូ ឆ្នាំ ២០០៩ ។

## គោលការណ៍នៃការបកស្រាយច្បាប់

មិនថាដំណើរការធ្វើច្បាប់ប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយ អ្នកធ្វើសេចក្ដីព្រាងច្បាប់ថ្មីនេះ មិនអាចមើលឃើញជាមុន នូវស្ថានការណ៍ទាំងអស់ ដែលនឹងកើតឡើងចៀសមិនរួច ហើយដែលនឹងតម្រូវឱ្យប្រព័ន្ធតុលាការ ដែលរួមមាន ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ធ្វើការត្រួតពិនិត្យ និងបកស្រាយច្បាប់ដើម្បីអនុវត្ត ឱ្យស្របទៅតាមអង្គហេតុ ។

ច្បាប់ទាំងអស់ មិនថាច្បាប់ស៊ីវិល ឬ ច្បាប់អង្គនីតិវិធីសុង ប្រឈមមុខនឹងឧបសគ្គទាំងនេះ ហើយអ្នកជំនាញខាងច្បាប់ បានបង្កើតនូវឧបករណ៍មួយចំនួន ដើម្បីជួយពួកគេក្នុងការបកស្រាយច្បាប់ ។ គោលការណ៍ខ្លះៗ នៃការបកស្រាយច្បាប់អាចផ្សេងគ្នាពីយុត្តាធិការមួយ ទៅយុត្តាធិការមួយផ្សេងទៀត ប៉ុន្តែមានគោលការណ៍គ្រឹះជាច្រើន ដែលត្រូវបានទទួលយកទូលំទូលាយជុំវិញពិភពលោក ។ ផ្នែកនេះ នឹងត្រួតពិនិត្យឡើងវិញ នូវគោលការណ៍ជាមូលដ្ឋានខ្លះៗនៃការបកស្រាយច្បាប់ ដែលនាំផ្លូវទៅដល់ការបង្កើត កំណត់ពន្យល់ទាំងនេះ ។

***គោលការណ៍មានគោលបំណង*** ( *purposive principle* ) បញ្ជាក់ថា នៅពេលបកស្រាយបទប្បញ្ញត្តិច្បាប់ គួរតែនាំទៅរកលទ្ធផលដែលស្រប និងមិនផ្ទុយពីគោលបំណង និងកម្មវត្ថុនៃច្បាប់នោះ ។ ចំពោះច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មាត្រា ១ ចែងពី គោលបំណងរបស់ច្បាប់នេះ យ៉ាងច្បាស់ ។ ភាពស្របគ្នាទៅតាមគោលបំណងដែលបានបញ្ជាក់នេះ គួរតែជាការបកស្រាយដែលត្រូវយកមកពិនិត្យមុនគេ មុននឹងធ្វើការបកស្រាយឈរលើគោលការណ៍ផ្សេងៗទៀត ។

***ភាពស្របគ្នាផ្ទៃក្នុង*** ( *internal consistency* ) គួរតែចងចាំនៅពេលធ្វើការបកស្រាយបទប្បញ្ញត្តិច្បាប់ណាមួយ ។ នៅពេលដែលបទប្បញ្ញត្តិ ឬ ពាក្យច្បាប់ ត្រូវតែធ្វើការបកស្រាយ ( ប្រហែលដោយសារ វាមិនច្បាស់ មិនបានឱ្យនិយមន័យ ឬ ដោយសារតែបទប្បញ្ញត្តិនេះត្រូវតែអនុវត្ត នៅក្នុងស្ថានការណ៍ដែលអ្នកធ្វើសេចក្ដីព្រាង មិនអាចព្យាករណ៍ជាមុន ) ការបកស្រាយនេះ គួរតែធ្វើឡើងកុំឱ្យផ្ទុយពីរបៀបដែលបទប្បញ្ញត្តិ ឬ ពាក្យច្បាប់ ដែលប្រើនៅកន្លែងផ្សេង នៅក្នុងច្បាប់ដដែល ។

**គោលបំណងទីពីរ គឺ** *ភាពស្របគ្នាទៅនឹងច្បាប់ផ្សេងទៀត នៅក្នុងយុត្តាធិការដូចគ្នា* ។ នៅពេលបក ស្រាយច្បាប់ កិច្ចខិតខំប្រឹងប្រែងទាំងអស់គួរតែធ្វើឡើង ដើម្បីធានាថាការបកស្រាយបទប្បញ្ញត្តិ ឬ ពាក្យណាមួយ កុំឱ្យផ្ទុយទៅនឹងរបៀបដែលបទប្បញ្ញត្តិ ឬ ពាក្យ ដែលប្រើនៅកន្លែងផ្សេងទៀត នៅក្នុងអង្គច្បាប់ដែលកំពុងអនុវត្ត ។ ចំពោះហេតុផលនេះ ការពិនិត្យច្បាប់ដែលពាក់ព័ន្ធទាំងអស់មានសារៈសំខាន់ណាស់ ។ ក្នុងការបង្កើត កំណត់ពន្យល់នេះ ជាការសំខាន់ត្រូវពិនិត្យឡើងវិញ នូវបទប្បញ្ញត្តិនៃច្បាប់កម្ពុជាដែលពាក់ព័ន្ធជាច្រើន រួមមាន : រដ្ឋធម្មនុញ្ញ ច្បាប់ព្រហ្មទណ្ឌ (រួមមានក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ) ច្បាប់ ស្ដីពីរបបសារព័ត៌មាន ច្បាប់ស្ដីពីការងារ ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងអនុក្រឹត្យ ប្រកាស សារាចរ និងគោលការណ៍ណែនាំ ជាច្រើនទៀត ។

ប្រសិនបើ ច្បាប់មានប្រធានបទផ្សេងៗគ្នា នៅក្នុងសំណុំច្បាប់ពិតជានឹងកើតមាននូវភាពមិនស្របគ្នា អំពីរបៀបដែលច្បាប់ប្រើបទប្បញ្ញត្តិ និងពាក្យដូចគ្នា ។ នៅពេលដែលមានឃើញភាពមិនស្របគ្នាបែបនេះ វិធានដែល

ត្រូវទទួលយកជាទូទៅ គឺថាឧបករណ៍ច្បាប់ដែលមានឋានៈខ្ពស់ជាង នឹងមានអាទិភាពលើឧបករណ៍ច្បាប់ដែលមានឋានៈទាបជាង ។ គួរតែចងចាំនូវវិធាន ពីរ នៅពេលដែលមានភាពមិនស្របគ្នា រវាងបទប្បញ្ញត្តិនៃឧបករណ៍ច្បាប់ដែលមានកំរិតដូចគ្នា :

១) ថ្មី និង ចាស់ ។ ច្បាប់ដែលថ្មីជាង នឹងមានអាទិភាពលើច្បាប់ដែលចាស់ជាង ។

២) ពិសេស និង ទូទៅ ។ ច្បាប់ពិសេស និងមានអាទិភាពលើច្បាប់ទូទៅ ។

ក្នុងករណីដែលច្បាប់ថ្មី ដែលជាច្បាប់ទូទៅមានបទប្បញ្ញត្តិ មិនស្របគ្នាដោយប្រយោលទៅនឹង ច្បាប់ចាស់ដែលជាច្បាប់ពិសេស ហេតុដូច្នេះ ច្បាប់ថ្មី នឹងមានអាទិភាព ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើច្បាប់ទូទៅថ្មី មានភាពស្ងប់ស្ងាត់ ដោយមិនបានចែង ទៅលើបញ្ហាជាក់លាក់ណាមួយ តែបញ្ហាទាំងនោះ មានចែងក្នុងច្បាប់ពិសេសចាស់ ( ហេតុដូច្នេះច្បាប់ទូទៅថ្មី និងច្បាប់ពិសេសចាស់ មិនមានទំនាស់នឹងគ្នា ទៅលើបញ្ហាទាំងនេះ ) ហេតុដូច្នេះ បទប្បញ្ញត្តិនៃច្បាប់ពិសេសចាស់ ដែលជាទូទៅ ត្រូវចាត់ទុកថានៅតែមានសុពលភាព ។

គោលការណ៍នៃការបកស្រាយច្បាប់ទាំងនេះ ជួយដោះស្រាយភាពមិនស្របគ្នារវាង ឧទាហរណ៍ : មាត្រា ២២ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលដាក់ទោសអស់មួយជីវិតចំពោះការបង្ខាំងដែលមានស្ថានទម្ងន់ ) និងមាត្រា ៧ នៃច្បាប់ចាស់ ស្តីពីស្ថានទម្ងន់ទោស (ដែលអនុញ្ញាតឱ្យបទល្មើសដូចគ្នា ត្រូវដាក់ទោសជាប់ពន្ធនាគាររយៈពេល ១៥ ឆ្នាំ )។ ដោយសារតែ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅទីនេះជាច្បាប់ថ្មី ហើយអាចអះអាងថា មានលក្ខណៈជាច្បាប់ពិសេសជាង ច្បាប់ចាស់ ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ បទប្បញ្ញត្តិអំពីទោសបញ្ញត្តិ ក្នុងមាត្រា ២២ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានអាទិភាពលើបទប្បញ្ញត្តិ ក្នុងមាត្រា ៧ នៃច្បាប់ចាស់ ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ឧទាហរណ៍មួយទៀត : ក្រមព្រហ្មទណ្ឌថ្មី ដែលបានចូលជាធរមាន យ៉ាងពេញលេញនៅខែ ធ្នូ ឆ្នាំ២០១០ គឺជាច្បាប់មួយដែលត្រូវបានអនុម័តក្រោយពីច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហើយដែលច្បាប់ព្រហ្មទណ្ឌថ្មីនោះ អាចមានបទប្បញ្ញត្តិដែលអាចចែងមានទំនាស់ទៅនឹង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ យោងទៅតាមក្រមព្រហ្មទណ្ឌ (គន្ថីទី ៦ "អវសានប្បញ្ញត្តិ" មាត្រា ៦៧១ " និរាករណ៍ និងអានុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន " ) បទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌដែលចូលជាធរមានពីមុន ដែលមិនស្របគ្នាទៅនឹងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មី ត្រូវចាត់ទុកថាមិនមានសុពលភាព ចំពោះតែបទប្បញ្ញត្តិណាដែលមិនស្របគ្នាតែប៉ុណ្ណោះ ។ យោងទៅតាមនោះដែរ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងនៅតែជាធរមានដដែល តែបើបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានទំនាស់គ្នាទៅនឹងបទប្បញ្ញត្តិដែលមានចែងនៅក្នុង ក្រមព្រហ្មទណ្ឌ បទប្បញ្ញត្តិដែលមានចែងនៅក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងត្រូវបានជំនួសតែពាក្យណាដែលផ្ទុយគ្នាប៉ុណ្ណោះ ។

យ៉ាងណាមិញ ចំពោះអំពើល្មើសដែលទាក់ទងនឹងបទល្មើសជួញដូរមនុស្ស ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អាចត្រូវយកមកប្រើ ទោះបីជាមានទំនាស់គ្នាទៅនឹង បទប្បញ្ញត្តិនៃក្រម ព្រហ្មទណ្ឌ យោងតាមការទទួលស្គាល់ គោលការណ៍នៃការបកស្រាយច្បាប់ ដែលថាជាទូទៅ ច្បាប់ពិសេសមានអាទិភាពទៅលើច្បាប់ទូទៅ ។ គួរកត់សំគាល់ថា ក្រមព្រហ្មទណ្ឌដែលមិនមានចែងពីបទល្មើស " ជាក់លាក់ " ទាក់ទងនឹងការជួញដូរមនុស្ស ហេតុដូច្នេះហើយ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅតែជាច្បាប់គោល គ្រប់គ្រងទៅលើបទល្មើសដែលទាក់ទងទៅនឹងការជួញដូរមនុស្ស ។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌ ទទួលស្គាល់ឧត្តមភាព នៃច្បាប់ពិសេស ដែលមានទៅលើច្បាប់ទូទៅនៅក្នុងមាត្រា ៦៦៨ (ការអនុវត្តបទប្បញ្ញត្តិ ព្រហ្មទណ្ឌដោយឡែក) គន្ថីទី ៥ "អន្តរប្បញ្ញត្តិ" ដែលចែងថា :

*"ចំពោះបទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសដោយច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌ ដោយឡែកផ្សេងទៀត ដែលកំពុងនៅជាធរមាន ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះ ។*

*នៅក្នុងករណីដែលមានទំនាស់រវាងច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក និងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវអនុវត្តដោយអនុលោមតាមវិធានដែលមានចែងក្នុងគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ។*[6]

*បទប្បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើ មិនត្រូវយកមកអនុវត្ត ចំពោះច្បាប់ព្រហ្មទណ្ឌ ដែលមានចរិត ពិសេស ។"*

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អាចត្រូវគេចាត់ទុកថាជាច្បាប់ព្រហ្មទណ្ឌពិសេសដោយផ្អែកទៅលើគោលបំណងរបស់ច្បាប់ដែលមានចែងនៅក្នុងមាត្រា ១ " បង្ក្រាបអំពើជួញដូរមនុស្ស " និងដើម្បី " អនុវត្តឱ្យបានសមស្របផងដែរ តាមពិធីសារអង្គការ សហប្រជាជាតិ ស្តីពីការទប់ស្កាត់ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ " ។ យោងតាមនោះផងដែរ ក្នុងពេលមានទំនាស់គ្នា ដោយផ្ទាល់យ៉ាងច្បាស់ រវាងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ និងបទប្បញ្ញត្តិ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចំពោះករណីដែលទាក់ទងនឹងអំពើជួញដូរមនុស្ស នៅតែត្រូវអនុវត្តបទប្បញ្ញត្តិ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ជាចុងក្រោយ ជាការសំខាន់ណាស់ក្នុងការចងចាំថា ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាមានអត្ថិភាព នៅក្នុងក្របខណ្ឌច្បាប់អន្តរជាតិដ៏ទូលំទូលាយ ដែលប្រទេសកម្ពុជា មានកាតព្វកិច្ចមួយចំនួនយោងតាមច្បាប់អន្តរជាតិ ។ រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ទទួលស្គាល់កាតព្វកិច្ចទាំងនេះ តាមរយៈមាត្រា ៣១ ដែលចងកាតព្វកិច្ច " ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកល ស្តីពី សិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹង សិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ " ។ បទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញនេះ បង្កើតឱ្យមានកាតព្វកិច្ចផ្អែកច្បាប់ ដែលប្រទេសកម្ពុជាត្រូវបំពេញ ក្នុងការ

---

[6] យោងតាមក្រមព្រហ្មទណ្ឌ គន្ថីទី ១ "បទប្បញ្ញត្តិទូទៅ" មាតិកាទី ១ ជំពូកទី ២ មាត្រា ១០ (ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬធ្ងន់ជាង) *"បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម.........បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។"*

ដាក់បញ្ចូលសិទ្ធិទាំងនេះទៅក្នុងច្បាប់ជាតិ ដូច្នេះហើយ ត្រូវធានាថា ច្បាប់របស់ខ្លួន ត្រូវធ្វើការបកស្រាយ ដើម្បីកុំឱ្យច្បាប់នោះ មានភាពមិនស្របគ្នា ជាមួយកាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិ ទាំងនេះ ។ វិធីសាស្ត្រនេះ ត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាធម្មនុញ្ញរបស់ប្រទេសកម្ពុជា ដែល (ថ្មីៗនេះ នៅក្នុងសេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧) បានបកស្រាយច្បាប់កម្ពុជា ដើម្បីឱ្យច្បាប់នោះ ស្របទៅតាមសិទ្ធិមនុស្សអន្តរជាតិ ។

ចំណុចជាចុងក្រោយនេះ ពាក់ព័ន្ធសំខាន់ណាស់នៅពេលធ្វើការបកស្រាយច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយសារតែច្បាប់នេះ មានគោលបំណងច្បាស់លាស់ក្នុងការអនុវត្ត ពិធីសារអន្តរជាតិ (ពិធីសារប៉ាឡឺម៉ូ)។ ការបង្កើតកំណត់ពន្យល់នេះ មានបញ្ចូលការពិនិត្យមើលឡើងវិញ ដោយប្រយ័ត្នប្រយែង ទៅលើឧបករណ៍អន្តរជាតិដែលពាក់ព័ន្ធ ហើយអ្នកធ្វើសេចក្តីព្រាងនៃឯកសារនេះ លើកទឹកចិត្ត តុលាការ នៅពេលស្នើឱ្យបកស្រាយច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឱ្យពិនិត្យមើលអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ និងបកស្រាយច្បាប់ ក្នុងលក្ខណៈស្របទៅនឹងបទប្បញ្ញត្តិ របស់ពិធីសារ ឬអនុសញ្ញាទាំងនោះ ។

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

ជំពូកទី ១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានបញ្ចូលគោល-បំណងរបស់ច្បាប់ ការអនុវត្តច្បាប់នៅក្នុងដែនដី និងនៅខាងក្រៅដែនដី របស់ប្រទេសកម្ពុជា គោលការណ៍ដែលពាក់ព័ន្ធមួយចំនួន នៃច្បាប់ព្រហ្មទណ្ឌកម្ពុជា និងនិយមន័យនៃអនីតិជន យោងតាមច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**មាត្រា ១.- គោលបំណងនៃច្បាប់នេះ**

**ច្បាប់នេះ មានគោលបំណងបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបង្កើននូវសុខភាព និងសុខមាលភាព របស់ប្រជាពលរដ្ឋ និង រក្សាការពារ លើកកម្ពស់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិ និងមានគោលបំណងអនុវត្តឱ្យបានសមស្របផងដែរ តាមពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ឬ ឧបករណ៍ ឬ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត ទាក់ទងនឹងការជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជា បានឱ្យសច្ចាប័ន ឬ ចុះហត្ថលេខា។**

មាត្រានេះ ពន្យល់អំពី កម្មវត្ថុ និងគោលបំណងនៃច្បាប់នេះ ។ មាត្រានេះ អំពាវនាវឱ្យមានការអនុវត្តពិធីសារអង្គការសហប្រជាជាតិ ស្តីពី ការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ដែលនៅក្នុងកំណត់ពន្យល់នេះ ហៅថា " ពិធីសារប៉ាឡឺម៉ូ " បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (ដែលនៅក្នុងកំណត់ពន្យល់នេះ ហៅថា " អនុសញ្ញាឧក្រិដ្ឋកម្មឆ្លងដែន " ) ។ ពិធីសារប៉ាឡឺម៉ូ ត្រូវបានអនុម័តជាដំបូងឡើង ដោយអង្គការសហប្រជាជាតិ នៅទីក្រុងប៉ាឡឺម៉ូ ប្រទេសអ៊ីតាលី ក្នុងឆ្នាំ ២០០០ ។ ក្រោយមកទៀត ពិធីសារនេះ បានចូលជាធរមាន នៅខែធ្នូ ឆ្នាំ ២០០៣ ។ មកដល់ ឆ្នាំ ២០០៦ ពិធីសារ ប៉ាឡឺម៉ូ ត្រូវបានចុះហត្ថលេខាដោយ រដ្ឋ ចំនួន ១១៧ និងបានឱ្យសច្ចាប័នដោយ រដ្ឋ ចំនួន ១០០ ។ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើពិធីសារនេះ នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៣ និងបានសន្យាអនុវត្តបទប្បញ្ញត្តិ របស់ពិធីសារនេះ តាមរយៈច្បាប់នេះ ។

គោលបំណងរបស់ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺទូលំទូលាយបន្តិចជាង គោលបំណង នៃពិធីសារប៉ាឡឺម៉ូ ។

**" ដើម្បី បង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ "**

ពិធីសារប៉ាឡឺម៉ូ កំណត់និយមន័យ និងហាមឃាត់អំពើជួញដូរមនុស្ស ប៉ុន្តែ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និយាយវែងជាងនេះ ដោយសារតែច្បាប់នេះ ក៏កំណត់និយមន័យ និងផ្តន្ទាទោស

ចំពោះបទល្មើសមួយចំនួនដែលទាក់ទងនឹង អំពើធ្វើអាជីវកម្មផ្លូវភេទ ។ ជាទូទៅ បទល្មើសទាំងនេះ មិនមានឃើញ នៅក្នុងពិធីសារ ប៉ាឡឺម៉ូ ទេ ។

ជាការសំខាន់ក្នុងការបញ្ជាក់ឱ្យបានច្បាស់នូវប្រភេទនៃបទល្មើសជួញដូរមនុស្ស និងបទល្មើសធ្វើអាជីវកម្មផ្លូវភេទ ដោយសារបទល្មើសទាំងពីរនេះ ជូនកាលកើតឡើងជាមួយគ្នា និងជូនកាលកើតឡើងដាច់ដោយឡែកពីគ្នា ។ ឧទាហរណ៍ : ប្រភេទបទល្មើសទាំងពីរនេះ កើតឡើងជាមួយគ្នា ក្នុងករណីដែលជនងាយរងគ្រោះ ដោយអំពើជួញដូរ (ជាទូទៅ ស្ត្រីក្មេងៗ និងកុមារ ) ត្រូវបានគេជួញដូរឱ្យធ្វើការងារផ្លូវភេទ ក្នុងគោលបំណងធ្វើអាជីវកម្មផ្លូវភេទ។ ប៉ុន្តែក៏មានករណីជាច្រើនទៀត នៃអំពើជួញដូរដែលមិនជាប់ទាក់ទងនឹងអំពើធ្វើអាជីវកម្មផ្លូវភេទ ដូចជា ជនដែលត្រូវគេជួញដូរ ឱ្យធ្វើការងារក្នុងស្ថានភាពបង្ខំ ដែលមិនទាក់ទងនឹងការងារផ្លូវភេទ ឬ អំពើធ្វើអាជីវកម្មផ្លូវភេទ ឡើយ ។ ឧទាហរណ៍ : មានករណីជាច្រើន ដែលត្រូវគេចងក្រងជាឯកសារ នៃប្រជាជនកម្ពុជា ដែលត្រូវគេជួញដូរឱ្យធ្វើការងារដោយបង្ខំ នៅលើទូកនេសាទ ឬ ជាអ្នកបម្រើ ឬ ឈ្នួលក្នុងផ្ទះ ។ ដូចគ្នានេះដែរ បទល្មើសអាជីវកម្មផ្លូវភេទ អាចកើតឡើង ដោយមិនមានអំពើជួញដូរមនុស្ស ដូចជាករណី រូបភាព និងសម្ភារៈអាសអាភាស ឬ ទំនាក់ទំនងផ្លូវភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ ។

**" ដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់មនុស្ស ដើម្បីបង្កើននូវសុខភាព និងសុខមាលភាព របស់ប្រជាពលរដ្ឋ "**

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានគោលបំណងមួយទៀត ដើម្បីការពារសិទ្ធិមនុស្ស និងបង្កើននូវសុខភាព និងសុខមាលភាព របស់ប្រជាពលរដ្ឋ ។ នៅពេលធ្វើការបកស្រាយបទប្បញ្ញត្តិ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គួរតែចងចាំគោលបំណងនេះ និងរាល់ការបកស្រាយទាំងអស់ ដែលថាលទ្ធផល គួរតែស្របនឹងការការពារសិទ្ធិមនុស្ស និង ការបង្កើននូវសុខភាព និងសុខមាលភាព របស់ប្រជាពលរដ្ឋ ។ ជាចុងក្រោយ ជាការសំខាន់ណាស់ ក្នុងការការពារជនរងគ្រោះដោយសារអំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រសើរជាងធ្វើការផ្តន្ទាទោសទៅលើបទល្មើស ឬ សកម្មភាពណាមួយ ដែលទាក់ទងនឹងអំពើជួញដូរនេះ ។

**" ដើម្បីអនុវត្តឱ្យបានសមស្របផងដែរ តាមពិធីសារអង្គការសហប្រជាជាតិ ស្តីពី ការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោស ការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន "**

ការអនុវត្តពិធីសារអង្គការសហប្រជាជាតិ ស្តីពី ការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ( " ពិធីសារប៉ាឡឺម៉ូ " ) គឺជាគោលបំណងដ៏សំខាន់ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើ

ជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។ ក្រោយពីប្រទេសកម្ពុជា បានចុះហត្ថលេខាលើ ពិធីសារប៉ាឡឺម៉ូ នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៣ សេចក្តីព្រាងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបាន កែប្រែ ដើម្បីឱ្យស្របនឹងបទប្បញ្ញត្តិ នៃពិធីសារប៉ាឡឺម៉ូ ។ មានន័យថា នៅពេលដែលមានសំនួរកើតឡើង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវតែធ្វើការបកស្រាយ និងអនុវត្ត នៅក្នុងលក្ខណៈឱ្យស្របទៅតាមពិធីសារប៉ាឡឺម៉ូ ។

## " ឬ ឧបករណ៍ ឬ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងការជួញដូរមនុស្ស "

ទាក់ទងនឹងគោលបំណងបច្ចុប្បន្ន ឧបករណ៍ ឬ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតទាំងនេះ រួមមាន ជាអាទិ៍ អនុសញ្ញា ស្តីពី ការប្រឆាំងការធ្វើទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប និងអនុសញ្ញា ស្តីពី ការលប់បំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងស្ត្រីភេទ និង អនុសញ្ញាស្តីពី សិទ្ធិកុមារ ។ ប្រទេសកម្ពុជា ក៏ជាភាគីនៃអនុស្សារណៈនៃការយោគយល់គ្នា ស្តីពី កិច្ចសហប្រតិបត្តការប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់ទន្លេមេគង្គ ដែរ ។

បទប្បញ្ញត្តិនេះ ស្របនឹងរដ្ឋធម្មនុញ្ញកម្ពុជា ។ រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា នៅក្នុងមាត្រា ៣១ កថាខ័ណ្ឌទី ១ ចែងថា :

*" ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស កតិកាសញ្ញា ព្រមទាំងអនុសញ្ញា ទាំងឡាយ ទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ "*

នៅខែ កក្កដា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានអះអាងបញ្ជាក់ លើការស្នើសុំឱ្យមានការធ្វើសេចក្តីសម្រេច ដែលទាក់ទងនឹងភាពមិនស្របគ្នារវាង មាត្រា ៨ នៃច្បាប់ចាស់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ (ឆ្នាំ ២០០២) ទៅនឹងកាតព្វកិច្ចរបស់ប្រទេសកម្ពុជា យោងតាមអនុសញ្ញា ស្តីពីសិទ្ធិកុមារ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យទៅលើញត្តិរបស់សង្គមស៊ីវិល ដែលបានធ្វើការជំទាស់នឹងមាត្រា ៨ នៃច្បាប់ចាស់ ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលបានរំលោភ លើរដ្ឋធម្មនុញ្ញ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបានចែងថា " ទោសដាក់ពន្ធនាគារកុមារ ត្រូវធ្វើឡើងជាវិធានការចុងក្រោយ និង ក្នុងរយៈពេលដែលសមរម្យខ្លីបំផុត " ។ រីឯមាត្រា ៨ នៃច្បាប់ចាស់ ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ បានដកអំណាចរបស់ ចៅក្រមក្នុងការបន្ថយទោស លើជនល្មើស (ជនល្មើសទូទៅដែលរួមទាំងអនីតិជន) ដែលជាប់ទោសពីបទឧក្រិដ្ឋ ។

នៅមុនពេលមានច្បាប់ចាស់ ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ នេះ បើយោងតាមច្បាប់ព្រហ្មទណ្ឌ និង នីតិវិធី ព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល (ច្បាប់អ៊ុនតាក់) នៅពេលធ្វើការផ្តន្ទាទោសចៅក្រមត្រូវពិចារណាលើអាយុ ថាជាស្ថានសម្រាលទោស ហើយធ្វើការបន្ធូរបន្ថយ ទោសពាក់កណ្តាល នៅពេលធ្វើការដាក់ទោសមកលើអនីតិជន ។ ប៉ុន្តែក្រោយពីបានអនុម័តច្បាប់ចាស់ ស្តីពី ស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ឆ្នាំ ២០០២ កុមារ

ជាច្រើនត្រូវបានត្រូវបានផ្តន្ទាទោស ជាប់ពន្ធនាគាររយៈពេលវែង ដែលវិសមមាត្រទៅ នឹងអាយុរបស់កុមារ និង បទល្មើសដែលកុមារនោះបានប្រព្រឹត្ត ។

ក្នុងការធ្វើសេចក្តីសម្រេចលើញត្តិនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានរកឃើញថា ច្បាប់របស់ប្រទេសកម្ពុជា បាន បញ្ចូលសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាជាភាគីនៃសន្ធិសញ្ញានេះ ហើយសន្ធិសញ្ញាទាំងនោះ ត្រូវអនុវត្ត ដោយផ្ទាល់ចំពោះការជំនុំជំរះក្តីរបស់តុលាការក្នុងស្រុក ។ ក្រុមប្រឹក្សាធម្មនុញ្ញបានកត់សំគាល់ថា *"....នៅពេល ការជំនុំជំរះក្តី ជាគោលការណ៍ ចៅក្រម....ក៏ផ្អែកលើច្បាប់ ។ ពាក្យច្បាប់ នៅទីនេះ សំដៅលើច្បាប់ជាតិ ដែលរួមមានរដ្ឋធម្មនុញ្ញ ដែលគឺជាច្បាប់កំពូល និងច្បាប់ជាធរមានផ្សេងទៀត ព្រមទាំង អនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជា បានទទួលស្គាល់..."*

*ហេតុដូច្នេះចៅក្រមអាចយកសេចក្តីសម្រេចនេះមកប្រើសម្រាប់ការ សម្រេចសេចក្តីក្រោយៗទៀត ដោយមានការសម្រាលទោសទៅលើ អនីតិជនដែលប្រព្រឹត្តបទល្មើស ដោយផ្អែកលើ អនុសញ្ញា ស្តីពី សិទ្ធិកុមារ ។*

ហេតុដូច្នេះ នៅពេលអនុវត្តច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្ម ផ្លូវភេទ តុលាការគួរតែ ពិចារណាលើសន្ធិសញ្ញាទាំងនេះ ក្នុងករណីដែលសន្ធិសញ្ញាពាក់ព័ន្ធ និង ចូលរួមចំណែកទប់ស្កាត់ និង បង្ក្រាប រាល់ប្រភេទនៃការជួញដូរមនុស្ស និងការពារជនរងគ្រោះដោយសារការជួញដូរនេះ ។

## មាត្រា ២.. ការអនុវត្តច្បាប់នេះនៅក្នុងដែនដី

**ច្បាប់នេះត្រូវអនុវត្តទៅលើបទល្មើស ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។**

**ដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងច្បាប់នេះ រួមបញ្ចូលទាំងនាវា ឬ អាកាសយានណាមួយដែលមានសិទ្ធិប្រើប្រាស់ទង់ជាតិកម្ពុជា ។**

**បទល្មើសមួយត្រូវចាត់ទុកថា បានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើរួមផ្សំណាមួយនៃបទល្មើសនោះកើតឡើងនៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ។**

មាត្រានេះចែងពី ការអនុវត្តនៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងក៏បានពង្រីកនិយមន័យ នៃយុត្តាធិការដែនដីរបស់ប្រទេសកម្ពុជា ក្នុង គោលបំណងអនុវត្តច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ជាការសំខាន់ ផងដែរ ក្នុងការកត់សំគាល់ថា មាត្រានេះផ្តល់ការអនុវត្តនៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្ម ផ្លូវភេទ ទោះបីជាមានធាតុផ្សំតែមួយគត់ នៃបទល្មើសកើតឡើង នៅក្នុងដែនដីនៃប្រទេសកម្ពុជា ។

គួរកត់សំគាល់ថា ទោះយ៉ាងណាក៏ដោយ មាត្រា ៥១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា មាត្រានេះនឹងត្រូវជំនួស នៅពេលដែល ក្រមព្រហ្មទណ្ឌ ត្រូវប្រកាសឱ្យប្រើ ។ (សូមពិនិត្យមើល ការពិភាក្សាយោងតាមមាត្រា ៥១ ខាងក្រោម ) ។ មាត្រា ២ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានភាពស្របគ្នាទៅនឹងក្រមព្រហ្មទណ្ឌថ្មី (គន្ថីទី ១ មាតិកាទី ១ ផ្នែកទី ១ "បទល្មើស

ដែលបានប្រព្រឹត្ត ឬ ចាត់ថាបានប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា " ជាពិសេស មាត្រា ១៣ ( " ទីកន្លែងប្រព្រឹត្តបទល្មើស " ) មាត្រា ១៤ ( " បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា " ) និងមាត្រា ១៦ ( "បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា" ) នៃក្រមព្រហ្មទណ្ឌ ។

**" បទល្មើសណាមួយ ដែលត្រូវបានប្រព្រឹត្តឡើង នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា "**

មាត្រានេះចែងថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវអនុវត្តទៅលើបទល្មើសណាមួយ ។ ច្បាប់អ៊ុនតាក់ នៅពេលដែលកំពុងនៅជាធរមាន នៅពេលដែលច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានប្រកាសឱ្យប្រើ បានបែងចែកបទល្មើសជាពីរប្រភេទ គឺបទល្មើសឧក្រិដ្ឋ និងបទល្មើសមជ្ឈិម ។ ផ្ទុយទៅវិញ ក្រមព្រហ្មទណ្ឌ បែងចែកបទល្មើសជាបីប្រភេទ គឺបទល្មើសឧក្រិដ្ឋ មជ្ឈិម និងលហុ ។ ទោះជាយ៉ាងណាក៏ដោយ ការបែងចែកឱ្យដាច់នេះ មិនទាក់ទងនឹងបទល្មើសណាមួយដែលមានការកំណត់និយមន័យ ក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជាទេ ដូចមាត្រានេះចែងថា រាល់គ្រប់បទល្មើសបែបនេះ អាចត្រូវផ្តន្ទាទោស ។

**" ដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងច្បាប់នេះ រួមបញ្ចូលទាំងនាវា ឬ អាកាសយានណាមួយ ដែលមានសិទ្ធិប្រើប្រាស់ទង់ជាតិកម្ពុជា "**

ប្រសិនបើបទល្មើស ( ឬ អំពើរួមផ្សំ ឬ ធាតុផ្សំសត្យានុម័តនៃបទល្មើស សូមពិនិត្យមើលខាងក្រោម ) ដែលមានការកំណត់និយមន័យក្នុងច្បាប់នេះ កើតឡើងនៅលើនាវា ដែលមានដោតទង់ជាតិកម្ពុជា ឬ អាកាសយានដែលមានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា ហេតុដូច្នេះ ត្រូវអនុវត្តច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ មិនថាឡើយ តើ នាវា ឬ អាកាសយាន នោះស្ថិតកន្លែងណាមួយនៅពេលនោះ ។ ទោះបីជា នាវា ឬ អាកាសយាននោះ ស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ នៅពេលមានបទល្មើស ឬ អំពើមួយកើតឡើង ច្បាប់នេះនៅតែមាន យុត្តាធិការយ៉ាងសមរម្យ លើបទល្មើសនោះ ។

**" បទល្មើសមួយត្រូវចាត់ទុកថា បានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើ រួមផ្សំណាមួយនៃបទល្មើសនោះកើតឡើង នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា "**

កថាខ័ណ្ឌទី ៣ នៃមាត្រានេះ សំខាន់ណាស់ ដូចដែលមាត្រានេះ ពង្រីកការអនុវត្តនៃច្បាប់នេះ នៅក្នុងលក្ខណៈជាមូលដ្ឋានគ្រឹះ ។ បទប្បញ្ញត្តិនេះមានន័យថា បទល្មើសមួយត្រូវចាត់ទុកថា បានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា នៅពេលដែលគ្រប់ផ្នែកទាំងអស់ ឬ ផ្នែកណាមួយនៃបទល្មើសត្រូវបានប្រព្រឹត្តឡើង នៅក្នុងប្រទេសកម្ពុជាពោលគឺ នៅពេលដែលមានធាតុផ្សំសត្យានុម័តណាមួយនៃបទល្មើស ត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា ។

គួរកត់សំគាល់ នេះមានន័យថា បទល្មើសមួយដែលកើតឡើង ត្រូវតែមានធាតុផ្សំនៃបទល្មើសទាំងអស់ ប៉ុន្តែ មិនចាំបាច់ធាតុផ្សំទាំងអស់នោះ ត្រូវប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជាទេ ។

ឧទាហរណ៍ : មាត្រា ១៩ នៃច្បាប់នេះ ផ្តន្ទាទោសជនណា ដែលទទួលយកជនរងគ្រោះ ដោយសារការនាំយកចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ ។ ប្រសិនបើ ជនល្មើសម្នាក់ នៅក្នុងប្រទេសថៃឡង់ដ៏ ទទួលយកជនរងគ្រោះដោយសារការនាំយកចេញ ដោយមិនស្របច្បាប់ ពីកន្លែងមួយក្នុងប្រទេសកម្ពុជា តុលាការកម្ពុជា ត្រូវមានយុត្តាធិការ ទៅលើជនល្មើសនោះ ដោយសារតែធាតុផ្សំសត្យានុម័តមួយនៃបទល្មើស (ការនាំយកចេញជនរងគ្រោះដោយមិនស្របច្បាប់) បានកើតឡើង នៅក្នុងប្រទេសកម្ពុជា ទោះបីជាបទល្មើសនោះត្រូវបានប្រព្រឹត្តនៅប្រទេសថៃឡង់ដ៏ក៏ដោយ និងហេតុដូច្នេះយោងតាម មាត្រានេះ ត្រូវតែអនុវត្តច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។

ពាក្យថា " អំពើរូមផ្សំ " និង " ធាតុផ្សំ " ត្រូវគេយល់ថា សំដៅទៅលើធាតុផ្សំសត្យានុម័តនៃបទល្មើស មិនមែនជាធាតុផ្សំអត្តនោម័ត ដែលជាចេតនារបស់ជនល្មើសទេ ។

ជាការសំខាន់គួរកត់សំគាល់ថា អំពើមួយ ឬ ច្រើន មិនចាំបាច់ត្រូវបានប្រព្រឹត្តឡើងដោយ ឬ ទៅលើជនណាម្នាក់ ដែលមានសញ្ជាតិកម្ពុជាទេ ។ មាត្រានេះ សំដៅលើយុត្តាធិការដែនដី និងដូច្នេះ សញ្ជាតិរបស់ជនល្មើស និង/ឬ ជនរងគ្រោះមិនពាក់ព័ន្ធទេ មានតែបញ្ហាមួយគត់ គឺថា តើអំពើរូមផ្សំមួយ ឬ ច្រើន នៃបទល្មើសបានកើតឡើងនៅក្នុងដែនដីរបស់ប្រទេសកម្ពុជា ។

**មាត្រា ៣.- ការអនុវត្តច្បាប់នេះនៅក្រៅដែនដី**

**ច្បាប់នេះត្រូវអនុវត្តទៅលើបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលត្រូវបានប្រព្រឹត្តឡើង នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពលរដ្ឋខ្មែរ ។**

**ច្បាប់នេះអនុវត្តទៅលើបទឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលត្រូវបានប្រព្រឹត្តឡើង នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយជនបរទេស ហើយជនរងគ្រោះគឺជាពលរដ្ឋខ្មែរ នៅពេលដែលបទល្មើសកើតឡើង ។**

មាត្រានេះចែងពី ការអនុវត្តច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលទាក់ទងនឹងបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្តឡើង នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងស្រុង ប្រសិនបើជនល្មើស ឬ ជនរងគ្រោះជាពលរដ្ឋខ្មែរ ។

មាត្រានេះ មិនមានន័យថា អំណាចនគរបាល ឬ តុលាការកម្ពុជា នឹងត្រូវអនុវត្តនៅក្នុងដែនដីនៃរដ្ឋ បរទេសទេ ។ ប៉ុន្តែប្រទេសកម្ពុជាអាចជ្រើសរើសធ្វើការចោទប្រកាន់ និង ផ្តន្ទាទោស ទៅលើបទល្មើស យោងតាម ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ប្រសិនបើ នៅពេលដែលជនល្មើសចូលមកក្នុង ប្រទេស

កម្ពុជា ។ នេះស្របទៅនឹងគោលការណ៍ដែលទទួលយកនៃច្បាប់អន្តរជាតិ ដែលថា រដ្ឋមួយ ជាទូទៅមិនអនុវត្តច្បាប់របស់ខ្លួន នៅក្នុងដែនដីនៃរដ្ឋបរទេសទេ ។ ប៉ុន្តែអាចជ្រើសរើសផ្តន្ទាទោសទៅលើបទល្មើស នៅពេលដែលជនល្មើសនោះ ចូលមកក្នុងយុត្តាធិការនៃរដ្ឋរបស់ខ្លួន ។

ទោះជាយ៉ាងណាក៏ដោយ ស្ថិតក្រោមកាលៈទេសៈមួយចំនួន និង/ឬ ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធ អាជ្ញាធរកម្ពុជា ក៏អាចជ្រើសរើសស្វែងរកការធ្វើបត្យាប័ន ឬ ផ្ទេរជនល្មើសដែលជាប់ចោទ ដើម្បីឱ្យជននោះអាចត្រូវកាត់ទោស នៅក្នុងតុលាការកម្ពុជា ។ ការធ្វើបត្យាប័ន ឬ ការផ្ទេរបែបនេះជាទូទៅ ត្រូវគ្រប់គ្រងដោយ សន្ធិសញ្ញា ឬ អនុស្សារណៈ ស្តីពី ការយោគយល់គ្នា ដែលត្រូវបានចុះហត្ថលេខា ជាមួយប្រទេស ដែលប្រទេសកម្ពុជា ស្វែងរកការធ្វើបត្យាប័ន ឬ ផ្ទេរជនជាប់ចោទពីប្រទេសនោះ ។ យ៉ាងណាមិញ បន្ថែមនឹងបញ្ហាច្បាប់ដែលពាក់ព័ន្ធ ការសម្រេចចិត្តក្នុងការស្វែងរក ឬ ផ្តល់បត្យាប័ន មានឥទ្ធិពលនយោបាយ និងការទូតយ៉ាងខ្លាំង ហេតុដូច្នេះ ជាទូទៅការធ្វើបែបនេះ ហួសពីវិសាលភាពនៃឯកសារនេះ ។

គួរកត់សំគាល់ផងដែរ មាត្រា ៥១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា មាត្រានេះ នឹងត្រូវជំនួស នៅពេលក្រមព្រហ្មទណ្ឌចូលជាធរមាន និងអនុវត្ត។ (សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៥១ ខាងក្រោម)។ ក្រមព្រហ្មទណ្ឌថ្មី (គន្ថីទី ១ មាតិកាទី ១ ជំពូកទី ៣ ផ្នែកទី ២ "បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃ ព្រះរាជាណាចក្រកម្ពុជា" បានកំរិតវិសាលភាព នៃការអនុវត្ត ច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ នៅខាងក្រៅដែនដីនៃប្រទេសកម្ពុជា ។

ឧទាហរណ៍ : មាត្រា ១៩ ("បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ") នៃក្រមព្រហ្មទណ្ឌចែងថា :

*"ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋ ដែលប្រព្រឹត្ត ដោយពលរដ្ឋ ខ្មែរ នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្ត ដោយពលរដ្ឋខ្មែរនៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ ។"*

*ផ្ទុយទៅវិញ នៅក្នុងមាត្រា ៣ កថាខ័ណ្ឌទី ១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា :*

*"ច្បាប់នេះត្រូវអនុវត្តទៅលើបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលត្រូវបានប្រព្រឹត្តឡើង នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពលរដ្ឋខ្មែរ ។"*

លើសពីនេះទៀត មាត្រា ២០ (ជនរងគ្រោះជាជនជាតិខ្មែរ) នៃច្បាប់ព្រហ្មទណ្ឌថ្មី ចែងថា :

*"ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដី នៃព្រះរាជាណាចក្រកម្ពុជា ដោយពលរដ្ឋខ្មែរ ឬ ដោយជនបរទេស ទៅលើជនរងគ្រោះ ដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។"*

ហេតុដូច្នេះ យោងតាមមាត្រា ២០ នៃច្បាប់ព្រហ្មទណ្ឌប្រទេសកម្ពុជា រួមទាំងច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនគ្របដណ្ដប់ទៅលើបទល្មើសមជ្ឈិម និងបទលហុណា ដែលបានប្រព្រឹត្តមកលើពលរដ្ឋកម្ពុជានៅខាងក្រៅប្រទេសកម្ពុជានោះទេ ។

## " បទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ "

បទប្បញ្ញត្តិនេះ មានន័យថា ច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងអនុវត្តបានចំពោះតែបទល្មើស ដែលប្រព្រឹត្តនៅខាងក្រៅដែនដីនៃប្រទេសកម្ពុជា ប្រសិនបើបទល្មើសទាំងនោះ ត្រូវចាត់ចូលក្នុងប្រភេទ បទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម ។ ច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងមិនត្រូវអនុវត្ត ចំពោះបទល្មើសស្រាលជាងនេះ (ដូចជា អំពើអូសទាញ ដូចមានការកំណត់និយមន័យ ក្នុងមាត្រា ២៤ ) ដែលត្រូវប្រព្រឹត្តឡើង នៅខាងក្រៅដែនដីនៃប្រទេសកម្ពុជា ។

ទោះបីជាយ៉ាងណាក៏ដោយ គួរតែកត់ សំគាល់ថា នៅពេលដែលក្រមព្រហ្មទណ្ឌថ្មីចូលជាធរមាន ច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងលែងអនុវត្តទៅលើបទល្មើសមជ្ឈិមណា ដែលប្រព្រឹត្តនៅខាងក្រៅប្រទេសកម្ពុជា តទៅទៀតហើយ ។ លើកលែងតែបទមជ្ឈិមនោះត្រូវបានប្រព្រឹត្តដោយពលរដ្ឋកម្ពុជានៅក្រៅប្រទេសកម្ពុជា ហើយបទល្មើសនោះ មានចែងនិងត្រូវទទួលទោសទៅតាមច្បាប់នៃប្រទេសនោះ ដូច្នេះហើយជនល្មើសអាចត្រូវផ្ដន្ទាទោសនៅប្រទេសកម្ពុជា បានតាមច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។

## " បានប្រព្រឹត្តនៅខាងក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា "

មាត្រា ២ ចែងរួចរាល់ហើយថា នៅពេលអំពើរួមផ្សំ ឬ ធាតុផ្សំសត្យានុម័តនៃបទល្មើស ត្រូវប្រព្រឹត្តឡើងនៅក្នុងដែនដី ( ដែលរួមមាន នាវា ឬ អាកាសយានដែលមានទង់ជាតិ ) នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា បទល្មើសនោះ ត្រូវបានប្រព្រឹត្តឡើង នៅក្នុងប្រទេសកម្ពុជា ហេតុដូច្នេះត្រូវតែអនុវត្ត ច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។ ដូច្នេះ មាត្រានេះ សំដៅទៅលើស្ថានការណ៍ ក្នុងករណីដែល អំពើរួមផ្សំទាំងអស់ ឬ ធាតុផ្សំនៃបទល្មើស ត្រូវបានប្រព្រឹត្តឡើងនៅក្រៅដែនដីកម្ពុជា ។ ក្នុងកាលៈទេសៈបែបនេះ ច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ នឹងអនុវត្តក្នុងកាលៈទេសៈពីរ :

១) ក្នុងករណីដែលបទល្មើសត្រូវប្រព្រឹត្តដោយពលរដ្ឋខ្មែរ ឬ

២) ក្នុងករណីដែលជនរងគ្រោះ គឺជាពលរដ្ឋខ្មែរ នៅពេលដែលប្រព្រឹត្តបទល្មើស ។

កាលៈទេសៈទាំងនេះ ត្រូវពិពណ៌នា យ៉ាងលំអិតជាងនេះ នៅខាងក្រោម ។

## " ត្រូវប្រព្រឹត្ត.....ដោយពលរដ្ឋខ្មែរ "

បទប្បញ្ញត្តិ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវតែអនុវត្ត ក្នុងករណី នរណាម្នាក់ដែលគឺជាពលរដ្ឋកម្ពុជា ប្រព្រឹត្តបទល្មើសទៅលើជនបរទេស ហើយការប្រព្រឹត្តបទល្មើសនោះ កើតឡើងនៅខាងក្រៅប្រទេសកម្ពុជា ។ នេះគឺជាការបង្ហាញយ៉ាងច្បាស់ *អំពីគោលការណ៍សញ្ជាតិ* ដែលជាគោលការណ៍ ត្រូវទទួលយកយ៉ាងទូលំទូលាយ នៅក្នុងច្បាប់អន្តរជាតិ ដែលតាមគោលការណ៍នោះ រដ្ឋ ព្យាយាមធ្វើការផ្តន្ទាទោស បទល្មើស ដែលត្រូវប្រព្រឹត្តឡើង ដោយពលរដ្ឋរបស់ខ្លួន ទោះបីជាបទល្មើសទាំងនោះ ត្រូវបានប្រព្រឹត្តឡើង នៅលើ ទឹកដីនៃរដ្ឋបរទេសក៏ដោយ ។ កត់សំគាល់ថា យោងតាមកថាខ័ណ្ឌនេះ ការអនុវត្តច្បាប់នេះ មិនមែនមានតែមកលើ ចារី ដែលជាពលរដ្ឋកម្ពុជា នៅពេលបទល្មើសនោះត្រូវបានប្រព្រឹត្តឡើងទេ ( ប្រៀបធៀប ជាមួយមាត្រា ៣ កថាខ័ណ្ឌ ទី ៣ ខាងក្រោម ) ។ យោងតាមបទប្បញ្ញត្តិនេះ ជនល្មើសដែលមិនមែនជាពលរដ្ឋកម្ពុជា នៅពេលដែលប្រព្រឹត្ត បទល្មើស អាចនៅតែត្រូវធ្វើការចោទប្រកាន់ ប្រសិនបើបុគ្គលនោះ ក្រោយមកទៀត ទទួលបានសញ្ជាតិកម្ពុជា ។ នេះស្របទៅតាមក្រមព្រហ្មទណ្ឌថ្មី (គន្ថីទី ១ មាតិកាទី១ ជំពូកទី ៣ ផ្នែកទី ២ មាត្រា ១៩ "បទឧក្រិដ្ឋ ឬបទមជ្ឈិម ប្រព្រឹត្តដោយពលរដ្ឋខ្មែរ") ។

នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៩ នៃក្រមព្រហ្មទណ្ឌ បានចែងថា " បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្ត ផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរ ក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ " ។

គួរកត់សំគាល់ផងដែរថា ពាក្យថា " ពលរដ្ឋខ្មែរ " ដែលត្រូវប្រើនៅទីនេះ សំដៅទៅលើ ពលរដ្ឋនៃព្រះរាជា ណាចក្រកម្ពុជា ដោយមិនគិតពីជាតិពន្ធុរបស់បុគ្គលនោះឡើយ ។ ការប្រើពាក្យនេះ មិនមានន័យថា មានតែជនជាតិ

ដើមជាខ្មែរ ទើបស្ថិតនៅក្រោមយុត្តាធិការនៃច្បាប់នេះទេ ។ គេយល់ថា មានក្រុមជនជាតិភាគតិចផ្សេងៗគ្នាជាច្រើន ( ដូចជា ចាម វៀតណាម ព្រៅ ភ្នង ។ល។ ) ដែលក៏ជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាដែរ ។ ប្រសិនបើមានសំនួរ លើកឡើង ទាក់ទងនឹងសញ្ជាតិរបស់ជនល្មើសដែលជាប់ចោទ ឬ របស់ជនរងគ្រោះ តុលាការគួរឆ្លើយសំនួរទាំងនេះ តាមរយៈពិនិត្យមើល ច្បាប់កម្ពុជា ដែលពាក់ព័ន្ធ ។ ជាពិសេស ច្បាប់ ស្តីពី សញ្ជាតិ ( ១៩៩៦ ) កំណត់និយមន័យថា ជនណាអាចទទួលបាន សញ្ជាតិខ្មែរពីកំណើត (មាត្រា ៤) ប្រសិនបើ ឪពុក ឬ ម្តាយ មានសញ្ជាតិខ្មែរ ( មាត្រា ៤ កថាខ័ណ្ឌទី ១ ) ឬ ឪពុក ឬ ម្តាយ បរទេសដែលកើត និងរស់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ( មាត្រា ៤ កថាខ័ណ្ឌទី ២ ចំណុច ក ) តាមរយៈ ការរៀបអាពាហ៍ពិពាហ៍ ( មាត្រា ៥ ) ឬ តាមរយៈ សញ្ជាតិតូបនីយកម្ម ( មាត្រា ៧ ដល់ មាត្រា ១៧ ) ។

## " ត្រូវប្រព្រឹត្ត.....ដោយជនបរទេស ប្រសិនបើជនរងគ្រោះជាពលរដ្ឋខ្មែរ "

បទប្បញ្ញត្តិ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវអនុវត្ត ក្នុងករណីដែល ជនបរទេស បានប្រព្រឹត្តបទល្មើស ទៅលើជនរងគ្រោះ ដែលនៅពេលនោះ ជាពលរដ្ឋកម្ពុជា ។ នេះគឺជាការបង្ហាញយ៉ាងច្បាស់ នៃ*គោលការណ៍បុគ្គលិកលក្ខណៈអកម្ម ( passive personality principle )* ដែលតាមគោលការណ៍នោះ រដ្ឋអាចមានសិទ្ធិទទួលបានយុត្តាធិការទៅលើអំពើដែលធ្វើឱ្យប៉ះពាល់ដល់ពលរដ្ឋ មួយ ឬ ច្រើនរបស់ខ្លួន ហើយទោះបីជាអំពើនោះ ត្រូវបានប្រព្រឹត្តនៅឯបរទេស ដោយជនជាតិបរទេសក៏ដោយ ។

ដូចកត់សំគាល់ខាងលើ ប្រសិនបើមានសំនួរ លើកឡើងទាក់ទងនឹងសញ្ជាតិរបស់ជនល្មើស ដែលជាប់ចោទ ឬរបស់ជនរងគ្រោះ តុលាការគួរឆ្លើយសំនួរទាំងនេះ តាមរយៈពិនិត្យមើល ច្បាប់ និងបទបញ្ជារបស់ប្រទេសកម្ពុជាដែលពាក់ព័ន្ធ ។ ជាពិសេស ច្បាប់ ស្តីពី សញ្ជាតិ ( ១៩៩៦ ) កំណត់និយមន័យថា ជនណាអាចទទួលបាន សញ្ជាតិខ្មែរពីកំណើត ( មាត្រា ៤ ) ប្រសិនបើ ឪពុក ឬ ម្តាយមានសញ្ជាតិខ្មែរ ( មាត្រា ៤ កថាខ័ណ្ឌទី ១ ) ឬ ឪពុក ឬ ម្តាយបរទេសដែលកើត និងរស់នៅស្របច្បាប់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ( មាត្រា ៤ កថាខ័ណ្ឌទី ២ ចំណុចក ) តាមរយៈ ការរៀបអាពាហ៍ពិពាហ៍ ( មាត្រា ៥ ) ឬ តាមរយៈ សញ្ជាតិតូបនីយកម្ម ( មាត្រា ៧ ដល់ មាត្រា ១៧ ) ។

## " ចំពេលដែលប្រព្រឹត្តបទល្មើស "

ក្នុងករណី ដែលច្បាប់ត្រូវយកមកអនុវត្ត ចំពោះបទល្មើសដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយសារតែជនរងគ្រោះ ជាជនជាតិកម្ពុជា ការអនុវត្តនៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អនុវត្តត្រឹមតែ ក្នុងករណីដែលជនរងគ្រោះជាពលរដ្ឋកម្ពុជា ចំពេលដែលបទល្មើសត្រូវបានប្រព្រឹត្តឡើង ។ នេះមានន័យថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនអាចអនុវត្តបានក្នុងករណីដែល ជនរងគ្រោះមិនមែនជាជនជាតិកម្ពុជា ចំពេលដែលប្រព្រឹត្តបទល្មើស ហើយទោះបីជាជនរងគ្រោះនោះក្រោយមកទទួលបានសញ្ជាតិខ្មែរក៏ដោយ ។ បទប្បញ្ញត្តិនេះស្របទៅនឹង បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មី (គន្ថីទី ១ មាតិកាទី ១ ជំពូកទី ៣ ផ្នែកទី២ "បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា") ជាពិសេស មាត្រា ២០ "ជនរងគ្រោះជាជនជាតិខ្មែរ") ។

**មាត្រា ៤.- ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ**

**រាល់ការប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវផ្តន្ទាទោស និងត្រូវទទួលខុសត្រូវ ដូចករណីដែលបទល្មើសត្រូវបានប្រព្រឹត្ត ។**

**អ្នកសមគំនិត និង អ្នកផ្តើមគំនិត ក្នុងបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលមានចែង នៅក្នុងច្បាប់នេះ ត្រូវផ្តន្ទាទោស និងត្រូវទទួលខុសត្រូវ ដូចចារីដែលប្រព្រឹត្តបទល្មើស ។**

**អ្នកសមគំនិត និងអ្នកផ្តើមគំនិត រួមមាន អ្នករៀបចំ ឬ ចង្អុលបង្ហាញជាអាទិ៍ឱ្យជនដទៃ ប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់នេះ ។**

នៅពេលដែល អ្នកតំណាង ភ្នាក់ងារ ឬ និយោជិត នៃនីតិបុគ្គល ឬ ភាវប្បទាយីណាមួយ ប្រព្រឹត្តបទល្មើសណាមួយ ដែលមានចែងនៅក្នុងច្បាប់នេះ ក្នុងក្របខ័ណ្ឌនៃមុខជំនួញ ឬ ផលប្រយោជន៍នៃនីតិបុគ្គល ឬ ភាវប្បទាយីនោះ នីតិបុគ្គល ឬ ភាវប្បទាយីនោះ ត្រូវផ្តន្ទាទោសដោយពិន័យជាប្រាក់ និង ទោសបន្ថែម ដោយយោងទៅតាមការផ្តន្ទាទោស ដែលមានចែងនៅក្នុងមាត្រា ដែលពាក់ព័ន្ធ ។

មាត្រានេះកំណត់វិសាលភាពនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះជនណាដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ដែលមានការកំណត់និយមន័យក្នុងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឬ ចំពោះជនណាដែលជួយ ឬ ផ្តើមគំនិត ឱ្យចារីប្រព្រឹត្តបទល្មើស ។

គួរកត់សំគាល់ថា មាត្រា ៥១ នៃ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា មាត្រានេះ នឹងត្រូវជំនួស នៅពេលក្រមព្រហ្មទណ្ឌចូលជាធរមាន ។ ( សូមមើលការពិភាក្សា យោងតាម មាត្រា ៥១ ខាងក្រោម ) ។

### " បទល្មើស ឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលមានចែងក្នុងច្បាប់នេះ "

បទប្បញ្ញត្តិនេះមានន័យថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ត្រូវបង្កើតឡើងដោយអ្នកដែល ប៉ុនប៉ង ជួយ ឬ ផ្តើមគំនិត ឱ្យមានបទល្មើស យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ លុះត្រាតែ បទល្មើសទាំងនោះ ស្ថិតក្នុងចំណាត់ថ្នាក់ជាប្រភេទ បទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម ។ យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ជនណាដែលប៉ុនប៉ង ជួយ ឬ ផ្តើមគំនិត ឱ្យមានបទល្មើសស្រាលជាងនេះ ( ដូចជា អំពើអូសទាញ ដូចមានការកំណត់និយមន័យ ក្នុងមាត្រា ២៤ ) មិនមាន ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ ។

**" ការប៉ុនប៉ង... ត្រូវផ្តន្ទាទោស.. "**

**" អ្នកសមគំនិត និង អ្នកផ្តើមគំនិត......ត្រូវផ្តន្ទាទោស.. "**

បទប្បញ្ញត្តិទាំងនេះ បញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើជនណាប៉ុនប៉ង ជួយ ឬ ផ្តើមគំនិត ឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលមានការកំណត់និយមន័យក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជននោះត្រូវទទួលការផ្តន្ទាទោស ។

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានកំណត់និយមន័យពាក្យ " ការប៉ុនប៉ង " " អ្នកសមគំនិត " ឬ " អ្នកផ្តើមគំនិត " ប៉ុន្តែ និយមន័យពាក្យទាំងនេះ អាចមានឃើញនៅកន្លែងផ្សេងទៀត ក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលរួមមានក្រមព្រហ្មទណ្ឌថ្មីដូចខាងក្រោម :

~ **ការប៉ុនប៉ង**

ក្រមព្រហ្មទណ្ឌថ្មី ផ្តល់និយមន័យ យ៉ាងច្បាស់ថា នៅក្នុងមាត្រា ២៧ ស្តីពី និយមន័យនៃការប៉ុនប៉ង ដែលមាននៅក្នុងគន្ថីទី ១ ( បទប្បញ្ញត្តិទូទៅ នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ ) មាតិកាទី ២ ( ការទទួលខុសត្រូវ ព្រហ្មទណ្ឌ ) ជំពូកទី ១ ( បទប្បញ្ញត្តិទូទៅ ) :

*"ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណា លក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :*

*- ចារីបានចាប់ផ្តើមអនុវត្តបទល្មើស គឺមានន័យថា ចារីបានប្រព្រឹត្តអំពើ ដែលមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស និង*

*- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬ រាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។*

*អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្តើមអនុវត្តទេ ។ ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ ។"*

## ~ អ្នកសមគំនិត

ក្រមព្រហ្មទណ្ឌថ្មី មាននិយមន័យយ៉ាងច្បាស់ ក្នុងមាត្រា ២៩ ស្តីពី និយមន័យនៃអ្នកសមគំនិតដែលមាននៅក្នុងគន្ថីទី ១ ( បទប្បញ្ញត្តិទូទៅនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ ) មាតិកាទី ២ ( ការទទួលខុសត្រូវព្រហ្មទណ្ឌ ) ជំពូកទី ១ ( បទប្បញ្ញត្តិទូទៅ ) :

*"ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែល ជួយសម្រួលដោយចេតនាដល់ ការប៉ុនប៉ង ឬ ការសម្រេចបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន ។*

*អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវ បានសម្រេច ឬបានប៉ុនប៉ង ។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។"*

## ~ អ្នកផ្តើមគំនិត

ក្រមព្រហ្មទណ្ឌថ្មីផ្តល់ និយមន័យយ៉ាងច្បាស់ នៅក្នុងមាត្រា ២៨ ស្តីពី និយមន័យនៃអ្នកផ្តើមគំនិត ដែលមាននៅក្នុងគន្ថីទី ១ ( បទប្បញ្ញត្តិ ទូទៅ នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ ) មាតិកាទី ២ ( ការទទួលខុសត្រូវព្រហ្មទណ្ឌ ) ជំពូកទី ១ ( បទប្បញ្ញត្តិទូទៅ) :

*"ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែល :*

*១-ជម្រុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ តាមការណែនាំ ឬ ការបញ្ជា ។*

*២-បង្កឱ្យមានបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំ-ហែង ការញុះញង់ ការលួងលោម ឬ ក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន ។*

*អ្នកផ្ដើមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវបានសម្រេច ឬ បានប៉ុនប៉ង ។ អ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវទទួលទោសដូចគ្នានឹងចារីដែរ ។"*

### " ....និងទទួលការផ្តន្ទាទោសដូចគ្នា "

បទប្បញ្ញត្តិនេះចែងថា ជនណាដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម ត្រូវ " ទទួលការផ្តន្ទាទោស " ហាក់បីដូចជា ដែលបទល្មើសនោះត្រូវបានប្រព្រឹត្តដោយជននោះផ្ទាល់ ហើយអ្នកសមគំនិត ឬ អ្នកផ្តើមគំនិត ត្រូវ " ទទួលការផ្តន្ទាទោស " ដូចចារីដែរ ។

វិធីសាស្ត្រនេះសង្កត់ធ្ងន់លើ ចេតនាប្រព្រឹត្តបទល្មើស ។ ការប៉ុនប៉ង ការសមគំនិត និងការផ្តើមគំនិត ទាំងអស់តម្រូវឱ្យមានចេតនាប្រព្រឹត្តបទល្មើស និងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ ផ្តន្ទាទោសចេតនានេះ ។ ហេតុដូច្នេះ ទោះបីជាជននោះគ្រាន់តែបានប៉ុនប៉ង ( ប៉ុន្តែមិនបានសម្រេច ) ប្រព្រឹត្ត បទល្មើសដែលទាក់ទងនឹងអំពើជួញដូរ និងអំពើធ្វើអាជីវកម្ម ជននោះត្រូវទទួលការផ្តន្ទាទោស ដូចដែលបទល្មើសនោះ បានប្រព្រឹត្តបានសម្រេចដែរ ។

នេះមិនមានន័យថា ជនដែលគេរកឃើញមានទោសពីបទ ប៉ុនប៉ង សមគំនិត ផ្តើមគំនិត នឹងជាចាំបាច់ ទទួល កម្រិតផ្តន្ទាទោសដូចគ្នានោះទេ ។ ទោះបីជា ជនល្មើសទទួលការផ្តន្ទាទោសដូចគ្នា ចៅក្រម អាចនៅតែអនុវត្តឆន្ទានុសិទ្ធិ ទាក់ទងនឹង កម្រិតនៃការផ្តន្ទាទោស ។

**ឧទាហរណ៍ : ការប្រព្រឹត្តបទល្មើស " ការដឹកជញ្ជូនដោយមានគោលដៅ " មាត្រា ១៧ នៃ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ធ្វើការផ្តន្ទាទោស ពី ៧ ឆ្នាំ ដល់ ១៥ ឆ្នាំ ។ ជនណាដែល គ្រាន់តែជួយចារី ដើម្បីប្រព្រឹត្តបទល្មើស ត្រូវទទួលការផ្តន្ទាទោសដូចគ្នានឹងចារីដែរ គឺថា ត្រូវជាប់ពន្ធនាគារ រយៈពេល ពី ៧ ឆ្នាំ ទៅ ១៥ ឆ្នាំ ។ ប៉ុន្តែ ចៅក្រម អាចនឹងកាត់ទោស អ្នកសមគំនិត ឱ្យជាប់ ទោសរយៈពេលខ្លីជាង ចារី នៅក្នុង ថេរវេលានៃទោសដែលបានចែងក្នុងច្បាប់ ។**

ចំពោះករណីដែលទាក់ទិននឹងការ ប៉ុនប៉ង នៅពេលដែលពិចារណាទៅលើ ចេតនារបស់អ្នកប្រព្រឹត្តនៅពេល ប៉ុនប៉ង តុលាការគួរតែពិនិត្យមើល ហេតុអ្វីបានជាសកម្មភាពនោះ មិននាំឱ្យមានការប្រព្រឹត្តបទល្មើសបានសម្រេច ។ ក្នុងករណីដែលអ្នកប្រព្រឹត្ត លះបង់ ផែនការប្រព្រឹត្តបទល្មើសដោយស្ម័គ្រចិត្ត និងទាំងស្រុង មុនពេលដល់ដំណាក់កាល សំខាន់នៃការប្រព្រឹត្តបទល្មើស គាត់អាចត្រូវចាត់ទុកថា មិនមានចេតនា ដូចជនដែល ត្រូវបានទប់ស្កាត់ដោយកាលៈ ទេសៈណាមួយនោះទេ និងទោះបីជាគាត់មានចេតនា អនុវត្តផែនការប្រព្រឹត្តបទល្មើស ឱ្យបានសម្រេចក៏ដោយ ។ ប្រសិនបើតុលាការ ពិចារណាថា ចេតនារបស់ជនល្មើស មានតិចតួច ហេតុដូច្នេះ ចៅក្រម អាចជ្រើសរើសដាក់ទោស ស្រាលនៅក្នុងចន្លោះថិរវេលានៃទោស ដែលច្បាប់បានចែង ។ យ៉ាងណាមិញ ប្រសិនបើអ្នកប្រព្រឹត្ត មិនអាចអនុវត្ត ផែនការប្រព្រឹត្តបទល្មើស ដោយសារតែកាលៈទេសៈខាងក្រៅ ដែលនាំឱ្យការប្រព្រឹត្តបទល្មើសមិនអាចទៅរួច ឬ ពិបាកជាងនេះ ឬ ប្រសិនបើ អ្នកប្រព្រឹត្ត មិនអាចអនុវត្តផែនការប្រព្រឹត្តបទល្មើស ប៉ុន្តែបានសម្រេចចិត្ត រងចាំ "

ឱកាសល្អ " តុលាការអាចចាត់ទុកថា ចេតនាប្រព្រឹត្តបទល្មើសនេះ គឺដូចគ្នានឹងចេតនារបស់ជនល្មើសបានសម្រេចដែរ ហេតុដូច្នេះ ចៅក្រមអាចដាក់ទោសធ្ងន់ធ្ងរនៅក្នុងចន្លោះថិរវេលានៃទោស ដែលច្បាប់បានចែង ។

គួរតែផ្តោតអារម្មណ៍ទៅលើ ចេតនារបស់ជនល្មើស ក្នុងករណីដែលទាក់ទងនឹងអំពើសមគំនិត ឬ ការផ្តើមគំនិត ។ តុលាការគួរពិចារណាថាតើ អ្នកសមគំនិត ឬ អ្នកផ្តើមគំនិតដែលត្រូវចោទប្រកាន់ មានចេតនាជួយ ចារីនៅក្នុងការប្រព្រឹត្តបទល្មើស ឬ បានដឹងថា សកម្មភាពរបស់គាត់ នឹងប្រហែលជាជួយ ចារី ក្នុងការប្រព្រឹត្តបទល្មើស ដែរឬទេ ? ។ ប្រសិនបើ អ្នកសមគំនិត ដែលត្រូវចោទប្រកាន់ មិនមានគោលបំណង និងមិនបានដឹង អាចចាត់ទុកថា គាត់មិនមានចេតនា ដែលតម្រូវដោយច្បាប់ធ្វើជាអ្នកសមគំនិត ឬ អ្នកផ្តើមគំនិត ទេ ។ តាមទ្រឹស្តីនៃការចូលរួមប្រព្រឹត្តបទល្មើស ទាមទារអោយមានទំនាក់ទំនងទ្វេទិស រវាង ឆន្ទៈរបស់ចារី និងអ្នកសមគំនិត ឬ អ្នកផ្តើមគំនិត មានន័យថា ចារីបានដឹងថា អ្នកសមគំនិត ឬ អ្នកផ្តើមគំនិត មានបំណងជួយខ្លួនក្នុងការប្រព្រឹត្ត បទល្មើស និងផ្ទុយពីនេះ អ្នកសមគំនិត ឬ អ្នកផ្តើមគំនិត ក៏បានដឹងអំពីបំណងរបស់ចារីផងដែរ ។

**" អ្នកសមគំនិត និងអ្នកផ្តើមគំនិត រួមមាន អ្នករៀបចំ ឬ ទទួលបន្ទាញជាអាទិ៍ ឱ្យជនដទៃ ប្រព្រឹត្តបទល្មើស ឧក្រិដ្ឋ ឬ មជ្ឈិមទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់នេះ "**

ក្នុងអត្ថបទ ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ មិនមានកំណត់និយមន័យពាក្យថា " រៀបចំ " ទេ ។ ប៉ុន្តែពាក្យ " រៀបចំ " ដែលប្រើក្នុងមាត្រានេះ ត្រូវបានគេយល់ថា ជាការរៀបចំជាមួយនរណាម្នាក់ ដោយមានគោលបំណង ដើម្បីប្រព្រឹត្តបទល្មើសណាមួយ ។

**" នៅពេលដែល អ្នកតំណាង ភ្នាក់ងារ ឬ និយោជិត នៃនីតិបុគ្គល ឬ ភារប្បទាយីណាមួយ....."**

បទប្បញ្ញត្តិចុងក្រោយនៃមាត្រានេះ អាចឱ្យមានការអនុវត្តច្បាប់ ដើម្បីដាក់ទោស និងធ្វើឱ្យនីតិបុគ្គល (ឧទាហរណ៍ : ក្រុមហ៊ុន អង្គការ ឬ សមាគម...) ឬ ភារប្បទាយី ដែលទាក់ទិនក្នុងការប្រព្រឹត្តបទល្មើស ដូចមានកំណត់ក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានការញញើត ទោះបីជាបទល្មើសនោះប្រព្រឹត្តដោយ អ្នកតំណាងភ្នាក់ងារ ឬ និយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ប្រសិនបើអំពើនោះត្រូវបានធ្វើឡើងនៅក្នុងក្របខណ្ឌនៃមុខជំនួញ ឬ ផលប្រយោជន៍នៃនីតិបុគ្គល ឬ ភារប្បទាយីនោះ ។

ស្របទៅនឹងក្រមព្រហ្មទណ្ឌថ្មី (គន្ថីទី ១ មាតិកាទី ២ ជំពូកទី ៤ " ការទទួលខុសត្រូវ ព្រហ្មទណ្ឌរបស់នីតិបុគ្គល " ) ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នីតិបុគ្គល មិនលើកលែងនូវ ការទទួលខុសត្រូវព្រហ្មទណ្ឌ របស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

" អ្នកតំណាង " ឬ " ភ្នាក់ងារ " សំដៅលើបុគ្គលដែលទទួលបានសិទ្ធិតំណាងឱ្យនីតិបុគ្គល ឬ ភារប្បទាយី ។

" និយោជិត " មានការកំណត់និយមន័យក្នុងលក្ខណៈស្របទៅនឹង មាត្រា ៣ នៃច្បាប់ ស្តីពី ការងារដែលបានចែងថា " កម្មករនិយោជិត តាមន័យនៃច្បាប់នេះ គឺជនគ្រប់ប្រភេទ និងគ្រប់សញ្ជាតិ ដែលបានចុះកិច្ចសន្យាធ្វើការយកកំរៃក្រោមការដឹកនាំ និងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀត ជារូបវន្តបុគ្គល ឬ នីតិបុគ្គលជាសាធារណៈ ឬ ឯកជន។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ពីលក្ខណៈសម្បត្តិនៃកម្មករនិយោជិត គេមិនត្រូវគិតពីលក្ខន្តិកៈគតិយុត្តិនៃនិយោជក ឬ លក្ខន្តិកៈគតិយុត្តិនៃកម្មករនិយោជិត ព្រមទាំងមិនត្រូវគិតពីចំនួនប្រាក់ឈ្នួលតិច ឬ ច្រើនទេ " ។

" នីតិបុគ្គល " មានពន្យល់នៅក្នុងក្រមរដ្ឋប្បវេណី ( គន្ថីទី ២ " បុគ្គល " ជំពូកទី ២ " នីតិបុគ្គល " ) និងបានអោយនិយមន័យ នៅក្នុងសន្ទានុក្រម នៃក្រមរដ្ឋប្បវេណីថា " ក្រុមមនុស្ស ឬ មូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយដែលជាម្ចាស់ នៃសិទ្ធិ និងកាតព្វកិច្ច ឧទាហរណ៍ : សមាគម ក្រុមហ៊ុន ក្រុមហ៊ុនសហកម្មសិទ្ធិ អង្គការ មូលនិធិ ។ល។ ទោះបីជា នីតិបុគ្គលនោះ ជានីតិបុគ្គល យកចំណេញ ឬ មិនយកចំណេញ និងទទួលខុសត្រូវមានកម្រិត ឬ ទទួលខុសត្រូវគ្មានកម្រិតក៏ដោយ ។ "

ក្រមព្រហ្មទណ្ឌថ្មី ( គន្ថីទី ១ មាតិកាទី ២ ជំពូកទី ៤ " ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល " រដ្ឋមិនត្រូវចាត់ទុកថា ជានីតិបុគ្គល ដែលមានការទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

" ភារប្បទាយី " សំដៅលើ បុគ្គលណាម្នាក់ ដែលផ្តល់សិទ្ធិទៅអោយអ្នកតំណាង ឬ ភ្នាក់ងារឱ្យធ្វើកិច្ចការជំនួសខ្លួន ។

**ឧទាហរណ៍ : ក គឺជាម្ចាស់សណ្ឋាគារ បានផ្តល់សិទ្ធិឱ្យ ខ ដែលជាអ្នកគ្រប់គ្រងលើសណ្ឋាគារនោះ ក្នុងការជ្រើសរើសបុគ្គលិកបំរើការងារនៅក្នុងសណ្ឋាគារ ។ នៅក្នុងការគ្រប់គ្រងសណ្ឋាគារ ក បានដឹងថា ខ បានជ្រើសរើសស្ត្រីឱ្យបំរើការងារផង និងឱ្យបំរើផ្លូវភេទសម្រាប់ភ្ញៀវសណ្ឋាគារផង ។ ករណីនេះ ក គឺជាភារប្បទាយី ហើយ ខ គឺជាភ្នាក់ងារ ដែលត្រូវទទួលទោសពីបទ សញ្ចារកម្ម ។**

## "...ប្រព្រឹត្តិបទល្មើសណាមួយ ដែលមានចែងនៅក្នុងច្បាប់នេះ ក្នុងក្របខ័ណ្ឌនៃមុខជំនួញ ឬ ផលប្រយោជន៍នៃនីតិបុគ្គល ឬ ភារប្បទាយីនោះ..."

យោងតាមមាត្រានេះ នីតិបុគ្គល ឬ ភារប្បទាយី មានការទទួលខុសត្រូវ លុះត្រាតែ ជនល្មើសនោះ ( អ្នកតំណាង ភ្នាក់ងារ ឬ និយោជិត ) បានប្រព្រឹត្តបទល្មើស ក្នុងក្របខ័ណ្ឌនៃមុខជំនួញដូចគ្នានឹងមុខជំនួញដែលធ្វើឡើងដោយនីតិបុគ្គល ឬ ភារប្បទាយី ឬ ធ្វើឱ្យរីកចំរើន ដល់ផលប្រយោជន៍ របស់នីតិបុគ្គល ឬ ភារប្បទាយីនោះ ។ ឧទាហរណ៍ : ក គឺជាភ្នាក់ងាររបស់ " ក្រុមហ៊ុន ខ " ។ ក្រុមហ៊ុន ខ ធ្វើការជ្រើសរើសប្រជាពលរដ្ឋកម្ពុជា ឱ្យធ្វើការនៅក្រៅប្រទេស ។ ករណីនេះ បើ ក នាំយកចេញជនរងគ្រោះដោយមិនស្របច្បាប់ ដើម្បីបញ្ជូនជននោះ ទៅធ្វើការនៅក្រៅប្រទេស តាមរយៈសេវាកម្មរបស់ក្រុមហ៊ុន ខ ហេតុដូច្នេះ ក្រុមហ៊ុន ខ ក៏អាចមានការទទួលខុសត្រូវដោយសារតែបទល្មើសប្រព្រឹត្តឡើង ក្នុងក្របខ័ណ្ឌនៃមុខជំនួញ និងធ្វើឱ្យមានការរីកចំរើនដល់ផលប្រយោជន៍របស់ក្រុមហ៊ុន ខ នោះ ។

### " នីតិបុគ្គល ឬ ភារប្បទាយី......ត្រូវផ្តន្ទាទោសដោយ ពិន័យជាប្រាក់ "

ប្រសិនបើជាការចាំបាច់ ក្នុងការផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយី ហេតុដូច្នេះជាទូទៅ ការផ្តន្ទាទោស គួរតែធ្វើឡើងដោយពិន័យជាប្រាក់ ។ ក្នុងករណី នៃនីតិបុគ្គល ការផ្តន្ទាទោសដោយពិន័យជាប្រាក់ គឺជាការផ្តន្ទាទោសដ៏សមរម្យ ដោយសារតែ នីតិបុគ្គល មិនអាចទទួលការផ្តន្ទាទោសដាក់ពន្ធនាគារបានទេ ។ នេះក៏ស្របទៅនឹងក្រមព្រហ្មទណ្ឌថ្មី ( គន្ថីទី ១ មាតិកាទី ៣ ជំពូក ៧ " ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល " ដែលចែងថា ទោសពិន័យគឺជាទោសចំបង ដែលដាក់ទៅលើនីតិបុគ្គល ) ។

### " ទោសបន្ថែម "

ពាក្យនេះសំដៅ ទៅលើទោសបន្ថែម ដែលមានចែងក្នុង មាត្រា ៤៨ នៃ ច្បាប់ ស្តីពី ការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសទាំងនេះមានដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ដែលមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងការប្រព្រឹត្តបទល្មើសនោះ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) អាចជាការសមរម្យ នៅពេលដាក់ទោសនីតិបុគ្គល ។ ( សូមពិនិត្យមើល ការពិភាក្សាយោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ជាងនេះ ) ។

**មាត្រា ៥.. ការប្រកាសមុខទោស**

**នៅក្នុងគ្រប់ករណី ដែលបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារផង និង ពិន័យជាប្រាក់ផង តុលាការអាចប្រកាស :**

**១- ទោសជាប់ពន្ធនាគារ និងទោសពិន័យត្រួតគ្នា ។**

**២- ទោសដាក់ពន្ធនាគារតែមួយប៉ុណ្ណោះ ។**

**៣- ឬ ក៏ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។**

ក្នុងករណីដែល ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងពីការផ្តន្ទាទោសដោយដាក់ពន្ធនាគារ និងពិន័យជាប្រាក់ មាត្រានេះផ្តល់ឱ្យតុលាការនូវឆន្ទានុសិទ្ធិ ក្នុងការផ្តន្ទាទោស តែមួយមុខ ឬ ទាំងពីរមុខ ។ ប្រសិនបើតុលាការរកឃើញថា ជនល្មើសមានទោសប្រព្រឹត្តបទល្មើស ត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ផង នោះតុលាការអាចធ្វើការដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ ពិន័យតែជាប្រាក់ ឬ ទាំងដាក់ពន្ធនាគារ និងពិន័យជាប្រាក់ ។

ក្នុងករណីដែលមានបទល្មើសមួយកើតឡើង ច្បាប់នេះ ចែងពីទោសជាប់ពន្ធនាគារ និងពិន័យជាប្រាក់ ហេតុដូច្នេះ ដើម្បីឱ្យស្របទៅនឹងគោលបំណង នៃច្បាប់នេះ ការពិចារណាទៅលើការដាក់ពន្ធនាគារ ជនល្មើស ឬ មិនដាក់

នោះ ចៅក្រម គប្បីពិចារណាទៅលើការដាក់ពន្ធគារ ដើម្បីធានាសុវត្ថិភាពរបស់ជនរងគ្រោះ និងការពារមិនអោយជនល្មើសអាចធ្វើការសងសឹកទៅលើជនរងគ្រោះ ដែលបានធ្វើកសិណសាក្សីនៅក្នុងតុលាការប្រឆាំងនឹងជនល្មើស ។

**មាត្រា ៦.. បទល្មើសត្រួតគ្នា**

**កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមាន ពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវប្រកាសឡើង ។ ប៉ុន្តែកាលបើទោសត្រូវទទួលមានច្រើន និងមានប្រភេទដូចគ្នា ទោសតែមួយនៃប្រភេទនេះ អាចត្រូវបានប្រកាសជាអតិបរមានៅក្នុងព្រំដែន ស្របច្បាប់ដែលខ្ពស់ជាងគេ ។**

មាត្រានេះចែងថា ប្រសិនបើ ជនល្មើសត្រូវគេរកឃើញថា មានពិរុទ្ធពីបទល្មើសត្រួតគ្នាច្រើន និងទទួលទោសច្រើន ដែលមានប្រភេទដូចគ្នា ត្រូវអនុវត្តទោសមិនអាចហួសពី ទោសដែលខ្ពស់បំផុត ដែលមានចែងក្នុងបទល្មើសណាមួយ ។ យ៉ាងណាមិញ គេអាចដាក់ការផ្តន្ទាទោសដែលមានប្រភេទផ្សេងៗគ្នា ជាមួយគ្នាបាន ( ឧទាហរណ៍ : ការដាក់ពន្ធនាគារ និងពិន័យជាប្រាក់ ) ។

គួរកត់សំគាល់ថា មាត្រា ៥១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា មាត្រានេះនឹងត្រូវជំនួស នៅពេលក្រមព្រហ្មទណ្ឌត្រូវប្រកាសឱ្យប្រើ ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៥១ ខាងក្រោម ) ។ សូមមើលក្រមព្រហ្មទណ្ឌ គន្ថីទី ១ មាតិកាទី ៣ ជំពូកទី ៤ " វិធានអនុវត្តនៅក្នុងករណីបទល្មើសត្រួតគ្នា " ។ គួរកត់សំគាល់ថាមាត្រា ៦ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ស្របទៅនឹងមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌថ្មីដែលចែងថា : កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមាន ពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវប្រកាសឡើង ។ ប៉ុន្តែកាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះនៅក្នុងព្រំដែននៃអតបិរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។

**" កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន "**

មាត្រានេះ អនុវត្តក្នុងស្ថានការណ៍ពីរ :

១) នៅពេលដែលមាន ការជំនុំជម្រះមួយ ជនល្មើសត្រូវបានគេរកឃើញមានពិរុទ្ធពី បទល្មើសត្រួតគ្នា ឬ

២) នៅពេលដែលមាន ការជំនុំជម្រះ ដោយតុលាការផ្សេងទៀត ជនល្មើសត្រូវគេរកឃើញមានពិរុទ្ធពីបទល្មើសត្រួតគ្នា មុនពេលកាត់ឱ្យជាប់ទោសដោយតុលាការចុងក្រោយ ។

" បទល្មើសត្រួតគ្នា " មានន័យថា ជាបទល្មើសទាំងអស់ ដែលត្រូវបានប្រព្រឹត្តដោយ បុគ្គលម្នាក់មុនពេលដែលបុគ្គលនោះ ត្រូវបាន ជំនុំជម្រះជាស្ថាពរ ពីបទល្មើសមួយផ្សេងទៀត ។ នេះស្របទៅនឹង និយមន័យដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ (គន្ថីទី ១ មាតិកាទី ៣ ជំពូកទី ៤ " វិធានអនុវត្តនៅក្នុងករណីបទល្មើសត្រួតគ្នា " ) ។

ឧទាហរណ៍ : ប្រសិនបើជនល្មើស នាំយកចេញជនរងគ្រោះដោយមិនស្របច្បាប់ ដើម្បីប្រគល់ជនរងគ្រោះ ទៅកាន់ប្រទេសមួយផ្សេងទៀត និងក៏បានបង្ខាំងជនរងគ្រោះ ហេតុដូច្នេះ យោងតាម ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដោយសារតែជនល្មើសត្រូវបានរកឃើញមានពិរុទ្ធពីបទល្មើសពីរ គឺ ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន (មាត្រា ១១) និង ការបង្ខាំង (មាត្រា ២១ ) ។ ប្រសិនបើជនល្មើសត្រូវចោទប្រកាន់ពីបទល្មើសទាំងពីរ ក្នុងការជំនុំជម្រះតែមួយ ហេតុដូច្នេះ បទល្មើសទាំងនេះ ត្រូវចាត់ទុកថាជាបទល្មើសត្រួតគ្នា ដោយសារតែបទល្មើសទាំងនេះ ត្រូវប្រព្រឹត្តឡើងមុនពេលជនល្មើសត្រូវបានកាត់ឱ្យជាប់ទោស ។

ប្រសិនបើមុនពេលជំនុំជម្រះដែលពិពណ៌នាខាងលើ ជនល្មើសខាងលើ ក៏ត្រូវបានចោទប្រកាន់ក្នុងតុលាការមួយផ្សេងទៀត ពីបទប្រព្រឹត្តបទល្មើស រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ និងត្រូវផ្តន្ទាទោសពីបទល្មើសនោះ (យោងតាមមាត្រា ៤២ ) ក្នុងតុលាការទីពីរ ហេតុដូច្នេះ តុលាការទីពីរ នឹងចាត់ទុកបទល្មើសណាមួយដែលតុលាការទីមួយ បានរកឃើញជនល្មើសបានប្រព្រឹត្តថាជា " បទល្មើសត្រួតគ្នា " ។

### " នៅពេលដែលមានទោសជាច្រើនដែលមានប្រភេទដូចគ្នា "

" ទោសដែលមានប្រភេទដូចគ្នា " មានន័យថា ជាទោសដែលអាចមានកំរិតចំនួននៃការផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ក៏ចំនួននៃការពិន័យជាប្រាក់ផ្សេងៗគ្នា ប៉ុន្តែអ្វីដែលសំខាន់គឺ បើទោសនោះ ជាទោសដាក់ពន្ធនាគារត្រូវតែទោសដាក់ពន្ធនាគារដូចគ្នា ឬ បើទោសនោះជាទោសពិន័យជាប្រាក់ ត្រូវតែទោសពិន័យជាប្រាក់ដូចគ្នា ទោះបីជាចំនួនឆ្នាំ ដែលដាក់ពន្ធនាគារខុសគ្នា ឬ ចំនួននៃការពិន័យជាប្រាក់ខុសគ្នាក៏ដោយ ។

ឧទាហរណ៍ : ការដាក់ទោសឱ្យជាប់ពន្ធនាគារ រយៈពេលពី ២ ឆ្នាំ ដល់ ៥ ឆ្នាំ និងការដាក់ទោសឱ្យជាប់ពន្ធនាគារ រយៈពេលពី ៧ ឆ្នាំ ដល់ ១៥ ឆ្នាំ គឺជាទោសដែលមានប្រភេទដូចគ្នា ។

ប្រហាក់ប្រហែលគ្នានេះដែរ ការពិន័យជាប្រាក់ ១០.០០០ រៀល និង ការពិន័យជាប្រាក់ ២៥០.០០០ រៀល គឺជាទោស ដែលមានប្រភេទដូចគ្នា ។

### "ទោសតែមួយនៃប្រភេទនេះ អាចត្រូវបានប្រកាសជាអតិបរមានៅក្នុងព្រំដែនស្របច្បាប់ដែលខ្ពស់ជាងគេ "

បទប្បញ្ញត្តិនេះ មានន័យថា កាលបើតុលាការ រកឃើញជនល្មើស ថាមានពិរុទ្ធពីបទល្មើស ត្រួតគ្នាច្រើន និងដាក់ទោសជនល្មើសនោះ ឱ្យជាប់ទោសជាច្រើន ដែលទោសនោះមានប្រភេទដូចគ្នា ពីបទល្មើសត្រួតគ្នានោះ តុលាការអាចគ្រាន់តែ ដាក់ទោសកុំឱ្យហួសពីអតិបរមានៃទោស ដែលមានចែងក្នុងបទល្មើសធ្ងន់ធ្ងរជាងគេបំផុត ។ ក្នុងន័យផ្សេងទៀត ជនល្មើសនៅពេលដែលត្រូវគេរកឃើញថា បានប្រព្រឹត្តបទល្មើសត្រួតគ្នា ត្រូវទទួលទោសដែលធ្ងន់ធ្ងរជាងគេបំផុត ហើយទោសដែលត្រូវដាក់គួរតែស្ថិតនៅក្នុងថេរវេលានៃទោសដែលអនុញ្ញាតដោយច្បាប់ ។

ហេតុនេះ ប្រសិនបើតុលាការផ្តន្ទាទោសជនល្មើស ឱ្យជាប់ពន្ធនាគារក្នុងថេរវេលាពេលផ្សេងៗគ្នាជាច្រើន ពីបទល្មើសត្រួតគ្នា ជនល្មើសនឹងគ្រាន់តែ ជាប់ពន្ធនាគារក្នុងថិរវេលានៃទោសវែងជាងគេបំផុត ដែលច្បាប់បានចែង ។ ដូចគ្នានេះដែរ ប្រសិនបើជនល្មើស ត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសត្រួតគ្នាច្រើន និងត្រូវពិន័យជាប្រាក់ ចំនួនផ្សេងៗគ្នាច្រើន នឹងអនុវត្តតែការពិន័យជាប្រាក់ដែលច្រើនជាងគេបំផុត ។ យ៉ាងណាមិញ ប្រសិនបើជនល្មើសត្រូវផ្តន្ទាទោស ឱ្យជាប់ពន្ធនាគារចំពោះបទល្មើសមួយ និង ពិន័យជាប្រាក់ ចំពោះបទល្មើសដែលទាក់ទងមួយផ្សេងទៀត ហេតុដូច្នេះ នឹងត្រូវអនុវត្តទោសទាំងពីរ គឺទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផង ។

ឧទាហរណ៍ : ជនល្មើសត្រូវគេរកឃើញថា មានពិរុទ្ធ ថាបានប្រព្រឹត្ត អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ និងមានពិរុទ្ធ ក្នុងបទលក់ដូរមនុស្ស ហេតុដូច្នេះ យោងតាមមាត្រា ៤២ នៃច្បាប់នេះ ជនល្មើសអាចត្រូវបានផ្តន្ទាទោសដាក់ពន្ធគារពី ៥ ឆ្នាំ ដល់ ១០ ឆ្នាំ និងយោងតាមមាត្រា ១៤ នៃច្បាប់នេះ ជនល្មើសអាចត្រូវបានផ្តន្ទាទោស ដាក់ពន្ធគារពី ៥ ឆ្នាំ ដល់ ១០ ឆ្នាំ ។ ក្នុងករណីនេះ តុលាការអាចដាក់ទោសតែមួយ មិនឱ្យលើសពី ១០ ឆ្នាំ ដែលត្រូវបានចាត់ទុកថា ជាទោសរួមចំពោះបទល្មើសទាំងពីរ ។

បន្ថែមពីនេះទៀត ក្រមព្រហ្មទណ្ឌ ក្នុងមាត្រា ១៣៨ (ការចោទប្រកាន់ដាច់ពីគ្នា) ក្នុងករណីដែលមានបទល្មើសត្រួតគ្នា ហើយមានការចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាសត្រូវអនុវត្តត្រួតគ្នា នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។ ប៉ុន្តែតុលាការ ចុងក្រោយ ដែលត្រូវសម្រេច អាចប្រកាសអោយអនុវត្តទោស ស្រូបបញ្ចូលគ្នាទាំងមូល ឬ មួយផ្នែកទោសដែលមានប្រភេទដូចគ្នា ។ ឧទាហរណ៍ : ជនល្មើស ត្រូវបានរកឃើញ ដោយតុលាការមួយថា មានពិរុទ្ធបានប្រព្រឹត្តបទបង្ខាំងកុមារលើសពីរយៈពេល ១ ខែ ( មាត្រា ២១ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ) ហើយរកឃើញថា មានពិរុទ្ធដោយតុលាការ មួយផ្សេងទៀត ពីបទលក់ដូរកុមារ ( មាត្រា ១៤ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ) ជនល្មើសនោះ នឹងត្រូវផ្តន្ទាទោសជាប់ ពន្ធនាគារ ពី ៥ឆ្នាំ ដល់ ១០ឆ្នាំ យោងតាមមាត្រា ២១ និង ពី ២ឆ្នាំ ដល់ ៥ឆ្នាំ យោងតាមមាត្រា ១៤ ។

ក្នុងករណីនេះ ប្រសិនបើតុលាការទី ១ បានផ្តន្ទាទោសជនល្មើសដាក់ពន្ធគាររយៈពេល ៩ ឆ្នាំ ហើយតុលាការ ទី ២ បានផ្តន្ទាទោសជនល្មើសដាក់ពន្ធគាររយៈពេល ៥ ឆ្នាំ ។ ដោយអនុលោមតាមគោលការណ៍ស្រូបទោស តុលាការ ទី ២ អាចប្រកាសអោយអនុវត្តទោសស្រូបបញ្ចូលគ្នា រវាងទោសទី ១ និងទោសទី ២ ក្នុងព្រំដែននៃអតិបរមាស្របច្បាប់

ដែលខ្ពស់ជាងគេ ពោលគឺ ១០ ឆ្នាំ តែប៉ុណ្ណោះ ដូចជា ទោសទី ២(ចំនួន ៥ ឆ្នាំ) ត្រូវស្រូបចូលទៅក្នុងទោសទី ១ ចំនួន ៤ ឆ្នាំ ដូចនេះទោសដែលត្រូវអនុវត្ត គឺ ១០ ឆ្នាំ (៥ ឆ្នាំ - ៤ឆ្នាំ = ១ ឆ្នាំ ហើយទោស ១ ឆ្នាំ បូក ៩ ឆ្នាំ ស្មើ ១០ឆ្នាំ) ។

**មាត្រា ៧.. និយមន័យនៃអនីតិជន**

អនីតិជននៅក្នុងច្បាប់នេះ មានន័យថា ជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ។ ជនណាដែលរក្សាទុក អនីតិជន ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង ឬ ត្រួតពិនិត្យរបស់ខ្លួននឹងត្រូវចាត់ទុកថា បាន ដឹងពីអាយុរបស់អនីតិជននោះ លើកលែងតែជននោះបង្ហាញឱ្យឃើញថា ខ្លួនមានការជឿជាក់ដោយសមហេតុផលថា
អនីតិជននោះ មានអាយុ ១៨ ឆ្នាំ ឬ ច្រើនជាង ១៨ ឆ្នាំ ។

ចំពោះគោលបំណង នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ មាត្រានេះ កំណត់និយមន័យ ពាក្យថា " អនីតិជន " ដោយកំណត់ នីតិភាព នៅអាយុ ១៨ ឆ្នាំ ។

ជាការសំខាន់គួរកត់សំគាល់ថា អាយុដែលកំណត់ដោយ មាត្រានេះ គឺមិនដូចគ្នា នឹងអាយុ នៃការព្រមព្រៀង រួមភេទ ដែលមានការកំណត់ និយមន័យក្នុងមាត្រា ៤២ ដល់មាត្រា ៤៣ នៅអាយុ ១៥ ឆ្នាំ ។ ហេតុដូច្នេះ ជនណា ដែលមានអាយុយ៉ាងតិច ១៥ ឆ្នាំ អាចយល់ព្រមរួមភេទ ដោយស្ម័គ្រចិត្ត (ប៉ុន្តែកត់សំគាល់ថា ការប្រកបរបរ ពេស្យាចារ កំណត់តែចំពោះ ជនណាដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ) ។ (សូមមើលការពិភាក្សា យោងតាមមាត្រា ៤២ ដល់ មាត្រា ៤៤ សម្រាប់ព័ត៌មានលំអិតជាងនេះ) ។

### " អនីតិជននៅក្នុងច្បាប់នេះ មានន័យថា ជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ "

មាត្រានេះកំណត់ និយមន័យថា ពាក្យ " អនីតិជន " នៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ មានន័យថា ជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ។ ហេតុដូច្នេះ កន្លែងណាដែលមានពាក្យ " អនីតិជន " នៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺសំដៅទៅ ជនណាដែល មានអាយុក្រោម ១៨ ឆ្នាំ ។

នីតិភាព ដែលកំណត់ក្នុងមាត្រានេះ សំខាន់ណាស់ សម្រាប់កំណត់ការទទួលខុសត្រូវព្រហ្មទណ្ឌ និង/ឬ សម្រាប់កំណត់ទោស ទៅលើជនល្មើសដែលជា អនីតិជន ឬ សម្រាប់កំណត់កំរិតនៃទោស ទៅលើជនល្មើសជា នីតិជន ដែលត្រូវរកឃើញថា មានពិរុទ្ធ ពីបទល្មើសដែលប្រព្រឹត្តមកលើ អនីតិជន ។ ក្នុងករណីដែលជនរងគ្រោះ ជាអនីតិជន មាត្រាខ្លះ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ដាក់ទោសឱ្យខ្ពស់ ចំពោះជន ណា ដែលត្រូវគេរកឃើញថាបានប្រព្រឹត្តបទល្មើសនេះ លើអនីតិជន ។

កត់សំគាល់ថា ចំពោះជនល្មើសជាអនីតិជន ក្រមព្រហ្មទណ្ឌ ( គន្ថីទី ១ មាតិកាទី ២ ជំពូកទី ៣ " ការទទួល ត្រូវព្រហ្មទណ្ឌរបស់អនីតិជន " ចែងពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌស្រាល និងផ្តន្ទាទោស ក្នុងករណីដែលជនល្មើស ជាអនីតិជន ដែលមានអាយុនៅចន្លោះ ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ។ យ៉ាងណាមិញ យោងតាមមាត្រា ៤៤ នៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អនីតិជនអាយុក្រោម ១៥ ឆ្នាំ មិនត្រូវទទួលការ

ផ្តន្ទាទោស ពីការ ប្រព្រឹត្តបទ ល្មើស យោងតាមមាត្រា ៤២ " អមពើរួម ភេទជាមួយ អនីតិជនអាយុក្រោម ១៥ ឆ្នាំ " ) ឬ មាត្រា ៤៣ ( " អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ " )[៧] ។

អាយុរបស់អនីតិជនត្រូវគណនាដោយគិតចាប់ពីថ្ងៃកំណើត ឱ្យស្របទៅនឹង ក្រមរដ្ឋប្បវេណី ( មាត្រា ៩៨៦ "វិធីគណនាអាយុ " ) ។

### " ជនណាដែលរក្សាទុកអនីតិជនឱ្យស្ថិតនៅក្រោមការគ្រប់គ្រង ឬ ត្រួតពិនិត្យរបស់ខ្លួន "

បទប្បញ្ញត្តិនេះ សំដៅទៅលើជនណាដែល គ្រប់គ្រង ឬ ត្រួតពិនិត្យ លើអនីតិជន ។ " ការគ្រប់គ្រង ឬ ត្រួតពិនិត្យ " មានន័យថាជាស្ថានការណ៍ពីរ :

១) អំណាចស្របច្បាប់ ដែលច្បាប់ផ្តល់ទៅឱ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬ អ្នកថែរក្សាអនីតិជន ។

២) ការគ្រប់គ្រង ឬ ការត្រួតពិនិត្យ ដ៏សមរម្យទៅលើអនីតិជន សូម្បីតែក្នុងករណីដែល នីតិជនមិនមានអំណាចតាមផ្លូវច្បាប់ ទៅលើអនីតតិជននោះ ដូចនៅក្នុងចំណុចទី ១ ខាងលើ ក៏ដោយ ។

**ឧទាហរណ៍ : ប្រសិនបើ ឪពុក ឬ ម្តាយ សុំឱ្យសាច់ញាតិ ឬ អ្នកជិតខាងថែរក្សាកូន ដែលជាអនីតិជនរបស់គាត់ក្នុងពេលមួយ សាច់ញាតិ ឬ អ្នកជិតខាងនោះ ត្រូវគេចាត់ទុកថា មានការគ្រប់គ្រង ឬ ត្រួតពិនិត្យ ទៅលើអនីតិជននោះ ។ ប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើអនីតិជន ត្រូវគេជ្រើសរើសឱ្យបម្រើការងារ និយោជក ត្រូវគេចាត់ទុកថា មានការគ្រប់គ្រង ឬ ត្រួតពិនិត្យ ទៅលើអនីតិជន នៅពេលម៉ោងការងារ ឬ ចំពេលដែល អនីតិជន នោះកំពុងធ្វើការងារ ។ ប្រសិនបើ អនីតិជនទៅឯសាលារៀន លោកគ្រូ ឬ អ្នកគ្រូ និងនាយកសាលា ត្រូវចាត់ទុកថា មានការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជននោះ ។**

### " ចាត់ទុកថា បានដឹងពីអាយុរបស់អនីតិជននោះ លើកលែងតែជននោះបង្ហាញឱ្យឃើញថាសមហេតុផល "

បទបញ្ញត្តិនេះ មានន័យថា ក្នុងករណី ជនណាម្នាក់មានការគ្រប់គ្រង ឬ ការត្រួតពិនិត្យ ទៅលើអនីតិជន ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា បានដឹងអំពីអាយុអនីតិជននោះ ។ ហេតុដូច្នេះ មាត្រានេះ ធ្វើការដាក់បន្ទុកនៃភស្តុតាង ទៅកាន់ជនដែលមានការគ្រប់គ្រង ឬ ត្រួតពិនិត្យ លើអនីតិជន ។

**ឧទាហរណ៍ : ប្រសិនបើ នីតិជន មានការគ្រប់គ្រង ឬ ត្រួតពិនិត្យ ទៅលើជនរងគ្រោះ ដែលជាអនីតិជន ហើយគាត់ត្រូវគេរកឃើញថា មានពិរុទ្ធប្រព្រឹត្តបទល្មើសមកលើជនរងគ្រោះ ដែលជាអនីតិជន ហេតុដូច្នេះ ក្នុងករណី**

---

[៧] ទោះបីជាគត់សំគាល់ថា ក្នុងករណីដែលអនីតិជនអាយុក្រោម ១៥ ឆ្នាំ ប្រព្រឹត្តបទល្មើសដូចជា រំលោភសេពសន្ថវៈ ឬ ប្រភេទផ្សេងទៀតនៃការឈ្លានពានខាងផ្លូវភេទ (សូមមើល ក្រមព្រហ្មទណ្ឌ គន្ថីទី ២ មាតិកាទី ២ "ការឈ្លានពានខាងផ្លូវភេទ" ហេតុដូច្នេះជនល្មើសជាអនីតិជន មិនត្រូវទទួលទោសយោងតាមមាត្រា ៤២ ដល់ មាត្រា ៤៣ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញ ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទេ ។ ប៉ុន្តែអាចនៅតែទទួលទោស យោងតាមមាត្រាដែលពាក់ព័ន្ធ នៃច្បាប់ព្រហ្មទណ្ឌ ។

នេះ ជនល្មើសមិនអាចងាយស្រួលសុំឱ្យមានការការពារដែលថា គាត់មិនដឹងថា ជនរងគ្រោះជាអនីតិជន ដោយសារតែមាត្រានេះចាត់ទុកថា ជននោះបានដឹងពីអាយុរបស់អនីតិជន ដោយសារតែ ការគ្រប់គ្រង ឬ ការត្រួតពិនិត្យ របស់ខ្លួនទៅលើអនីតិជននោះ ។

ប្រសិនបើជនល្មើស នៅក្នុងឧទាហរណ៍នេះ ចង់ទាមទារឱ្យមានការការពារ ដែលថា គាត់មិនបានដឹងពី អាយុរបស់អនីតិជន គាត់ត្រូវតែផ្តល់ភស្តុតាងថា គាត់បានជឿដោយសមហេតុផលថា អនីតិជននោះ មានអាយុ ១៨ ឆ្នាំ ឬ លើសពី ១៨ ឆ្នាំ ។

ទោះបីជាមាត្រានេះ ចែងពី នីតិភាព និងមិនមែនជាអាយុយល់ព្រមរួមភេទ ការសន្មត់ជាមុនថាបានដឹងដោយជនណាម្នាក់ដែលបាន គ្រប់គ្រង ឬ ត្រួតពិនិត្យ ទៅលើអនីតិជន ក៏គ្របដណ្តប់ទៅលើសំនួរ ដែលទាក់ទងនឹងអាយុនៃការយល់ព្រមរួមភេទផងដែរ និងជាពិសេស ទាក់ទងទៅនឹង បទល្មើសដែលមានចែងក្នុងមាត្រា ៤២ ( អំពើរួមភេទ ជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ ) និងមាត្រា ៤៣ ( អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ ") នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។ ឧទាហរណ៍ : ក្នុងករណីដែល ជនណាម្នាក់មានការគ្រប់គ្រង ឬ ត្រួតពិនិត្យ ទៅលើអនីតិជន មានទំនាក់ទំនងផ្លូវភេទជាមួយអនីតិជននោះ មាត្រានេះចាត់ទុកថា ជននោះបានដឹងពីអាយុរបស់អនីតិជន និងដូច្នេះហើយ ជននោះមិនអាចងាយស្រួល ទាមទារការការពារ ដែលថា គាត់មិនបានដឹងពីអាយុរបស់អនីតិជន ថាមានអាយុក្រោម ១៥ ឆ្នាំ ទេ ។

## " ខ្លួនមានការជឿជាក់ ដោយសមហេតុផលថា អនីតិជននោះ មានអាយុ ១៨ ឆ្នាំ ឬ ច្រើនជាង ១៨ ឆ្នាំ "

ក្នុងករណីដែលជនណាម្នាក់ ដែលមានការ គ្រប់គ្រង ឬ ត្រួតពិនិត្យ ទៅលើអនីតិជន ចង់ទាមទារឱ្យមានការការពារដែលគាត់បានជឿថា អនីតិជននោះ មានអាយុ ១៨ ឆ្នាំ ឬ លើសពី ១៨ ឆ្នាំ ជាការមិនគ្រប់គ្រាន់ទេ សម្រាប់ជនជាប់ចោទ ដោយគ្រាន់តែអះអាងថា អនីតិជននោះមើលទៅមានអាយុ ១៨ ឆ្នាំ ឬ លើសពី ១៨ ឆ្នាំ ។ ក្នុងករណីបែបនេះ ជនជាប់ចោទត្រូវតែបង្ហាញ ការជឿ របស់គាត់ថា សមហេតុផល ។

ក្នុងការបកស្រាយ អ្វីដែលបង្កើតឱ្យមាន " ជំនឿសមហេតុផល " យោងតាមអនុសាសន៍ តុលាការត្រូវអនុវត្តវិធីសាស្ត្រ សត្យានុម័ត និងធ្វើការវាយតម្លៃតាមរឿងក្តីនីមួយៗ ដោយផ្អែកទៅលើអង្គហេតុ ។ ជំនឿសមហេតុផល មានន័យថា មនុស្សធម្មតាដែលមានការវិនិច្ឆ័យជាមធ្យម គួរតែជឿថា អនីតិជននោះមានអាយុ ១៨ ឆ្នាំ ឬ លើសពី ១៨ ឆ្នាំ ។ ក្នុងការពិចារណាថាតើជំនឿនេះ សមហេតុផល ដែរ ឬ ទេ ? តុលាការអាចមើលកត្តាជាច្រើនដែលរួមមាន ជាអាទិ៍ អាយុពិតរបស់ជនរងគ្រោះ ការបង្ហាញពីអាយុតាមរយៈការផ្តល់ឯកសារ ( ឧទាហរណ៍ : ក្នុងករណីដែល អនីតិជន ផ្តល់សំបុត្រកំណើត ឬ អត្តសញ្ញាណប័ណ្ណក្លែងក្លាយ ដែលបញ្ជាក់ថា អនីតិជននោះ មានអាយុ ១៨ ឆ្នាំ ឬ លើសពី ១៨ ឆ្នាំ ) ។ល។

# ជំពូកទី ២
## អំពើលក់-ដូរមនុស្ស

ជំពូកនេះ មានការកំណត់និយមន័យបទល្មើស និងធ្វើការផ្តន្ទាទោស ចំពោះបទល្មើសលក់-ដូរមនុស្ស ។ ហេតុដូច្នេះ ជំពូកនេះ គឺជាមធ្យោបាយដ៏ចំបង ដែលច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្យាយាមអនុវត្ត ពិធីសារប៉ាឡឺម៉ូ ។

ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្រនៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្សេងគ្នាពី វិធីសាស្ត្រនៃពិធីសារប៉ាឡឺម៉ូ ។ ពិធីសារប៉ាឡឺម៉ូ មានចែងពីការផ្សំនៃ អំពើមធ្យោបាយ និងគោលបំណង ផ្សេងៗគ្នាជាច្រើន ក្នុងការកំណត់និយមន័យបទល្មើស " អំពើលក់-ដូរមនុស្ស " ។ ផ្ទុយទៅវិញ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្យាយាមបែងចែកអំពើទាំងនេះ ឱ្យទៅជាបទល្មើសដាច់ដោយឡែក និងផ្សេងៗគ្នា ដូចជាជំពូកនេះ បែងចែកឱ្យផ្សេងពីគ្នា រវាងបទល្មើស ការនាំយកចេញដោយមិនស្របច្បាប់ និងការជ្រើសរើសដោយមិនស្របច្បាប់ អំពើលក់-ដូរមនុស្ស ការដឹកជញ្ជូនជនរងគ្រោះដោយអំពើជួញដូរ ទៅនឹងការទទួលយកជនរងគ្រោះ ដោយអំពើជួញដូរ ។ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កំណត់និយមន័យយ៉ាងច្បាស់ និងផ្តល់ការផ្តន្ទាទោសចំពោះបទល្មើសនីមួយៗ និងក្នុងករណីជាច្រើនទៀត ក៏មានការចែងពីកត្តាស្ថានទម្ងន់ទោស និងការផ្តន្ទាទោសកើនឡើង ឆ្លើយតបនឹងកត្តាស្ថានទម្ងន់ទោសនោះ ។

នៅក្នុងប្រទេសមួយចំនួន ច្បាប់ដែលពាក់ព័ន្ធមានបញ្ចូលបទប្បញ្ញត្តិ ស្តីពី ការការពារជនរងគ្រោះ ។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាផ្នែកមួយ នៃច្បាប់ព្រហ្មទណ្ឌទូទៅ និងហេតុដូច្នេះ បទប្បញ្ញត្តិទាំងនោះ មិនត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់នេះទេ ។ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានបង្កើត និងបន្តបង្កើត បទដ្ឋាន ស្តីពី ការការពារជនរងគ្រោះ តាមរយៈ ឧបករណ៍ ច្បាប់ផ្សេងទៀត ព្រមទាំងមានបទបញ្ជា និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធផងដែរ ។

រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្តីសម្រេច និងគោលការណ៍ណែនាំ ស្តីពី ការការពារជនរងគ្រោះ ហើយនៅពេលសរសេរនេះ កំពុងតែរៀបចំបទដ្ឋានអប្បបរិមាថ្នាក់ជាតិ ស្តីពី ការការពារជនរងគ្រោះ ។ ឧទាហរណ៍ : ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានចេញសេចក្តីសម្រេច ស្តីពី គោលការណ៍ណែនាំសម្រាប់ការ ការពារសិទ្ធិកុមារ ដែលត្រូវគេជួញដូរ នៃព្រះរាជាណាចក្រកម្ពុជា ( សេចក្តីសម្រេចលេខ ១០៧ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧) ។ នៅឆ្នាំដដែល ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយ អង្គការមិនមែនរដ្ឋាភិបាល ចំនួន ២៤ ស្តីពី គោលការណ៍ណែនាំសម្រាប់កិច្ចប្រតិបត្តិ និងកិច្ចសហប្រតិបត្តិការ រវាង ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ និងទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងករណីអំពើជួញដូរមនុស្ស ។

ប្រទេសកម្ពុជាក៏បានចុះកិច្ចព្រមព្រៀងអន្តរជាតិ ដែលមានចែងពីបទប្បញ្ញត្តិ ស្តីពី ការការពារជនរងគ្រោះដែរ ។ ក្នុងឆ្នាំ ២០០៧ ប្រទេសកម្ពុជាបានចុះហត្ថលេខាតំបន់អាស៊ាន ស្តីពី ការការពារជនរងគ្រោះជាកុមារ ដោយសារអំពើជួញដូរ[៨] ។ មុនឆ្នាំ ២០០៧ ប្រទេសកម្ពុជាក៏បានចុះហត្ថលេខាលើ អនុស្សារណៈនៃការយោគយល់គ្នា ទ្វេភាគីជាមួយប្រទេសថៃឡង់ដ៍[៩] និង ប្រទេសវៀតណាម[១០] ព្រមទាំងកិច្ចព្រមព្រៀងតំបន់ សម្រាប់មហាអនុតំបន់ទន្លេមេគង្គ[១១] ។

**មាត្រា ៨.- និយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់**

ការនាំយកចេញដោយមិនស្របច្បាប់ នៅក្នុងច្បាប់នេះមានន័យថា :

១- ការធ្វើឱ្យមនុស្សម្នាក់ ផ្លាស់ទីពីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃដែលស្ថិត នៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬ របស់តតិយជន តាមមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬ លួងលោម ។

២- ការនាំយកអនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬ នៅក្រោមបិត្តុបត្ថម្ភ ឬ នៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬ យុត្តិកម្មតាមផ្លូវច្បាប់ ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្តាយ អ្នកថែរក្សា ឬ អ្នកអាណាព្យាបាលរបស់គេ ។

មាត្រានេះកំណត់និយមន័យពាក្យ " ការនាំយកចេញដោយមិនស្របច្បាប់ " ដែលក៏សំដៅទៅមាត្រា ៩ ដល់មាត្រា ១១ នៃជំពូកនេះ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ មាត្រានេះមិនបង្កើតឱ្យមានបទល្មើស ការនាំចេញដោយមិនស្របច្បាប់ និងយោងតាមមាត្រានេះ មិនគួរឱ្យមានការផ្តន្ទាទោសទេ ។ ការចោទប្រកាន់បទល្មើស ដែលទាក់ទងនឹងបទល្មើសការនាំយកចេញដោយមិនស្របច្បាប់ គួរតែធ្វើឡើងយោងតាមមាត្រាដែលសមស្រប ។ ( សូមពិនិត្យមើល មាត្រា ៩ ដល់ មាត្រា ១១ ) ។

ជាសំខាន់ ការនាំចេញដោយមិនស្របច្បាប់ ប្រហាក់ប្រហែលគ្នានឹងបទល្មើស " អំពើចាប់ពង្រត់ " ដូចមាននិយមន័យ ក្នុងច្បាប់ជួញដូរ ឆ្នាំ ១៩៩៦ និងច្បាប់ព្រហ្មទណ្ឌផ្សេងខ្លះទៀត ។

---

[៨] គោលការណ៍ណែនាំអាស៊ីអគ្នេយ៍ សម្រាប់ការ ការពារសិទ្ធិ នៃជនរងគ្រោះជាកុមារ ដោយសារអំពើជួញដូរ ( ខែធ្នូ ឆ្នាំ ២០០៧)

[៩] អនុស្សារណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី សម្រាប់លុបបំបាត់អំពើជួញដូរកុមារ និងស្ត្រី និងជួយជនរងគ្រោះដោយសារអំពើជួញដូរ បានត្រូវ ចុះហត្ថលេខានៅទីក្រុងសៀមរាប នៅថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៣ ។ កិច្ចព្រមព្រៀងនេះ បន្ថែមដោយគោលការណ៍ណែនាំ សម្រាប់កិច្ចសហប្រតិបត្តិការ រវាងប្រទេសកម្ពុជា និងប្រទេសថៃឡង់ដ៍ ស្តីពី ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ នៃបទល្មើសដែល ទាក់ទងនឹងអំពើជួញដូរ ។

[១០] កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពី កិច្ចសហ ប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ចោលអំពើជួញដូរស្ត្រី និងកុមារ និងជួយជនរងគ្រោះដោយសារអំពើជួញដូរត្រូវបានចុះហត្ថ- លេខា នៅទីក្រុងហាណូយ នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥ ។

[១១] អនុស្សារណៈនៃការយោគយល់គ្នា ស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់ទន្លេមេគង្គត្រូវបានចុះហត្ថលេខា ដោយរដ្ឋាភិបាលនៃប្រទេសកម្ពុជា នៅទីក្រុង រ៉ាងហ្គូន ប្រទេសភូមា នៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤ ។

មាត្រានេះកំណត់និយមន័យពាក្យ " ការនាំយកចេញដោយមិនស្របច្បាប់ " ក្នុងវិធីពីរ ផ្សេងៗគ្នា ទោះបី ជានៅក្នុងករណីទាំង ពីរ នេះ បញ្ហាជាគន្លឹះគឺថា យោងតាមច្បាប់ ជនរងគ្រោះមិនអាចយល់ព្រម ចំពោះការនាំយកចេញខ្លួនគាត់ ។ កថាខ័ណ្ឌទី ១ តម្រូវឱ្យជនល្មើសប្រព្រឹត្តអំពើ ដោយប្រើប្រាស់មធ្យោបាយមួយចំនួន ដែលធ្វើឱ្យមានមោឃៈភាពដល់សមត្ថភាពរបស់ជនរងគ្រោះ ក្នុងការយល់ព្រម ( ឧទាហរណ៍ : តាមរយៈការបង្ខិតបង្ខំ ឬ ការគម្រាមកំហែង ឬ ប្រើប្រាស់ថ្នាំញៀន ដែលធ្វើឱ្យមានមោឃៈភាពដល់សមត្ថភាពរបស់ជនរងគ្រោះ ក្នុងការយល់ព្រម ) ឬធ្វើឱ្យមានមោឃៈភាពដល់សមត្ថភាពរបស់ជនរងគ្រោះ ក្នុងការយល់ព្រម ដោយមានការបោកប្រាស់ (ការបោកបញ្ឆោត ការលួងលោម ) ។ កថាខ័ណ្ឌទី ២ មិនតម្រូវឱ្យមានមធ្យោបាយជាក់លាក់ណាមួយទេ ប៉ុន្តែតម្រូវថា ជនល្មើសប្រព្រឹត្តអំពើប្រឆាំងនឹងជនរងគ្រោះ ដែលមានសមត្ថភាពតាមផ្លូវច្បាប់តិចតួច ដែលស្ថិតនៅក្រោមការគ្រប់គ្រង ឬ នៅក្រោមហិតូបត្ថម្ភរបស់ជនម្នាក់ទៀត ។ កថាខ័ណ្ឌ ទី ២ គឺជាកថាខ័ណ្ឌ ដែលអនុវត្តជាទូទៅបំផុត ក្នុងស្ថានការណ៍ដែលទាក់ទិននឹងការនាំយកចេញអនីតិជន ដែលយោងតាមច្បាប់ ខ្វះសមត្ថភាពក្នុងការយល់ព្រម ។ ជនល្មើសប្រព្រឹត្តបទល្មើស ការនាំយកចេញដោយមិនស្របច្បាប់ នៅពេលដែលជនល្មើសនោះ បំពេញតាមនិយមន័យទី ១ ឬនិយមន័យទី ២ ។

មានភាពខុសគ្នាមួយទៀត រវាងនិយមន័យដែលមាននៅក្នុងកថាខ័ណ្ឌទី ១ និងនិយមន័យដែលមាននៅក្នុងកថាខ័ណ្ឌទី ២ គឺថា កថាខ័ណ្ឌទី ១ តម្រូវឱ្យជនរងគ្រោះត្រូវបាននាំយកចេញពី " ទីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬ របស់តតិយជន " ។ នៅក្នុងកថាខ័ណ្ឌទី ២ មិនតម្រូវដូច្នេះទេ ដោយគ្រាន់តែបញ្ជាក់ថា ជនរងគ្រោះ " ត្រូវបាននាំយកចេញពីការគ្រប់គ្រងស្របច្បាប់នៃ ឪពុកម្តាយអ្នកថែរក្សា ឬ អ្នកអាណាព្យាបាល របស់គេ " ។

**កថាខ័ណ្ឌទី ១** នៃមាត្រានេះ ចែងពីធាតុផ្សំនៃបទល្មើសសំខាន់ៗ បី :

១) ការនាំយកចេញ

២) ការត្រួតពិនិត្យ

៣) មធ្យោបាយ

ធាតុផ្សំទាំងនេះ ត្រូវពិពណ៌នាយ៉ាងលំអិតដូចខាងក្រោម ។

## " ការធ្វើឱ្យមនុស្សម្នាក់ ផ្លាស់ទីពីកន្លែងដែលគេកំពុងរស់នៅ "

ដើម្បីឱ្យមានបទល្មើសការនាំចេញដោយខុសច្បាប់ ជនល្មើសត្រូវតែនាំយកចេញរូបកាយ ឬ នាំយកចេញជនណាម្នាក់ ( ជនរងគ្រោះ ) ពីទីកន្លែងដែលគេកំពុងរស់នៅ ។

ចំពោះច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពាក្យថា " ទីកន្លែងដែលគេកំពុងរស់នៅ " មិនមែនមានន័យថា គ្រាន់តែជាផ្ទះ ឬ ទីលំនៅឋានរបស់ជនរងគ្រោះ ប៉ុណ្ណោះទេ ប៉ុន្តែជា " មូលដ្ឋាន និងមជ្ឈដ្ឋាននៃជីវិត ពោលគឺ ជាទីកន្លែងដែលជននោះធ្វើការចិញ្ចឹមជីវិតរបស់ខ្លួនជាអចិន្ត្រៃយ៍ ។ និយមន័យនេះស្រប

ទៅនឹងនិយមន័យដែលមានចែងក្នុង មាត្រា ៣៤ ដល់ មាត្រា ៣៦ នៃក្រមរដ្ឋប្បវេណី ។ ក្នុងន័យផ្សេងទៀត ពាក្យថា " ទីកន្លែងដែលគេកំពុងរស់នៅ " ក្នុងមាត្រានេះ មានចេតនាត្រូវបានយល់យ៉ាងទូលំទូលាយ និងរាប់បញ្ចូល ទីកន្លែងទាំងអស់ នៅក្នុងបរិវេណជុំវិញលំនៅដ្ឋានរបស់ជនរងគ្រោះ ។ ការនាំយកចេញពីទីកន្លែង បែបនេះ មានន័យថា ជនរងគ្រោះត្រូវនាំយកចេញឱ្យឆ្ងាយពីលំនៅដ្ឋានរបស់គាត់ និង/ឬ បើមិនដូច្នេះទេ ត្រូវបានហាមឃាត់រូបកាយពីការចូលទៅក្នុងលំនៅដ្ឋានរបស់គាត់ ។ ឧទាហរណ៍ : ប្រសិនបើជនណាម្នាក់ត្រូវនាំយកចេញដោយមិនស្របច្បាប់ នៅពេលកំពុងធ្វើការ អំពើនេះត្រូវចាត់ទុកថា ជាការនាំយកចេញដោយមិនស្របច្បាប់ពី " ទីកន្លែងដែលគាត់កំពុងរស់នៅ " ( ទោះបីជាជននោះ ត្រូវនាំយកចេញពីកន្លែងការងារ និងមិនមែនជាផ្ទះរបស់ខ្លួនក៏ដោយ ) ដោយសារតែគាត់មិនអាចចេញពីកន្លែងការងារទៅផ្ទះ ដូចធម្មតា ។ ប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើ ជនរងគ្រោះនោះ គឺជាជនដែលគ្មានផ្ទះសម្បែងអចិន្ត្រៃយ៍ " ទីកន្លែងដែលគាត់រស់នៅ " សំដៅទៅលើទីកន្លែង ដែលជននោះ ចំណាយពេលវេលានៅទីនោះជាទម្លាប់ ។

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា ជនល្មើសនោះគឺជាជនដែលធ្វើការនាំយកចេញ ឬ ដឹកនាំឱ្យមានការនាំយកចេញ និងមិនមែនជាជនដែលដឹកជញ្ជូនជនរងគ្រោះទេ ។ ឧទាហរណ៍ : និយោជកប្រាប់ អ្នកបើកបរតាក់ស៊ីឱ្យជូននិយោជិតភេទស្រីរបស់ខ្លួនទៅកាន់ផ្ទះសំណាក់ ដែលនិយោជិតនោះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់តតិយជន តាមមធ្យោបាយជាក់លាក់ណាមួយដែលមានចែងក្នុងមាត្រានេះ ។ អ្នកបើកបរតាក់ស៊ីគ្រាន់តែដឹកជញ្ជូននិយោជិតនោះ ដោយមិនបានដឹងអំពីបទល្មើសនោះ និងមិនបានប្រើប្រាស់ មធ្យោបាយជាក់លាក់ណាមួយ ។ ក្នុងករណីនេះ អ្នកបើកបរតាក់ស៊ីនោះមិនទទួលទោស ប៉ុន្តែនិយោជក អាចត្រូវបានចាត់ទុកថាជាជនល្មើស និងយោងតាមមាត្រានេះ ត្រូវទទួលទោស ។

**" នៅកាន់ទីកន្លែងដទៃដែលស្ថិត នៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬ របស់តតិយជន "**

ដើម្បីឱ្យកើតមានឡើង បទល្មើសនាំចេញដោយមិនស្របច្បាប់ ជនរងគ្រោះត្រូវតែត្រូវនាំយកចេញពីទីកន្លែងមួយ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ជនល្មើស ឬ របស់តតិយជន ។ មានន័យថា ជនរងគ្រោះត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ជនម្នាក់ទៀត និងមិនអាចចាកចេញដោយស្ម័គ្រចិត្ត ពីទីកន្លែងដែលគាត់ត្រូវបាននាំយកចេញ។

**" តាមមធ្យោបាយ "**

និយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់ មានចែងក្នុងកថាខ័ណ្ឌទី ១ តម្រូវឱ្យជនល្មើសប្រើប្រាស់មធ្យោបាយមួយដូចខាងក្រោម ដើម្បីសម្រេចបានការនាំយកចេញជនរងគ្រោះ ។ លក្ខណៈរួមនៃមធ្យោបាយទាំងអស់នេះ គឺថាជនរងគ្រោះ មិនបានយល់ព្រមដោយសេរី និងពេញលេញចំពោះការនាំយកចេញខ្លួនគាត់នោះឡើយ ។

## " ការបង្ខិតបង្ខំ "

" ការបង្ខិតបង្ខំ " មានន័យថា ជាការបង្ខិតបង្ខំផ្លូវកាយ ឬ ផ្លូវចិត្ត ប្រឆាំងនឹងឆន្ទៈរបស់ជនរងគ្រោះ ។ មាត្រានេះ មិនតម្រូវឱ្យជនល្មើសប្រើអំពើហិង្សា ឬ មិនតម្រូវឱ្យជនរងគ្រោះប្រឆាំងតទល់ ឬ ទទួលរងរបួសដោយសារតែ ការប្រើប្រាស់ការបង្ខិតបង្ខំនោះទេ ។ ឧទាហរណ៍ : ប្រសិនបើ ជនល្មើសចាប់ជនណាម្នាក់ និងបានរុញ ឬ ទាញជននោះ អំពើនេះ នៅតែត្រូវចាត់ទុកថា ជាការប្រើការបង្ខិតបង្ខំ ទោះបីជនរងគ្រោះមិនឈឺក៏ដោយ ។

តុលាការអាចកត់សំគាល់ពីការកើនឡើង នៃភាពងាយទទួលរងគ្រោះនៃជនរងគ្រោះ និងហេតុដូច្នេះ ជាពិសេស តុលាការ ក៏ត្រូវពិចារណាលើការបង្ខិតបង្ខំដែលមិនមែនមកលើរូបកាយ ដូចជាការបង្ខិតបង្ខំតាមផ្លូវចិត្ត ។

## " ការគម្រាមកំហែង "

" ការគម្រាមកំហែង " មានន័យថា ជាការគម្រាមកំហែងទាំង ដោយផ្ទាល់ និងដោយប្រយោល ដែលធ្វើឱ្យជនរងគ្រោះភ័យខ្លាចពីការធ្វើបាបរូបកាយ ឬ ផ្លូវចិត្ត ឬ ភ័យខ្លាចមានគ្រោះថ្នាក់ផ្សេងទៀតដល់ខ្លួន ឬ ដល់តតិយជន។ ឧទាហរណ៍ : នេះជាការគម្រាមកំហែង ប្រសិនបើជនល្មើសនាំយកចេញជនរងគ្រោះ ដោយធ្វើឱ្យជនរងគ្រោះជឿថា ជនល្មើស នឹងធ្វើបាបសាច់ញាតិរបស់ជនរងគ្រោះ ប្រសិនបើជនរងគ្រោះ មិនទៅជាមួយជនល្មើស ទេ ។

ជនល្មើសមិនចាំបាច់គម្រាមកំហែងជនរងគ្រោះ ឬ តតិយជន ដោយធ្វើបាបរូបកាយទេ ។ ជាការគ្រប់គ្រាន់ហើយ ដែលថាជនល្មើសគម្រាមប្រព្រឹត្តបទល្មើស ឧក្រិដ្ឋ ឬ មជ្ឈិម ប្រឆាំងនឹងជនណាម្នាក់ ( ជនរងគ្រោះ ឬ តតិយជន ) ។ នេះស្របទៅនឹង ផ្នែកស្តីពី " ការគម្រាមកំហែង " ក្នុងក្រមព្រហ្មទណ្ឌ ( មាត្រា ២៣១ ដល់មាត្រា ២៣៤ ) ។

ក្នុងករណីដែលជនល្មើសគម្រាមប្រព្រឹត្តអំពើស្របច្បាប់ ប៉ុន្តែប្រើប្រាស់ការគម្រាមកំហែងនោះ ដើម្បីប្រព្រឹត្តបទល្មើស អំពើនេះ នៅតែត្រូវចាត់ទុកថា ជាការគម្រាមកំហែង ។ ឧទាហរណ៍ : ប្រសិនបើជនល្មើសឱ្យខ្ចីលុយ និងគម្រាមកំហែងឱ្យសងបំណុល ដើម្បីប្រព្រឹត្តបទល្មើស យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ហេតុដូច្នេះអំពើនេះ នៅតែត្រូវចាត់ទុកថាជាបទល្មើស ។ ដូចគ្នានេះដែរ ប្រសិនបើជនល្មើសគម្រាមកំហែងថា នឹងរាយការណ៍អំពីការធ្វើអន្តោប្រវេសន៍ខុសច្បាប់ របស់ជនរងគ្រោះ ទៅដល់អាជ្ញាធរមានសមត្ថកិច្ច និងបានប្រើការគម្រាមកំហែងនោះ ដើម្បីឱ្យខ្លួន (ជនល្មើស) បានសម្រេចគោលបំណងក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ហេតុដូច្នេះ អំពើនេះ នៅតែត្រូវចាត់ទុកថា ជាបទល្មើស ។

## " ការបោកបញ្ឆោត "

" ការបោកបញ្ឆោត " មានន័យថា ជាស្ថានការណ៍ដែលជនល្មើសប្រើពាក្យកុហក ការផ្តល់ព័ត៌មានមិនពេញលេញ ឬ រឿងមិនពិត ជាពាក្យសំដី ឬ ជាទង្វើ ដើម្បីឱ្យជនរងគ្រោះជឿធ្វើអ្វីមួយ ។

## " ការបំពានដោយអំណាច "

" ការបំពានដោយអំណាច " មានន័យថា ជាស្ថានការណ៍ណាមួយ ដែលមន្ត្រីសាធារណៈ (ដែលរួមមាន មន្ត្រីរាជការ បុគ្គលដែលមានតួនាទីដោយការបោះឆ្នោតជ្រើសរើស ឬ មន្ត្រីដែលត្រូវបានតែងតាំងផ្សេងទៀត ) ប្រើប្រាស់តួនាទីរបស់ខ្លួន ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះ ស្របនឹងនិយមន័យ ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ ( គន្ថីទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ កថាភាគទី ២ " ការរំលោភអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភអំណាចនេះ ប្រើប្រាស់ដើម្បីកេងប្រវ័ញ្ចពីមនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយទទួលរងគ្រោះ ដើម្បីធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីមួយ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទាំងមូល បានបង្ហាញពីចេតនាយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយរបស់មន្ត្រីសាធារណៈ ក្នុងអំពើជួញដូរមនុស្ស ។ នេះរួមមាន : តួនាទីដូចជាមន្ត្រីរដ្ឋាភិបាល មន្ត្រីនគរបាល និងមន្ត្រីយោធា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនៅក្នុងសាលារៀន ឬ សាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកនៅមន្ទីរពេទ្យ ឬ មជ្ឈមណ្ឌលសុខភាពសាធារណៈ ឬ បុគ្គលដែលមានតួនាទីសាធារណៈ ដោយការបោះឆ្នោតជ្រើសរើស នៅកំរិតណាមួយ ជាអាទិ៍ ។

## " ការលួងលោម "

" ការលួងលោម " សំដៅទៅស្ថានការណ៍ដែលជនល្មើស លួងលោម ជនរងគ្រោះដោយធ្វើការសន្យា ក្លែងក្លាយ ឬ ដោយមិនបានផ្តល់ព័ត៌មានពេញលេញ ដោយហេតុនោះ ធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីមួយ ។

" ការលួងលោម " មិនសំដៅទៅលើ ការផ្តល់ការងារដោយធម្មានរូប ឬ ការផ្សាយពាណិជ្ជកម្ម បែបណាមួយដោយធម្មានរូបទេ ។

**កថាខ័ណ្ឌទី ២** នៃមាត្រានេះ មានធាតុផ្សំផ្សេងទៀត ច្រើនជាងនៅក្នុងកថាខ័ណ្ឌទី ១ ។ កថាខ័ណ្ឌទី ២ មិនតម្រូវឱ្យជនល្មើសប្រើប្រាស់មធ្យោបាយជាក់លាក់ណាមួយ ប៉ុន្តែ តម្រូវឱ្យជនរងគ្រោះ មិនមានសមត្ថភាពតាមផ្លូវច្បាប់ពេញលេញ ។ ដូចគ្នានេះដែរ កថាខ័ណ្ឌទី ២ មិនតម្រូវឱ្យជនរងគ្រោះ ត្រូវបាននាំយកចេញពី " ទីកន្លែងដែលគាត់កំពុងរស់នៅ ទៅកាន់ទីកន្លែងដទៃដែលស្ថិតនៅក្រោម ការត្រួតពិនិត្យរបស់ខ្លួន ឬ របស់តតិយជន " ប៉ុន្តែ គ្រាន់តែបញ្ជាក់ច្បាស់ថា ជនរងគ្រោះ "ត្រូវបាននាំយកចេញពីការគ្រប់គ្រងស្របច្បាប់នៃ ឪពុកម្តាយ អ្នកថែរក្សា ឬ អ្នកអាណាព្យាបាលរបស់គេ " ។

កថាខ័ណ្ឌទី ២ នៃមាត្រានេះ មានចែងពីធាតុផ្សំ បី នៃបទល្មើស ។

១) ជនល្មើសមិនមានអំណាចតាមផ្លូវច្បាប់ ឬ យុត្តិកម្មតាមផ្លូវច្បាប់ ។

២) ជនរងគ្រោះជាអនីតិជន ឬ ជនផ្សេងទៀត ដែលនៅក្រោមការគ្រប់គ្រង ឬ ហិតូបត្ថម្ភ ។

៣) ជនល្មើសនាំយកជនរងគ្រោះចេញពី ឪពុកម្តាយ អ្នកថែរក្សា ឬ អ្នកអាណាព្យាបាលរបស់គាត់ ។

ធាតុផ្សំទាំងនេះ មានពិពណ៌នាយ៉ាងលំអិតខាងក្រោមនេះ ។

### " ដោយគ្មានអំណាចតាមផ្លូវច្បាប់ "

បទប្បញ្ញត្តិនេះមិនមានន័យថា តើជនជាប់ចោទមានតួនាទីជាអាជ្ញាធរស្របច្បាប់ ដូចជាមន្ត្រីសាធារណៈ ដែរ ឬ អត់ទេ ។ ប៉ុន្តែ ឃ្លានេះសំដៅទៅលើ សំនួរថាតើ យោងទៅតាមច្បាប់ ជនជាប់ចោទមានសិទ្ធិស្របច្បាប់ក្នុងការនាំយកចេញជនរងគ្រោះ ( អនីតិជន ឬ ជនដទៃទៀត ដែលខ្វះសមត្ថភាពពេញលេញ ) ពីការគ្រប់គ្រងស្របច្បាប់របស់ឪពុកម្តាយ អ្នកថែរក្សា ឬ អ្នកអាណាព្យាបាលរបស់អនីតិជន ។

ដូច្នេះហើយ ការនាំយកចេញដោយគ្មានអំណាចតាមផ្លូវច្បាប់ អាចកើតឡើង ក្នុងលក្ខណៈផ្សេង២គ្នា :

- បុគ្គល ដែលមិនមានអំណាចតាមផ្លូវច្បាប់ នាំយកចេញជនរងគ្រោះ ។ ឧទាហរណ៍ : ប្រសិនបើជាប្រជាពលរដ្ឋឯកជន ( អ្នកដែលមិនមែនជាមន្ត្រីសាធារណៈ និងដែលមិនមានអំណាចតាមផ្លូវច្បាប់យោងតាមច្បាប់ ) នាំយកចេញជនរងគ្រោះ ដែលជាអនីតិជន ដោយគ្មានការយល់ព្រម ពីឪពុកម្តាយរបស់អនីតិជន និងក៏គ្មានយុត្តិកម្ម តាមផ្លូវច្បាប់ឱ្យធ្វើដូច្នេះ ការនាំយកចេញនេះធ្វើឡើងដោយ " គ្មានអំណាចតាមផ្លូវច្បាប់ " ។
- មន្ត្រីសាធារណៈ (ដូចជា មន្ត្រីនគរបាល ឬ មន្ត្រីរដ្ឋាភិបាល ) ដែលជាធម្មតាតម្រូវឱ្យមានអំណាចតាមផ្លូវច្បាប់ បាននាំយកចេញជនរងគ្រោះក្នុងលក្ខណៈដែលហាមឃាត់ដោយច្បាប់ ។ ឧទាហរណ៍ : ប្រសិនបើមន្ត្រីនគរបាល ឬ មន្ត្រីរដ្ឋាភិបាល នាំយកចេញជនរងគ្រោះជាអនីតិជន ដោយគ្មានការយល់ព្រមពីឪពុកម្តាយរបស់អនីតិជន និងច្បាប់មិនអនុញ្ញាតឱ្យមានការនាំយកចេញនោះ ហេតុដូច្នេះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា មន្ត្រីនោះបានប្រព្រឹត្ត " ដោយគ្មានអំណាចតាមផ្លូវច្បាប់ " ។

គួរកត់សំគាល់ថា ក្នុងកាលៈទេសៈខ្លះ ច្បាប់អាចផ្តល់ឱ្យបុគ្គល ឬ អង្គការឯកជន អាចមានអំណាចពិសេសធ្វើការនាំយកចេញជនណាម្នាក់ ដែលគ្មានសមត្ថភាពពេញលេញ ដោយប្រឆាំងនឹងឆន្ទៈរបស់ជននោះ ពីទីកន្លែងណាមួយ ។ ឧទាហរណ៍ : មជ្ឈមណ្ឌលកុមារកំព្រា ត្រូវបានផ្តល់ឱ្យការគ្រប់គ្រងស្របច្បាប់ ទៅលើអនីតិជន ( កុមារកំព្រា ) ក្នុងការថែទាំរបស់ខ្លួន មជ្ឈមណ្ឌលនោះ អាចនាំយកអនីតិជនទៅ ឬ ពីមជ្ឈមណ្ឌលកុមារកំព្រា ។

### " ឬ យុត្តិកម្មតាមផ្លូវច្បាប់ផ្សេងទៀត ឱ្យធ្វើដូច្នេះ "

" យុត្តិកម្មតាមផ្លូវច្បាប់ផ្សេងទៀត " សំដៅទៅលើ យុត្តិកម្មផ្សេងទៀត ដែលទទួលស្គាល់ដោយច្បាប់ ។ ឧទាហរណ៍ : ក្នុងករណីដែលជនណាម្នាក់ ដែលប្រព្រឹត្តក្នុងវិសាលភាពនៃច្បាប់ នាំយកចេញកុមារពីការគ្រប់គ្រង របស់ឪពុកម្តាយដែលបំពានច្បាប់ ការនាំយកចេញនេះ ត្រូវបានធ្វើឡើងដោយមានការពិចារណាពីផលប្រយោជន៍ ដ៏ល្អបំផុតរបស់កុមារនោះ និងដូច្នេះ ច្បាប់ទទួលស្គាល់ការនាំយកចេញបែបនេះ ។

" **ការនាំយកអនីតិជន** "

ពាក្យថា " អនីតិជន " មានន័យថា ជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ដូចមានចែងក្នុងមាត្រា ៧ ។

" **ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬ នៅក្រោមហិតូបត្ថម្ភ ឬ នៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់** "

ជនដែលនៅក្រោម " **អាណាព្យាបាលទូទៅ** " សំដៅទៅលើ ជនណាដែលនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះលទ្ធភាពក្នុងការយល់ដឹង និងវិនិច្ឆ័យ អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។ និយមន័យនេះ ស្របនឹងមាត្រា ២៤ នៃក្រមរដ្ឋប្បវេណី ។

ជនដែលនៅក្រោម " **ហិតូបត្ថម្ភ** " សំដៅទៅលើ ជនណាដែលមានសមត្ថភាពតិចតួចពេក ក្នុងការយល់ដឹង និងវិនិច្ឆ័យ អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។ និយមន័យនេះ ស្របនឹងមាត្រា ២៨ នៃក្រមរដ្ឋប្បវេណី ។

" ការគ្រប់គ្រងស្របច្បាប់ " សំដៅទៅលើការអនុវត្តសិទ្ធិ និងកាតព្វកិច្ច ដែលជារបស់ឪពុកម្តាយ របស់អនីតិជន ។ ក្នុងករណីដែលឪពុកម្តាយរបស់អនីតិជនស្លាប់ ឬ មិនអាចថែរក្សាអនីតិជន ច្បាប់អាចផ្តល់ឱ្យនូវការគ្រប់គ្រងស្របច្បាប់ទៅដល់អ្នកអាណាព្យាបាល ។ និយមន័យនេះ ស្របទៅនឹងក្រមរដ្ឋប្បវេណី ( គន្ថីទី ៧ " ញាតិ " ជំពូកទី ៦ " អាណាព្យាបាល " ) ។ យោងតាមច្បាប់ អ្នកអាណាព្យាបាលស្របច្បាប់ អាចជ្រើសរើសដោយឪពុកម្តាយរបស់អនីតិជនដោយឆន្ទៈ ( មានប្រសិទ្ធិភាពក្រោយពេលស្លាប់ ) ឬ កំណត់ដោយតុលាការ ។ ឧទាហរណ៍ : ក្នុងករណី លែងលះ តុលាការអាចផ្តល់ការគ្រប់គ្រងស្របច្បាប់ លើកុមារ ទៅដល់ឪពុក ឬ ម្តាយណាម្នាក់ ។ ឧទាហរណ៍ : មួយផ្សេងទៀត មជ្ឈមណ្ឌលកុមារកំព្រាដែលកាន់កាប់ ឬ ចុះឈ្មោះដោយរដ្ឋ មានការគ្រប់គ្រងស្របច្បាប់ ទៅលើកុមារកំព្រា ដែលស្ថិតនៅក្រោមការថែទាំរបស់ខ្លួនស្របទៅតាមច្បាប់ ។

ទោះជាយ៉ាងណាក៏ដោយ សំខាន់គួរកត់សំគាល់ថា ច្បាប់នេះ មិនអនុញ្ញាតឱ្យឪពុកម្តាយ បោះបង់ដោយស្រួល នូវសិទ្ធិមេបាររបស់ខ្លួន ដោយជ្រើសរើសអ្នកអាណាព្យាបាល និងដោយគ្មានការឯកភាពរបស់តុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចឡើយ ។

" **ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្តាយ អ្នកថែរក្សា ឬ អ្នកអាណាព្យាបាល** "

ដើម្បីឱ្យមានបទល្មើសការនាំយកចេញដោយមិនស្របច្បាប់ ជនល្មើសត្រូវតែនាំយកជនរងគ្រោះ ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្តាយ អ្នកថែរក្សា ឬ អ្នកអាណាព្យាបាល ។

បទប្បញ្ញត្តិនេះ មិនតម្រូវឱ្យជនល្មើសប្រើប្រាស់មធ្យោបាយជាក់លាក់ណាមួយទេ ឬ ក៏មិនតម្រូវឱ្យជនរងគ្រោះ ត្រូវបាននាំយកចេញពី " ទីកន្លែងដែលគេកំពុងរស់នៅ ទៅកាន់ទីកន្លែងផ្សេងដែលស្ថិត នៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬ របស់តតិយជន " ឡើយ ។

ដូចបានកត់សំគាល់ខាងលើ ច្បាប់មិនអនុញ្ញាតឱ្យឪពុកម្តាយ ធ្វើការបោះបង់ចោលសិទ្ធិមេបាររបស់ខ្លួន ដោយគ្មានការឯកភាពរបស់តុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ច ឡើយ ហេតុដូច្នេះយោងតាមបទប្បញ្ញត្តិនេះ ជនណាដែលនាំយកអនីតិជនអាចជាជនល្មើស ទោះបីជា ឪពុកម្តាយរបស់អនីតិជនបានយល់ព្រមចំពោះ ការនាំយកអនីតិជននេះក៏ដោយ ដោយសារលក្ខណៈនេះ ច្បាប់មិនបានអនុញ្ញាតឱ្យធ្វើដូច្នេះទេ ។ ឧទាហរណ៍ : ប្រសិនបើ ឪពុកម្តាយប្រគល់កូនរបស់ខ្លួន ឱ្យគេដែលរួមទាំងសិទ្ធិមេបាទៅឱ្យជនដទៃ ដោយគ្មាននីតិវិធីតាមច្បាប់ដូចខាងក្រោម ហេតុដូច្នេះ ជនដទៃនោះ អាចត្រូវចាត់ទុកថា ជាជនល្មើសយោងតាមកថាខណ្ឌនេះ ដោយសារតែគាត់មិនមានអំណាចតាមផ្លូវច្បាប់ក្នុងការគ្រប់គ្រងសិទ្ធិមេបា ឬ សិទ្ធិអាណាព្យាបាលទៅ លើអនីតិជននោះ (លុះត្រាតែគាត់មានយុត្តិកម្មតាមផ្លូវច្បាប់ ) ។

ក្នុងករណីដែល អនីតិជនដែលគេមិនស្គាល់ឪពុកម្តាយ ឬ អាណាព្យាបាល (ឧ. ក្មេងដែលគេបោះបង់ចោលតាមផ្លូវ ) អនីតិជននោះអាចត្រូវចាត់ទុកថា ស្ថិតនៅក្រោមការថែទាំ និងការការពារជាទូទៅរបស់រដ្ឋ ។ ហេតុដូច្នេះ ប្រសិនបើ ជនណាម្នាក់ដែលមិនមានអំណាចតាមផ្លូវច្បាប់ ឬ យុត្តិកម្មតាមផ្លូវច្បាប់ ធ្វើការនាំយកក្មេង ដែលគេបោះបង់ចោលតាមផ្លូវនោះ ដោយគ្មានការឯកភាពរបស់អាជ្ញាធរមានសមត្ថកិច្ច ហេតុដូច្នេះ យោងតាមមាត្រានេះ ជននេះអាចចាត់ទុកថាជាជនល្មើស ។

**មាត្រា ៩.- ការនាំយកអនីតិជន ជាអាទិ៍ ចេញដោយមិនស្របច្បាប់**

**ជនណានាំយកអនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬ នៅក្រោមហិតូបត្ថម្ភ ឬ នៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ ចេញដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។**

**ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះ ការផ្តន្ទាទោសត្រូវលើកលែង ឬ ទទួលស្ថានសម្រាល ក្នុងករណីលក្ខខណ្ឌទាំងអស់ ត្រូវបានបំពេញដូចតទៅនេះ :**

**១- បើជនស្ថិតនៅក្រោមការគ្រប់គ្រង ដែលគេនាំយកទៅនោះ មានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ និងយល់ព្រមដោយស្ម័គ្រចិត្ត ចំពោះអំពើល្មើស ។**

**២- ការពុំមានប្រើវិធានការណាមួយ ដែលមានចែងក្នុងកថាខណ្ឌទី ១ មាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រើប្រាស់ ។**

**៣- ជនល្មើសមិនមានគោលបំណង ប្រព្រឹត្តបទល្មើសណាមួយ ។**

**ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះ អាចធ្វើការចោទប្រកាន់បាន លុះត្រាតែមានពាក្យបណ្តឹងពីឪពុកម្តាយ អ្នកថែរក្សា ឬ អ្នកអាណាព្យាបាលស្របច្បាប់ ប្រសិនបើមធ្យោបាយណាមួយដូចមានចែងនៅក្នុងកថាខណ្ឌទី ១ មាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រើប្រាស់ ។**

មាត្រានេះ ចែងពីបទល្មើស និងធ្វើការផ្តន្ទាទោស ចំពោះបទល្មើសការនាំយកចេញដោយមិនស្របច្បាប់ នូវអនីតិជន ឬ ជនផ្សេងទៀត ដែលខ្វះសមត្ថភាពតាមផ្លូវច្បាប់ ដែលមានការកំណត់និយមន័យក្នុងមាត្រា ៨ ខាងលើ ជាពិសេសផ្អែកលើមាត្រា ៨ កថាខ័ណ្ឌទី ២ ។ ជនល្មើសត្រូវតែទទួលការចោទប្រកាន់ និងការផ្តន្ទាទោសយោងតាមមាត្រានេះ មិនមែនយោងតាមមាត្រា ៨ ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីរកឱ្យឃើញជនល្មើសមានទោសយោងតាមមាត្រានេះ ព្រះរាជអាជ្ញា និងតុលាការត្រូវវិធានាថា ជនល្មើសបំពេញតាមលក្ខខណ្ឌទាំងអស់ យោងតាមនិយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់ ដូចមានចែង ក្នុងកថាខ័ណ្ឌទី ១ និងទី២ នៃមាត្រា ៨ ។

ក្នុងករណីដែល ជនល្មើសបានប្រព្រឹត្តអំពើនាំយកចេញដោយមិនស្របច្បាប់ នូវជនណាម្នាក់ ដែលមានសម្ថភាពតាមផ្លូវច្បាប់ពេញលេញ និងការនាំយកចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រព្រឹត្តអំពើកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មបង្ខំ ឬ ទម្រង់ណាមួយ នៃការកេងប្រវ័ញ្ចផ្សេងទៀត ហេតុដូច្នេះជនល្មើស ត្រូវទទួលការចោទប្រកាន់ និងការផ្តន្ទាទោស យោងតាមមាត្រា ១០ ។

ក្នុងករណីដែល ជនល្មើសបានប្រព្រឹត្តអំពើ ការនាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ នាំជនរងគ្រោះឆ្លងកាត់ព្រំដែនអន្តរជាតិ ហេតុដូច្នេះ ជនល្មើសត្រូវទទួលការចោទប្រកាន់ និងការផ្តន្ទាទោស យោងតាមមាត្រា ១១ ។

ប្រសិនបើជនល្មើស ត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេល ពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

**" ការផ្តន្ទាទោសត្រូវលើកលែង ឬ ទទួលស្ថានសម្រាល ក្នុងករណីលក្ខខណ្ឌទាំងអស់ត្រូវបានបំពេញដូចតទៅនេះ "**

ក្នុងករណីលក្ខខណ្ឌទាំងអស់ ដែលបានរៀបរាប់ក្នុងកថាខ័ណ្ឌទី ២ ត្រូវបានបំពេញ មាត្រានេះ តម្រូវឱ្យតុលាការសម្រាលទោស ។ ប្រសិនបើលក្ខខណ្ឌ មួយ ឬ ពីរ ត្រូវបានបំពេញ ការផ្តន្ទាទោស មិនត្រូវលើកលែង ឬ ទទួលស្ថានសម្រាលទេ ។

លក្ខខណ្ឌដែលតម្រូវឱ្យមានស្ថានសម្រាលមានដូចខាងក្រោមនេះ :

**" ១. បើជននោះស្ថិតនៅក្រោមការគ្រប់គ្រង ដែលគេនាំយកទៅនោះ មានអាយុ ចាប់ពី ១៥ (ដប់ប្រាំ ) ឆ្នាំឡើងទៅ និងយល់ព្រមដោយស្ម័គ្រចិត្ត ចំពោះអំពើ ល្មើស " ២**

ត្រូវបំពេញលក្ខខណ្ឌនេះ :

ក) ជនរងគ្រោះត្រូវតែមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ និង

ខ) ជនរងគ្រោះត្រូវតែបានយល់ព្រមឱ្យជនល្មើសនាំយកចេញ ។ ចំពោះគោលបំណង នៃមាត្រានេះ គ្រាន់តែថា អនីតិជនដែលមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ឬ នីតិជនដែលមានសមត្ថភាព

តិចតួចត្រូវចាត់ទុកថា អាចផ្ដល់ការយល់ព្រមឱ្យមានការនាំយកចេញ ។ ដោយសារតែភាពងាយទទួលរងគ្រោះនៃជនរងគ្រោះ តុលាការគួរធ្វើកិច្ចខិតខំប្រឹងប្រែង ពិសេសដើម្បីកំណត់ថា ជនរងគ្រោះបានយល់ព្រមដោយពិតប្រាកដ ។

**" ២. ការពុំមានប្រើវិធានការណាមួយ ដែលមានចែងក្នុងកថាខណ្ឌទី ១ មាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រើប្រាស់ និង "**

ដើម្បីឱ្យមានស្ថានសម្រាលនៃការផ្ដន្ទាទោស តុលាការក៏ត្រូវតែរកឱ្យឃើញថា ជនល្មើសមិនបាននាំយកចេញជនរងគ្រោះ តាមមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬ លោងលោម ។ (ចំពោះនិយមន័យនៃពាក្យទាំងនេះ សូមមើលការពិភាក្សា យោងតាមមាត្រា ៨ ខាងលើ ) ។

**" ៣. ជនល្មើសមិនមានគោលបំណង ប្រព្រឹត្តបទល្មើសណាមួយ "**

លក្ខខណ្ឌទី ៣ នេះ ដែលតម្រូវឱ្យទទួលស្ថានសម្រាលទោស គឺថា តុលាការត្រូវតែរកឱ្យឃើញថា ជនល្មើសដែលបាននាំយកអនីតិជន ជាអាទិ៍ ចេញដោយមិនស្របច្បាប់ គ្មានគោលបំណងប្រព្រឹត្តបទល្មើសណាមួយផ្សេងទៀតទេ ។

**ឧទាហរណ៍ : ប្រសិនបើ អ្នកប្រព្រឹត្តមានទំនាក់ទំនងស្នេហាជាមួយអនីតិជន ដែលមានអាយុ ១៦ ឆ្នាំ និងអ្នកទាំងពីរបានសម្រេចចិត្តរត់ចេញពីផ្ទះ ( អនីតិជនមិនត្រូវបង្ខំឱ្យចាកចេញប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ) អ្នកប្រព្រឹត្តមិនគួរត្រូវចោទប្រកាន់ និងទទួលការផ្ដន្ទាទោស យោងតាមមាត្រានេះទេ ដោយសារតែ :**

**ក) i. អនីតិជនមានអាយុលើសពី ១៥ ឆ្នាំ**

**ii. អនីតិជនបានយល់ព្រមរត់ចេញជាមួយអ្នកប្រព្រឹត្ត**

**ខ) អ្នកប្រព្រឹត្តមិនបាននាំយកចេញអនីតិជន តាមមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬ លោងលោម ។**

**គ) អ្នកប្រព្រឹត្តមិនមានចេតនាប្រព្រឹត្តបទល្មើសណាមួយផ្សេងទៀតទេ ។**

ផ្ទុយទៅវិញ ប្រសិនបើ អ្នកប្រព្រឹត្តបានបំពានទៅនឹងលក្ខខណ្ឌណាមួយខាងលើនេះ ដូច្នេះអ្នកប្រព្រឹត្តនោះមិនត្រូវទទួលនូវការលើកលែងពីការផ្ដន្ទាទោស ឬ ទទួលស្ថានសម្រាលទោស ឡើយ ។

**ឧទាហរណ៍ : ឪពុកម្ដាយរបស់អនីតិជនដែលមានអាយុ ១៥ ឆ្នាំ បានលែងលះគ្នា ហើយតុលាការផ្ដល់ការគ្រប់គ្រងពេញលេញទៅឱ្យម្ដាយ ។ ឪពុកមិនសប្បាយចិត្ត ហើយថ្ងៃមួយ នៅពេលដែលម្ដាយមិននៅផ្ទះ ឪពុកបាននាំយកអនីតិជននោះចេញពីផ្ទះ ហើយអនីតិជននោះ យល់ព្រមទៅតាមឪពុក ។ ប៉ុន្តែ ឪពុកបានដឹងថា តុលាការបានផ្ដល់ការគ្រប់គ្រងទៅឱ្យម្ដាយ ហើយឪពុកមានចេតនាជ្រៀតជ្រែកការគ្រប់គ្រងនេះ ។ ហេតុដូច្នេះ អំពើនេះ អាចត្រូវ**

ផ្តន្ទាទោស យោងតាមមាត្រានេះ ដោយសារតែឪពុកមានចេតនាប្រព្រឹត្តបទល្មើស និងមិនបានបំពេញតាមលក្ខខណ្ឌទាំងអស់ ដូចមានការរៀបរាប់ខាងលើ ។

កថាខ័ណ្ឌទី ៣ នៃមាត្រានេះ បង្កើតលក្ខខណ្ឌ យោងតាមលក្ខខណ្ឌនេះ អាចឱ្យមានការចោទប្រកាន់បទល្មើសបាន ។

**" ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះ អាចត្រូវធ្វើការចោទប្រកាន់ "**

យោងតាមបទប្បញ្ញត្តិនេះ ការចោទប្រកាន់អាចចាប់ផ្តើមបាន ក្នុងលក្ខណៈណាមួយខាងក្រោមនេះ :

**១) " មានពាក្យបណ្តឹងពីឪពុកម្តាយ អ្នកថែរក្សា ឬ អ្នកអាណាព្យាបាលស្របច្បាប់ "**

ឪពុកម្តាយ អ្នកថែរក្សា ឬអ្នកអាណាព្យាបាលស្របច្បាប់ បានធ្វើពាក្យបណ្តឹងដោយអះអាងថា ជនរងគ្រោះត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ឬ

**២) " ប្រសិនបើ មធ្យោបាយណាមួយ ដូចមានចែងនៅក្នុង កថាខ័ណ្ឌទី ១ មាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រើប្រាស់ "**

ព្រះរាជអាជ្ញា អាចចាត់ការមុនពេលមានពាក្យបណ្តឹងណាមួយ ប្រសិនបើ គាត់ជឿដោយសមហេតុផលថា ជនរងគ្រោះត្រូវបាននាំយកចេញ តាមមធ្យោបាយ បង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬ លោងលោម ។ (ចំពោះនិយមន័យនៃពាក្យទាំងនេះ សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៨ កថាខ័ណ្ឌទី ១ ខាងលើ )។ ក្នុងករណីនេះ នគរបាល ឬ ព្រះរាជអាជ្ញា មិនចាំបាច់រង់ចាំ ឪពុកម្តាយ អ្នកថែរក្សា អ្នកអាណាព្យាបាល ធ្វើពាក្យបណ្តឹងមុនពេលដែលនគរបាល ឬ ព្រះរាជអាជ្ញា អាចចាត់ការ (ស៊ើបអង្កេត ឬ ចោទប្រកាន់។ល។)

**"ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ ឆ្នាំ ដល់ ៥ ឆ្នាំ"**

មាត្រានេះចែងអំពីការផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ដល់ ៥ឆ្នាំ ។ គួរកត់សំគាល់ថាបទប្បញ្ញត្តិប្រហាក់ប្រហែលគ្នានេះ មានចែងនៅក្នុងក្រមព្រហ្មទណ្ឌថ្មី យោងតាម គន្ថីទី ២ មាតិកាទី ៣ ជំពូកទី ៣ "ការប៉ះពាល់ដល់ការថែរក្សាអនីតិជន" មាត្រា ៣២៧ (បទដកយកអនីតិជន ) ផ្តន្ទាទោសដាក់ពន្ធាគារពី ១ខែ ទៅ ១ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០ ០០០រៀល ២ ០០០ ០០០ រៀល ចំពោះអំពើ "ដកយកអនីតិជនពីបុគ្គល ដែលថែរក្សាអនីតិជននោះស្របច្បាប់" ។

ការផ្តន្ទាទោសដែលមានចែងនៅក្នុងមាត្រា ៩ នៃ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និង មាត្រា ៣២៧ នៃក្រមព្រហ្មទណ្ឌមានភាពផ្ទុយគ្នា ចំពោះការនាំយកចេញអនីតិជន ដោយមិនស្របច្បាប់ ។ យោងតាមគោលការណ៍នៃការបកស្រាយច្បាប់ និងវិធានដែលមានចែងនៅក្នុង មាត្រា ៦៧១ និង មាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌ (សូមមើលការការពិភាក្សា ស្តីពី "គោលការណ៍ នៃការបកស្រាយច្បាប់" នៅក្នុងសេចក្តីផ្តើម និងនៅក្នុងមាត្រា ៥០ ខាងក្រោម) ជាទូទៅ ទោសដែលស្រាលជាង ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌថ្មី ត្រូវយកទៅជំនួសទោសដែលមានចែងនៅក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម

ផ្លូវភេទ ទាក់ទងទៅនឹងអំពើ ការនាំយកចេញអនីតិជន ដោយមិនស្របច្បាប់ ។ ប៉ុន្តែប្រសិនបើការនាំយកចេញអនីតិជន ដោយមិនស្របច្បាប់ ត្រូវបានធ្វើឡើង នៅក្នុងបរិបទនៃការ ជួញដូរមនុស្ស ហេតុដូច្នេះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលជាច្បាប់ពិសេស) ត្រូវមានអាទិភាព ហើយជនល្មើសត្រូវតែបានចោទប្រកាន់ និងផ្តន្ទាទោសឱ្យខ្ពស់ យោងតាមច្បាប់ស្តី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ឧទាហរណ៍ : ប្រសិនបើឪពុកដែលបានលែងលះគ្នា របស់កុមារអាយុ ៧ឆ្នាំ ចង់ចំណាយពេលជាមួយនឹងកូនប្រុសរបស់គាត់ ហើយគាត់ក៏បាននាំយកចេញកុមារនោះពីការគ្រប់គ្រងដោយស្រប ច្បាប់របស់ម្តាយដែលបានទទួលការគ្រប់គ្រងទៅលើកុមារ តាមរយៈការជំនុំជម្រះក្តីលែងលះគ្នាដោយតុលាការ ហើយគ្មានការអនុញ្ញាតពីម្តាយរបស់កុមារនោះទេ ហើយឪពុកនោះមិនមានចេតនាក្នុងការប្រព្រឹត្តអំពើទាក់ទង ទៅនឹងការកេងប្រវ័ញ្ចន៍ និងការជួញដូរកុមារ ឪពុកនោះអាចត្រូវចោទប្រកាន់ និងផ្តន្ទាទោស តាមមាត្រា៣២៧ (បទដកយកអនីតិជន) នៃក្រមព្រហ្មទណ្ឌ ។

ឧទាហរណ៍មួយទៀត ប្រសិនបើអ្នកជួញដូរធ្វើការនៅក្នុងរោងចក្រ ហើយជួលកម្មករកុមារដោយខុសច្បាប់ និងក៏បាននាំយកអនីតិជនដោយខុសច្បាប់ពីការថែរក្សារបស់ឪពុក-ម្តាយរបស់កុមារនោះដោយមានគោលដៅប្រើប្រាស់ពលកម្មកុមារ ។ ជនប្រព្រឹត្តអំពើនេះ គប្បីត្រូវបានចោទប្រកាន់យោងតាមមាត្រា ១០ " ការនាំយកចេញ ដោយមិនស្របច្បាប់ដោយមានគោលដៅ " នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**មាត្រា ១០.. ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ**

**ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ ឈ្មួញខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទម្រង់ណាមួយ នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។**

**ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែល :**

- **ជនរងគ្រោះជាអនីតិជន**
- **អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។**
- **អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។**

**ពាក្យថា ទម្រង់នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត នៅក្នុងមាត្រានេះ និងមាត្រា ១២ មាត្រា ១៥ មាត្រា ១៧ និងមាត្រា ១៩ នៃច្បាប់នេះ រួមមាន ការកេងប្រវ័ញ្ចន៍លើពេស្យាកម្មជនដទៃ រូបភាព និងសម្ភារៈអាសអាភាស ពាណិជ្ជកម្មផ្លូវភេទ សេវា ឬ ពលកម្មដោយបង្ខំ ទាសភាព ឬ ការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុល សេវភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬ ការដកហូតសរីរាង្គ ។**

**ការយល់ព្រមរបស់អនីតិជនរងគ្រោះចំពោះគោលដៅ ដែលមានចែងក្នុងកថាខណ្ឌ ទី ១ នៃមាត្រានេះ មិនទាក់ទងនឹងមធ្យោបាយណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌទី ១ មាត្រា ៨ នៃច្បាប់នេះ ដែលត្រូវបានប្រើនោះទេ ។**

**ករណីនេះត្រូវយកទៅអនុវត្តផងដែរ ចំពោះបទល្មើស ដែលមានចែងក្នុងមាត្រា ១៥ មាត្រា ១៧ និងមាត្រា ១៩ នៃច្បាប់នេះ ។**

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះបទល្មើសការនាំយកចេញដោយមិនស្របច្បាប់ នូវជនណាម្នាក់ និងក្នុងករណីដែល ការនាំចេញដោយមិនស្របច្បាប់នោះ ត្រូវធ្វើឡើងដោយមានគោលដៅកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មដោយបង្ខំ ឬ ទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ច ។

ជនល្មើសត្រូវតែទទួលការចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រានេះ មិនមែនយោងតាមមាត្រា ៨។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីស្វែងរកឱ្យឃើញជនល្មើសមានទោស យោងតាមមាត្រានេះ ព្រះរាជអាជ្ញា និង តុលាការត្រូវធានាថា ជនល្មើសបំពេញតាមលក្ខខណ្ឌទាំងអស់ យោងតាមនិយមន័យ នៃការនាំយកចេញដោយខុសច្បាប់ ដូចមានចែងក្នុងមាត្រា ៨ ។ ប្រសិនបើជនល្មើសនាំយកចេញដោយមិនស្របច្បាប់ នូវជនរងគ្រោះដោយមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬ លោងលោម ហេតុដូច្នេះជនល្មើសត្រូវទទួលទោស ទោះបីជាជនរងគ្រោះបានយល់ព្រម (ឬ ហាក់បីដូចជាបានយល់ព្រម) ចំពោះការនាំយកចេញនេះ ក៏ ដោយ ។

ក្នុងករណីដែលជនល្មើស ប្រព្រឹត្តអំពើនាំយកចេញជនណាម្នាក់ ដោយមានគោលដៅនាំជនរងគ្រោះ ឆ្លងកាត់ព្រំដែនអន្តរជាតិ ហេតុដូច្នេះជនល្មើសត្រូវទទួលការចោទប្រកាន់ កាត់ទោស និងផ្តន្ទាទោស យោងតាមមាត្រា ១១។

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ តុលាការត្រូវតែផ្តន្ទាទោសជនល្មើសដោយដាក់ពន្ធនាគារ ពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។ យ៉ាងណាមិញ ប្រសិនបើ តុលាការរកឃើញមានកត្តាស្ថានទម្ងន់ទោសណាមួយ ដូចមានរៀបរាប់ខាងក្រោមនេះ ហេតុដូច្នេះ ការផ្តន្ទាទោសត្រូវកើនឡើង ពី ១៥ (ដប់ប្រាំ) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ។

បទល្មើសដែលមានចែងក្នុងមាត្រានេះ មានធាតុផ្សំសំខាន់ៗ ពីរ ដែលធាតុផ្សំទាំងពីរនេះ ត្រូវបំពេញ :

១) **ការនាំយកចេញដោយមិនស្របច្បាប់** (សូមមើលនិយមន័យ ក្នុងមាត្រា ៨)

ជនល្មើសត្រូវតែបានប្រព្រឹត្តអំពើ នាំយកចេញដោយមិនស្របច្បាប់ ដែលមានន័យថា ជនល្មើសត្រូវតែបំពេញតាមលក្ខខណ្ឌទាំងអស់ ក្នុងនិយមន័យនៃ ការនាំយកចេញដោយមិនស្របច្បាប់ ដូចមានចែងក្នុងមាត្រា ៨ កថាខ័ណ្ឌទី ១ ចំពោះបុគ្គលដែលមានសមត្ថភាពខាងផ្លូវច្បាប់ពេញលេញ ។ ឬ មាត្រា ៨ កថាខ័ណ្ឌទី ២ ចំពោះបុគ្គលដែលមិនមានសមត្ថភាពខាងផ្លូវច្បាប់ពេញលេញ ។ (សូមមើលការពិភាក្សាយោងតាមមាត្រា ៨ សម្រាប់ព័ត៌មានលំអិត) ។

២) **ដោយមានគោលដៅ.....**

បន្ថែមទៅនឹងការប្រព្រឹត្តបទល្មើសនាំយកចេញដោយខុសច្បាប់ ជនល្មើសត្រូវមានចេតនាជាក់លាក់ ក្នុងការប្រព្រឹត្តអំពើ ណាមួយ ដូចខាងក្រោម ។ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនតម្រូវថា ជនល្មើសបានប្រព្រឹត្តអំពើទាំងនេះ ដោយជោគជ័យទេ ។ ប៉ុន្តែគ្រាន់តែតម្រូវថា ជនល្មើសមានចេតនាប្រព្រឹត្តដូច្នេះ ។ ដូចគ្នានេះដែរ ច្បាប់នេះ មិនតម្រូវថា

ជនល្មើសមានគោលដៅ ច្រើនជាងមួយ ដូចខាងក្រោមទេ ។ មានន័យថា មានគោលដៅតែមួយ គឺគ្រប់គ្រាន់ហើយ ។

ប្រសិនបើ ជនល្មើសមានគោលដៅ មួយដូចខាងក្រោម និងបានធ្វើការនាំយកចេញដោយមិនស្របច្បាប់ ដោយមធ្យោបាយ បង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬលោងលោម ហេតុដូច្នេះ យោងតាមកថាខណ្ឌទី ៤ នៃមាត្រានេះ ជនល្មើសត្រូវទទួលទោស ទោះបីជាជនរងគ្រោះ បានយល់ព្រមចំពោះគោលដៅនេះក៏ដោយ ។

## " ស្វែងរកប្រយោជន៍ "

ពាក្យថា " ស្វែងរកប្រយោជន៍ " ដូចមានប្រើក្នុងមាត្រានេះ មានន័យថា ជនល្មើសបានធ្វើការនាំយកចេញដោយមិនស្របច្បាប់ ដើម្បី ផ្តោះប្តូរ ឬ ដើម្បីទទួលយកវត្ថុមានតម្លៃអ្វីមួយ ដែលរួមមានជាអាទិ៍ ប្រាក់របស់មានតម្លៃផ្សេងទៀត ( មាស គ្រឿងអលង្ការ ។ល។ ) សេវាកម្ម ឬ មនុស្ស ។ ប្រសិនបើ ជនល្មើសបានប្រព្រឹត្ត ការនាំយកចេញដោយមិនស្របច្បាប់ ក្នុងគោលដៅនេះ ហេតុដូច្នេះជនល្មើស ត្រូវទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។

## " ឈ្លានពានខាងផ្លូវភេទ "

ពាក្យថា " ឈ្លានពានខាងផ្លូវភេទ " ដូចមានប្រើក្នុងមាត្រានេះ មានន័យថា ជនល្មើសបានធ្វើការនាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅប្រព្រឹត្តបទល្មើស ផ្លូវភេទប្រឆាំងនឹងជនរងគ្រោះ ដូចជា អំពើរំលោភសេពសន្ថវៈ ឬ អំពើឈ្លានពានផ្លូវភេទផ្សេងទៀត (សូមមើលនិយមន័យនៃបទល្មើសទាំងនេះ យោងតាមច្បាប់ព្រហ្មទណ្ឌ ដែលកំពុងអនុវត្ត ) ឬ ក្នុងករណីដែល អនីតិជនអាយុក្រោម ១៥ ឆ្នាំ អំពើអាសដូចមានការកំណត់និយមន័យក្នុងជំពូកទី ៦ នៃច្បាប់នេះ ។ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ នាំយកចេញដោយមិនស្របច្បាប់ សម្រាប់គោលដៅនេះ ហេតុដូច្នេះ ជនល្មើសគួរត្រូវទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ។

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ នាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅនេះ និងបានធ្វើការឈ្លានពានខាងផ្លូវភេទ ជនល្មើស គប្បីត្រូវទទួលការចោទប្រកាន់ពីបទល្មើសទាំងពីរ។ ឧទាហរណ៍ : ប្រសិនបើ អ្នកប្រព្រឹត្តនាំយកចេញដោយមិនស្របច្បាប់ នូវជនណាម្នាក់ដោយមានគោលដៅ រំលោភសេពន្ថវៈលើជនរងគ្រោះ និងក្រោយមកបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ អ្នកប្រព្រឹត្តគួរតែត្រូវចោទប្រកាន់ពីបទល្មើស ដូចមានចែងក្នុងមាត្រានេះ ( ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ) ព្រមទាំងបទល្មើស ឈ្លានពានខាងផ្លូវភេទដែលជនល្មើសបានប្រព្រឹត្ត (រំលោភសេពសន្ថវៈ) ដូចមាន ការកំណត់និយមន័យ ក្នុងមាត្រានៃច្បាប់ព្រហ្មទណ្ឌដែលពាក់ព័ន្ធ ។

### " ផលិតរូបភាពអាសអាភាស "

ជនល្មើស ទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ នាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ បង្កើត ឬ ចូលរួមបង្កើតរូបភាព និងសម្ភារៈអាសអាភាស ។ " រូបភាព និងសម្ភារៈអាសអាភាស " មាននិយមន័យចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

មិនតម្រូវឱ្យជនល្មើសបានទទួល ឬ មានចេតនាទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុណាមួយ ពីអំពើនេះទេ ។

### " រៀបអាពាហ៍ពិពាហ៍ ប្រឆាំងនឹងឆន្ទៈជនរងគ្រោះ "

ជនល្មើសទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ នាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ បង្ខំជនរងគ្រោះឱ្យរៀបអាពាហ៍ពិពាហ៍ប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ។

មិនតម្រូវឱ្យជនល្មើសបានទទួល ឬ មានចេតនាទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុណាមួយ ពីអំពើនេះទេ ។

### " សុំកូន "

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ នាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ ផ្តល់ ឬ លក់ជនរងគ្រោះឱ្យអ្នកសុំកូន ហេតុដូច្នេះ ជនល្មើសគួរតែទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។ ( ទាក់ទងនឹងការសុំកូន សូមមើលក្រមរដ្ឋប្បវេណី គន្ថីទី ៧ " ញាតិ " ជំពូកទី ៤ " ឳពុកម្តាយ និងកូន " ផ្នែកទី ២ " ការសុំកូន " ) ព្រមទាំងច្បាប់ ស្តីពី ការសុំកូនអន្តរប្រទេស ។ មិនតម្រូវឱ្យជនល្មើសទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុណាមួយ ពីការសុំកូនទេ ។ គ្រប់គ្រាន់ហើយ ដែលថាជនល្មើស មានគោលដៅ ផ្តល់ជនរងគ្រោះដោយផ្ទាល់ ទៅកាន់ជនណាម្នាក់ទៀត ដែលសុំកូន ឬ ផ្តល់ជនរងគ្រោះទៅឱ្យជនណាម្នាក់ទៀត ដែលនឹងសម្រួលឱ្យមានការសុំកូន ។

### " ទម្រង់ណាមួយ នៃការកេងប្រវ័ញ្ចផ្សេងទៀត "

### " ពាក្យថា " ទម្រង់ណាមួយ នៃការកេងប្រវ័ញ្ច ".....ត្រូវរាប់បញ្ចូល "

ពាក្យថា " ទម្រង់ណាមួយ នៃការកេងប្រវ័ញ្ចផ្សេងទៀត " រួមមានជាអាទិ៍ អំពើដែលមានរៀបរាប់ក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ដូចជា : ការកេងប្រវ័ញ្ចលើពេស្យាចារកម្មជនដទៃ រូបភាព និងសម្ភារៈអាសអាភាស ពាណិជ្ជកម្មផ្លូវភេទ សេវា ឬ ពលកម្មដោយបង្ខំ ទាសភាព ឬ ការអនុវត្តស្រដៀងគ្នានឹងទាសភាពការបញ្ចាំខ្លួនដោះបំណុល សេវភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬ ការដកហូតសរីរាង្គ ។ ចំពោះនិយមន័យនៃពាក្យទាំងនេះ សូមមើលការពិភាក្សាខាងក្រោមនេះ ។ តុលាការក៏អាចរាប់បញ្ចូលប្រភេទនៃការកេងប្រវ័ញ្ចផ្សេងទៀត ដែលមិនបានរៀបរាប់នៅទីនេះ ។ ប្រសិនបើជនល្មើសប្រព្រឹត្តអំពើ នាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅទាំងនេះណាមួយ ហេតុដូច្នេះ ជនល្មើសគួរតែត្រូវផ្តន្ទាទោសយោងតាមមាត្រានេះ ។

## " ការកេងប្រវ័ញ្ចន៍លើពេស្យាកម្មជនដទៃ "

ពាក្យថា " ការកេងប្រវ័ញ្ចន៍លើពេស្យាកម្មជនដទៃ " សំដៅទៅលើ ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចារ ឬ ពីការប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ២៦ ដល់ មាត្រា ៣៧ នៃច្បាប់នេះ ។

" អំពើពេស្យាចារ " មានការកំណត់និយមន័យ ក្នុងមាត្រា ២៣ នៃច្បាប់នេះ និងមានន័យថា ជាការរួមភេទជាមួយជនណាម្នាក់ ដែលមិនកំណត់ ឬ អំពើគ្រប់ប្រភេទផ្សេងទៀត ដែលទាក់ទងនឹងភេទ ដោយផ្តោះប្តូរនឹងវត្ថុមានតម្លៃអ្វីមួយ ។ (ចំពោះការពិភាក្សានៃនិយមន័យនេះ សូមមើលការពន្យល់មាត្រា ២៣ ខាងក្រោម) ។

## " រូបភាព និងសម្ភារៈអាសអាភាស "

ដោយសារតែមាត្រានេះ ដាក់ទោសរួចជាស្រេចហើយនូវ ការនាំចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ ផលិតរូបភាព និងសម្ភារៈអាសអាភាស ការប្រើប្រាស់ពាក្យ " រូបភាព និងសម្ភារៈអាសអាភាស " នៅទីនេះសំដៅទៅលើបទល្មើសផ្សេងទៀត ដែលទាក់ទងនឹង រូបភាព និងសម្ភារៈអាសអាភាស ដូចមានចែងក្នុង មាត្រា ៣៩ ដូចជាការចែកចាយ លក់ ឬ ជួល រូបភាព និងសម្ភារៈអាសអាភាស ។

" រូបភាព និងសម្ភារៈអាសអាភាស " មានន័យថា ជាសម្ភារៈដែលអាចមើលឃើញ ដែលមាននិយមន័យក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។ ការប្រើពាក្យ " រូបភាព និងសម្ភារៈអាសអាភាស " នៅទីនេះ សំដៅទៅលើបទល្មើសដែលទាក់ទងនឹង រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ដែលមានការកំណត់និយមន័យនៅក្នុង មាត្រា ៤១ នៃច្បាប់នេះ ។ ក្នុងករណីដែល រូបភាព និងសម្ភារៈអាសអាភាសនេះ បង្ហាញឱ្យឃើញពីអនីតិជន សម្ភារៈបែបនេះគឺជារូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ដូចមាននិយមន័យក្នុង មាត្រា ៤0 នៃច្បាប់នេះ ។

សម្រាប់ព័ត៌មានលំអិត សូមមើលការពិភាក្សា មាត្រា ៣៨ ដល់ មាត្រា ៤១ ។

## " ពាណិជ្ជកម្មផ្លូវភេទ "

ពាក្យថា " ពាណិជ្ជកម្មផ្លូវភេទ " សំដៅទៅលើ សកម្មភាពផ្លូវភេទណាមួយផ្សេងទៀត ដែលទាក់ទង នឹងជនណាម្នាក់ ផ្តល់ ឬ ទទួលយក វត្ថុមានតម្លៃអ្វីមួយ ។ អត្ថន័យនេះ ទូលំទូលាយជាងពាក្យ " អំពើពេស្យាចារ " និងអាចរាប់បញ្ចូលសកម្មភាពផ្សេងទៀត ដូចជាការសំដែងផ្លូវភេទបន្តផ្ទាល់ ។

## " ពលកម្មដោយបង្ខំ ឬ សេវា "

ពលកម្មដោយបង្ខំ ឬ សេវា មានន័យថា " រាល់ការងារ ឬ សេវាកម្មណា ដែលតម្រូវពីជនណាម្នាក់ ដោយការគម្រាមកំហែងថានឹងដាក់ទណ្ឌកម្មណាមួយ ហើយដែលជននោះមិនបានស្ម័គ្រចិត្តធ្វើដោយខ្លួនឯងផងទេ " ។ និយមន័យនេះ ស្របទៅនឹងអនុសញ្ញា លេខ ២៩ ស្តីពី ការងារដោយបង្ខំ ឬ ជាកាតព្វកិច្ច របស់អង្គការពលកម្មពិភពលោក

ដែលត្រូវបានអនុម័តនៅឆ្នាំ ១៩៣០ និងត្រូវបានឱ្យសច្ចាប័ន ដោយព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៦៩ ។ " ការងារដោយបង្ខំ ត្រូវហាមឃាត់ជាដាច់ខាត " យោងតាមច្បាប់កម្ពុជា[១២] និងច្បាប់ អន្តរជាតិ ។

### " ទាសភាព ឬ ការអនុវត្តស្រដៀងគ្នា នឹងទាសភាព "

" ទាសភាព " មានន័យថា ជាឋានៈ ឬ ស្ថានភាព នៃជនណាម្នាក់ដែលត្រូវគេគ្រប់គ្រងទៅលើជននោះក្នុងកិរិតមួយ ដោយចាត់ទុកខ្លួនដូចជាទ្រព្យសម្បត្តិ ។

### " ការបញ្ចាំខ្លួនដោះបំណុល "

" ការបញ្ចាំខ្លួនដោះបំណុល " មានន័យថា ជាប្រព័ន្ធមួយដែលជនណាម្នាក់បញ្ចាំខ្លួនបម្រើគេ ឬ ស្ថិតក្រោមការគ្រប់គ្រងរបស់ជនម្នាក់ទៀត ដែលជនរងគ្រោះមិនអាចសងបំណុលពិតដែលខ្លួនបានជំពាក់ ។

### " សេវភាពដោយមិនស្ម័គ្រចិត្ត "

" សេវភាពដោយមិនស្ម័គ្រចិត្ត " មានន័យថា ជាលក្ខខណ្ឌការងារ និង/ឬ ជាកាតព្វកិច្ចធ្វើការងារ ឬ ផ្តល់សេវាភាពដែលជននោះមិនអាចជៀសផុត និងជននោះមិនអាចផ្លាស់ប្តូរបាន ។

### " ពលកម្មកុមារ "

ពាក្យថា " ពលកម្មកុមារ " មានន័យថា ជាពលកម្មដែលធ្វើដោយអនីតិជន ( ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) និងដែលត្រូវហាមឃាត់ដោយច្បាប់ ។ ច្បាប់ ស្តីពី ការងារ អនុញ្ញាតឱ្យអនីតិជនធ្វើការក្នុង កាលៈទេសៈមួយចំនួន ( សូមមើលមាត្រា ១៧២ ដល់ មាត្រា ១៨១ នៃច្បាប់ ស្តីពី ការងារ ) និងការងារ បែបនេះគឺស្របច្បាប់ និងហេតុដូច្នេះ ពាក្យនេះមិនស្ថិតក្នុងការងារបែបនេះទេ ។

### " ការដកហូតសរីរាង្គ "

ពាក្យថា " ការដកហូតសរីរាង្គ " មានន័យថា ជាការយកចេញផ្នែកសារពាង្គកាយណាមួយ ពីជនណាម្នាក់ដោយមិនមានការយល់ព្រមដោយសេរី ពេញលេញ និងដោយបានដឹងជាមុន ។

**ការផ្តន្ទាទោស និងកត្តាស្ថានទម្ងន់ទោស**

---

[១២] មាត្រា ១៥ នៃច្បាប់ ស្តីពី ការងារចែងថា " ការងារដោយបង្ខំត្រូវហាមឃាត់ជាដាច់ខាត "

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ ជនល្មើសនោះត្រូវតែទទួលការផ្តន្ទាទោសជាប់ពន្ធនាគារ ពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។ ទោសបន្ថែម អាចក៏ត្រូវអនុវត្តដោយឆន្ទានុសិទ្ធិ របស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខណ្ឌទី ៤ ប្រសិនបើ អ្នកតំណាងភ្នាក់ងារ ឬ និយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់ រួមមាន ការផ្តន្ទាទោសដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

យ៉ាងណាមិញ ប្រសិនបើ តុលាការរកឃើញមានកត្តាស្ថានទម្ងន់ទោសណាមួយ ដូចបានរៀបរាប់ខាងក្រោមនេះ ហេតុដូច្នេះការផ្តន្ទាទោស ត្រូវកើនឡើង ពី ១៥ ( ដប់ប្រាំ ) ឆ្នាំ ដល់ ២០ ( ម្ភៃ ) ឆ្នាំ ។

ច្បាប់នេះ មិនតម្រូវឱ្យបំពេញតាមកត្តាស្ថានទម្ងន់ទោស ទាំងអស់ទេ ។ ជាការគ្រប់គ្រាន់ហើយ ប្រសិនបើមានស្ថានទម្ងន់ទោសតែមួយប៉ុណ្ណោះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

### ~ ជនរងគ្រោះជាអនីតិជន

ប្រសិនបើ ជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

ប្រសិនបើ ជនល្មើសមានការគ្រប់គ្រង និងការត្រួតពិនិត្យលើអនីតិជន ហេតុដូច្នេះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា ជនល្មើសបានដឹងពីអាយុរបស់អនីតិជន ។ សូមមើលការពិភាក្សា យោងតាមមាត្រា ៧ ( និយមន័យនៃអនីតិជន ) ខាងលើ ។

### ~ អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ

ប្រសិនបើជនល្មើស គឺជាមន្ត្រីសាធារណៈ និងបានប្រព្រឹត្តអំពើ ដោយមធ្យោបាយបំពានដោយអំណាច ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

" មន្ត្រីសាធារណៈ " មានន័យថា ជាមន្ត្រីរាជការ ឬ ពលរដ្ឋដែលត្រូវផ្តល់អាណត្តិឱ្យ តាមរយៈការបោះឆ្នោត ។ ទាំងនេះ រួមមាន : តួនាទីជាមន្ត្រីរដ្ឋាភិបាល នគរបាល យោធា គ្រូបង្រៀន និងបុគ្គលិក ក្នុងសាលារៀន និងសាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យសាធារណៈ ឬ មជ្ឈមណ្ឌលសុខភាព និង បុគ្គលដែលកំពុងមានតួនាទីសាធារណៈដែលជាប់ឆ្នោត នៅក៏រិតណាមួយជាអាទិ៍ ។

" ការបំពានដោយសិទ្ធិអំណាច " មានន័យដូចពាក្យ " ការបំពានអំណាច " ដូចត្រូវពិភាក្សា យោងតាមមាត្រា ៨ ពោលគឺជាស្ថានការណ៍ដែល មន្ត្រីរាជការ ឬ ពលរដ្ឋ ដែលគេផ្តល់អាណត្តិបោះឆ្នោតឱ្យ បានប្រើប្រាស់តួនាទីរបស់ខ្លួន មិនសមរម្យ ឬ ឆ្លៀតយកប្រយោជន៍ ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះស្របនឹងនិយមន័យ ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ (សូមពិនិត្យមើល គន្លីទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ កថាភាគទី ២ " ការរំលោភអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភដោយអំណាចនេះ ប្រើប្រាស់ដើម្បីកេងប្រវ័ញ្ចន៍ពីមនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយរងគ្រោះ ដើម្បីធ្វើឱ្យជនរងគ្រោះ ជឿធ្វើអ្វីដែលជនរងគ្រោះ នឹងមិនធ្វើដោយឆន្ទៈ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទាំងមូលបានបង្ហាញពីចេតនាយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយ របស់មន្ត្រីសាធារណៈ ក្នុងអំពើជួញដូរមនុស្ស ។

## - អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង

ប្រសិនបើ ជនល្មើសបានប្រព្រឹត្តបទល្មើស ដោយជាផ្នែកមួយនៃក្រុមមានការចាត់តាំង ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៧៧ " ក្រុមមានការចាត់តាំង " មានន័យថា គឺជាការប្រមូលផ្តុំ ដែលបានបង្កើតឡើង ឬ ជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

ក្នុងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ មាននិយមន័យ ប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែតម្រូវបន្ថែមឱ្យក្រុមមានការចាត់តាំង ត្រូវតែបញ្ចូលមនុស្សពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ។ ឧទាហរណ៍ : អនុសញ្ញា អង្គការសហប្រជាជាតិ ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័នឱ្យនិយមន័យ " ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង " ក្នុងមាត្រា ២ (ក) ថាជា " ក្រុមដែនមានរចនាសម្ព័ន្ធដែលមានគ្នា ពី ៣នាក់ ឬ ច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណងបទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរមួយ ឬ ច្រើន ដែលត្រូវធ្វើឡើងស្របទៅនឹង អនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ សម្ភារៈផ្សេងទៀត " ។

ដូច្នេះហើយ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានឱ្យនិយមន័យ " ក្រុមមានការចាត់តាំង " មានន័យថា ជាក្រុម ផ្លូវការ ឬ មិនផ្លូវការ ដែលមានគ្នាបីនាក់ ឬ ច្រើននាក់ជាងនេះ ដែលត្រូវបានបង្កើត ឡើងដើម្បីរៀបចំផែនការ ឬដើម្បីប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

**" ការយល់ព្រមរបស់ជនរងគ្រោះ ចំពោះគោលដៅមានចេតនាណាមួយ ដូចមានចែងក្នុង កថាខ័ណ្ឌទី ១ នៃមាត្រានេះ ត្រូវមិនទាក់ទងក្នុងករណី ដែលមធ្យោបាយ ណាមួយដែលមានចែងក្នុង កថាខ័ណ្ឌទី ១ ) នៃមាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រើ "**

ប្រសិនបើជនល្មើស បាននាំយកចេញដោយខុសច្បាប់នូវជនរងគ្រោះ តាមមធ្យោបាយ បង្ខិតបង្ខំ គម្រាម កំហែង បញ្ឆោត បំពានដោយអំណាច ឬ លួងលោម ហេតុដូច្នេះជនល្មើសត្រូវទទួលខុសត្រូវ ទោះបីជា ជនរងគ្រោះ បានយល់ព្រម ( ឬ ហាក់បីដូចជាយល់ព្រម ) ចំពោះការនាំយកចេញនេះក៏ដោយ ។ នេះដោយសារតែ ជនរងគ្រោះមិន អាចយល់ព្រមដោយស្របច្បាប់ នៅពេលដែលមានការប្រើប្រាស់មធ្យោបាយ ណាមួយ ។

**មាត្រា ១១: ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន**

**ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬ នាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។**

**ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងប្រទេសណាមួយក្រៅពី ព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ នាំជននោះទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នា នឹងកថាខ័ណ្ឌទី ១ ខាងលើ ។**

**ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១៥ ( ដប់ប្រាំ ) ឆ្នាំ ទៅ ២០ ( ម្ភៃ ) ឆ្នាំ ក្នុងករណីដែល :**

**- ជនរងគ្រោះជាអនីតិជន ។**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាច របស់ខ្លួនមកលើជនរងគ្រោះ ។**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។**

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះការនាំយកចេញដោយមិនស្របច្បាប់ នៃជន ណាម្នាក់ ដោយមានគោលដៅនាំយកជននោះឆ្លងព្រំដែនអន្តរជាតិ ។ ជនល្មើសគួរទទួលការផ្តន្ទាទោស យោងតាម មាត្រានេះ មិនមែនយោងតាមមាត្រា ៨ ។

ប្រសិនបើ ជនល្មើសមិនមានចេតនានាំយកជនរងគ្រោះឆ្លងព្រំដែនអន្តរជាតិ ហេតុដូច្នេះត្រូវទទួលការផ្តន្ទាទោស ពីបទនាំយកចេញដោយមិនស្របច្បាប់ យោងតាមមាត្រា ៩ ( ការនាំយកចេញអនីតិជនដោយមិនស្របច្បាប់ ) ឬ មាត្រា ១០ ( ការនាំយកចេញដោយមានគោលដៅ ) ។

បទល្មើសដែលមានចែងក្នុងមាត្រានេះ មានធាតុផ្សំសំខាន់ៗពីរ ហើយត្រូវតែបំពេញតាមធាតុផ្សំទាំងពីរនេះ:

១) **ការនាំយកចេញដោយមិនស្របច្បាប់** ( សូមពិនិត្យមើលនិយមន័យនៅមាត្រា ៨ )

ជនល្មើសត្រូវតែបានប្រព្រឹត្តអំពើ នាំយកចេញដោយខុសច្បាប់ ដែលមានន័យថា ជនល្មើសត្រូវតែ បំពេញតាមលក្ខខណ្ឌទាំងអស់ ក្នុងនិយមន័យ នៃការនាំយកចេញដោយខុសច្បាប់ ដូចមានចែងក្នុងមាត្រា ៨ កថាខ័ណ្ឌទី ១ ចំពោះបុគ្គលដែលមានសមត្ថភាពខាងផ្លូវច្បាប់ពេញលេញ ។ ឬ មាត្រា ៨ កថាខ័ណ្ឌទី ២ ចំពោះបុគ្គលដែលមិនមានសមត្ថភាពខាងផ្លូវច្បាប់ពេញលេញ ។ ( សូមពិនិត្យមើលការពិភាក្សា មាត្រា ៨ សម្រាប់ព័ត៌មានលំអិត ) ។

២) **ដោយមានគោលដៅសម្រាប់នាំឆ្លងព្រំដែន**

ជនល្មើសត្រូវតែបានប្រព្រឹត្ត ការនាំយកចេញដោយមិនស្របច្បាប់ ក្នុងគោលដៅនាំយកជនរងគ្រោះឆ្លងកាត់ព្រំដែនអន្តរជាតិ ។ ជនល្មើសមិនចាំបាច់ឆ្លង ឬ មានចេតនាឆ្លងព្រំដែនអន្តរជាតិ ដោយខ្លួនឯងទេ អ្វីដែលសំខាន់គឺថា ជនល្មើសមានចេតនានាំយកជនរងគ្រោះឆ្លងដែន ។ មិនចាំបាច់តម្រូវថា ជនរងគ្រោះ ពិតប្រាកដបានឆ្លងដែន ។ ជាការគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនល្មើសនោះបានមានចេតនានាំយកជនរងគ្រោះឆ្លងដែន ។

គួរកត់សំគាល់ថាមាត្រានេះ មិនសំដៅទៅលើ អំពើរត់ពន្ធ ឬ ដឹកជញ្ជូនខុសច្បាប់ នូវជនណាម្នាក់ដែលមានបំណងដោយស្ម័គ្រចិត្តឆ្លងកាត់ព្រំដែនទេ ។ ប្រសិនបើ ជនណាម្នាក់ដែលមានសមត្ថភាពខាងផ្លូវច្បាប់ពេញលេញ ចង់ឆ្លងព្រំដែន ហេតុដូច្នេះ មិនកើតមានធាតុផ្សំនៃការនាំយកចេញដោយខុសច្បាប់ ទេ ( ដូចមាននិយមន័យ ក្នុងមាត្រា ៨ កថាខ័ណ្ឌទី ១ ) ហើយដូច្នេះ មិនមានការប្រព្រឹត្តបទល្មើសក្នុងមាត្រានេះទេ ។ ប្រសិនបើជននោះ មិនមានសមត្ថភាពខាងផ្លូវច្បាប់ពេញលេញ ហេតុដូច្នេះ អាចមានការទទួលខុសត្រូវ ប្រសិនបើបានបំពេញតាមលក្ខខណ្ឌនៃការនាំយកចេញដោយខុសច្បាប់ ដូចបានបញ្ជាក់ក្នុង មាត្រា ៨ កថាខ័ណ្ឌទី ២ ។

" **នាំឆ្លងដែន** "

យោងតាមមាត្រានេះ ពាក្យថា " នាំឆ្លងដែន " មានន័យដូចខាងក្រោម :

" **ក្នុងគោលដៅប្រគល់ ឬ នាំយកជននោះ ទៅក្រៅព្រះរាជាណាចក្រកម្ពុជា** "

បទបញ្ញត្តិនេះ ផ្តន្ទាទោសចេតនាក្នុងការនាំជនរងគ្រោះពីប្រទេសកម្ពុជា ទៅកាន់ប្រទេសក្រៅ ។

" **ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ នាំជននោះ ទៅប្រទេសផ្សេងទៀត** "

បទប្បញ្ញត្តិនេះ ផ្តន្ទាទោសចេតនាណាមួយដូចខាងក្រោម :

- នាំជនរងគ្រោះពីប្រទេសក្រៅមួយ ទៅកាន់ប្រទេសក្រៅមួយផ្សេងទៀត
- នាំជនរងគ្រោះពីប្រទេសក្រៅ ទៅកាន់ប្រទេសកម្ពុជា

គួរតែអានមាត្រានេះ ជាមួយគ្នានឹងបទប្បញ្ញត្តិយុត្តាធិការ នៃមាត្រា ២ និងមាត្រា ៣ ខាងលើ ។ ឧទាហរណ៍ : មាត្រានេះ អាចត្រូវបានប្រើដើម្បីដាក់ទោសអំពើដែលកើតឡើង នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលជនរងគ្រោះ ឬ ជនល្មើស ជាពលរដ្ឋខ្មែរ ។ ( សូមមើលការពិភាក្សាយោងតាម មាត្រា ៣ សម្រាប់ព័ត៌មានលំអិត ) ។ ដូចគ្នានេះដែរ ប្រសិនបើជនរងគ្រោះ ត្រូវបានផ្ទេររវាងប្រទេសក្រៅពីរ តាមនាវាដែលមានទង់ជាតិកម្ពុជា យោងតាមមាត្រា ២ យុត្តាធិការប្រទេសកម្ពុជា គឺជាយុត្តាធិការដ៏សមរម្យ ។ ( សូមមើលការពិភាក្សាយោងតាម មាត្រា ២ សម្រាប់ព័ត៌មានលំអិត ) ។

**ការផ្តន្ទាទោស និងកត្តាស្ថានទម្ងន់ទោស**

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ ជនល្មើសនោះត្រូវតែទទួលការផ្តន្ទាទោសជាប់ពន្ធនាគារ ពី ៧ ( ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។ ទោសបន្ថែម អាចក៏ត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតរបស់ នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើ ចាំបាច់ត្រូវដាក់រួមមាន ការផ្តន្ទាទោសដូចជាការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

យ៉ាងណាមិញ ប្រសិនបើ តុលាការរកឃើញមានកត្តាស្ថានទម្ងន់ទោសមួយ ដូចបានរៀបរាប់ខាងក្រោមនេះ ហេតុដូច្នេះការផ្តន្ទាទោស ត្រូវកើនឡើង ពី ១៥ (ដប់ប្រាំ) ដល់ ២០ ( ម្ភៃ) ឆ្នាំ ។ ច្បាប់នេះ មិនតម្រូវឱ្យបំពេញតាមកត្តាស្ថានទម្ងន់ទោសទាំងអស់ទេ ។ ជាការគ្រប់គ្រាន់ហើយ ដែលថាមានកត្តាស្ថានទម្ងន់ទោសតែមួយប៉ុណ្ណោះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

~ **ជនរងគ្រោះជាអនីតិជន**

ប្រសិនបើ ជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

ប្រសិនបើ ជនល្មើសមានការគ្រប់គ្រង និងការត្រួតពិនិត្យលើអនីតិជន ហេតុដូច្នេះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា ជនល្មើសបានដឹងពីអាយុរបស់អនីតិជន ។ សូមមើលការពិភាក្សាយោងតាមមាត្រា ៧ ( និយមន័យនៃអនីតិជន ) ខាងលើ ។

~ **អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើ ជនរងគ្រោះ**

ប្រសិនបើជនល្មើស គឺជាមន្ត្រីសាធារណៈ និងបានប្រព្រឹត្តអំពើដោយមធ្យោបាយ បំពានដោយអំណាច ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

" មន្ត្រីសាធារណៈ " មានន័យថា ជាមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលត្រូវផ្តល់អាណត្តិឱ្យតាមរយៈការបោះឆ្នោត ។ ទាំងនេះរួមមាន : តួនាទីជាមន្ត្រីរដ្ឋាភិបាល នគរបាល យោធា គ្រូបង្រៀន និងបុគ្គលិក ក្នុងសាលារៀន និងសាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យសាធារណៈ ឬ មជ្ឈមណ្ឌលសុខភាព និង បុគ្គលដែលកំពុងមានតួនាទីសាធារណៈដែលជាប់ឆ្នោត នៅក៏រិតណាមួយជាអាទិ៍ ។

" ការបំពានដោយសិទ្ធិអំណាច " មានន័យដូចពាក្យ " ការបំពានអំណាច " ដូចត្រូវបានពិភាក្សា យោងតាម មាត្រា ៨ ពោលគឺជា ស្ថានការណ៍ដែលមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលគេផ្តល់អាណត្តិបោះឆ្នោតឱ្យបានប្រើប្រាស់តួនាទីរបស់ខ្លួន មិនសមរម្យ ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះ ស្រប នឹងនិយមន័យ ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ (សូមពិនិត្យមើល គន្ថីទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ កថាភាគីទី ២ " ការបំពានអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភដោយអំណាចនេះ ប្រើប្រាស់ដើម្បី កេងប្រវ័ញ្ចន៍ពីមនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយទទួលរងគ្រោះ ដើម្បីធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីដែលជនរងគ្រោះ នឹងមិនធ្វើដោយឆន្ទៈ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទាំងមូលបានបង្ហាញពីចេតនាយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយរបស់មន្ត្រីសាធារណៈ ក្នុងអំពើជួញដូរមនុស្ស ។

## - អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង

ប្រសិនបើ ជនល្មើសបានប្រព្រឹត្តបទល្មើស ដោយជាផ្នែកមួយនៃក្រុមមានការចាត់តាំង ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៧៧ " ក្រុមមានការចាត់តាំង " មានន័យថា គឺជាការប្រមូលផ្តុំ ដែលបានបង្កើតឡើង ឬ ជាសន្ទិដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

ក្នុងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ មាននិយមន័យ ប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែតម្រូវបន្ថែមឱ្យក្រុមមានការចាត់តាំង ត្រូវតែបញ្ចូលមនុស្សពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ។ ឧទាហរណ៍ : អនុសញ្ញា អង្គការសហប្រជាជាតិ ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័ន ឱ្យនិយមន័យ " ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង " ក្នុងមាត្រា ២ (ក) ថាជា " ក្រុមដែនមានរចនាសម្ព័ន្ធ ដែលមានគ្នា ពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណងបទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មួយ ឬ ច្រើន ដែលត្រូវធ្វើឡើងស្របទៅនឹង អនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ សម្ភារៈផ្សេងទៀត " ។

ដូច្នេះហើយ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានឱ្យនិយមន័យ " ក្រុមមានការចាត់តាំង " មានន័យថា ជាក្រុម ផ្លូវការ ឬ មិនផ្លូវការ ដែលមានគ្នាបីនាក់ ឬ ច្រើននាក់ជាងនេះ ដែលត្រូវបានបង្កើត ឡើងដើម្បីរៀបចំផែនការ ឬ ដើម្បីប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

គួរកត់សំគាល់ថាបទប្បញ្ញត្តិដែលប្រហាក់ប្រហែលនឹងមាត្រានេះ អាចមានឃើញនៅក្នុងមាត្រា ៣២៧ "បទដកយកអនីតិជន" នៃក្រមព្រហ្មទណ្ឌ (សូមមើលគន្ថីទី ២ មាតិកាទី ៣ ជំពូកទី ៣ "ការប៉ះពាល់ដល់ការថែរក្សាអនីតិជន" ។ ប្រសិនបើយើងធ្វើការប្រៀបធៀប មាត្រា ៣២៧ កថាខណ្ឌទី ១ ឃើញថា មាត្រា ៣២៧ កថាខណ្ឌទី ២ ចែងពី ស្ថានទម្ងន់ទោសជាប់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀល ដល់ ៦ លានរៀល

ចំពោះអំពើ "នាំយកអនីតិជនពីមនុស្សដែលមានការថែរក្សាស្របច្បាប់....ប្រសិនបើ អនីតិជននោះត្រូវបានថែរក្សាទុកនៅក្រៅដែនដីនៃ ព្រះរាជាណាចក្រកម្ពុជា" ។ មាត្រា ៣២៧ នៃក្រមព្រហ្មទណ្ឌ មានភាពខុសគ្នាបន្តិចបន្តួចពីមាត្រា ១១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គ្រាន់តែតម្រូវឱ្យមានចេតនាផ្ទេរ អនីតិជនឆ្លងកាត់ព្រំដែនអន្តរជាតិ ចំណែកឯក្រមព្រហ្មទណ្ឌតម្រូវថា អនីតិជននោះត្រូវបានរក្សាទុកនៅក្រៅដែនដីនៃប្រទេសកម្ពុជា ។ កថាខណ្ឌទី ២ នៃមាត្រា ៣២៧ នៃក្រមព្រហ្មទណ្ឌក៏បានចែងពីទោសយ៉ាងស្រាលបើប្រៀបធៀបទៅនឹង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ដោយសារតែមានភាពខុសគ្នានៅក្នុងធាតុផ្សំនៃបទល្មើសទាំងពីរ មាត្រាទាំងពីរនេះ គេអាចនិយាយបានថាមានលក្ខណៈបង្គ្រប់គ្នាទៅវិញទៅមក មិនមែនផ្ទុយគ្នាទេ ។ ហេតុដូច្នេះ ប្រសិនបើអនីតិជនត្រូវបានគេនាំយកចេញដោយមិនស្របច្បាប់ពីប្រទេសកម្ពុជា ហើយបន្ទាប់មកត្រូវបានផ្ទេរ និងត្រូវបានរក្សាទុកក្នុងប្រទេសមួយ ផ្សេងទៀតដោយជនល្មើសដដែលនេះ ជនល្មើសនោះអាចត្រូវបានចោទប្រកាន់ យោងតាមក្រមព្រហ្មទណ្ឌ និងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ) ។

គួរកត់សំគាល់ដែរថា ប្រសិនបើការនាំយកចេញនូវអនីតិជនដោយមិនស្របច្បាប់នោះ ត្រូវបានធ្វើឡើងនៅក្នុងបរិបទជួញដូរមនុស្ស ជនដែលគួរតែត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសឱ្យធ្ងន់ធ្ងរ យោងតាមមាត្រា ១១ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលជាច្បាប់ពិសេស) យោងទៅតាមវិធាន ដែលមានចែងនៅក្នុង មាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌ ទាក់ទងនឹងច្បាប់ពិសេសនេះ សូមមើល (ការពិភាក្សា ស្តីពី "គោលការណ៍នៃការបកស្រាយច្បាប់" នៅក្នុងសេចក្តីផ្តើម និងនៅក្នុងមាត្រា ៥០ ខាងក្រោម) ។

**មាត្រា ១២.- ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច**

**ការជ្រើសរើសដោយមិនស្របច្បាប់នៅក្នុងច្បាប់នេះ មានន័យថា ការបញ្ចុះបញ្ចូល ការជួល ឬ ការឱ្យជនណាមួយបម្រើការក្រោមទំរង់នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត តាមមធ្យោបាយបោកបញ្ឆោត បំពានដោយអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគម្រាមកំហែង ឬ មធ្យោបាយបង្ខិតបង្ខំផ្សេងទៀត ។**

**ជនណាដែលជ្រើសរើសជនដទៃដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។**

**ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ ( ដប់ប្រាំ ) ឆ្នាំ ដល់ ២០ ( ម្ភៃ ) ឆ្នាំ ក្នុងករណីដែល :**

- **ជនរងគ្រោះជាអនីតិជន ។**
- **អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។**
- **អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។**

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះការជ្រើសរើសដោយមិនស្របច្បាប់ ។

គួរកត់សំគាល់ថា ការជ្រើសរើសដោយមិនស្របច្បាប់ មិនសំដៅទៅលើ ថាតើនិយោជក គឺជានីតិបុគ្គលដែរ ឬ ទេ ឬ ថាតើនិយោជកបានចុះបញ្ជី ឬ ត្រូវផ្តល់អាជ្ញាប័ណ្ណយ៉ាងត្រឹមត្រូវ ដោយក្រសួងការងារ ឬ អាជ្ញាធរ ដែលពាក់ព័ន្ធផ្សេងទៀត ដែរ ឬ ទេ ។

គួរកត់សំគាល់ថា បទល្មើសការជ្រើសដោយមិនស្របច្បាប់ មិនរាប់បញ្ចូលធាតុផ្សំណាមួយ នៃការនាំយកចេញ ការដឹកជញ្ជូន ឬ ការផ្ទេរ ទេ ។ ជនរងគ្រោះអាចត្រូវជ្រើសរើសដោយមិនស្របច្បាប់ សូម្បីតែនៅពេលដែលជនរងគ្រោះនោះ មិនត្រូវបាននាំយក ឬ ដឹកជញ្ជូន ទៅកាន់ទីកន្លែងណាមួយផ្សេងទៀត ។ ប្រសិនបើ ជនរងគ្រោះត្រូវបាននាំយកចេញដោយមិនស្របច្បាប់ និងក៏ត្រូវបានជ្រើសរើសដោយមិនស្របច្បាប់ ហេតុដូច្នេះជនល្មើសអាចត្រូវចោទប្រកាន់ និងកាត់ទោសពីបទល្មើសទាំង ពីរ យោងតាមមាត្រា មួយ នៃមាត្រា ៩ ដល់ មាត្រា ១១ ( ការនាំយកចេញដោយមិនស្របច្បាប់ ) និងមាត្រានេះ ( ការជ្រើសដោយមិនស្របច្បាប់ ) ។ ដូចចែងក្នុងមាត្រា ៦ ( បទល្មើសត្រួតគ្នា ) ជនល្មើសគួរតែត្រូវចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រាដែលធ្ងន់ធ្ងរបំផុត ដែលអនុវត្តចំពោះបទល្មើសនេះ ។

បទល្មើស ការជ្រើសដោយមិនស្របច្បាប់ មានធាតុផ្សំសំខាន់៣បី ត្រូវបំពេញតាមធាតុផ្សំទាំងអស់នេះ :

១) ការបញ្ចុះបញ្ចូល ការជួល ឬ ការឱ្យជនណាមួយបម្រើការ

២) ក្នុងគោលដៅកេងប្រវ័ញ្ចនី

៣) តាមមធ្យោបាយ បោកបញ្ឆោត បំពានដោយអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កំលាំង
ការគំរាមកំហែង ឬ មធ្យោបាយបង្ខិតបង្ខំផ្សេងទៀត

ធាតុផ្សំទាំងនេះ មានការកំណត់និយមន័យដូចខាងក្រោម :

### " ការបញ្ចុះបញ្ចូល ការជួល ឬ ការឱ្យជនណាមួយបម្រើការ "

បទប្បញ្ញត្តិនេះ មានន័យថា ជាការអូសទាញជនណាម្នាក់ឱ្យប្រព្រឹត្តអំពើមួយ ឬ ជួលជនណាម្នាក់ ក្នុងគោលដៅឱ្យធ្វើការងារ ឬ មានទំនាក់ទំនងការងារជាមួយជននោះ ។

" ការងារ " ដូចបានប្រើនៅទីនេះ គឺមិនសំដៅតែទៅលើការងារស្របច្បាប់ ( ការងារធម្មតារូប) ប៉ុណ្ណោះទេ ហើយថែមទាំងសំដៅទៅលើការងារមិនស្របច្បាប់ផងដែរ ។

### " ក្រោមទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត "

ពាក្យថា " ក្រោមទម្រង់ណាមួយនៃការកេងប្រវ័ញ្ចនីផ្សេងទៀត " រួមមានជាអាទិ៍ អំពើដែលមានរៀបរាប់ក្នុងមាត្រា ១០ កថាខ័ណ្ឌទី ៣ ដូចជា ការកេងប្រវ័ញ្ចនីលើពេស្យាចារកម្មជនដទៃ រូបភាព និងសម្ភារៈអាសអាភាស ពាណិជ្ជកម្មផ្លូវភេទ សេវា ឬ ពលកម្មដោយបង្ខំ ទាសភាព ឬ ការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុល សេវភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬ ការដកហូតសរីរាង្គ ។ ចំពោះ និយមន័យនៃពាក្យទាំងនេះ

សូមមើលការពិភាក្សាក្នុងមាត្រា ៣ កថាខ័ណ្ឌទី ៣ ។ បន្ថែមពីនេះទៀត តុលាការក៏អាចមានឆន្ទានុសិទ្ធិ ពិចារណាទៅលើ ប្រភេទនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ដែលមិនបានរៀបរាប់នៅទីនេះ ។ ប្រសិនបើជនល្មើសប្រព្រឹត្តអំពើ នាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅទាំងនេះណាមួយ ហេតុដូច្នេះ ជនល្មើសគួរតែត្រូវផ្តន្ទាទោស យោងតាមមាត្រានេះ ។

### " តាមមធ្យោបាយ "

និយមន័យ នៃការជ្រើសរើសដោយមិនស្របច្បាប់ ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ តម្រូវថា ជនល្មើសប្រើប្រាស់មធ្យោបាយមួយដូចខាងក្រោម ដើម្បីសម្រេចបានការជ្រើសរើសជនរងគ្រោះ ។ លក្ខណៈរួមនៃមធ្យោបាយ ទាំងអស់នេះ គឺថា ជនរងគ្រោះមិនបានយល់ព្រមដោយសេរី ឬ ពេញលេញចំពោះការជ្រើសរើសនេះ ដោយសារជនរងគ្រោះត្រូវបានជ្រើសរើសប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ដោយសារជនរងគ្រោះត្រូវបោកបញ្ឆោត ឬ ដោយសារជនរងគ្រោះមិនបានទទួលព័ត៌មានពេញលេញអំពីការងារ ។

### " ការបោកបញ្ឆោត "

" ការបោកបញ្ឆោត " មានន័យថា ជាស្ថានការណ៍ដែលជនល្មើសប្រើពាក្យកុហក ការផ្តល់ព័ត៌មាន មិនពេញលេញ ឬ រឿងមិនពិត ជាពាក្យសំដី ឬ ជាទង្វើ ដើម្បីឱ្យជនរងគ្រោះជឿធ្វើអ្វីមួយ ។

### " ការបំពានដោយអំណាច "

" ការបំពានដោយអំណាច " មានន័យថា ជាស្ថានការណ៍ដែលមន្ត្រីសាធារណៈ (រួមមានមន្ត្រីរាជការ បុគ្គលដែលមានតួនាទីដោយជាប់ឆ្នោត ឬ មន្ត្រីដែលត្រូវបានតែងតាំងផ្សេងទៀត ) បានប្រើប្រាស់តួនាទីរបស់ខ្លួន មិនសមរម្យ ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះ ស្របនឹងនិយមន័យដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ ( គន្ថីទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ កថាភាគទី ២ " ការរំលោភអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភអំណាចនេះ ប្រើប្រាស់ដើម្បី កេងប្រវ័ញ្ចន៍ពីមនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយទទួលរងគ្រោះ ដើម្បីធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីមួយ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទាំងមូល បានបង្ហាញពីចេតនាយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយ របស់មន្ត្រីសាធារណៈ ក្នុងអំពើជួញដូរមនុស្ស ។ មន្ត្រីទាំងនេះរួមមាន : តួនាទីជាមន្ត្រីរដ្ឋាភិបាល នគរបាល យោធា គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន និងសាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យសាធារណៈ ឬ មជ្ឈមណ្ឌលសុខភាព និងបុគ្គលដែលកំពុងមានតួនាទីសាធារណៈដែលជាប់ឆ្នោត នៅកំរិតណាមួយជាអាទិ៍ ។

### " ការបង្ខាំង "

" ការបង្ខាំង " មានការកំណត់និយមន័យ ក្នុងជំពូកទី ៣ នៃច្បាប់នេះ និងសំដៅទៅលើស្ថានការណ៍ ដែលជនល្មើសធ្វើការបង្ខាំងជនរងគ្រោះ ប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ដោយរារាំងជនរងគ្រោះមិនឱ្យចាកចេញពីទីកន្លែង ដែលខ្លួនត្រូវគេបង្ខាំង ។

### " ការបង្ខិតបង្ខំ "

" ការបង្ខិតបង្ខំ " មានន័យថា ជាការបង្ខិតបង្ខំផ្លូវកាយ ឬ ផ្លូវចិត្ត ប្រឆាំងនឹងឆន្ទៈរបស់ជនរងគ្រោះ ។ មាត្រានេះ មិនតម្រូវឱ្យជនល្មើសប្រើអំពើហិង្សា ឬ មិនតម្រូវឱ្យជនរងគ្រោះប្រឆាំងតទល់ ឬ ទទួលរងរបួសដោយសារតែ ការប្រើប្រាស់ការបង្ខិតបង្ខំនោះទេ ។ ឧទាហរណ៍ : ប្រសិនបើ ជនល្មើសចាប់ជនណាម្នាក់ និងបានរុញ ឬ ទាញជននោះ អំពើនេះនៅតែត្រូវចាត់ទុកថា ជាការប្រើការបង្ខិតបង្ខំ ទោះបីជនរងគ្រោះមិនឈឺក៏ដោយ ។

តុលាការអាចកត់សំគាល់ពីការកើនឡើង នៃភាពងាយទទួលរងគ្រោះនៃជនរងគ្រោះ និងហេតុដូច្នេះ ជាពិសេស តុលាការ ក៏ត្រូវពិចារណាលើការបង្ខិតបង្ខំ ដែលមិនមែនមកលើរូបកាយ ដូចជាការបង្ខិតបង្ខំតាមផ្លូវចិត្ត ។

### " ការគម្រាមកំហែង "

" ការគម្រាមកំហែង " មានន័យថា ជាការគម្រាមកំហែងទាំង ដោយផ្ទាល់ និងដោយប្រយោល ដែលធ្វើឱ្យជនរងគ្រោះភ័យខ្លាចពីការធ្វើបាបរូបកាយ ឬ ផ្លូវចិត្ត ឬ ភ័យខ្លាចមានគ្រោះថ្នាក់ផ្សេងទៀត ដល់ខ្លួន ឬ ដល់ តតិយជន ។ ឧទាហរណ៍ : នេះជាការគម្រាមកំហែង ប្រសិនបើ ជនល្មើសនាំយកចេញជនរងគ្រោះ ដោយធ្វើឱ្យជនរងគ្រោះជឿថា ជនល្មើស នឹងធ្វើបាបសាច់ញាតិរបស់ជនរងគ្រោះ ប្រសិនបើ ជនរងគ្រោះមិនទៅជាមួយជនល្មើស ទេ ។

ជនល្មើសមិនចាំបាច់គម្រាមកំហែង ជនរងគ្រោះ ឬ តតិយជន ដោយធ្វើបាបរូបកាយទេ ។ ជាការគ្រប់គ្រាន់ហើយ ដែលថាជនល្មើសគម្រាមប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម ប្រឆាំងនឹងជនណាម្នាក់ ( ជនរងគ្រោះ ឬ តតិយជន ) ។ នេះស្របទៅនឹងផ្នែក ស្តីពី " ការគម្រាមកំហែង " ក្នុងក្រមព្រហ្មទណ្ឌ ( មាត្រា ២៣១ ដល់ មាត្រា ២៣៤ ) ។

ក្នុងករណីដែលជនល្មើសគម្រាមប្រព្រឹត្តអំពើស្របច្បាប់ ប៉ុន្តែប្រើប្រាស់ការគម្រាមកំហែងនោះ ដើម្បីប្រព្រឹត្តបទល្មើស អំពើនេះ នៅតែត្រូវចាត់ទុកថា ជាការគម្រាមកំហែង ។ ឧទាហរណ៍ : ប្រសិនបើជនល្មើសឱ្យខ្ចីលុយ និងគម្រាមកំហែងឱ្យសងបំណុល ដើម្បីប្រព្រឹត្តបទល្មើស យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ហេតុដូច្នេះអំពើនេះ នៅតែត្រូវចាត់ទុកថាជាបទល្មើស ។ ដូចគ្នានេះដែរ ប្រសិនបើជនល្មើសគម្រាមកំហែងថា នឹងរាយការណ៍អំពីការធ្វើអន្តោប្រវេសន៍ខុសច្បាប់ របស់ជនរងគ្រោះ ទៅដល់អាជ្ញាធរមានសមត្ថកិច្ច និងបានប្រើការគម្រាមកំហែងនោះ ដើម្បីឱ្យខ្លួន (ជនល្មើស) បានសម្រេចគោលបំណងក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ហេតុដូច្នេះ អំពើនេះ នៅតែត្រូវចាត់ទុកថា ជាបទល្មើស ។

## ˝ ការបង្ខិតបង្ខំ ˝

˝ ការបង្ខិតបង្ខំ ˝ នៅទីនេះមានន័យថា ជាការប្រើប្រាស់កំលាំង ឬ ការប្រើប្រាស់ការគម្រាមកំហែង ដោយផ្ទាល់ ឬ ដោយប្រយោល ដែលរួមមានទម្រង់ខ្លះៗ នៃការប្រើប្រាស់កំលាំង ឬ ការគម្រាមកំហែងដោយអហិង្សា ឬ ចិត្តសាស្ត្រ ។ ទាំងនេះរួមមានដូចជា :

ក) ការប្រើប្រាស់កំលាំង ឬ ការគម្រាមកំហែងបង្កឱ្យមានគ្រោះថ្នាក់ (រួមមានបណ្តាលឱ្យស្លាប់ រងរបួសរូបកាយ ឬ រំលោភសេពសន្ថវៈ និងការឈ្លានពានផ្លូវភេទ ) ឬ បង្ខាំងរូបកាយដល់ជនណាម្នាក់ ។

ខ) គ្រោងការណ៍ ផែនការ ឬ គំរូ ដែលមានចេតនាបណ្តាលឱ្យជនណាម្នាក់ជឿជាក់ថា ការខកខានមិនបានប្រព្រឹត្តអំពើណាមួយ នឹងនាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬ បង្ខាំងរូបកាយដល់ជនណាម្នាក់ ។

គ) ការបំពាន ឬ ការគម្រាមកំហែងណាមួយដែលជាប់ទាក់ទងនឹងឋានៈនៃជនណាម្នាក់ ។

ឃ) ការគាបសង្កត់ផ្លូវចិត្ត ដែលរួមមានបណ្តាលឱ្យជនណាម្នាក់ជឿថា គាត់ ឬ បុគ្គលផ្សេងទៀត នឹងត្រូវគេនាំយកចេញ លក់ ឬ បង្ខាំង ដោយខុសច្បាប់ ។

ការបង្ខិតបង្ខំ ក្នុងន័យនេះ គឺជាអំពើដែលធ្វើឡើងប្រឆាំងនឹងជនម្នាក់ផ្សេងទៀត ដើម្បីឱ្យជននោះមិនអាចបញ្ចេញឆន្ទៈសេរីរបស់ខ្លួន ។

**<u>ការផ្តន្ទាទោស និងកត្តាស្ថានទម្ងន់ទោស</u>**

ប្រសិនបើជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ ជនល្មើសនោះត្រូវតែទទួលការផ្តន្ទាទោសជាប់ពន្ធនាគារ ពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។ ទោសបន្ថែម អាចក៏ត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់ រួមមាន ការផ្តន្ទាទោសដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ (មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត (មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ (សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

យ៉ាងណាមិញ ប្រសិនបើ តុលាការរកឃើញមានកត្តាស្ថានទម្ងន់ទោសមួយ ដូចបានរៀបរាប់ខាងក្រោមនេះ ហេតុដូច្នេះការផ្តន្ទាទោស ត្រូវកើនឡើង ពី ១៥ (ដប់ប្រាំ) ដល់ ២០ (ម្ភៃ) ឆ្នាំ ។ ច្បាប់នេះ មិនតម្រូវឱ្យបំពេញតាមកត្តាស្ថានទម្ងន់ទោសទាំងអស់ទេ ។ ជាការគ្រប់គ្រាន់ហើយ ដែលថាមានកត្តាស្ថានទម្ងន់ទោសតែមួយប៉ុណ្ណោះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

- **ជនរងគ្រោះជាអនីតិជន**

ប្រសិនបើ ជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

ប្រសិនបើ ជនល្មើសមានការគ្រប់គ្រង និងការត្រួតពិនិត្យលើអនីតិជន ហេតុ ដូច្នេះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចាត់ទុកថា ជនល្មើសបានដឹងពីអាយុរបស់អនីតិជន ។ សូមមើលការពិភាក្សា យោងតាមមាត្រា ៧ (និយមន័យនៃអនីតិជន ) ខាងលើ ។

- **អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើ ជនរងគ្រោះ**

ប្រសិនបើ ជនល្មើស គឺជាមន្ត្រីសាធារណៈ និងបានប្រព្រឹត្តអំពើដោយមធ្យោបាយ បំពានដោយអំណាច ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

" មន្ត្រីសាធារណៈ " មានន័យថា ជាមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលត្រូវផ្តល់អាណត្តិឱ្យតាមរយៈ ការបោះឆ្នោត ។ ទាំងនេះរួមមាន : តួនាទីជាមន្ត្រីរដ្ឋាភិបាល នគរបាល យោធា គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន និងសាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យសាធារណៈ ឬ មជ្ឈមណ្ឌលសុខភាព និង បុគ្គលដែលកំពុងមានតួនាទីសាធារណៈដែលជាប់ឆ្នោត នៅកំរិតណាមួយជាអាទិ៍ ។

" ការបំពានដោយសិទ្ធិអំណាច " មានន័យដូចពាក្យ " ការបំពានអំណាច " ដូចត្រូវពិភាក្សា យោងតាមមាត្រា ៨ ពោលគឺ ជាស្ថានការណ៍ដែលមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលគេផ្តល់អាណត្តិបោះឆ្នោតឱ្យបានប្រើប្រាស់តួនាទីរបស់ខ្លួន មិនសមរម្យ ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះ ស្របនឹងនិយមន័យដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ (សូមពិនិត្យមើល គន្ថីទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ កថាភាគទី ២ " ការរំលោភអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភអំណាចនេះ ប្រើប្រាស់ដើម្បីកេងប្រវ័ញ្ចន៍ពី មនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយទទួលរងគ្រោះ ដើម្បីធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីដែលជនរងគ្រោះ នឹងមិនធ្វើដោយឆន្ទៈ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទាំងមូលបានបង្ហាញពីចេតនាយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយរបស់មន្ត្រីសាធារណៈក្នុងអំពើជួញដូរមនុស្ស ។

- **អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង**

ប្រសិនបើ ជនល្មើសបានប្រព្រឹត្តបទល្មើស ដោយជាផ្នែកមួយនៃក្រុមមានការចាត់តាំង ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៧៧ " ក្រុមមានការចាត់តាំង " មានន័យថា គឺជាការប្រមូលផ្តុំ ដែលបានបង្កើតឡើង ឬ ជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

ក្នុងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ មាននិយមន័យ ប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែតម្រូវបន្ថែមឱ្យក្រុមមានការចាត់តាំង ត្រូវតែបញ្ចូលមនុស្សពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ។ ឧទាហរណ៍ : អនុសញ្ញា អង្គការសហប្រជាជាតិ ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័ន ឱ្យនិយមន័យ " ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង " ក្នុងមាត្រា ២ (ក) ថាជា " ក្រុមដែលមានរចនាសម្ព័ន្ធ ដែលមានគ្នា ពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណងបទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មួយ ឬ ច្រើន ដែលត្រូវធ្វើឡើងស្របទៅនឹង អនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ សម្ភារៈផ្សេងទៀត " ។

ដូច្នេះហើយ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានឱ្យនិយមន័យ " ក្រុមមានការចាត់តាំង " មានន័យថា ជាក្រុម ផ្លូវការ ឬ មិនផ្លូវការ ដែលមានគ្នាបីនាក់ ឬ ច្រើននាក់ជាងនេះ ដែលត្រូវបានបង្កើត ឡើងដើម្បីរៀបចំផែនការ ឬដើម្បីប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

**មាត្រា ១៣.- និយមន័យនៃអំពើលក់-ដូរមនុស្ស**

**អំពើលក់-ដូរមនុស្សមានន័យថា ប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬ ទទួលដោយខុសច្បាប់នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយផ្តោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង ។**

**អំពើធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ដូរមនុស្ស ត្រូវផ្តន្ទាទោសដូចគ្នានឹងអំពើលក់-ដូរមនុស្សដោយផ្ទាល់ ។**

មាត្រានេះ កំណត់និយមន័យ អំពើលក់-ដូរមនុស្ស ដែលក៏សំដៅទៅលើអំពើលក់-ដូរមនុស្ស ក្នុងមាត្រា ១៤ ដល់មាត្រា ១៦ នៃជំពូកនេះ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសនៃអំពើលក់ដូរមនុស្ស ក៏មានចែងនៅក្នុងមាត្រា ១៤ ដល់មាត្រា ១៦ នៃច្បាប់នេះ ។ ជនល្មើសគួរត្រូវចោទប្រកាន់ និងផ្តន្ទាទោស ពីបទល្មើសដែលទាក់ទងនឹងអំពើលក់-ដូរមនុស្ស យោងតាមមាត្រាដែលសមស្រប (សូមពិនិត្យមើល មាត្រា ១៤ ដល់ មាត្រា ១៦) ។

គួរកត់សំគាល់ថា អ្នកលក់ និងអ្នកទិញ ត្រូវទទួលទោសដូចគ្នា ចំពោះការប្រព្រឹត្តបទល្មើសនេះ ។

បទល្មើស លក់-ដូរមនុស្ស មានធាតុផ្សំសំខាន់ៗពីរ ដែលធាតុផ្សំទាំងពីរនេះត្រូវបំពេញ :

១) ប្រគល់ឱ្យដោយខុសច្បាប់ (ការលក់) នូវការគ្រប់គ្រងលើជនណាម្នាក់ ឬ ទទួលដោយខុសច្បាប់ (ការទិញ) លើជនណាម្នាក់ និង

២) ដោយផ្តោះប្តូរ ទៅនឹងរបស់មានតម្លៃ អ្វីមួយ ។

### " ប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ "

ប្រគល់ដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ ( ជនរងគ្រោះដោយអំពើជួញដូរ ) ទៅកាន់ជនណាម្នាក់ផ្សេងទៀត ( អ្នកទិញ ) មានន័យថា ជនល្មើស ( អ្នកលក់ ) ដែលមានការគ្រប់គ្រងរួចជាស្រេច លើជនណាម្នាក់ផ្ទេរការគ្រប់គ្រងនោះ ទៅឱ្យជនណាម្នាក់ផ្សេងទៀត ( អ្នកទិញ ) ដោយផ្ដោះប្ដូររបស់មានតម្លៃ អ្វីមួយ ។

ការប្រគល់ឱ្យ គឺ " ខុសច្បាប់ " នៅពេលដែលធ្វើឡើងដោយមធ្យោបាយខុសច្បាប់ ( ឧទាហរណ៍ : តាមមធ្យោបាយ ប្រើប្រាស់កំលាំង បង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬ លោងលោម ) នៅពេលធ្វើឡើងដោយមានគោលដៅខុសច្បាប់ ឬ ទៅលើអនីតិជន ឬ ជនផ្សេងទៀត ដែលមិនមានសមត្ថភាពខាងផ្លូវច្បាប់ នៅពេលដែលធ្វើឡើងក្នុងលក្ខណៈដែលមានធាតុផ្សំ នៃមាត្រា ៨ កថាខ័ណ្ឌទី ២ ។

### " ទទួលដោយខុសច្បាប់ នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ "

ការទទួលដោយខុសច្បាប់ នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ ( ជនរងគ្រោះដោយអំពើជួញដូរ ) ពីជនដទៃ ( អ្នកលក់ ) មានន័យថា ជនល្មើស ( អ្នកទិញ ) ទទួលនូវការគ្រប់គ្រងនោះ ពីជនម្នាក់ផ្សេងទៀត ( អ្នកលក់ ) ។

ការទទួលដោយខុសច្បាប់ នូវការប្រគល់ការគ្រប់គ្រងលើជនរងគ្រោះដោយអំពើជួញដូរ ត្រូវតែមានគោលដៅខុសច្បាប់ ឬ តាមមធ្យោបាយខុសច្បាប់ ដូចជា ប្រើប្រាស់កំលាំង បង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬ លោងលោម ឬ ទៅលើអនីតិជន ឬ ជនផ្សេងទៀត ដែលមិនមានសមត្ថភាពខាងផ្លូវច្បាប់ នៅពេលដែលធ្វើឡើងក្នុងលក្ខណៈដែលមានធាតុផ្សំ នៃមាត្រា ៨ កថាខ័ណ្ឌទី ២ ។ នេះជាការពិតនៅក្នុងករណី ក្នុងស្ថានការណ៍ជួញដូរ ប៉ុន្តែអាចមានអញ្ញត្រកម្ម ។ ឧទាហរណ៍ : ប្រសិនបើ ជនណាម្នាក់ ឬ អង្គការមិនមែនរដ្ឋាភិបាល បានទិញជនរងគ្រោះដោយអំពើជួញដូរ ដើម្បីឱ្យជនរងគ្រោះមានសេរីភាព ហេតុដូច្នេះអំពើនេះ មិនគួរត្រូវផ្ដន្ទាទោស ដោយសារតែអំពើនេះ មិនត្រូវបានធ្វើឡើងក្នុងគោលដៅខុសច្បាប់ឡើយ ។

### " ការគ្រប់គ្រងលើមនុស្ស "

ពាក្យថា " ការគ្រប់គ្រងលើមនុស្ស " គួរត្រូវបានបកស្រាយឱ្យទូលំទូលាយ ។ ជាទូទៅមានន័យថា ជាអំពើដែលត្រូវធ្វើឡើងដោយផ្ទុយនឹងឆន្ទៈ ឬ សេចក្ដីប្រាថ្នារបស់ជនរងគ្រោះ ហើយដែលថា ជនរងគ្រោះមិនអាចបដិសេធន៍ ឬ ទប់ស្កាត់អំពើនេះ ឬ ការបញ្ជាផ្សេងទៀតណាមួយ ពីអ្នកទិញ ឬ អ្នកលក់ ។ យ៉ាងណាមិញ ការគ្រប់គ្រងជាចាំបាច់គួរមិនកំណត់ចំពោះករណីដែលរាងកាយរបស់ជនរងគ្រោះ ត្រូវប្រគល់ឱ្យ ឬ ផ្ទេរ រវាងតែមនុស្ស ពីរ នាក់ ទេ ។

ឧទាហរណ៍ : ប្រសិនបើ អ្នកលក់ "ក" ប្រាប់ កម្មករផ្លូវភេទដែលគេជួញដូរ "ខ" ឱ្យទៅរងចាំនៅទល់មុខកន្លែងមួយ និង "ក" ក៏ប្រាប់ អ្នកទិញ "គ" ដែលជាម្ចាស់ផ្ទះបន ដើម្បីទៅយក "ខ" នៅកន្លែងនោះ ការប្រគល់ឱ្យ និងការទទួល នៃការគ្រប់គ្រងលើជនណាម្នាក់បានកើតឡើង ។ ឧទាហរណ៍មួយទៀត នៃការប្រគល់ឱ្យ និងការទទួល នៃការគ្រប់គ្រងលើជនណាម្នាក់ ដែលមិនទាក់ទិននឹងការប្រគល់រូបកាយ នឹងជាការផ្ទេរសិទ្ធិគ្រប់គ្រង ឧទាហរណ៍ : តាមរយៈឯកសារកិច្ចសន្យា។ ប្រសិនបើ អ្នកលក់ "ក" ជាម្ចាស់ផ្ទះបន បានផ្ទេរឯកសារកិច្ចសន្យា ដែលចងភ្ជាប់ "ខ"

ដែលជាកម្មករផ្លូវភេទឱ្យធ្វើការងារឱ្យ "ក" ក្នុងរយៈពេលណាមួយ ទៅកាន់ "គ" ដែលជាម្ចាស់ផ្ទះបនផ្សេងទៀត ហេតុដូច្នេះ នេះគួរតែត្រូវចាត់ទុកថា ជាការប្រគល់ឱ្យ និងការទទួល នូវការគ្រប់គ្រងលើជនណាម្នាក់ ។

**" ដោយផ្ដោះប្ដូរ ទៅនឹងរបស់មានតម្លៃ អ្វីមួយ "**

ការទិញមនុស្សតម្រូវថា អ្នកទិញផ្ដល់ " របស់មានតម្លៃអ្វីមួយ " ដោយផ្ដោះប្ដូរទៅនឹង ការទទួល ការគ្រប់គ្រង លើជនរងគ្រោះ ពីអ្នកលក់ ។

ការលក់មនុស្សតម្រូវថា អ្នកលក់ទទួល " របស់មានតម្លៃអ្វីមួយ " ដោយផ្ដោះប្ដូរទៅនឹង ការប្រគល់ឱ្យ ការគ្រប់គ្រងលើជនរងគ្រោះ ទៅកាន់អ្នកទិញ ។

ការផ្ដោះប្ដូរមនុស្ស សំដៅទៅលើស្ថានការណ៍ដែលជនល្មើសបានប្ដូរ ការគ្រប់គ្រងរបស់ខ្លួន លើមនុស្សម្នាក់ យកការគ្រប់គ្រងលើមនុស្សម្នាក់ផ្សេងទៀត ។

ពាក្យថា " វត្ថុមានតម្លៃអ្វីមួយ " រាប់បញ្ចូលជាអាទិ៍ លាភការជាប្រាក់ ឬ ជារបស់ ប្រាក់ វត្ថុមានតម្លៃ ទ្រព្យសម្បត្តិ ( ដែលរួមមាន សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ លក់ ឬ ជួល ប្រភេទណាមួយ នៃចលន ឬ អចលនទ្រព្យ) សេវាកម្ម ការបង់ប្រាក់ដោយផ្ទាល់ ឬ ដោយប្រយោល ឬ ថ្លៃឈ្នួល ( ដែលផ្ដល់ទៅឱ្យតាមរយៈ ឬ ក្នុងនាមជន ផ្សេងទៀត ) ព័ត៌មានមានតម្លៃ ឬ ការគ្រប់គ្រងលើមនុស្សផ្សេងទៀត ។

**" អំពើធ្វើជាភ្នាក់ងារកណ្ដាល នៃការលក់-ដូរមនុស្ស ត្រូវផ្ដន្ទាទោសដូចគ្នា នឹងអំពើលក់-ដូរមនុស្សដោយផ្ទាល់ "**

កថាខ័ណ្ឌទី ២ នៃមាត្រានេះ ចែងថា ជនណាដែលធ្វើជាភ្នាក់ងារកណ្ដាលនៃ ការលក់-ដូរមនុស្ស ( ដូចមាននិយមន័យក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ) ត្រូវផ្ដន្ទាទោសដូចគ្នា នឹងអំពើ លក់-ដូរមនុស្សដោយផ្ទាល់ ។

## មាត្រា ១៤.- អំពើលក់-ដូរមនុស្ស

ជនណាដែលលក់-ដូរជនដទៃ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ពី ២ ( ពីរ) ឆ្នាំ ដល់ ៥ ( ប្រាំ) ឆ្នាំ ។

មាត្រានេះ ចែងពីបទល្មើស និងធ្វើការផ្ដន្ទាទោសអំពើ លក់-ដូរមនុស្ស ដែលមានការកំណត់និយមន័យ ក្នុងមាត្រា ១៣ ខាងលើ ។ ជនល្មើសត្រូវផ្ដន្ទាទោស យោងតាមមាត្រានេះ មិនមែនយោងតាមមាត្រា ១៣ ទេ ។ មាត្រានេះអនុវត្តតែក្នុងករណីដែលមិនមានភស្តុតាងនៃគោលដៅ ។ ជាទូទៅគេរំពឹងថា ក្នុងករណី អំពើជួញដូរមនុស្ស នឹងមានភស្តុតាងនៃគោលដៅមួយចំនួន ។ ហេតុដូច្នេះ ប្រសិនបើមានភស្តុតាងណាមួយថា ជនល្មើសបានលក់-ដូរមនុស្ស ក្នុងគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាព អាសអាភាស រៀបអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទម្រង់ណាមួយ នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ហេតុដូច្នេះ ជនល្មើសគួរតែត្រូវចោទប្រកាន់ និងផ្ដន្ទាទោសយោងតាមមាត្រា ១៥ ( អំពើលក់-ដូរមនុស្ស ដោយមានគោលដៅ ) ។

ដូចគ្នានេះដែរ ប្រសិនបើ មានភស្តុតាងណាមួយថា ជនល្មើសបានលក់-ដូរមនុស្ស ដោយមានគោលដៅនាំយកឆ្លងដែន ហេតុដូច្នេះជនល្មើសគួរតែត្រូវចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រា ១៦ (អំពើលក់-ដូរមនុស្សដោយមានគោលដៅនាំឆ្លងដែន) ។

មាត្រានេះ ផ្តន្ទាទោសបទល្មើសលក់-ដូរមនុស្ស ដោយដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។ ទោសបន្ថែម ក៏អាចត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ការផ្តន្ទាទោសដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ (មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣) ឬ ការបិទអាជីវកម្ម (មាត្រា ៤៨ កថាខ័ណ្ឌទី ៤) ។ (សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត) ។

**មាត្រា ១៥.- អំពើលក់-ដូរមនុស្សដោយមានគោលដៅ**

**ជនណាដែលលក់-ដូរជនដទៃ ដោយមានគោលដៅស្វែងរកប្រយោជន៍ ឈ្មួញកាមខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ ឬ សុំកូន ឬ ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។**

**ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែល :**

**- ជនរងគ្រោះជាអនីតិជន ។**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។**

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោសចំពោះ អំពើលក់-ដូរមនុស្ស ក្នុងករណីដែលអំពើលក់-ដូរមនុស្សនោះ ត្រូវធ្វើឡើងដោយមានគោលដៅ កេងប្រវ័ញ្ចផ្លូវភេទ ពលកម្មដោយបង្ខំ ឬ ទម្រង់ផ្សេងទៀត នៃការកេងប្រវ័ញ្ច ។

ជនល្មើសត្រូវតែទទួលការចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រានេះ មិនមែនយោងតាមមាត្រា ១៣ ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីស្វែងរកឱ្យឃើញជនល្មើសមានទោស យោងតាមមាត្រានេះ ព្រះរាជអាជ្ញា និង តុលាការត្រូវធានាថា ជនល្មើសបំពេញតាមលក្ខខណ្ឌទាំងអស់ យោងតាមនិយមន័យនៃ អំពើលក់-ដូរមនុស្ស ដូចមានចែងក្នុងមាត្រា ១៣ ។

ក្នុងករណីដែលជនល្មើស បានទិញ លក់ ឬ ដោះដូរមនុស្ស ប៉ុន្តែមិនមានគោលដៅណាមួយដូចបានរៀបរាប់នៅក្នុងមាត្រានេះ ជនល្មើសអាចត្រូវទទួលការចោទប្រកាន់ យោងតាមមាត្រា ១៤ ។

ក្នុងករណីដែលជនល្មើស ប្រព្រឹត្តអំពើ លក់-ដូរមនុស្ស ដោយមានគោលដៅសម្រាប់នាំជនរងគ្រោះ ឆ្លងព្រំដែនអន្តរជាតិ ហេតុដូច្នេះ ជនល្មើសត្រូវតែទទួលការចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រា ១៦ ។

បទល្មើសដែលមានចែងក្នុងមាត្រានេះ មានធាតុផ្សំសំខាន់ៗ ពីរ ដែលធាតុផ្សំទាំងពីរនេះត្រូវបំពេញ :

១) **អំពើលក់-ដូរមនុស្ស** ( សូមមើលនិយមន័យ ក្នុងមាត្រា ១៣)

ជនល្មើសត្រូវតែបានប្រព្រឹត្តអំពើ លក់-ដូរមនុស្ស ដែលមានន័យថា ជនល្មើសត្រូវតែបំពេញតាមលក្ខណៈទាំងអស់ ដូចមានចែងក្នុងមាត្រា ១៣ ( សូមមើលការពិភាក្សា យោងតាមមាត្រា ១៣ សម្រាប់ព័ត៌មានលំអិត ) ។

២) **ដោយមានគោលដៅ.....**

បន្ថែមទៅនឹងការប្រព្រឹត្តអំពើ លក់-ដូរមនុស្ស ជនល្មើសត្រូវមានចេតនាជាក់លាក់ ក្នុងការប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ។ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនតម្រូវថា ជនល្មើសបានប្រព្រឹត្តអំពើទាំងនេះដោយជោគជ័យទេ ប៉ុន្តែគ្រាន់តែតម្រូវថា ជនល្មើសមានចេតនាប្រព្រឹត្តដូច្នេះ ។ ដូចគ្នានេះដែរ ច្បាប់នេះមិនតម្រូវថា ជនល្មើសមានគោលដៅច្រើនជាងមួយ ដូចខាងក្រោម ។ មានន័យថា មានគោលដៅតែមួយគឺ គ្រប់គ្រាន់ហើយ ។

### " ស្វែងរកប្រយោជន៍ "

ពាក្យថា " ស្វែងរកប្រយោជន៍ " ដូចមានប្រើក្នុងមាត្រានេះ មានន័យថា ជនល្មើសបានប្រព្រឹត្តអំពើរ លក់-ដូរមនុស្ស ដើម្បីផ្តោះប្តូរ ឬ ដើម្បីទទួលយកវត្ថុមានតម្លៃអ្វីមួយ ដែលរួមមានជាអាទិ៍ ប្រាក់ របស់មានតម្លៃផ្សេងទៀត ( មាស គ្រឿងអលង្កការ ។ល។ ) សេវាកម្ម ឬ មនុស្ស ។ ប្រសិនបើ ជនល្មើសបានប្រព្រឹត្តអំពើ លក់-ដូរមនុស្ស ក្នុងគោលដៅនេះ ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោស យោងតាមមាត្រា នេះ ។

### " ឈ្លានពានខាងផ្លូវភេទ "

ពាក្យថា " ឈ្លានពានខាងផ្លូវភេទ " ដូចមានប្រើក្នុងមាត្រានេះ មានន័យថា ជនល្មើសបានប្រព្រឹត្តអំពើ លក់-ដូរមនុស្សដោយមានគោលដៅ ប្រព្រឹត្តបទល្មើសផ្លូវភេទប្រឆាំងនឹងជនរងគ្រោះ ដូចជា អំពើរំលោភសេពសន្ថវៈ ឬ អំពើបំពានផ្លូវភេទផ្សេងទៀត ( សូមមើលនិយមន័យនៃបទល្មើសទាំងនេះ យោងតាមច្បាប់ព្រហ្មទណ្ឌ ដែលកំពុងអនុវត្ត ) ឬ ក្នុងករណី ដែលអនីតិជនអាយុក្រោម ១៥ ឆ្នាំ អំពើអាសដូចមានការ កំណត់និយមន័យ ក្នុងជំពូកទី ៦ នៃច្បាប់នេះ ។ ប្រសិនបើជនល្មើសប្រព្រឹត្តអំពើ លក់-ដូរមនុស្ស សម្រាប់គោលដៅនេះ ហេតុដូច្នេះ ជនល្មើសគួរត្រូវទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើរ លក់-ដូរមនុស្សដោយមានគោលដៅនេះ និងបន្ទាប់មកធ្វើការ ឈ្លានពានខាងផ្លូវភេទ ជនល្មើសគប្បីត្រូវទទួលការចោទប្រកាន់ ពីបទល្មើសទាំងពីរ ។ ឧទាហរណ៍ : ប្រសិនបើអ្នកប្រព្រឹត្តប្រព្រឹត្តអំពើ លក់-ដូរមនុស្ស ទិញជនណាម្នាក់ដោយមិនស្របច្បាប់ ដោយមានគោលដៅ រំលោភសេពន្ទវៈជនរងគ្រោះ និងក្រោយមកបានប្រព្រឹត្តអំពើ រំលោភសេពន្ទវៈ អ្នកប្រព្រឹត្តគប្បីត្រូវចោទប្រកាន់ពីបទល្មើស ដូចមានចែងក្នុងមាត្រានេះ ( អំពើលក់-ដូរមនុស្សដោយមានគោលដៅ ) ព្រមទាំង បទល្មើស ការឈ្លានពានខាងផ្លូវភេទ ដែលជនល្មើសបានប្រព្រឹត្ត (រំលោភសេពសន្ទវៈ) ដូចមានការកំណត់និយមន័យ ក្នុងមាត្រាដែលពាក់ព័ន្ធ នៃច្បាប់ព្រហ្មទណ្ឌ ។

**" ផលិតរូបភាពអាសអាភាស "**

ជនល្មើស ទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ប្រសិនបើជនល្មើសប្រព្រឹត្តអំពើលក់-ដូរមនុស្ស ដោយមានគោលដៅ បង្កើត ឬ ចូលរួមបង្កើត រូបភាព និងសម្ភារៈអាសអាភាស ។ " រូបភាព និងសម្ភារៈ អាសអា ភាស " មាននិយមន័យចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

មិនតម្រូវឱ្យជនល្មើសបានទទួល ឬ មានចេតនាទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុ ណាមួយពីអំពើនេះទេ ។

**" រៀបអាពាហ៍ពិពាហ៍ ប្រឆាំងនឹងឆន្ទៈជនរងគ្រោះ "**

ជនល្មើសទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ លក់-ដូរមនុស្ស ដោយមានគោលដៅ បង្ខំជនរងគ្រោះឱ្យរៀបអាពាហ៍ពិពាហ៍ប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ។

មិនតម្រូវឱ្យជនល្មើសបានទទួល ឬ មានចេតនាទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុ ណាមួយពីអំពើនេះទេ ។

**" សុំកូន "**

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ លក់-ដូរមនុស្សដោយមានគោលដៅ ផ្តល់ ឬ លក់ ជនរងគ្រោះឱ្យអ្នកសុំកូន ហេតុដូច្នេះ ជនល្មើសគួរតែទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។ (ទាក់ទងនឹងការសុំកូន សូមមើលក្រមរដ្ឋប្បវេណី គន្ថីទី ៧ " ញាតិ " ជំពូកទី ៤ " ឪពុកម្តាយ និងកូន " ផ្នែកទី ២ " សុំកូន " ) ព្រមទាំង ច្បាប់ស្តីពីការសុំកូនអន្តរប្រទេស ។

មិនតម្រូវឱ្យជនល្មើសទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុ ណាមួយពីការសុំកូន ទេ ។ គ្រប់គ្រាន់ហើយដែលថា ជនល្មើសមានគោលដៅផ្តល់ជនរងគ្រោះដោយផ្ទាល់ ទៅកាន់ជនណាម្នាក់ទៀត ដែលសុំកូន ឬ ផ្តល់ជនរងគ្រោះទៅឱ្យជនណាម្នាក់ទៀត ដែលនឹងសម្រួលឱ្យមានការសុំកូន ។

**" ទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត "**

ពាក្យថា " ក្រោមទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត " រួមមានជាអាទិ៍ អំពើដែលមានរៀបរាប់ក្នុងមាត្រា ១០ កថាខ័ណ្ឌទី ៣ ដូចជា ការកេងប្រវ័ញ្ចន៍លើពេស្យាចារកម្មជនដទៃ រូបភាព និងសម្ភារៈអាសអាភាស

ពាណិជ្ជកម្មផ្លូវភេទ សេវា ឬ ពលកម្មដោយបង្ខំ ទាសភាព ឬ ការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុល សេរីភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬ ការដកហូតសរីរាង្គ ។ ចំពោះនិយមន័យ នៃពាក្យទាំងនេះ សូមមើលការពិភាក្សាក្នុងមាត្រា ១០ កថាខ័ណ្ឌទី ៣ ។ បន្ថែមពីនេះទៀត តុលាការក៏អាចមានឆន្ទានុសិទ្ធិ ពិចារណាទៅលើប្រភេទនៃ ការកេងប្រវ័ញ្ចផ្សេងទៀត ដែលមិនបានរៀបរាប់នៅទីនេះ ។ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើលក់-ដូរមនុស្សដោយមានគោលដៅទាំងនេះណាមួយ ហេតុដូច្នេះ ជនល្មើសគួរតែត្រូវផ្តន្ទាទោស យោងតាមមាត្រានេះ។

**<u>ការផ្តន្ទាទោស និងកត្តាស្ថានទម្ងន់ទោស</u>**

ប្រសិនបើជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ តុលាការត្រូវតែផ្តន្ទាទោសជនល្មើសដោយដាក់ពន្ធនាគារ ពី ៧ ( ប្រាំពីរ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ) ឆ្នាំ ។ ទោសបន្ថែម អាចក៏ត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ការផ្តន្ទាទោសដូចជាការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

យ៉ាងណាមិញ ប្រសិនបើ តុលាការរកឃើញមានកត្តាស្ថានទម្ងន់ទោសណាមួយ ដូចបានរៀបរាប់ខាងក្រោមនេះ ហេតុដូច្នេះ ការផ្តន្ទាទោសត្រូវកើនឡើង ពី ១៥ ( ដប់ប្រាំ) ឆ្នាំ ដល់ ២០ ( ម្ភៃ) ឆ្នាំ ។

ច្បាប់នេះ មិនតម្រូវឱ្យបំពេញតាមកត្តាស្ថានទម្ងន់ទោសទាំងអស់ទេ ។ ជាការគ្រប់គ្រាន់ហើយ ប្រសិនបើមានស្ថានទម្ងន់ទោសតែមួយប៉ុណ្ណោះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

**~ ជនរងគ្រោះជាអនីតិជន**

ប្រសិនបើ ជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

ប្រសិនបើ ជនល្មើសមានការគ្រប់គ្រង និងការត្រួតពិនិត្យ លើអនីតិជន ហេតុដូច្នេះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា ជនល្មើសបានដឹងពីអាយុរបស់អនីតិជន ។ សូមមើលការពិភាក្សា យោងតាមមាត្រា ៧ ( និយមន័យនៃអនីតិជន ) ខាងលើ ។

**~ អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើ ជនរងគ្រោះ**

ប្រសិនបើជនល្មើស គឺជាមន្ត្រីសាធារណៈ និងបានប្រព្រឹត្តអំពើដោយមធ្យោបាយ បំពានដោយអំណាច ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

" មន្ត្រីសាធារណៈ " មានន័យថា ជាមន្ត្រីរាជការ ឬ ពលរដ្ឋដែលត្រូវផ្តល់អាណត្តិឱ្យតាមរយៈការបោះឆ្នោត ។ ទាំងនេះរួមមាន : តួនាទីជាមន្ត្រីរដ្ឋាភិបាល នគរបាល យោធា គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន និងសាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យសាធារណៈ ឬ មជ្ឈមណ្ឌលសុខភាព និង បុគ្គលដែលកំពុងមានតួនាទីសាធារណៈដែលជាប់ឆ្នោត នៅកំរិតណាមួយជាអាទិ៍ ។

" ការបំពានដោយសិទ្ធិអំណាច " មានន័យដូចពាក្យ " ការបំពានអំណាច " ដូចត្រូវពិភាក្សា យោងតាមមាត្រា ៨ ពោលគឺ ជាស្ថានការណ៍ដែលមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលគេផ្តល់អាណត្តិបោះឆ្នោតឱ្យ បានប្រើប្រាស់តួនាទីរបស់ខ្លួន មិនសមរម្យ ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះស្រប នឹងនិយមន័យ ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ (សូមពិនិត្យមើល គន្ថីទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ កថាភាគទី ២ " ការរំលោភអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភដោយអំណាចនេះ ប្រើប្រាស់ដើម្បី កេងប្រវ័ញ្ចន៍ពីមនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយទទួលរងគ្រោះ ដើម្បីធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីដែលជនរងគ្រោះ នឹងមិនធ្វើដោយឆន្ទៈ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទាំងមូលបានបង្ហាញពីចេតនាយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយរបស់មន្ត្រីសាធារណៈ ក្នុងអំពើជួញដូរមនុស្ស ។

## ~ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង

ប្រសិនបើ ជនល្មើសបានប្រព្រឹត្តបទល្មើស ដោយជាផ្នែកមួយនៃក្រុមមានការចាត់តាំង ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៧៧ " ក្រុមមានការចាត់តាំង " មានន័យថា គឺជាការប្រមូលផ្តុំ ដែលបានបង្កើតឡើង ឬ ជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

ក្នុងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ មាននិយមន័យ ប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែតម្រូវបន្ថែមឱ្យក្រុមមានការចាត់តាំង ត្រូវតែបញ្ចូលមនុស្សពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ។ ឧទាហរណ៍ : អនុសញ្ញា អង្គការសហប្រជាជាតិ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័ន ឱ្យនិយមន័យ " ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង " ក្នុងមាត្រា ២ (ក) ថាជា " ក្រុមដែនមានរចនាសម្ព័ន្ធ ដែលមានគ្នា ពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណងបទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មួយ ឬ ច្រើន ដែលត្រូវធ្វើឡើងស្របទៅនឹង អនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ សម្ភារៈផ្សេងទៀត " ។

ដូច្នេះហើយ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានឱ្យនិយមន័យ " ក្រុម មានការចាត់តាំង " មានន័យថា ជាក្រុម ផ្លូវការ ឬ មិនផ្លូវការ ដែលមានគ្នាបីនាក់ ឬ ច្រើននាក់ជាងនេះ ដែលត្រូវបានបង្កើត ឡើងដើម្បីរៀបចំផែនការ ឬដើម្បីប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

**មាត្រា ១៦.- អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន**

**ជនណាដែលលក់-ដូរជនដទៃ ក្នុងគោលដៅប្រគល់ ឬ នាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។**

**ជនណាដែលលក់-ដូរជនដទៃ ក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ នាំជននោះ ទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខ័ណ្ឌទី ១ ខាងលើ ។**

**ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១៥ ( ដប់ប្រាំ ) ឆ្នាំ ទៅ ២០ ( ម្ភៃ ) ឆ្នាំ ក្នុងករណីដែល :**

**- ជនរងគ្រោះជាអនីតិជន ។**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។**

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះអំពើ លក់-ដូរមនុស្ស នៃជនណាម្នាក់ដោយមានគោលដៅនាំជននោះឆ្លងព្រំដែនអន្តរជាតិ ។ ជនល្មើស គួរទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ មិនមែនយោងតាមមាត្រា ១៣ ដល់មាត្រា ១៥ ។

ប្រសិនបើ ជនល្មើសមិនមានចេតនានាំយកជនរងគ្រោះឆ្លងដែនអន្តរជាតិ ហេតុដូច្នេះ គួរតែផ្តន្ទាទោស អំពើលក់-ដូរមនុស្ស យោងតាមមាត្រា ១៤ ( អំពើលក់-ដូរមនុស្ស ) ឬ មាត្រា ១៥ ( អំពើលក់-ដូរមនុស្ស ដោយមានគោលដៅ ) ។

បទល្មើសដែលមានចែងក្នុងមាត្រានេះមានធាតុផ្សំសំខាន់ៗពីរ ហើយត្រូវតែបំពេញតាមធាតុផ្សំទាំងពីរនេះ :

១) **អំពើលក់-ដូរមនុស្ស** ( សូមពិនិត្យមើលនិយមន័យនៅមាត្រា ១៣ )

ជនល្មើស ត្រូវតែបានប្រព្រឹត្តអំពើ លក់-ដូរមនុស្ស ដែលមានន័យថា ជនល្មើសត្រូវតែបំពេញ តាមលក្ខខណ្ឌទាំងអស់ ក្នុងនិយមន័យនៃអំពើ លក់-ដូរមនុស្ស ដូចមានចែង ក្នុងមាត្រា ១៣ ។ ( សូមពិនិត្យមើល និយមន័យនៅមាត្រា ១៣ សម្រាប់ព័ត៌មានលំអិត ) ។

២) **ដោយមានគោលបំណងនាំឆ្លងព្រំដែន**

ជនល្មើសត្រូវតែបានប្រព្រឹត្ត អំពើ លក់-ដូរមនុស្ស ដោយមានគោលដៅនាំជនរងគ្រោះ ឆ្លងព្រំដែនអន្តរជាតិ ។ ជនល្មើស មិនចាំបាច់ឆ្លង ឬ មានចេតនាឆ្លងព្រំដែនអន្តរជាតិដោយខ្លួនឯង អ្វីដែលសំខាន់គឺថា ជនល្មើស មានចេតនានាំយកជនរងគ្រោះឆ្លងដែន ។ មិនចាំបាច់តម្រូវឱ្យជនរងគ្រោះ ពិតប្រាកដបានឆ្លងដែន ។ ជាការគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនល្មើសនោះ បានមានចេតនានាំជនរងគ្រោះឆ្លងដែន ។

គួរកត់សំគាល់ថា មាត្រានេះ មិនសំដៅទៅលើអំពើ រត់ពន្ធ ឬ ដឹកជញ្ជូន ដោយខុសច្បាប់នូវជនណាម្នាក់ ដែលមានបំណងដោយស្ម័គ្រចិត្តឆ្លងកាត់ព្រំដែន ។ ដើម្បីឱ្យមានបទល្មើសក្នុងមាត្រានេះ ជនដែលគេកំពុងនាំឆ្លងដែន ត្រូវតែមកពី ឬ ធ្លាក់ចូលក្នុងស្ថានការណ៍ជួញដូរ ប្រឆាំងនឹងឆន្ទៈខ្លួន ។

ឧទាហរណ៍ : កម្មករជនជាតិកម្ពុជា ម្នាក់ចង់ទៅប្រទេសថៃ ដូច្នេះក៏ឱ្យប្រាក់ដល់អ្នករត់ពន្ធ ដើម្បីនាំគាត់ឆ្លងកាត់ព្រំដែន ក្នុងករណីដែលគាត់មានសេរីភាពទៅដោយខ្លួនឯង ដើម្បីស្វែងរកការងារ ។ នេះមិនមែនជាបទល្មើសជួញដូរទេ ហេតុដូច្នេះមិនអាចត្រូវផ្តន្ទាទោស ដោយច្បាប់នេះទេ ។[១៣] យ៉ាងណាមិញ ប្រសិនបើ ទៅដល់ប្រទេសថៃឡើង អ្នករត់ពន្ធ លក់កម្មករនេះ ឱ្យធ្វើពលកម្មដោយបង្ខំ នៅលើទូកនេសាទ ហេតុដូច្នេះ អំពើនេះបង្កើតឱ្យមានបទល្មើស ដូចមានចែងក្នុងមាត្រានេះ ។

### " នាំឆ្លងដែន "

យោងតាមមាត្រានេះ ពាក្យថា " នាំឆ្លងដែន " មានន័យដូចខាងក្រោម :

**១) " ក្នុងគោលដៅប្រគល់ ឬ នាំយកជននោះ ទៅក្រៅព្រះរាជាណាចក្រកម្ពុជា "**

បទប្បញ្ញត្តិនេះ ផ្តន្ទាទោសចេតនាក្នុងការនាំជនរងគ្រោះពីប្រទេសកម្ពុជា ទៅកាន់ប្រទេសក្រៅ ។

**២) " ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ នាំជននោះ ទៅប្រទេសផ្សេងទៀត "**

បទប្បញ្ញត្តិនេះ ផ្តន្ទាទោស ចេតនាណាមួយដូចខាងក្រោម :

- នាំជនរងគ្រោះពីប្រទេសក្រៅមួយ ទៅកាន់ប្រទេសក្រៅមួយផ្សេងទៀត
- នាំជនរងគ្រោះពីប្រទេសក្រៅ ទៅកាន់ប្រទេសកម្ពុជា

គួរតែអានមាត្រានេះ ជាមួយគ្នានឹងបទប្បញ្ញត្តិយុត្តាធិការនៃមាត្រា ២ និងមាត្រា ៣ ខាងលើ ។ ឧទាហរណ៍: មាត្រានេះ អាចត្រូវបានប្រើដើម្បីដាក់ទោសអំពើដែលកើតឡើងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលជនរងគ្រោះ ឬ ជនល្មើសជាពលរដ្ឋខ្មែរ ។ (សូមមើលការពិភាក្សា យោងតាមមាត្រា ៣ សម្រាប់ព័ត៌មានលំអិត )។ ដូចគ្នានេះដែរ ប្រសិនបើជនរងគ្រោះត្រូវបានផ្ទេរ រវាងប្រទេសក្រៅពីរ តាមនាវាដែលមានទង់ជាតិកម្ពុជា យោងតាមមាត្រា ២ យុត្តាធិការប្រទេសកម្ពុជា គឺជាយុត្តាធិការដ៏សមរម្យ ។ ( សូមមើលការពិភាក្សាយោងតាមមាត្រា ២ សម្រាប់ព័ត៌មានលំអិត ) ។

---

[១៣] អំពើនេះ អាចជាបទល្មើសយោងតាមច្បាប់ផ្សេងទៀត ដូចជាអំពើដែលទាក់ទងនឹងអន្តោប្រវេសន៍ ។

**ការផ្តន្ទាទោស និងកត្តាស្ថានទម្ងន់ទោស**

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ ជនល្មើសនោះត្រូវតែទទួលការផ្តន្ទាទោសជាប់ពន្ធនាគារ ពី ៧ ( ប្រាំពីរ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ) ឆ្នាំ ។ ទោសបន្ថែម អាចក៏ត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់ រួមមាន ការផ្តន្ទាទោសដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

យ៉ាងណាមិញ ប្រសិនបើ តុលាការរកឃើញមានកត្តាស្ថានទម្ងន់ទោសមួយ ដូចបានរៀបរាប់ខាងក្រោមនេះ ហេតុដូច្នេះការផ្តន្ទាទោស ត្រូវកើនឡើង ពី ១៥ ( ដប់ប្រាំ) ដល់ ២០ ( ម្ភៃ) ឆ្នាំ ។

ច្បាប់នេះ មិនតម្រូវឱ្យបំពេញ តាមកត្តាស្ថានទម្ងន់ទោសទាំងអស់ទេ ។ ជាការគ្រប់គ្រាន់ហើយ ដែលថាមានកត្តាស្ថានទម្ងន់ទោសតែមួយប៉ុណ្ណោះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

~ **ជនរងគ្រោះជាអនីតិជន**

ប្រសិនបើ ជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

ប្រសិនបើ ជនល្មើសមានការគ្រប់គ្រង និងការត្រួតពិនិត្យលើអនីតិជន ហេតុដូច្នេះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា ជនល្មើសបានដឹងពីអាយុរបស់អនីតិជន ។ សូមមើលការពិភាក្សា យោងតាមមាត្រា ៧ ( និយមន័យនៃអនីតិជន ) ខាងលើ ។

~ **អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើ ជនរងគ្រោះ**

ប្រសិនបើ ជនល្មើស គឺជាមន្ត្រីសាធារណៈ និងបានប្រព្រឹត្តអំពើដោយមធ្យោបាយ បំពានដោយអំណាច ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

" មន្ត្រីសាធារណៈ " មានន័យថា ជាមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលត្រូវផ្តល់អាណត្តិឱ្យតាមរយៈការបោះឆ្នោត ។ ទាំងនេះរួមមាន : តួនាទីជាមន្ត្រីរដ្ឋាភិបាល នគរបាល យោធា គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន និងសាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យសាធារណៈ ឬ មជ្ឈមណ្ឌលសុខភាព និង បុគ្គលដែលកំពុងមានតួនាទីសាធារណៈដែលជាប់ឆ្នោត នៅកំរិតណាមួយជាអាទិ៍ ។

" ការបំពានដោយសិទ្ធិអំណាច " មានន័យដូចពាក្យ " ការបំពានអំណាច " ដូចត្រូវពិភាក្សា យោងតាម មាត្រា ៨ ពោលគឺ ជាស្ថានការណ៍ដែលមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលគេផ្តល់អាណត្តិបោះឆ្នោតឱ្យ បានប្រើប្រាស់តួនាទីរបស់ខ្លួន មិនសមរម្យ ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះស្រប នឹងនិយមន័យដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ (សូមពិនិត្យមើល គន្ថីទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ " ការរំលោភអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភដោយអំណាចនេះ ប្រើប្រាស់ដើម្បីកេងប្រវ័ញ្ចន៍ពីមនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយទទួលរងគ្រោះ ដើម្បីធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីដែលជនរងគ្រោះនឹងមិនធ្វើដោយឆន្ទៈ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទាំងមូល បានបង្ហាញពីចេតនាយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយ របស់មន្ត្រីសាធារណៈ ក្នុងអំពើជួញដូរមនុស្ស ។

## ~ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង

ប្រសិនបើ ជនល្មើសបានប្រព្រឹត្តបទល្មើស ដោយជាផ្នែកមួយនៃក្រុមមានការចាត់តាំង ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៧៧ " ក្រុមមានការចាត់តាំង " មានន័យថា គឺជាការប្រមូលផ្តុំ ដែលបានបង្កើតឡើង ឬ ជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

ក្នុងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ មាននិយមន័យ ប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែតម្រូវបន្ថែមឱ្យក្រុមមានការចាត់តាំង ត្រូវតែបញ្ចូលមនុស្សពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ។ ឧទាហរណ៍ : អនុសញ្ញា អង្គការសហប្រជាជាតិ ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័ន ឱ្យនិយមន័យ " ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង " ក្នុងមាត្រា ២ (ក) ថាជា " ក្រុមដែលមានរចនាសម្ព័ន្ធ ដែលមានគ្នា ពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណងបទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មួយ ឬ ច្រើន ដែលត្រូវធ្វើឡើងស្របទៅនឹង អនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ សម្ភារៈផ្សេងទៀត " ។

ដូច្នេះហើយ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានឱ្យនិយមន័យ " ក្រុមមានការចាត់តាំង " មានន័យថា ជាក្រុម ផ្លូវការ ឬ មិនផ្លូវការ ដែលមានគ្នាបីនាក់ ឬ ច្រើននាក់ជាងនេះ ដែលត្រូវបានបង្កើត ឡើងដើម្បីរៀបចំផែនការ ឬដើម្បីប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

**មាត្រា ១៧.. ការដឹកជញ្ជូនដោយ[illegible]**

**ជនណាដែលដឹកជញ្ជូនជនដទៃ ដែលត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ឬ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ដោយដឹងថាជននោះត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ឬ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ក្នុង**

**គោលដៅដើម្បីស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។**

**ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១៥ ( ដប់ប្រាំ ) ឆ្នាំ ទៅ ២០ ( ម្ភៃ ) ឆ្នាំ ក្នុងករណីដែល :**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។**

មាត្រា ១៧ ចែងពីបទល្មើស និងផ្តន្ទាទោសជនណាដែលដឹកជញ្ជូនជនផ្សេងទៀត ដែលត្រូវគេ នាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនដោយមិនស្របច្បាប់ ក្នុងគោលដៅដើម្បីស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត ។

បទល្មើសដែលមានចែងក្នុងមាត្រានេះ មានធាតុផ្សំសំខាន់ៗ បី ដែលធាតុផ្សំទាំង បី នេះ ត្រូវបំពេញ :

១) **ជនល្មើសដឹកជញ្ជូនជនផ្សេងទៀត**

ដឹកជញ្ជូន មានន័យថា ជាការនាំយកជនផ្សេងទៀត ពីទីកន្លែងមួយទៅកាន់កន្លែងមួយផ្សេងទៀត តាមប្រភេទយានយន្តណាមួយ ឬ អមដំណើរជននោះដោយថ្មើរជើង ។

២) **ជនល្មើសដឹងថា ជនដែលខ្លួនដឹកជញ្ជូន ត្រូវបាននាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ដោយខុសច្បាប់** ។

ដើម្បីឱ្យទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ អ្នកដឹកជញ្ជូនតម្រូវឱ្យបានដឹងថា ជនដែលគាត់ ដឹកជញ្ជូន ត្រូវបាននាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនដោយខុសច្បាប់ ហើយអ្នកដឹកជញ្ជូននោះ មានគោលដៅ ដើម្បីស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទម្រង់នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ។

ឧទាហរណ៍ : **ក** បានជ្រើសរើសដោយខុសច្បាប់ ឬ លក់-ដូរ **ខ** ។ បន្ទាប់មក **ក** បានជួលឱ្យ **គ** ដឹកជញ្ជូន **ខ** យកទៅកាន់ទីកន្លែងណាមួយ ។

ក្នុងករណីខាងលើនេះ បើ **គ** បានដឹងថា **ខ** ត្រូវបាន **ក** ជ្រើសរើសដោយខុសច្បាប់ ឬ លក់-ដូរ ហើយ **គ** នៅតែដឹកជញ្ជូន **ខ** ទៀត ក្នុងគោលដៅ ដើម្បីស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទម្រង់នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត នោះ **គ** ត្រូវទទួលការផ្តន្ទាទោសទៅតាមមាត្រានេះ ។ ប៉ុន្តែបើក្នុងករណី **គ** ពុំបានដឹងថា **ខ** ត្រូវបាន **ក** ជ្រើសរើសដោយខុសច្បាប់ ឬ លក់-ដូរ នោះទេ នោះ **គ** ពុំត្រូវទទួលទោសតាមមាត្រានេះឡើយ ។

**" ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ឬ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន "**

" ការនាំយកចេញដោយមិនស្របច្បាប់ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ៨

" ការជ្រើសរើសដោយមិនស្របច្បាប់ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១២

" លក់-ដូរ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១៣

" ការដឹកជញ្ជូន " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១៧

៣) **ជនល្មើសដឹកជញ្ជូនជនដទៃទៀត ដោយមានគោលដៅ.....**

បន្ថែមទៅនឹងការប្រព្រឹត្តអំពើ ដឹកជញ្ជូន ជនល្មើសត្រូវតែមានចេតនាជាក់លាក់ក្នុងការប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ។ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនតម្រូវថាជនល្មើសបានប្រព្រឹត្តអំពើទាំងនេះ ដោយជោគជ័យទេ ។ ប៉ុន្តែគ្រាន់តែ តម្រូវថាជនល្មើសមានចេតនាប្រព្រឹត្តដូច្នេះ ។ ដូចគ្នានេះដែរ ច្បាប់នេះ មិនតម្រូវថាជនល្មើសមានគោលដៅច្រើនជាងមួយ ដូចខាងក្រោម ។ មានន័យថា មានគោលដៅតែមួយ គឺគ្រប់គ្រាន់ហើយ ។

បន្ថែមពីនេះទៀត គួរកត់សំគាល់ថា អំពើ ដឹកជញ្ជូន ត្រូវតែធ្វើឡើងដោយមានគោលដៅ ។ មាត្រានេះ អាចអនុវត្តបានដោយមិនចាំបាច់ ជនដែលគេដឹកជញ្ជូន ត្រូវនាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនដោយខុសច្បាប់ ក្នុងគោលដៅដើម្បីស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទំរង់នៃការកេងប្រវ័ញ្ចន៏ផ្សេងទៀត ។ ឧទាហរណ៍ : ប្រសិនបើ "ខ" គឺជាជនរងគ្រោះ ដោយការនាំយកចេញជាធម្មតា ដែលមិនផ្សំឱ្យមានគោលដៅប្រព្រឹត្តបទល្មើសណាមួយលើសពីនេះ ប៉ុន្តែត្រូវបានដឹកជញ្ជូន ដោយ "ក" ដែលមានគោលដៅកេងប្រវ័ញ្ចន៏ ពី "ខ" ហេតុដូច្នេះ "ក" នៅតែទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។

## " ស្វែងរកប្រយោជន៍ "

ពាក្យថា " ស្វែងរកប្រយោជន៍ " ដូចមានប្រើក្នុងមាត្រានេះ មានន័យថា ជនល្មើសបានធ្វើការដឹកជញ្ជូនដើម្បីផ្តោះប្តូរ ឬ ដើម្បីទទួលយកវត្ថុមានតម្លៃអ្វីមួយ ដែលរួមមានជាអាទិ៍ ប្រាក់ របស់មានតម្លៃ ផ្សេងទៀត (មាស គ្រឿងអលង្កការ ។ល។) សេវាកម្ម ឬ មនុស្ស ។ ប្រសិនបើជនល្មើសបានប្រព្រឹត្តអំពើលក់-ដូរមនុស្ស ក្នុងគោលដៅនេះ ហេតុដូច្នេះជនល្មើសត្រូវទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ។

## " ឈ្លានពានខាងផ្លូវភេទ "

ពាក្យថា " ឈ្លានពានខាងផ្លូវភេទ " ដូចមានប្រើក្នុងមាត្រានេះ មានន័យថា ជនល្មើសបានធ្វើការដឹកជញ្ជូនដោយមានគោលដៅប្រព្រឹត្តបទល្មើសផ្លូវភេទប្រឆាំងនឹងជនរងគ្រោះ ដូចជា អំពើរំលោភ សេពសន្ថវៈ ឬ អំពើបំពានផ្លូវភេទផ្សេងទៀត (សូមមើលនិយមន័យនៃបទល្មើសទាំងនេះ យោងតាមច្បាប់ព្រហ្មទណ្ឌ ដែលកំពុងអនុវត្ត ) ឬ ក្នុងករណីដែលអនីតិជនអាយុក្រោម ១៥ ឆ្នាំ អំពើអាស ដូចមានការកំណត់និយមន័យ ក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ ដឹកជញ្ជូន សម្រាប់គោលដៅនេះ ហេតុដូច្នេះ ជនល្មើសគួរត្រូវទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ ដឹកជញ្ជូនដោយមានគោលដៅនេះ និងបានធ្វើការឈ្លានពានខាងផ្លូវភេទ ជនល្មើសអាចត្រូវទទួលការចោទប្រកាន់ពីបទល្មើសទាំងពីរ ។ ឧទាហរណ៍ : ប្រសិនបើ អ្នកប្រព្រឹត្តអំពើ ដឹកជញ្ជូន នូវជនណាម្នាក់ដោយមានគោលដៅរំលោភសេពសន្ថវៈ លើជនរងគ្រោះនិងក្រោយមកបានប្រព្រឹត្តអំពើរំលោភសេព សន្ថវៈ អ្នកប្រព្រឹត្តអាចត្រូវចោទប្រកាន់ពីបទល្មើស ដូចមានចែងក្នុងមាត្រានេះ ( ការដឹកជញ្ជូនដោយមានគោលដៅ ) ព្រមទាំងបទល្មើសឈ្លានពានខាងផ្លូវភេទ ដែលជនល្មើសបានប្រព្រឹត្ត ( រំលោភសេពសន្ថវៈ ) ដូចមានការកំណត់ និយម ន័យក្នុងមាត្រាដែលពាក់ព័ន្ធ នៃច្បាប់ព្រហ្មទណ្ឌ ។

**" ផលិតរូបភាពអាសអាភាស "**

ជនល្មើស ទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ ដឹកជញ្ជូនដោយ មានគោលដៅ បង្កើត ឬ ចូលរួមបង្កើត រូបភាព និងសម្ភារៈអាសអាភាស ។ " រូបភាព និងសម្ភារៈអាសអាភាស " មាន និយមន័យចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

មិនតម្រូវឱ្យជនល្មើសបានទទួល ឬ មានចេតនាទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុណាមួយ ពីអំពើនេះទេ ។

**" រៀបអាពាហ៍ពិពាហ៍ ប្រឆាំងនឹងឆន្ទៈជនរងគ្រោះ "**

ជនល្មើស ទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ប្រសិនបើជនល្មើសប្រព្រឹត្តអំពើ ដឹកជញ្ជូនដោយមាន គោលដៅ បង្ខំជនរងគ្រោះឱ្យរៀបអាពាហ៍ពិពាហ៍ប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ។

មិនតម្រូវឱ្យជនល្មើសបានទទួល ឬ មានចេតនាទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុណាមួយពីអំពើនេះទេ ។

**" សុំកូន "**

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ ដឹកជញ្ជូនដោយមានគោលដៅ ផ្តល់ ឬ លក់ជនរងគ្រោះ ឱ្យអ្នកសុំកូន ហេតុដូច្នេះ ជនល្មើសគួរតែទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។ ( ទាក់ទងនឹងការសុំកូន សូមមើលក្រម រដ្ឋប្បវេណី គន្ថីទី ៧ " ញាតិ " ជំពូកទី ៤ " ឪពុកម្តាយ និងកូន " ផ្នែកទី ២ " សុំកូន " ) ព្រមទាំង ច្បាប់ ស្តីពីការ សុំកូនអន្តរប្រទេស ។

មិនតម្រូវឱ្យជនល្មើសទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុ ណាមួយពីការ សុំកូនទេ ។

គ្រប់គ្រាន់ហើយដែលថា ជនល្មើសមានគោលដៅផ្តល់ជនរងគ្រោះដោយផ្ទាល់ ទៅកាន់ជនណាម្នាក់ទៀត ដែលសុំកូន ឬ ផ្តល់ជនរងគ្រោះ ទៅឱ្យជនណាម្នាក់ទៀត ដែលនឹងសម្រួលឱ្យមានការសុំកូន ។

**" ទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត "**

ពាក្យថា " ក្រោមទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត " រួមមានជាអាទិ៍ អំពើដែលមានរៀបរាប់ ក្នុងមាត្រា ១០ កថាខ័ណ្ឌទី ៣ ដូចជា ការកេងប្រវ័ញ្ចន៍លើពេស្យាចារកម្មជនដទៃ រូបភាព និងសម្ភារៈអាសអាភាស

ពាណិជ្ជកម្មផ្លូវភេទ សេវា ឬ ពលកម្មដោយបង្ខំ ទាសភាព ឬ ការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុល សេរីភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬ ការដកហូតសរីរាង្គ ។ ចំពោះ និយមន័យនៃពាក្យទាំងនេះ សូមមើលការពិភាក្សាក្នុងមាត្រា ១០ កថាខ័ណ្ឌទី ៣ ។ បន្ថែមពីនេះទៀត តុលាការក៏អាចមានឆន្ទានុសិទ្ធិពិចារណាទៅលើ ប្រភេទនៃការកេងប្រវ័ញ្ចផ្សេងទៀត ដែលមិនបានរៀបរាប់នៅទីនេះ ។ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើដឹកជញ្ជូនដោយមានគោលដៅ ទាំងនេះណាមួយ ហេតុដូច្នេះ ជនល្មើសគួរតែត្រូវផ្តន្ទាទោស យោងតាមមាត្រានេះ ។

**<u>ការផ្តន្ទាទោស និងកត្តាស្ថានទម្ងន់ទោស</u>**

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ តុលាការត្រូវតែផ្តន្ទាទោស ជនល្មើស ដោយដាក់ពន្ធនាគារ ពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។ ទោសបន្ថែម អាចក៏ត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬនិយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ការផ្តន្ទាទោសដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

យ៉ាងណាមិញ ប្រសិនបើ តុលាការរកឃើញមានកត្តាស្ថានទម្ងន់ទោសណាមួយ ដូចបានរៀបរាប់ខាងក្រោមនេះ ហេតុដូច្នេះ ការផ្តន្ទាទោសត្រូវកើនឡើង ពី ១៥ ( ដប់ប្រាំ) ឆ្នាំ ដល់ ២០ ( ម្ភៃ) ឆ្នាំ ។

ច្បាប់នេះ មិនតម្រូវឱ្យបំពេញតាមកត្តាស្ថានទម្ងន់ទោស ទាំងអស់ទេ ។ ជាការគ្រប់គ្រាន់ហើយ ប្រសិនបើមានស្ថានទម្ងន់ទោសតែមួយប៉ុណ្ណោះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

**~ អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ**

ប្រសិនបើ ជនល្មើស គឺជាមន្ត្រីសាធារណៈ និងបានប្រព្រឹត្តអំពើដោយមធ្យោបាយ បំពានដោយអំណាច ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

" មន្ត្រីសាធារណៈ " មានន័យថា ជាមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលត្រូវផ្តល់អាណត្តិឱ្យតាមរយៈការបោះឆ្នោត ។ ទាំងនេះរួមមាន : តួនាទីជាមន្ត្រីរដ្ឋាភិបាល នគរបាល យោធា គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន និងសាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យសាធារណៈ ឬ មជ្ឈមណ្ឌលសុខភាព និង បុគ្គលដែលកំពុងមានតួនាទីសាធារណៈដែលជាប់ឆ្នោត នៅកំរិតណាមួយជាអាទិ៍ ។

" ការបំពានដោយសិទ្ធិអំណាច " មានន័យដូចពាក្យ " ការបំពានអំណាច " ដូចត្រូវពិភាក្សា យោងតាម មាត្រា ៨ ពោលគឺ ជាស្ថានការណ៍ដែលមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលគេផ្តល់អាណត្តិបោះឆ្នោតឱ្យបានប្រើប្រាស់តួនាទីរបស់ខ្លួន មិនសមរម្យ ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះស្រប នឹងនិយមន័យដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ (សូមពិនិត្យមើល គន្លីទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ កថាភាគទី ២ " ការរំលោភអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភដោយអំណាចនេះ ប្រើប្រាស់ដើម្បីកេងប្រវ័ញ្ចន៍ពីមនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយទទួលរងគ្រោះ ដើម្បីធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីដែលជនរងគ្រោះ នឹងមិនធ្វើដោយឆន្ទៈ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទាំងមូលបានបង្ហាញពីចេតនាយ៉ាងច្បាស់ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយរបស់មន្ត្រីសាធារណៈ ក្នុងអំពើជួញដូរមនុស្ស ។

## ~ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង

ប្រសិនបើ ជនល្មើសបានប្រព្រឹត្តបទល្មើស ដោយជាផ្នែកមួយនៃក្រុមមានការចាត់តាំង ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៧៧ " ក្រុមមានការចាត់តាំង " មានន័យថា គឺជាការប្រមូលផ្តុំ ដែលបានបង្កើតឡើង ឬ ជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

ក្នុងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ មាននិយមន័យ ប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែតម្រូវបន្ថែមឱ្យក្រុមមានការចាត់តាំង ត្រូវតែបញ្ចូលមនុស្សពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ។ ឧទាហរណ៍ : អនុសញ្ញា អង្គការសហប្រជាជាតិ ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័នឱ្យនិយមន័យ " ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង " ក្នុងមាត្រា ២ (ក) ថាជា " ក្រុមដែលមានរចនាសម្ព័ន្ធ ដែលមានគ្នា ពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណងបទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មួយ ឬ ច្រើន ដែលត្រូវធ្វើឡើងស្របទៅនឹង អនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ សម្ភារៈផ្សេងទៀត " ។

ដូច្នេះហើយ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានឱ្យនិយមន័យ " ក្រុមមានការចាត់តាំង " មានន័យថា ជាក្រុម ផ្លូវការ ឬ មិនផ្លូវការ ដែលមានគ្នាបីនាក់ ឬ ច្រើននាក់ជាងនេះ ដែលត្រូវបានបង្កើត ឡើងដើម្បីរៀបចំផែនការ ឬដើម្បីប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

**មាត្រា ១៨.. អំពើនាំឆ្លងដែន**

**ជនណាដែលនាំយកជនដទៃ ដោយដឹងថាជននោះ ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។**

**ជនណាដែលនាំយកជនដទៃ ដោយដឹងថាជននោះ ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជាទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខ័ណ្ឌទី ១ ខាងលើ ។**

**ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១៥ ( ដប់ប្រាំ ) ឆ្នាំ ទៅ ២០ ( ម្ភៃ ) ឆ្នាំ ក្នុងករណីដែល :**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។**

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះការដឹកជញ្ជូនជនណាម្នាក់ឆ្លងកាត់ព្រំដែនអន្តរ-ជាតិ ក្នុងករណីជនល្មើសដឹងថា ជននោះត្រូវបាននាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនដោយខុសច្បាប់ ។

ប្រសិនបើ ជនល្មើសមិនបានដឹកជញ្ជូនជនរងគ្រោះ ឆ្លងកាត់ព្រំដែនអន្តរជាតិ ប៉ុន្តែ បែរជាដឹកជញ្ជូនជននោះ ដោយមានគោលដៅកេងប្រវ័ញ្ចន៍ ហេតុដូច្នេះ អំពើនេះអាចត្រូវផ្តន្ទាទោស យោងតាមមាត្រា ១៧ ( ការដឹកជញ្ជូន ដោយមានគោលដៅ ) ។

បទល្មើសដែលមានចែងក្នុងមាត្រានេះ មានធាតុផ្សំសំខាន់ៗ បី ដែលធាតុផ្សំទាំងអស់ ត្រូវបំពេញ :

១) **ជនល្មើសដឹកជញ្ជូនជនដទៃ**

ដឹកជញ្ជូនមានន័យថា ជាការនាំយកជនផ្សេងទៀត ពីទីកន្លែងមួយទៅកាន់កន្លែងមួយផ្សេងទៀត តាមប្រភេទយានយន្តណាមួយ ដោយអមដំណើរជននោះដោយថ្មើរជើង ឬ នាំជននោះឆ្លងកាត់ព្រំដែន និងធានាថាជននោះឆ្លងកាត់ព្រំដែន ។

២) **ជនល្មើសដឹងថា ជនដែលខ្លួនដឹកជញ្ជូន ត្រូវបាននាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ដោយខុសច្បាប់** ។

ដើម្បីឱ្យទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ អ្នកដឹកជញ្ជូន បាននាំយកជនរងគ្រោះចេញដោយឆ្លងកាត់ព្រំដែនអន្តរជាតិ ហើយជនដែលដឹកជញ្ជូននោះ បានដឹងថា ជនដែលគាត់ដឹកជញ្ជូនឆ្លងកាត់ព្រំដែនអន្តរជាតិនោះ ត្រូវបានគេ នាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនដោយខុសច្បាប់ ។

ឧទាហរណ៍ : **ក** បានជ្រើសរើសដោយខុសច្បាប់ ឬ លក់-ដូរ **ខ** ។ បន្ទាប់មក **ក** បានជួលឱ្យ **គ** ដឹកជញ្ជូន **ខ** យកទៅកាន់ប្រទេសថៃ ។

ក្នុងករណីខាងលើនេះ បើ ក បានដឹងថា ខ ត្រូវបាន ក ជ្រើសរើសដោយខុសច្បាប់ ឬ លក់-ដូរ ហើយ ត នៅតែដឹកជញ្ជូន ខ ឆ្លងដែនអន្តរជាតិទៀត នោះ ត ត្រូវទទួលការផ្តន្ទាទោសទៅតាមមាត្រានេះ ។ ប៉ុន្តែបើក្នុងករណី ត ពុំបានដឹងថា ខ ត្រូវបាន ក ជ្រើសរើសដោយខុសច្បាប់ ឬ លក់-ដូរ នោះទេ នោះ ត ពុំត្រូវទទួលទោសតាមមាត្រានេះឡើយ ។

" **ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន** "

" ការនាំយកចេញដោយមិនស្របច្បាប់ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ៨

" ការជ្រើសរើសដោយមិនស្របច្បាប់ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១២

" លក់-ដូរ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១៣

" ការដឹកជញ្ជូន " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១៧

៣) **ឆ្លងកាត់ព្រំដែនអន្តរជាតិ**

ជនល្មើសត្រូវតែដឹកជញ្ជូនជនរងគ្រោះ ឆ្លងកាត់ព្រំដែនអន្តរជាតិ ឬ ( តាមរយៈការអនុវត្តមាត្រា ៤ កថាខ័ណ្ឌទី ១ ) ដែលប៉ុនប៉ងប្រព្រឹត្តដូច្នេះ ។

គួរកត់សំគាល់ថា មាត្រានេះ មិនសំដៅទៅលើ អំពើរត់ពន្ធ ឬ ដឹកជញ្ជូន ខុសច្បាប់នូវជនណាម្នាក់ដែលមានបំណងដោយស្ម័គ្រចិត្តឆ្លងកាត់ព្រំដែន ។ ដើម្បីឱ្យមានបទល្មើស ក្នុងមាត្រានេះ ជនដែលគេកំពុងនាំឆ្លងដែនត្រូវតែមកពី ឬ ធ្លាក់ចូលក្នុងស្ថានការណ៍ ជួញដូរ ។

ឧទាហរណ៍ ៖ កម្មករជនជាតិកម្ពុជាម្នាក់ ចង់ទៅប្រទេសថៃ ដូច្នេះក៏ឱ្យប្រាក់ដល់អ្នករត់ពន្ធ ដើម្បីនាំគាត់ឆ្លងកាត់ព្រំដែន ក្នុងករណីដែលគាត់មានសេរីភាព ទៅដោយខ្លួនឯង ដើម្បីស្វែងរកការងារ ។ នេះមិនមែនជាបទល្មើសជួញដូរទេ ហេតុដូច្នេះមិនអាចត្រូវផ្តន្ទាទោស ដោយច្បាប់នេះទេ ។ យ៉ាងណាមិញ ប្រសិនបើ អ្នករត់ពន្ធត្រូវបានគេជួលឱ្យដឹកជញ្ជូន ជនដែលត្រូវបាននាំយកចេញដោយខុសច្បាប់ ឆ្លងកាត់ព្រំដែន ហើយអ្នកដឹកជញ្ជូននោះ ដឹងអំពីរឿងនេះ ហេតុដូច្នេះ អំពើនេះ បង្កើតឱ្យមានបទល្មើស ដូចមានចែងក្នុងមាត្រានេះ ។

" **នាំឆ្លងដែន** "

យោងតាមមាត្រានេះ ពាក្យថា " នាំឆ្លងដែន " មានន័យដូចខាងក្រោម ៖

" **ក្នុងគោលដៅប្រគល់ ឬ នាំយកជននោះ ទៅក្រៅព្រះរាជាណាចក្រកម្ពុជា** "

បទប្បញ្ញត្តិនេះ ផ្តន្ទាទោស ចេតនាក្នុងការនាំជនរងគ្រោះពីប្រទេសកម្ពុជាទៅកាន់ប្រទេសក្រៅ ។

" **ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ នាំជននោះ ទៅប្រទេសផ្សេងទៀត** "

បទប្បញ្ញត្តិនេះ ផ្ដន្ទាទោស ចេតនាណាមួយដូចខាងក្រោម :

- នាំជនរងគ្រោះពីប្រទេសក្រៅមួយ ទៅកាន់ប្រទេសក្រៅមួយផ្សេងទៀត
- នាំជនរងគ្រោះពីប្រទេសក្រៅ ទៅកាន់ប្រទេសកម្ពុជា

គួរតែអានមាត្រានេះ ជាមួយគ្នានឹងបទប្បញ្ញត្តិយុត្តាធិការ នៃមាត្រា ២ និងមាត្រា ៣ ខាងលើ ។ ឧទាហរណ៍ : មាត្រានេះ អាចត្រូវបានប្រើដើម្បីដាក់ទោសអំពើដែលកើតឡើង នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលជនរងគ្រោះ ឬ ជនល្មើសជាពលរដ្ឋខ្មែរ ។ ( សូមមើលការពិភាក្សា យោងតាមមាត្រា ៣ សម្រាប់ព័ត៌មានលំអិត ) ។ ដូចគ្នានេះដែរ ប្រសិនបើ ជនរងគ្រោះត្រូវបានផ្ទេរ រវាងប្រទេសក្រៅពីរ តាមនាវា ដែលមានទង់ជាតិកម្ពុជា យោងតាមមាត្រា ២ យុត្តាធិការប្រទេសកម្ពុជា គឺជាយុត្តាធិការដ៏សមរម្យ ។ ( សូមមើលការពិភាក្សាយោងតាមមាត្រា ២ សម្រាប់ព័ត៌មានលំអិត ) ។

**<u>ការផ្ដន្ទាទោស និងកត្តាស្ថានទម្ងន់ទោស</u>**

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ ជនល្មើសនោះត្រូវតែទទួលការផ្ដន្ទាទោសជាប់ពន្ធនាគារ ពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។ ទោសបន្ថែម អាចក៏ត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាច ផ្ដន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់ រួមមាន ការផ្ដន្ទាទោសដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

យ៉ាងណាមិញ ប្រសិនបើ តុលាការរកឃើញមានកត្តាស្ថានទម្ងន់ទោសមួយ ដូចបានរៀបរាប់ខាងក្រោមនេះ ហេតុដូច្នេះ ការផ្ដន្ទាទោសត្រូវកើនឡើង ពី ១៥ ( ដប់ប្រាំ ) ដល់ ២០ ( ម្ភៃ ) ឆ្នាំ ។

ច្បាប់នេះមិនតម្រូវឱ្យបំពេញតាមកត្តាស្ថានទម្ងន់ទោសទាំងអស់ទេ ។ ជាការគ្រប់គ្រាន់ហើយ ដែលថា មានកត្តាស្ថានទម្ងន់ទោសតែមួយប៉ុណ្ណោះ ជនល្មើស ត្រូវទទួលការផ្ដន្ទាទោសដ៏ធ្ងន់ធ្ងរ ។

**- អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ**

ប្រសិនបើ ជនល្មើស គឺជាមន្ត្រីសាធារណៈ និងបានប្រព្រឹត្តអំពើដោយមធ្យោបាយ បំពានដោយអំណាច ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្ដន្ទាទោសដ៏ធ្ងន់ធ្ងរ ។

" មន្ត្រីសាធារណៈ " មានន័យថា ជាមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលត្រូវផ្ដល់អាណត្តិឱ្យតាមរយៈការ

បោះឆ្នោត ។ ទាំងនេះរួមមាន : តួនាទីជាមន្ត្រីរដ្ឋាភិបាល នគរបាល យោធា គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន និងសាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យសាធារណៈ ឬ មជ្ឈមណ្ឌលសុខភាព និង បុគ្គលដែលកំពុងមានតួនាទីសាធារណៈដែលជាប់ឆ្នោត នៅកម្រិតណាមួយជាអាទិ៍ ។

" ការបំពានដោយសិទ្ធិអំណាច " មានន័យដូចពាក្យ " ការបំពានអំណាច " ដូចត្រូវពិភាក្សាយោងតាមមាត្រា ៨ ពោលគឺ ជាស្ថានការណ៍ដែលមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលគេផ្តល់អាណត្តិបោះឆ្នោតឱ្យ បានប្រើប្រាស់តួនាទីរបស់ខ្លួន មិនសមរម្យ ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះស្របនឹងនិយមន័យដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ (សូមពិនិត្យមើល គន្លឹះទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ " ការរំលោភអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភដោយអំណាចនេះ ប្រើប្រាស់ដើម្បី កេងប្រវ័ញ្ចន៍ពីមនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយទទួលរងគ្រោះ ដើម្បីធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីដែលជនរងគ្រោះ នឹងមិនធ្វើដោយឆន្ទៈ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទាំងមូលបានបង្ហាញពីចេតនាយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយរបស់មន្ត្រីសាធារណៈ ក្នុងអំពើជួញដូរមនុស្ស ។

## ~ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង

ប្រសិនបើ ជនល្មើស បានប្រព្រឹត្តបទល្មើស ដោយជាផ្នែកមួយនៃក្រុមមានការចាត់តាំង ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៧៧ " ក្រុមមានការចាត់តាំង " មានន័យថា គឺជាការប្រមូលផ្តុំ ដែលបានបង្កើតឡើង ឬ ជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

ក្នុងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ មាននិយមន័យ ប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែតម្រូវបន្ថែមឱ្យក្រុមមានការចាត់តាំង ត្រូវតែបញ្ចូលមនុស្សពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ។ ឧទាហរណ៍ : អនុសញ្ញា អង្គការសហប្រជាជាតិ ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័ន ឱ្យនិយមន័យ " ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង " ក្នុងមាត្រា ២ (ក) ថាជា " ក្រុមដែលមានរចនាសម្ព័ន្ធ ដែលមានគ្នា ពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណងបទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មួយ ឬ ច្រើន ដែលត្រូវធ្វើឡើងស្របទៅនឹង អនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ សម្ភារៈផ្សេងទៀត " ។

ដូច្នេះហើយ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានឱ្យនិយមន័យ " ក្រុមមានការចាត់តាំង " មានន័យថា ជាក្រុម ផ្លូវការ ឬ មិនផ្លូវការ ដែលមានគ្នាបីនាក់ ឬ ច្រើននាក់ជាងនេះ ដែលត្រូវបានបង្កើត ឡើងដើម្បីរៀបចំផែនការ ឬដើម្បីប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

**មាត្រា ១៩.. ការទទួលយកមនុស្សដោយមានគោលដៅ**

**ជនណាដែលទទួល ផ្តល់ជម្រក ឬ លាក់បំពួនជនណាមួយ ដែលបានមកពីអំពើនាំយកចេញដោយមិនស្រប ច្បាប់ ឬ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនក្នុងគោលដៅដើម្បីស្វែងរកប្រយោជន៍ ឈ្នួញពាណិជ្ជកម្មផ្លូវភេទ ផលិតរូបភាពអាសអាភាស អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទម្រង់នៃការកេងប្រវ័ញ្ចដទៃផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ( ប្រាំពីរ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ) ឆ្នាំ ។**

**ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ ( ដប់ប្រាំ) ឆ្នាំ ទៅ ២០ ( ម្ភៃ) ឆ្នាំ ក្នុងករណីដែល:**

**- ជនរងគ្រោះជាអនីតិជន ។**

**-អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ។**

**- អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។**

មាត្រានេះ ចែងពីបទល្មើស និងផ្តន្ទាទោសជនណាដែលទទួល ផ្តល់ជម្រក ឬ លាក់បំពួនជនផ្សេងទៀត ដែលត្រូវបាននាំចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនដោយមិនស្របច្បាប់ ក្នុងគោលដៅដើម្បីស្វែងរកប្រយោជន៍ ឈ្នួញពាណិជ្ជកម្មផ្លូវភេទ ផលិតរូបភាពអាសអាភាស អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទម្រង់នៃការកេងប្រវ័ញ្ចដទៃផ្សេងទៀត ។

បទល្មើសដែលមានចែងក្នុងមាត្រានេះ មានធាតុផ្សំសំខាន់ៗ បី ដែលធាតុផ្សំទាំងអស់នេះ ត្រូវបំពេញ :

១) **ជនល្មើសទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនណាមួយ**

ជនល្មើស ត្រូវផ្តន្ទាទោសយោងតាមមាត្រានេះ ប្រសិនបើ ជននោះ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនរងគ្រោះ ក្នុងគោលដៅកេងប្រវ័ញ្ច ។

**" ជនល្មើសទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនណាមួយ "**

" ទទួល " មានន័យថា ទទួលយក ឬ ការទទួលបាន

" ផ្តល់ជម្រក " មានន័យថា ការផ្តល់ជម្រកឱ្យជនណាមួយផ្សេងទៀត

" លាក់បំពួន " មានន័យថា ការលាក់រូបកាយជនណាមួយផ្សេងទៀត ( ឧទាហរណ៍ : ដាក់ជនរងគ្រោះក្នុងកន្លែងសំងាត់ ដែលមិនអាចត្រូវគេឃើញ ឬ រកឃើញ ) ឬ តាមមធ្យោបាយផ្សេងទៀត ដូចជាការបោកបញ្ឆោត ( ឧទាហរណ៍ : កុហកតតិយជន អំពីអត្តសញ្ញាណ របស់ជនរងគ្រោះ ) ។

២) **ជនដែលត្រូវបានគេ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ដោយជនល្មើស ពីមុនត្រូវបានគេនាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ដោយខុសច្បាប់ ។**

បទល្មើសនេះ អនុវត្ត ក្នុងករណីដែល**ជនរងគ្រោះដែលត្រូវបានគេ ទទួលយក ផ្តល់ជម្រក ឬ លាក់បំពួន ដោយជនល្មើស ដែលពីមុនឡើយជនរងគ្រោះនោះ ត្រូវបានគេ នាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ដោយមិនស្របច្បាប់ ។**

ដើម្បីឱ្យមានទទួលខុសត្រូវយោងតាមមាត្រានេះ ជនល្មើស **មិន**តម្រូវឱ្យបានដឹងថា ជនដែលគាត់ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ត្រូវបាននាំយក ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនដោយខុសច្បាប់ ។ អ្វីដែលសំខាន់គឺ គោលដៅរបស់ជនល្មើស ក្នុងការទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនរងគ្រោះ ។ ហេតុដូច្នេះ ប្រសិនបើ ជនល្មើស ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនណាម្នាក់ ក្នុងគោលដៅកេងប្រវ័ញ្ចនី ប៉ុន្តែមិនបានដឹងថា ជននោះត្រូវបាននាំយកដោយខុសច្បាប់ ហេតុដូច្នេះ ជនល្មើសនៅតែទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។

**" ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន "**

" ការនាំយកចេញដោយមិនស្របច្បាប់ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ៨

" ការជ្រើសរើសដោយមិនស្របច្បាប់ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១២

" លក់-ដូរ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១៣

" ការដឹកជញ្ជូន " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១៧

៣) **ជនល្មើស ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនដទៃទៀត ដោយមានគោលដៅ.....**

បន្ថែមទៅនឹងការប្រព្រឹត្តអំពើ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនល្មើសត្រូវតែមានចេតនាជាក់លាក់ក្នុងការប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ។ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនតម្រូវថា ជនល្មើសបានប្រព្រឹត្តអំពើទាំងនេះ ដោយជោគជ័យទេ ប៉ុន្តែគ្រាន់តែ តម្រូវថាជនល្មើស មានចេតនាប្រព្រឹត្តដូច្នេះ ។ ដូចគ្នានេះដែរ ច្បាប់នេះ មិនតម្រូវថាជនល្មើសមានគោលដៅច្រើនជាងមួយ ដូចខាងក្រោម ។ មានន័យថា មានគោលដៅតែមួយគឺគ្រប់គ្រាន់ហើយ ។

បន្ថែមពីនេះទៀត គួរកត់សំគាល់ថា អំពើ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ត្រូវតែបានប្រព្រឹត្តឡើងដោយមានគោលដៅ ។ ដើម្បីអនុវត្តមាត្រានេះ ជនដែលគេទទួល ផ្តល់ជម្រក ឬ លាក់បំពួន ត្រូវតែបាននាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនដោយខុសច្បាប់ ក្នុងគោលដៅដើម្បីស្វែងរកប្រយោជន៍ឈ្នានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទំរង់នៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ។ ឧទាហរណ៍ : ប្រសិនបើ "ខ" គឺជា ជនរងគ្រោះ ដោយការនាំយកចេញជាធម្មតា ដែលមិនផ្សំឱ្យមានគោលដៅ ប្រព្រឹត្តបទល្មើសណាមួយ លើសពីនេះ ។ ប៉ុន្តែត្រូវបានទទួល ផ្តល់ជម្រក ឬ លាក់បំពួន ដោយ "ក" ដែលមានគោលដៅកេងប្រវ័ញ្ចន៍ពី "ខ" ហេតុដូច្នេះ "ក" នៅតែទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។

**" ស្វែងរកប្រយោជន៍ "**

ពាក្យថា " ស្វែងរកប្រយោជន៍ " ដូចមានប្រើក្នុងមាត្រានេះ មានន័យថា ជនល្មើសបានប្រព្រឹត្តអំពើ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ដើម្បីផ្តោះប្តូរ ឬ ដើម្បីទទួលយកវត្ថុមានតម្លៃអ្វីមួយ ដែលរួមមានដូចជា ប្រាក់ វត្ថុមាន

តម្លៃផ្សេងទៀត ( មាស គ្រឿងអលង្ការ ។ល។ ) សេវាកម្ម ឬ មនុស្ស ។ ប្រសិនបើ ជនល្មើសបានប្រព្រឹត្ត ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ដោយមិនស្របច្បាប់ ក្នុងគោលដៅនេះ ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។

### " ឈ្លានពានខាងផ្លូវភេទ "

ពាក្យថា " ឈ្លានពានខាងផ្លូវភេទ " ដូចមានប្រើក្នុងមាត្រានេះ មានន័យថា ជនល្មើសបានធ្វើការ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ដោយមានគោលដៅ ប្រព្រឹត្តបទល្មើសផ្លូវភេទប្រឆាំងនឹងជនរងគ្រោះ ដូចជាអំពើរំលោភសេពសន្ថវៈ ឬ អំពើបំពានផ្លូវភេទផ្សេងទៀត (សូមមើលនិយមន័យនៃបទល្មើសទាំងនេះ យោងតាម ច្បាប់ព្រហ្មទណ្ឌ ដែលកំពុងអនុវត្ត ) ឬ ក្នុងករណីដែលអនីតិជនអាយុក្រោម ១៥ ឆ្នាំ អំពើអាស ដូចមានការកំណត់និយមន័យ ក្នុង ជំពូកទី ៦ នៃច្បាប់នេះ ។ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើការ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន សម្រាប់គោលដៅ នេះ ហេតុដូច្នេះ ជនល្មើសគួរត្រូវទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ ការទទួល ផ្តល់ជម្រក ឬ លាក់បំពួន ដោយមានគោលដៅនេះ និងបាន ធ្វើការឈ្លានពានខាងផ្លូវភេទ ជនល្មើសគប្បីត្រូវទទួលការចោទប្រកាន់ពីបទល្មើសទាំងពីរ ។ ឧទាហរណ៍ : ប្រសិនបើ អ្នកប្រព្រឹត្តអំពើ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន នូវជនណាម្នាក់ ដោយមានគោលដៅ រំលោភសេពន្ថវៈលើជននោះ និងក្រោយមកបានធ្វើការ រំលោភសេពន្ថវៈ អ្នកប្រព្រឹត្តគប្បីត្រូវចោទប្រកាន់ពីបទល្មើស ដូចមានចែងក្នុងមាត្រានេះ (ការទទួលយកមនុស្សដោយមានគោលដៅ ) ព្រមទាំង បទល្មើស ការឈ្លានពានខាងផ្លូវភេទ ដែលជនល្មើសបាន ប្រព្រឹត្ត ( រំលោភសេពសន្ថវៈ ការបំពានផ្លូវភេទផ្សេងទៀត ។ល។ ) ដូចមានការកំណត់និយមន័យ ក្នុងមាត្រាដែល ពាក់ព័ន្ធនៃច្បាប់ព្រហ្មទណ្ឌ ។

### " ផលិតរូបភាពអាសអាភាស "

ជនល្មើសទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន មនុស្ស ដោយមានគោលដៅ បង្កើត ឬ ចូលរួមបង្កើត រូបភាព និងសម្ភារៈអាសអាភាស ។ " រូបភាព និងសម្ភារៈអាស អាភាស " មាននិយមន័យ ចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

មិនតម្រូវឱ្យជនល្មើសបានទទួល ឬ មានចេតនាទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុណាមួយ ពីអំពើនេះទេ ។

### " ធ្វើអាពាហ៍ពិពាហ៍ ប្រឆាំងនឹងឆន្ទៈជនរងគ្រោះ "

ជនល្មើស ទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន មនុស្ស ដោយមានគោលដៅ បង្ខំជនរងគ្រោះឱ្យរៀបអាពាហ៍ពិពាហ៍ប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ។

មិនតម្រូវឱ្យជនល្មើសបានទទួល ឬ មានចេតនាទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុណាមួយ ពីអំពើនេះទេ ។

" ស្មុំកូន "

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន មនុស្សដោយមានគោលដៅ ផ្តល់ ឬ លក់ជនរងគ្រោះឱ្យអ្នកស្មុំ កូន ហេតុដូច្នេះ ជនល្មើសគួរតែទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ ។ ( ទាក់ទងនឹងការស្មុំកូន សូមមើល ក្រមរដ្ឋប្បវេណី គន្ថីទី ៧ " ញាតិ " ជំពូកទី ៤ " ឪពុកម្តាយ និងកូន " ផ្នែកទី ២ " ស្មុំកូន " ) ព្រមទាំង ច្បាប់ ស្តីពី ការស្មុំកូនអន្តរប្រទេស ។

មិនតម្រូវឱ្យជនល្មើសទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុណាមួយ ពីការស្មុំកូនទេ ។ គ្រប់គ្រាន់ហើយដែលថា ជនល្មើសមានគោលដៅផ្តល់ជនរងគ្រោះដោយផ្ទាល់ ទៅកាន់ជនណាម្នាក់ទៀត ដែលស្មុំកូន ឬ ផ្តល់ជនរងគ្រោះទៅឱ្យជនណាម្នាក់ទៀត ដែលនឹងសម្រួលឱ្យមានការស្មុំកូន ។

" ទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត "

ពាក្យថា " ក្រោមទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត " រួមមានជាអាទិ៍ អំពើដែលមានរៀបរាប់ក្នុងមាត្រា ១០ កថាខ័ណ្ឌទី ៣ ដូចជា ការកេងប្រវ័ញ្ចន៍លើពេស្យាចារកម្មជនដទៃ រូបភាព និងសម្ភារៈអាសអាភាស ពាណិជ្ជកម្មផ្លូវភេទ សេវា ឬ ពលកម្មដោយបង្ខំ ទាសភាព ឬ ការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុល សេវភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬ ការដកហូតសរីរាង្គ ។ ចំពោះ និយមន័យនៃពាក្យទាំងនេះ សូមមើលការពិភាក្សាក្នុងមាត្រា ១០ កថាខ័ណ្ឌទី ៣ ។ បន្ថែមពីនេះទៀត តុលាការក៏អាចមានឆន្ទានុសិទ្ធិ ពិចារណាទៅលើ ប្រភេទនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ដែលមិនបានរៀបរាប់នៅទីនេះ ។ ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើទទួល ផ្តល់ជម្រក ឬ លាក់បំពួន មនុស្សដោយមានគោលដៅទាំងនេះណាមួយ ហេតុដូច្នេះ ជនល្មើសគួរតែត្រូវផ្តន្ទាទោស យោងតាមមាត្រា នេះ ។

## ការផ្តន្ទាទោស និងកត្តាស្ថានទម្ងន់ទោស

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ តុលាការត្រូវតែផ្តន្ទាទោស ជនល្មើសដោយដាក់ពន្ធនាគារ ពី ៧ ( ប្រាំពីរ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ) ឆ្នាំ ។ ទោសបន្ថែម អាចក៏ត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬនិយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ការផ្តន្ទាទោសដូចជា

ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

យ៉ាងណាមិញ ប្រសិនបើ តុលាការរកឃើញមានកត្តាស្ថានទម្ងន់ទោសណាមួយ ដូចបានរៀបរាប់ខាងក្រោមនេះ ហេតុដូច្នេះការផ្តន្ទាទោសត្រូវកើនឡើង ពី ១៥ ( ដប់ប្រាំ ) ឆ្នាំ ដល់ ២០ ( ម្ភៃ ) ឆ្នាំ ។

ច្បាប់នេះ មិនតម្រូវឱ្យបំពេញតាមកត្តាស្ថានទម្ងន់ទោស ទាំងអស់ទេ ។ ជាការគ្រប់គ្រាន់ហើយ ប្រសិនបើមានស្ថានទម្ងន់ទោសតែមួយប៉ុណ្ណោះ ជនល្មើស ត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

~ **ជនរងគ្រោះជាអនីតិជន**

ប្រសិនបើ ជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

ប្រសិនបើ ជនល្មើសមានការគ្រប់គ្រង និងការត្រួតពិនិត្យលើអនីតិជន ហេតុដូច្នេះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា ជនល្មើសបានដឹងពីអាយុរបស់អនីតិជន ។ សូមមើលការពិភាក្សា យោងតាមមាត្រា ៧ ( និយមន័យនៃអនីតិជន ) ខាងលើ ។

~ **អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើ ជនរងគ្រោះ**

ប្រសិនបើ ជនល្មើស គឺជាមន្ត្រីសាធារណៈ និងបានប្រព្រឹត្តអំពើដោយមធ្យោបាយ បំពានដោយអំណាច ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

" មន្ត្រីសាធារណៈ " មានន័យថា ជាមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលត្រូវផ្តល់អាណត្តិឱ្យតាមរយៈការបោះឆ្នោត ។ ទាំងនេះរួមមាន : តួនាទីជាមន្ត្រីរដ្ឋាភិបាល នគរបាល យោធា គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន និង សាកលវិទ្យាល័យសាធារណៈ គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យសាធារណៈ ឬ មជ្ឈមណ្ឌលសុខភាព និង បុគ្គលដែលកំពុងមានតួនាទីសាធារណៈដែលជាប់ឆ្នោត នៅក៏រិតណាមួយជាអាទិ៍ ។

" ការបំពានដោយសិទ្ធិអំណាច " មានន័យដូចពាក្យ " ការបំពានអំណាច " ដូចត្រូវពិភាក្សាយោងតាមមាត្រា ៨ ពោលគឺ ជាស្ថានការណ៍ដែលមន្ត្រីរាជការ ឬ ពលរដ្ឋ ដែលគេផ្តល់អាណត្តិបោះឆ្នោតឱ្យបានប្រើប្រាស់តួនាទីរបស់ខ្លួន មិនសមរម្យ ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ និយមន័យនេះស្របនឹងនិយមន័យដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ ( សូមពិនិត្យមើល គន្ថីទី ៤ មាតិកាទី ៣ ជំពូកទី ១ ផ្នែកទី ១ កថាភាគទី ២ " ការរំលោភអំណាចប្រឆាំងនឹងបុគ្គល " ) ។ ជាញឹកញាប់ ការរំលោភអំណាចនេះ ប្រើប្រាស់ដើម្បីកេងប្រវ័ញ្ចន៍ពីមនុស្សម្នាក់ ឬ ច្រើននាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈងាយទទួលរងគ្រោះដើម្បីធ្វើឱ្យជនរងគ្រោះ ជឿធ្វើអ្វីដែលជនរងគ្រោះ នឹងមិនធ្វើដោយឆន្ទៈ ។

គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទាំងមូលបានបង្ហាញពីចេតនាយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោសឱ្យធ្ងន់ធ្ងរនូវការទាក់ទិនណាមួយរបស់មន្ត្រីសាធារណៈ ក្នុងអំពើជួញដូរមនុស្ស ។

**- អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង**

ប្រសិនបើ ជនល្មើសបានប្រព្រឹត្តបទល្មើស ដោយជាផ្នែកមួយនៃក្រុមមានការចាត់តាំង ហេតុដូច្នេះ ជនល្មើសត្រូវទទួលការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ។

នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៧៧ " ក្រុមមានការចាត់តាំង " មានន័យថា គឺជាការប្រមូលផ្តុំ ដែលបានបង្កើតឡើង ឬ ជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

ក្នុងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ មាននិយមន័យ ប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែតម្រូវបន្ថែមឱ្យក្រុមមានការចាត់តាំង ត្រូវតែបញ្ចូលមនុស្សពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ។ ឧទាហរណ៍ : អនុសញ្ញា អង្គការសហប្រជាជាតិ ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័ន ឱ្យនិយមន័យ " ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង " ក្នុងមាត្រា ២ (ក) ថាជា " ក្រុមដែនមានរចនាសម្ព័ន្ធ ដែលមានគ្នា ពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណងបទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មួយ ឬ ច្រើន ដែលត្រូវធ្វើឡើងស្របទៅនឹង អនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ សម្ភារៈផ្សេងទៀត " ។

ដូច្នេះហើយ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានឱ្យនិយមន័យ " ក្រុមមានការចាត់តាំង " មានន័យថា ជាក្រុម ផ្លូវការ ឬ មិនផ្លូវការ ដែលមានគ្នាបីនាក់ ឬ ច្រើននាក់ជាងនេះ ដែលត្រូវបានបង្កើត ឡើងដើម្បីរៀបចំផែនការ ឬដើម្បីប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

**មាត្រា ២០.- ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស**

ជនណាដែលទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនរងគ្រោះក្នុងអំពើនាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ក្នុងគោលដៅដើម្បីជួយដល់ជនល្មើស ដែលបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនជនរងគ្រោះនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ក្នុងករណីជនរងគ្រោះជាអនីតិជន ។

មាត្រានេះ ចែងពីបទល្មើស និងផ្តន្ទាទោសជនណាដែល ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនណាម្នាក់ផ្សេងទៀត ដែលជនល្មើសផ្សេងទៀតបាននាំចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនដោយមិនស្របច្បាប់ ដោយមានគោលដៅជួយជនល្មើសផ្សេងទៀត ។

បទល្មើសដែលមានចែងក្នុងមាត្រានេះ មានធាតុផ្សំសំខាន់ៗ បី ដែលធាតុផ្សំទាំងអស់នេះ ត្រូវបំពេញ :

**១) ជនល្មើសទទួល ផ្តល់ជម្រក ឬលាក់បំពួន ជនម្នាក់ទៀត**

ជនល្មើសត្រូវផ្តន្ទាទោសយោងតាមមាត្រានេះ ប្រសិនបើ ជននោះ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនរងគ្រោះ ។

**" ជនណាដែលទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនម្នាក់ទៀត "**

" ទទួល " មានន័យថា ទទួលយក ឬ ការទទួលបាន

" ផ្តល់ជម្រក " មានន័យថា ការផ្តល់ជម្រកឱ្យជនម្នាក់ទៀត

" លាក់បំពួន " មានន័យថា ការលាក់រូបកាយជនដទៃ ( ឧទាហរណ៍ : ដាក់ជនរងគ្រោះ ក្នុងកន្លែងសំងាត់ដែលមិនអាចត្រូវគេឃើញ ឬ រកឃើញ ) ឬ តាមមធ្យោបាយផ្សេងទៀត ដូចជា ការបោកបញ្ឆោត ( ឧទាហរណ៍ : កុហកតតិយជនអំពីអត្តសញ្ញាណរបស់ជនរងគ្រោះ ) ។

**២) ជនដែលជនល្មើសបានទទួល ផ្តល់ជម្រក ឬ លាក់បំពួន ពីមុនត្រូវបាននាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ដោយខុសច្បាប់**

ត្រូវអនុវត្តមាត្រានេះ ជនដែលជនល្មើសបានទទួល ផ្តល់ជម្រក ឬ លាក់បំពួន ពីមុនត្រូវបាននាំយកចេញ ជ្រើសរើស លក់-ដូរ ដឹកជញ្ជូនដោយមិនស្របច្បាប់ ។

**" ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន "**

" ការនាំយកចេញដោយមិនស្របច្បាប់ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ៨

" ការជ្រើសរើសដោយមិនស្របច្បាប់ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១២

" លក់-ដូរ " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១៣

" ការដឹកជញ្ជូន " មានន័យថា ជាអំពើដូចមាននិយមន័យក្នុងមាត្រា ១៧

**៣) ជនល្មើសប្រព្រឹត្តដោយមានគោលដៅជួយជនល្មើសដំបូង ដែលបាននាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូនជនរងគ្រោះ ដោយខុសច្បាប់**

បន្ថែមទៅនឹងការប្រព្រឹត្តអំពើ ទទួល ផ្តល់ជម្រក ឬ លាក់បំពួន ជនល្មើសត្រូវតែមានចេតនា ជាក់លាក់ជួយជនល្មើសដើម ដែលគឺជាជនដែលបាននាំយកចេញ ជ្រើសរើស លក់-ដូរ ដឹកជញ្ជូនជនរងគ្រោះ ដោយខុសច្បាប់ ។

" ជួយ " មានន័យថា ប្រព្រឹត្តជាអ្នកសមគំនិត ដូចមានការកំណត់និយមន័យក្នុងមាត្រា ៤ ។

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនតម្រូវថា ជនល្មើសផ្តល់ការជួយនេះដោយជោគជ័យ ។ ប៉ុន្តែគ្រាន់តែថា ជនល្មើសមានចេនាទប្រព្រឹត្តដូច្នេះ ។

បន្ថែមពីនេះ គួរកត់សំគាល់ថា ចេតនាជួយជនល្មើសទីមួយនេះ ចាត់ទុកបានដឹងថា ជនរងគ្រោះពីមុនត្រូវជនល្មើសទីមួយ បាននាំយកចេញ ជ្រើសរើស លក់-ដូរ ឬ ដឹកជញ្ជូន ដោយខុសច្បាប់ ។ ក្នុងន័យផ្សេងទៀត ជន

ដែលទទួល ផ្តល់ជម្រក ឬ លាក់បំពួនជនរងគ្រោះ ដើម្បីជួយជនល្មើសទីមួយ ត្រូវចាត់ទុកថាបានដឹងពីអំពើរបស់ជនល្មើសទីមួយ ប្រឆាំងនឹងជនរងគ្រោះ ។

**ការផ្តន្ទាទោស និងកត្តាស្ថានទម្ងន់ទោស**

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើស ក្នុងមាត្រានេះ តុលាការត្រូវតែផ្តន្ទាទោស ជនល្មើសដោយដាក់ពន្ធនាគារពី ពីរ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

ប្រសិនបើ ជនរងគ្រោះជាអនីតិជន ( ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) ហេតុដូច្នេះ ការផ្តន្ទាទោសដាក់ពន្ធនាគារត្រូវកើនឡើងពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

ប្រសិនបើ ជនល្មើសមានការគ្រប់គ្រង និងការត្រួតពិនិត្យលើជនរងគ្រោះ ហេតុដូច្នេះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា បានដឹងពីអាយុរបស់ជនរងគ្រោះ ។ សូមមើលការពិភាក្សាយោងតាមមាត្រា ៧ (និយមន័យនៃអនីតិជន ) ខាងលើ ។

ទោសបន្ថែម ក៏អាចត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ ។

ដូចក្នុងមាត្រា ៤ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬនិយោជិតរបស់នីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសនេះ តុលាការក៏អាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់ រួមមាន ការផ្តន្ទាទោសដូចជាការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

## ជំពូកទី ៣

## ការបង្ខាំង

ជំពូកនេះ ឱ្យនិយមន័យការផ្តន្ទាទោសចំពោះបទល្មើស ការចាប់ពង្រត់ ការឃុំឃាំង ឬ ការបង្ខាំង និងចែងពី ការផ្តន្ទាទោសកើនឡើង នៅពេលដែលបទល្មើសនោះប្រព្រឹត្តក្រោមស្ថានទម្ងន់ទោស ។ បទប្បញ្ញត្តិ ក្នុងជំពូក នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នេះ ប្រហាក់ប្រហែលនឹងបទល្មើសការ បង្ខាំងដោយ ខុសច្បាប់ ដូចមានចែងក្នុងមាត្រា ៣៥ នៃច្បាប់អ៊ុនតាក់ និងប្រហាក់ប្រហែលនឹង បទប្បញ្ញត្តិ ស្តីពី ការចាប់ ការឃុំ ឃាំង និងការបង្ខាំងដោយខុសច្បាប់ ក្នុងក្រមព្រហ្មទណ្ឌ (សូមមើល គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៤ ផ្នែកទី ១ " ការចាប់ ការឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់ " )[១៤] ។

**មាត្រា ២១.- ការចាប់ពង្រត់ ការឃុំឃាំង ឬ ការបង្ខាំង**

**បុគ្គលដែលចាប់ឃុំឃាំង ឬ បង្ខាំងជនដទៃ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ត្រូវផ្តន្ទាទោស :**

**១- ដាប់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬ ការបង្ខាំងខ្លួន មាន រយៈពេលតិចជាងមួយខែ ។**

**២- ដាប់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬ ការបង្ខាំងខ្លួន មាន រយៈពេល ស្មើ ឬ លើសពីមួយខែ ។**

មាត្រានេះ ឱ្យនិយមន័យបទល្មើស និង ធ្វើការផ្តន្ទាទោសចំពោះបុគ្គលណា ដែលចាប់ឃុំឃាំង ឬ បង្ខាំង ជន ដទៃ ដោយខុសច្បាប់ ។ បទល្មើសនេះ មានធាតុផ្សំជាក់លាក់មួយចំនួន ។

### " ដោយគ្មានអំណាចតាមផ្លូវច្បាប់ "

" ដោយគ្មានអំណាចតាមផ្លូវច្បាប់ " មានន័យថា ជាអំពើមួយដែលប្រព្រឹត្តឡើងដោយបុគ្គលម្នាក់ ដែល បុគ្គលនោះ គ្មានសិទ្ធិអំណាចទាល់តែសោះ ឬ ក៏ជាអំពើមួយដែលបុគ្គលម្នាក់មានសិទ្ធិអំណាច តែបុគ្គលនោះបាន ប្រព្រឹត្តហួសពីវិសាលភាពនៃសិទ្ធិអំណាចរបស់ខ្លួន ដែលច្បាប់ ឬ រដ្ឋប្រគល់ឱ្យ ។

ដូច្នេះហើយ ការចាប់ ការឃុំឃាំង ឬ ការបង្ខាំង ដោយគ្មានអំណាចតាមផ្លូវច្បាប់ អាចកើតឡើង ក្នុង លក្ខណៈផ្សេងៗគ្នា :

- បុគ្គល ដែលមិនមានអំណាចតាមផ្លូវច្បាប់ ធ្វើការចាប់ ឃុំឃាំង ឬ បង្ខាំង ជនរងគ្រោះ។ ឧទាហរណ៍ : ប្រសិនបើជា ប្រជាពលរដ្ឋឯកជន (អ្នកដែលមិនមែនជាមន្ត្រីសាធារណៈ និងដែលមិនមានអំណាចតាម ផ្លូវច្បាប់ ) បង្ខាំងជនរងគ្រោះ ដូច្នេះការបង្ខាំងនោះធ្វើឡើងដោយ " គ្មានអំណាចតាមផ្លូវច្បាប់ " ។

[១៤] គួរកត់សំគាល់ថា ទោះជាយ៉ាងណាក៏ដោយ ទោសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ខុសគ្នាត្រង់ចំនុចខ្លះនៃទោស ដែលមាន ចែងក្នុងជំពូកនេះ ។

- បុគ្គល ( ជាទូទៅ ជាមន្ត្រីនគរបាល ឬ មន្ត្រីរដ្ឋាភិបាល ) ដែលជាធម្មតាតម្រូវឱ្យមានអំណាចតាមផ្លូវច្បាប់ ធ្វើកាចាប់ឃុំឃាំង ឬ បង្ខាំង ក្នុងលក្ខណៈដែលមិនអនុញ្ញាតដោយច្បាប់ ។ ឧទាហរណ៍ : ប្រសិនបើ មន្ត្រីនគរបាល ឬ មន្ត្រីរដ្ឋាភិបាល ធ្វើការចាប់ ឬ ឃុំឃាំង ឬ បង្ខាំង ក្នុងលក្ខណៈដែល ជននោះដឹងថា ការចាប់ ឬ ការឃុំឃាំងនោះ មិនត្រូវបានអនុញ្ញាតដោយច្បាប់ ( ដូចជាក្នុងករណីដែល ជនរងគ្រោះមិនបានប្រព្រឹត្តអំពើខុសច្បាប់ ឬ ក្នុងករណី ដែលជនរងគ្រោះ ប្រព្រឹត្តអំពើខុសច្បាប់ ។ ប៉ុន្តែច្បាប់មិនអនុញ្ញាតឱ្យធ្វើការចាប់ ឬ ឃុំឃាំង ចំពោះអំពើនោះ ទេ ) ហេតុផលដូច្នេះ ច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា មន្ត្រីនោះបានប្រព្រឹត្ត " ដោយគ្មានអំណាចតាមផ្លូវច្បាប់ " ។ ឧទាហរណ៍ : ប្រសិនបើ មន្ត្រីនគរបាល ឃុំឃាំងជនណាម្នាក់ហួស ពីរយៈពេលកំណត់ដែលអនុញ្ញាតដោយ ក្រមនីតិវិធីព្រហ្មទណ្ឌ[១៥] និងថែមទាំង មិនមានអំណាចតាមផ្លូវច្បាប់ ( ដូចជាសេចក្ដីសម្រេចរបស់តុលាការ ) ហេតុដូច្នេះ អំពើនេះ អាចត្រូវចាត់ទុកថា ជាការឃុំឃាំង មិនស្របច្បាប់ ។

គួរកត់សំគាល់ថា ក្នុងកាលៈទេសៈខ្លះ ច្បាប់អាចផ្ដល់ឱ្យ បុគ្គល ឬ អង្គការឯកជន នូវអំណាចក្នុងការរក្សាបុគ្គលណាម្នាក់ដោយផ្ដុយពីឆន្ទៈរបស់បុគ្គលនោះនៅទីកន្លែងណាមួយ នៅពេលដែលបុគ្គលដែលត្រូវគេបង្ខាំងនោះមិនមានសមត្ថភាពពេញលេញទេ បើយោងទៅតាមច្បាប់ ( ដូចជាអនីតិជន ឬ ជនដែលតុលាការប្រកាសថា ខ្វះនូវសមត្ថភាពពេញលេញ )។ ឧទាហរណ៍ : ប្រសិនបើ មជ្ឈមណ្ឌលរក្សាក្មេងកំព្រាទទួលបានការគ្រប់គ្រងស្របច្បាប់ទៅលើអនីតិជន ( ក្មេងកំព្រា )ដែលស្ថិតក្រោមការថែទាំរបស់ខ្លួន អញ្ចឹងមជ្ឈមណ្ឌលនោះអាចតម្រូវឱ្យក្មេងកំព្រា ទាំងនោះ មិនឱ្យចាកចេញពីមជ្ឈមណ្ឌលរក្សាក្មេងកំព្រារបស់ខ្លួន ។ យ៉ាងណាមិញ ជាការសំខាន់គួរកត់សំគាល់ថា សិទ្ធិថែរក្សាបុគ្គលណាម្នាក់ ខុសគ្នាពី សិទ្ធិបង្ខាំងបុគ្គល ។ ឧទាហរណ៍ : អង្គការ ដែលធ្វើការងារនីតិសម្បទាសង្គម និងដែលទទួលអំណាចតាមផ្លូវច្បាប់ ក្នុងការទទួលយក និងថែរក្សាមនុស្សមួយចំនួន ( ដូចជា ជនរងគ្រោះ ដោយអំពើជួញដូរ អ្នកប្រើប្រាស់គ្រឿងញៀន កុមារតាមចិញ្ចើមថ្នល់ ។ល។ ) យ៉ាងណាក៏ដោយ មិនមានអំណាចតាមផ្លូវច្បាប់ ធ្វើការបង្ខាំងពួកគេ ដោយផ្ទុយពីឆន្ទៈរបស់ពួកគេ ឬ ហាមឃាត់ពួកគេមិនឱ្យចេញពីអគាររបស់អង្គការឡើយ ។

និយោជក ក៏មិនមានសិទ្ធិណាមួយ ធ្វើការបង្ខាំងនិយោជិត ដោយផ្ទុយពីឆន្ទៈរបស់ពួកគេដែរ ។ និយោជកអាចតម្រូវឱ្យមានជាលក្ខខ័ណ្ឌការងារ ដែលនិយោជិត មិនអាចចាកចេញពីកន្លែងការងារ នៅពេលម៉ោងធ្វើការ ( លើកលែងតែពេលសម្រាក ) ប៉ុន្តែ និយោជក មិនមានអំណាចតាមផ្លូវច្បាប់ ធ្វើការឃុំឃាំង ឬ បង្ខាំង និយោជិត ឬ តម្រូវឱ្យនិយោជិត ស្ថិតនៅក្នុងកន្លែងការងារ ហួសពីម៉ោងការងារស្របច្បាប់ និងយល់ព្រមឡើយ ។ ( ប្រសិនបើ និយោជិតជ្រើសរើសចាកចេញ ក្នុងអំឡុងពេលម៉ោងការងារ និយោជកអាចគ្រាន់តែពិន័យ ឬ បញ្ឈប់និយោជិត ពីការងារក្នុង

---

[១៥] ក្រមនីតិវិធីព្រហ្មទណ្ឌជាទូទៅអនុញ្ញាតឱ្យនគរបាល ធ្វើការឃាត់ខ្លួនជនសង្ស័យក្នុងថិរវេលា ៤៨ ម៉ោង ចំពោះបុគ្គល ដែលត្រូវគេសង្ស័យថា បានប្រព្រឹត្តបទឧក្រិដ្ឋ ថេរវេលានេះអាចពន្យាពេល ២៤ ទៀត ប្រសិនបើ អំណាចតាមផ្លូវច្បាប់ ដែលពាក់ព័ន្ធ អនុញ្ញាត ។ សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩៦ " ការឃាត់ខ្លួន " ។

កិរិតដែលអនុញ្ញាតដោយច្បាប់ ស្តីពី ការងារ )។ក៏ដូច្នោះដែរ ឧទាហរណ៍ : ម្ចាស់ផ្ទះ មិនអាចហាមឃាត់ឈ្នួលបម្រើ កុំឱ្យចាកចេញពីផ្ទះបានទេ ។

**" ការចាប់ ឃុំឃាំង ឬ បង្ខាំងជនដទៃ "**

មាត្រានេះ ផ្តន្ទាទោសជនល្មើស ដែលធ្វើការចាប់ ឃុំឃាំង ឬ បង្ខាំងជនដទៃ ដោយខុសច្បាប់ ។ ពាក្យថា ការចាប់ ឃុំឃាំង ឬ បង្ខាំង អាចត្រូវយល់ដូចខាងក្រោម :

" ការចាប់ " នៅក្នុងមាត្រានេះ សំដៅទៅលើ ការចាប់ខ្លួនបុគ្គលណាម្នាក់ ដោយមន្ត្រីនគរបាល ឬ មន្ត្រីមានសមត្ថកិច្ចផ្សេងទៀត ឬ ដោយបុគ្គលឯកជន ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬ ហួសពីវិសាលភាពនៃសិទ្ធិអំណាច ដែលច្បាប់បានកំណត់ និងដោយបានដាក់បុគ្គលនោះ ទៅកន្លែងណាមួយ ដើម្បីកុំឱ្យបុគ្គលនោះ មានសេរីភាពក្នុងការចាកចេញ ។

" ការឃុំឃាំង " និង " ការបង្ខាំង " សំដៅទៅលើ ការឃុំខ្លួន ឬ គ្រប់គ្រងទៅលើបុគ្គលម្នាក់ទៀត ដោយមន្ត្រីនគរបាល ឬ មន្ត្រីមានសមត្ថកិច្ចផ្សេងទៀត ឬ ដោយបុគ្គលឯកជន ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬ ហួសពីវិសាលភាពនៃសិទ្ធិអំណាចដែលច្បាប់បានកំណត់ និងដោយបានរារាំងជនរងគ្រោះមិនឱ្យចាកចេញពីទីកន្លែង ដែលគាត់ត្រូវបានគេឃុំឃាំង ។

ទាក់ទងនឹងអត្ថន័យដូចបានរៀបរាប់ខាងលើ ជាការសំខាន់គួរកត់សំគាល់ថា " ការគំរាមកំហែង " មានន័យថា ជាការគំរាមកំហែងដោយផ្ទាល់ និងដោយប្រយោល ។

ប្រហាក់ប្រហែលគ្នានេះ គំនិតពាក្យថា " ការបង្ខាំង " គួរត្រូវបកស្រាយឱ្យបានទូលំទូលាយ ហើយមិន សំដៅគ្រាន់តែលើការបង្ខាំងរូបកាយជនរងគ្រោះប៉ុណ្ណោះទេ (ឧទាហរណ៍ : ការរក្សាជនរងគ្រោះក្នុងបន្ទប់ចាក់សោរ )។ មានទម្រង់ផ្សេងទៀតជាច្រើននៃ ការបង្ខាំង ដែលក៏កំណត់ថាជាការបង្ខាំងដែរ ដូចជាការបង្ខាំងផ្លូវចិត្ត (ការបង្ខាំងដោយផ្អែកលើការគម្រាមកំហែង ) ការបង្ខាំងតាមវិជ្ជាជីវៈ (ឧទាហរណ៍ : និយោជករក្សាទុក លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀត របស់និយោជិត ដើម្បីជាការធានា ឬ រក្សានិយោជិតកុំឱ្យចាកចេញ តាមរយៈការគំរាមកំហែងបណ្តេញចេញពីការងារ )។

**" ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ "**

មាត្រានេះ បញ្ជាក់ច្បាស់ថា ការផ្តន្ទាទោសដែលយកមកអនុវត្ត មានតែជាប់ពន្ធនាគារប៉ុណ្ណោះ ។ មាត្រានេះ មិនអនុញ្ញាតឱ្យជនល្មើសចៀសវាងពីការជាប់ពន្ធនាគារ ដោយគ្រាន់តែបង់ប្រាក់ពិន័យឡើយ ។

**" ជាប់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬ ការបង្ខាំងខ្លួន មានរយៈពេលតិចជាងមួយខែ "**

មាត្រានេះ មិនបានបញ្ជាក់ឱ្យច្បាស់ពី រយៈពេលជាអប្បរមា នៃការចាប់ ការឃុំឃាំង ឬ ការបង្ខាំង ហេតុដូច្នេះ ការផ្តន្ទាទោស ( ជាប់ពន្ធនាគារពី ៣ ឆ្នាំ ទៅ ៥ ឆ្នាំ ) គឺដូចគ្នា ចំពោះបទល្មើសទាំងអស់ ក្នុងករណីជនរងគ្រោះត្រូវបានចាប់ ឃុំឃាំង ឬ បង្ខាំង មានរយៈពេលតិចជាងមួយខែ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលធ្វើការកាត់ទោស អំពើល្មើសព្រហ្មទណ្ឌណាមួយ តុលាការអាចពិចារណា ស្ថានភាពសម្រាលទោស និងកាត់បន្ថយទោសឱ្យសមស្រប និងដូចត្រូវអនុញ្ញាតដោយច្បាប់ ។ (សូមពិនិត្យមើលផ្នែក ស្តីពី ស្ថានសម្រាលទោស ក្នុងក្រមព្រហ្មទណ្ឌ គន្ថីទី ១ មាតិកាទី ៣ ជំពូកទី ២ ផ្នែកទី ២ " ស្ថានសម្រាលទោស " ) ។

គួរកត់សំគាល់ថា ក្រមព្រហ្មទណ្ឌ ចែងពីទោសផ្សេងៗគ្នាជាច្រើន ចំពោះបទល្មើស ការចាប់ ការឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់ (សូមមើល គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៤ ផ្នែកទី ១ " ការចាប់ ការឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់ " ) ។ ជាពិសេស មាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ ផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ បើការចាប់ការឃុំឃាំង ឬ ការបង្ខាំងខ្លួនមានរយៈពេលតិចជាង ៤៨ ម៉ោង ដែលការផ្តន្ទាទោសនេះស្រាលជាងមាត្រា ២១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៣ ឆ្នាំ ទៅ ៥ ឆ្នាំ បើការចាប់ ការឃុំឃាំង ឬការបង្ខាំងខ្លួន មានរយៈពេលតិចជាង មួយខែ (រយៈពេលប៉ុន្មានក៏ដោយ ឱ្យតែតិចជាង មួយខែ ) ។

យោងតាមគោល ការណ៍នៃការបកស្រាយច្បាប់ និងវិធានដែលមានចែងនៅក្នុង មាត្រា ៦៧១ និង មាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌ (សូមមើលការការពិភាក្សា ស្តីពី "គោលការណ៍ នៃការបកស្រាយច្បាប់"នៅក្នុងសេចក្តីផ្តើម និងនៅក្នុងមាត្រា ៥០ ខាងក្រោម) ជាទូទៅ ទោសស្រាលជាង ដែលចែងក្នុងក្រមព្រហ្មទណ្ឌថ្មី នឹងត្រូវជំនួសទោស ដែលមានចែងក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បើការចាប់ការឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈ ពេលតិចជាង ៤៨ ម៉ោង ។ ប៉ុន្តែ បើការចាប់ការឃុំឃាំង ឬ ការបង្ខាំងខ្លួនមានរយៈពេល (តិចជាង ៤៨ម៉ោង) ធ្វើឡើងក្នុងបរិបទជួញដូរមនុស្ស នោះច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលជាច្បាប់ពិសេស) នឹងមានអាទិភាព ហេតុដូច្នេះ ជនដៃដល់អាចត្រូវចោទប្រកាន់ និងផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ តាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។

**ឧទាហរណ៍ ក ជាម្ចាស់ក្រុមហ៊ុនបោះពុម្ព បានឃុំឃាំងនិយោជិត ខ ដោយខុសច្បាប់ នៅក្នុងបន្ទប់បោះពុម្ព ដោយសង្ស័យថា ខ បានលួចលុយក្រុមហ៊ុនសម្រាប់ប្រគល់ឱ្យអ្នកផ្គត់ផ្គង់ ។ ក បដិសេធពុំព្រមធ្វើការដោះលែង ខ រហូតដល់ ខ ប្រគល់លុយដែលលួចនោះមកវិញ ។ ក្រោយរយៈពេល ៤៥ម៉ោង ខ បានដោះលែង ក ដោយសារបានដឹងថា តាមពិតលុយដែលបាត់នោះគឺ គ ដែលជាអ្នកគ្រប់គ្រងការិយាល័យ ជាអ្នកយក ហើយប្រគល់ទៅឱ្យអ្នកផ្គត់ផ្គង់របស់ពួកគេ ។ ក្នុងករណីនេះមិនទាក់ទិននឹងករណីជួញដូរ ហេតុដូច្នេះហើយជនដៃដល់គួរតែត្រូវចោទប្រកាន់តាមមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ ពីបទ បទចាប់ឃុំឃាំង និង បង្ខាំងដោយខុសច្បាប់ ។**

**ឧទាហរណ៍មួយទៀត ក ដែលជាអ្នកជួញដូរមនុស្ស បានទាក់ទាញ ខ ដែលជាក្មេងស្រីឱ្យចាកចេញពីស្រុកកំណើតទៅធ្វើការជាមួយនាង ជាអ្នកបម្រើ នៅក្នុងភោជនីយដ្ឋានមួយនៅទីក្រុងភ្នំពេញ ហើយភោជនីយដ្ឋាននោះគឺ**

ជាផ្ទះបនផងនៅពេលល្ងាច ។ គ ដែលជាម្ចាស់ផ្ទះបន បានឱ្យលុយមួយចំនួនទៅ ក ហើយបានចាក់សោរឃុំឃាំង ខ ស្ទើរអស់រយៈពេល ២ថ្ងៃ មុនពេល ខ ត្រូវបានជួយសង្គ្រោះដោយឪពុកម្តាយរបស់នាង ។ ក្នុងករណីនេះ គ អាចត្រូវផ្តន្ទាទោស យោងតាម មាត្រា ២១ កថាខណ្ឌទី ១ ចំណុចទី ១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពីបទ ឃុំឃាំង និងបង្ខាំង ខ ដោយខុសច្បាប់ ហើយ គ អាចត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារ ពី ៣ឆ្នាំ ទៅ ៥ឆ្នាំ ដោយសារតែ អំពើនេះទាក់ទងនឹងបទល្មើសជួញដូរ ។

**មាត្រា ២២.- ស្ថានទម្ងន់ទោស**

**បុគ្គលដែលចាប់ឃុំឃាំង ឬ បង្ខាំងជនដទៃ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងករណីដូចខាងក្រោម :**

**១- ដោយមានទារុណកម្ម ឬ អំពើឃោរឃៅ**

**២- បណ្តាលឱ្យមានមនុស្សស្លាប់ ឬ**

**៣- ប្រព្រឹត្តក្នុងគោលដៅជំរិតយកប្រាក់ ។**

មាត្រានេះ ដាក់អាណត្តិថា ជនល្មើសត្រូវទទួលការផ្តន្ទាទោស ដាក់ពន្ធនាគារអស់មួយជីវិត ប្រសិនបើ ជននោះ បានធ្វើការចាប់ឃុំឃាំង ឬ បង្ខាំង ជនដទៃ យោងតាមកាលៈទេសៈដាក់លាក់មួយចំនួន :

គួរកត់សំគាល់ថា ក្រមព្រហ្មទណ្ឌ ចែងពីការផ្តន្ទាទោសផ្សេងៗគ្នាជាច្រើន ចំពោះស្ថានទម្ងន់ទោស ដែលទាក់ទងនឹងបទល្មើសនៃអំពើ ការចាប់ ឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់ ( សូមមើល គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៤ ផ្នែកទី ១ " បទចាប់ ឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់ " ) ។ ជាពិសេស ស្ថានទម្ងន់ទោស មាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ បានផ្តន្ទាទោស ពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ ដែលស្រាលជាងបើប្រៀបធៀប នឹងមាត្រា ២២ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលផ្តន្ទាទោសជាប់ពន្ធនាគារ អស់ មួយជីវិត ។ យោងតាម គោលការណ៍នៃការបកស្រាយច្បាប់ និងវិធានដែលមានចែង នៅក្នុង មាត្រា ៦៧១ និង មាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌ (សូមមើលការការពិភាក្សា ស្តីពី "គោលការណ៍ នៃការបកស្រាយច្បាប់" នៅក្នុង សេចក្តីផ្តើម និងនៅក្នុងមាត្រា ៥០ ខាងក្រោម) ជាទូទៅ ទោសស្រាលជាង ដែលចែង ក្នុងក្រមព្រហ្មទណ្ឌថ្មី នឹងត្រូវជំនួសទោស ដែលមានចែងក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើ អាជីវកម្មផ្លូវភេទ ។ ប៉ុន្តែ បើបទល្មើសធ្វើឡើងក្នុងបរិបទជួញដូរមនុស្ស ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ (ដែលជាច្បាប់ពិសេស) នឹងមានអាទិភាព ហេតុដូច្នេះ ជនល្មើសអាចត្រូវចោទប្រកាន់ និងផ្តន្ទាទោស តាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។

## " បទល្មើសប្រព្រឹត្តឡើងដោយមានទារុណកម្ម ឬ អំពើឃោរឃៅ "

ប្រសិនបើ ជនល្មើស ចាប់ ឃុំឃាំង ឬ បង្ខាំង បុគ្គលណាម្នាក់ ហើយទាក់ទងនឹង ការចាប់ ការឃុំឃាំង ឬ ការបង្ខាំងនោះ ជនល្មើសក៏ប្រើទារុណកម្ម ឬ អំពើឃោរឃៅដែរ ហេតុដូច្នេះ ជនល្មើស ត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានឱ្យនិយមន័យ " ទារុណកម្ម " ឬ " អំពើឃោរឃៅ " ទេ ។ ទោះជាយ៉ាងណា ពាក្យថា " ទារុណកម្ម " ត្រូវប្រើក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលរួមមាន ច្បាប់ ដែលចូលជាធរមាន នៅពេលដែល ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានប្រកាសឱ្យប្រើ ( សូមពិនិត្យមើល ឧទាហរណ៍ : មាត្រា ១២ នៃច្បាប់អ៊ុនតាក់ និងមាត្រា ៧ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោស ) ព្រមទាំង ក្រមព្រហ្មទណ្ឌ ( សូមមើល ឧទាហរណ៍ : គន្ថីទី ២ មាតិកាទី ២ ជំពូកទី ២ ផ្នែកទី ១ " ទារុណកម្ម និងអំពើឃោរឃៅ " ។ ទោះបីជា ច្បាប់ទាំងនេះ មិនបានឱ្យនិយមន័យពាក្យ " ទារុណកម្ម " ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវយល់ថាបានបញ្ចូល ( តាមរយៈឯកសារយោងក្នុងមាត្រា ១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តសន្ធិសញ្ញាអន្តរជាតិផ្សេងទៀត ) និយមន័យដែលមានចែងក្នុង អនុសញ្ញា ស្តីពី ការប្រឆាំង ការធ្វើទារុណកម្ម ។ ប្រទេសកម្ពុជាបានឱ្យសច្ចាប័ន លើអនុសញ្ញា ស្តីពី ការប្រឆាំងការធ្វើទារុណកម្ម នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ។ មាត្រា ១ នៃអនុសញ្ញា ស្តីពី ការប្រឆាំង ការធ្វើទារុណកម្មឱ្យនិយមន័យ ពាក្យថា " ទារុណកម្ម " ដូចខាងក្រោម :

*"...អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬ រងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬ ផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនា ទៅលើជនម្នាក់ទៀត ក្នុងគោលបំណងទាំងឡាយដូចជា ទាញយកព័ត៌មានពីជននោះ ឬ តតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយ ដែលជននោះ ឬ តតិយជនណាម្នាក់ បានប្រព្រឹត្ត ឬ សង្ស័យថាបានប្រព្រឹត្ត ឬ បំភិតបំភ័យ ឬ បង្ខិតបង្ខំជននោះ ឬ តតិយជនណាម្នាក់ ឬ ដើម្បីមូលហេតុណាផ្សេងទៀត ដោយផ្អែកលើការរើសអើងណាមួយ...."* ។

ចំពោះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ពាក្យ " ទារុណកម្ម " កំណត់ដោយធាតុផ្សំសំខាន់ៗ ពីរ :

១) នាំឱ្យមានការឈឺចាប់ ឬ រងទុក្ខខ្លាំង ទោះជាផ្លូវកាយក្តី ឬ ផ្លូវចិត្តក្តី

២) បង្កឡើងដោយចេតនា ។

គួរកត់សំគាល់ផងដែរថា ចំពេលដែលច្បាប់អន្តរជាតិចាត់ទុកថា ទារុណកម្ម អាចប្រព្រឹត្តឡើង ជាប់ទាក់ទងជាមួយ មន្ត្រីសាធារណៈ ឬ បុគ្គលដែលបំពេញក្នុងមុខតំណែងជាផ្លូវការ ក្នុងច្បាប់កម្ពុជា បទល្មើសប្រព្រឹត្ត អំពើទារុណកម្ម ក៏អាចអនុវត្តចំពោះអំពើមួយចំនួន ដែលប្រព្រឹត្តដោយបុគ្គលឯកជនដែរ ។ នេះស្របនឹង វិធីសាស្ត្រ ដែលមានចែង

ក្នុងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ដែលពាក់ព័ន្ធ ( សូមពិនិត្យមើល គន្ថីទី ២ មាតិកាទី ២ ជំពូកទី ២ ផ្នែកទី ១ " ទារុណកម្ម និងអំពើឃោរឃៅ " ) ។

ពាក្យថា " អំពើឃោរឃៅ " មិនមានឱ្យនិយមន័យ ក្នុងច្បាប់កម្ពុជា ឬ ច្បាប់អន្តរជាតិ ទេ ប៉ុន្តែពាក្យនេះត្រូវចាត់ទុកថា សំដៅទៅលើ ការប្រព្រឹត្តដោយឃោរឃៅផ្សេងទៀត ដែលមានកំរិតធ្ងន់ធ្ងរ ដូចជាការធ្វើទារុណកម្ម ដែរ ។ ក្នុងន័យនេះ គេយល់ថាអំពើឃោរឃៅ ប្រហាក់ប្រហែលនឹងពាក្យ " ការប្រព្រឹត្តដ៏ឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប " ដែលពាក្យនេះ ក៏ត្រូវបានប្រើ ( ប៉ុន្តែមិនមានការកំណត់និយមន័យ ) នៅក្នុង អនុសញ្ញាប្រឆាំងនឹងទារុណកម្ម ដែរ ។

### " បទល្មើសបណ្តាលឱ្យមនុស្សស្លាប់ "

ប្រសិនបើ បុគ្គលដែលត្រូវគេចាប់ ឃុំឃាំង ឬ បង្ខាំង ហើយបន្ទាប់មកស្លាប់ដោយសារជាប់ទាក់ទងនឹងការចាប់ ឃុំឃាំង ឬ បង្ខាំងនេះ ហេតុដូច្នេះ ជនល្មើស ( បុគ្គលដែលចាប់ ឃុំឃាំង ឬ បង្ខាំង ជនរងគ្រោះ ) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ អស់មួយជីវិត ។

ក្នុងករណីបែបនេះ មិនជាបញ្ហាសំខាន់ទេ ដែលថា ជនរងគ្រោះស្លាប់**ក្រោយ**ពេលត្រូវចាប់ ឃុំឃាំង ឬ បង្ខាំង ប៉ុន្តែកុំឱ្យតែជនរងគ្រោះត្រូវបានស្លាប់ **ដោយសារតែលទ្ធផល**នៃ ការចាប់ ការឃុំឃាំង ឬ ការបង្ខាំង ។ ទោះជាយ៉ាងណាក៏ដោយ មាត្រានេះ មិនតម្រូវថា ជនល្មើសមានចេតនាបណ្តាលឱ្យជនរងគ្រោះស្លាប់ឡើយ ។ ប្រសិនបើជនល្មើសមិនមានចេតនា សំលាប់ជនរងគ្រោះ ប៉ុន្តែជនរងគ្រោះស្លាប់ដោយសារតែ ការចាប់ ការឃុំឃាំង ឬ ការបង្ខាំង ( ឧទាហរណ៍ : ជនរងគ្រោះឈឺ ឬ រងរបួស ហើយមិនត្រូវអនុញ្ញាតឱ្យចាកចេញដើម្បីស្វែងរកការព្យាបាល ឬ លេបថ្នាំដែលចាំបាច់ ) ហេតុដូច្នេះ ជនល្មើសត្រូវផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិត ។ វិធីសាស្ត្រនេះ ស្របទៅនឹងវិធីសាស្ត្រដែលមានឃើញនៅក្នុងក្រមព្រហ្មទណ្ឌ ដែលបញ្ជាក់យ៉ាងច្បាស់ពីការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ទៅលើ ជនល្មើសដែលចាប់ ឃុំឃាំង ឬ បង្ខាំង ជនរងគ្រោះដោយខុសច្បាប់ ហើយការធ្វើដូច្នេះ " បណ្តាលឱ្យបាត់បង់ជីវិត ជនរងគ្រោះដោយគ្មានបំណងនឹងធ្វើឱ្យស្លាប់ " សូមមើលក្រមព្រហ្មទណ្ឌ គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៤ ផ្នែកទី ១ " ការចាប់ ការឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់ " ។

### " បទល្មើសប្រព្រឹត្តក្នុងគោលដៅជំរិតយកប្រាក់ "

ប្រសិនបើ បុគ្គលម្នាក់ត្រូវគេចាប់ ឃុំឃាំង ឬ បង្ខាំង ក្នុងគោលដៅជំរិតយកប្រាក់ ហេតុដូច្នេះ ជនល្មើស ( ជនដែលធ្វើការចាប់ ឃុំឃាំង ឬ បង្ខាំង ជនរងគ្រោះ ) ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារអស់មួយជីវិត ។

## ជំពូកទី ៤

## អំពើពេស្យាចារ និង អំពើពេស្យាចារកុមារ

ជំពូកនេះ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មាននិយាយអំពី អំពើធ្វើអាជីកម្មផ្លូវភេទ ក្នុងគោលបំណងធ្វើជំនួញ ។ ជំពូកនេះ មានការកំណត់និយមន័យ ពាក្យ " អំពើពេស្យាចារ " និង " អំពើពេស្យាចារកុមារ " និងមានចែងពីបទល្មើស និងការផ្តន្ទាទោស ចំពោះសកម្មភាពដែលទាក់ទងនឹង អំពើពេស្យាចារ និងអំពើពេស្យាចារកុមារ ។

ជាការសំខាន់គួរកត់សំគាល់ថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានផ្តន្ទាទោសជនណាម្នាក់ ដែលប្រព្រឹត្តអំពើពេស្យាចារទេ ( ទាំងបុគ្គលពេស្យា និងអតិថិជន )[១៦] ប៉ុន្តែគ្រាន់តែដាក់ឱ្យទៅជាទោសព្រហ្មទណ្ឌនូវសកម្មភាពដែលទាក់ទងមួយចំនួន ។ សូម្បីតែ ក្នុងករណីបែបនេះ ច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានចាត់ទុកបុគ្គលពេស្យាថាជា ជនល្មើសឡើយ ។ ជនល្មើស យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជា សញ្ចារិក ឬ សញ្ចារិកាមេពេស្យាចារ ឬ ជនផ្សេងទៀត ដែលទាញយកអត្ថប្រយោជន៍ពី អំពើពេស្យាចាររបស់ជនដទៃ ( អត្ថប្រយោជន៍ ពីសកម្មភាពរបស់បុគ្គលពេស្យា ) ។ ហេតុដូច្នេះ បុគ្គលពេស្យា មិនមែនជាជនល្មើសទេ ។ យោងតាមច្បាប់នេះ ជនណាដែលប្រកបការងារផ្លូវភេទដោយស្ម័គ្រចិត្ត ( អញ្ចឹងហើយតាមនិយមន័យជាជនដែលមិនមែនជាជនរងគ្រោះ ដោយអំពើជួញដូរ ) មិនត្រូវទទួលការផ្តន្ទាទោសឡើយ យោងតាមច្បាប់នេះ ។

យ៉ាងណាមិញ បុគ្គលពេស្យាអាចត្រូវផ្តន្ទាទោស ប្រសិនត្រូវគេរកឃើញថា បានប្រព្រឹត្តអំពើអូសទាញដើម្បីប្រព្រឹត្តអំពើពេស្យាចារ ក្នុងទីសាធារណៈ (សូមមើល មាត្រា ២៤ ) ។ ក្នុងករណីក្រោយនេះ បុគ្គលពេស្យាមិនមែនទទួលទោស ពីបទប្រព្រឹត្តអំពើពេស្យាចារទេ ប៉ុន្តែពីបទប្រព្រឹត្តអំពើអូសទាញ ដែលត្រូវបានចាត់ទុកថា ជាការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ។[១៧]

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តន្ទាទោសរាល់បុគ្គលដែលប្រព្រឹត្តអំពើពេស្យាចារកុមារ ( រួមទាំងអតិថិជន ) ប៉ុន្តែមិនបានចាត់ទុកកុមារ ដែលប្រព្រឹត្តអំពើពេស្យាចារ ថាជាជនល្មើសទេ។ កុមារដែលប្រព្រឹត្តអំពើពេស្យាចារ គឺជាជនរងគ្រោះ និងហេតុដូច្នេះ គួរត្រូវទទួលការការពារ ។ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា ជនល្មើសដែលប្រព្រឹត្តបទល្មើស ពេស្យាចារកុមារ គឺជាជនដែលប្រព្រឹត្ត អំពើ សញ្ចារកម្ម ជ្រើសរើស អូសទាញ ឬ បើមិនដូច្នេះទេ ទាញយកអត្ថប្រយោជន៍ពីសកម្មភាពរបស់បុគ្គល ពេស្យាកុមារ ។ បុគ្គលដែលទិញពេស្យាចារកុមារ ក៏ត្រូវចាត់ទុកថាជា ជនល្មើសដែរ ។

---

[១៦] អតិថិជន អាចទទួលការផ្តន្ទាទោស ពីបទល្មើសដែលទាក់ទងនឹងអំពើពេស្យាចារ មានតែបទល្មើសការទិញពេស្យាចារ ប៉ុណ្ណោះ។ សូមមើលការពិភាក្សាមាត្រា ៣៤ ( " ការទិញពេស្យាចារកុមារ " ) ខាងក្រោម ។

[១៧] ដំណោះស្រាយនេះ ស្របទៅនឹងក្រមព្រហ្មទណ្ឌ ដែលចាត់ចំណាត់ថ្នាក់បទល្មើស " បទហៅអ្នកដទៃនៅទីសាធារណៈ " រួម គ្នាជាមួយនឹងបទល្មើស " បទស្រើងជាក់ស្តែង " ក្នុងទីសាធារណៈ ។ សូមមើល ក្រមព្រហ្មទណ្ឌ គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៦ " ការប៉ះពាល់ផ្សេងទៀតដល់សេចក្តីថ្លៃថ្នូរ " ។

**មាត្រា ២៣.. និយមន័យនៃអំពើពេស្យាចារ និង អំពើពេស្យាចារកុមារ**

" អំពើពេស្យាចារ " នៅក្នុងច្បាប់នេះមានន័យថា ការរួមភេទជាមួយជនណាម្នាក់ ដែលមិនកំណត់ ឬ អំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទ ដោយផ្លោះប្តូរ នឹងវត្ថុមានតម្លៃអ្វីមួយ ។

" អំពើពេស្យាចារកុមារ " នៅក្នុងច្បាប់នេះមានន័យថា ជាអំពើរួមភេទ ឬ អំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទ រវាងអនីតិជនជាមួយជនដទៃ ដើម្បីផ្លោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ ។

មាត្រានេះ មានការកំណត់និយមន័យ ពាក្យថា " អំពើពេស្យាចារ " និង " អំពើពេស្យាចារកុមារ " ដែលត្រូវប្រើជាច្រើននៅទូទាំងជំពូកនេះ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ មាត្រានេះ មិនបានដាក់ឱ្យទៅជាទោសព្រហ្មទណ្ឌ នូវអំពើពេស្យាចារ និងអំពើពេស្យាចារកុមារ និងយោងតាមមាត្រានេះ មិនគួរឱ្យមានការចោទប្រកាន់ឡើយ ។

គួរកត់សំគាល់ថា យោងតាម ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អំពើពេស្យាចារ ដែលប្រព្រឹត្តដោយនីតិជន ដោយមានការយល់ព្រមដោយស្ម័គ្រចិត្ត មិនខុសច្បាប់ឡើយ ទោះបីជាសកម្មភាពដែលទាក់ទងផ្សេងទៀត ត្រូវដាក់ឱ្យទៅជាទោសព្រហ្មទណ្ឌ ក្នុងមាត្រា ២៤ មាត្រា ២៦ មាត្រា ២៧ និងមាត្រា ២៩ ដល់ មាត្រា ៣២ ។

អំពើពេស្យាចារកុមារ គឺជាអំពើខុសច្បាប់ យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប៉ុន្តែដូចបានកត់សំគាល់ខាងលើ កុមារពេស្យាមិនត្រូវផ្តន្ទាទោសឡើយ ។ ច្បាប់ចាត់ទុក កុមារពេស្យា ថាជាជនរងគ្រោះ និងមិនមែនជាជនល្មើស ទេ ។ បទល្មើសដែលទាក់ទងនឹងអំពើ ពេស្យាចារកុមារ មានចែងដោយផ្ទាល់ក្នុង មាត្រា ២៨ និងមាត្រា ៣៣ ដល់ មាត្រា ៣៧ និងមានការដាក់បញ្ចូលក្នុងមាត្រា ២៦ ដល់ មាត្រា ២៧ ( តាមរយៈ ការអនុវត្តមាត្រា ២៨ ) និងមាត្រា ៣០ ដល់ មាត្រា ៣២ ( តាមរយៈការអនុវត្តមាត្រា ៣៣ ) ។ មាត្រា ២៩ " សញ្ជារកម្មដោយមានការធ្វើទារុណកម្ម " ក៏អាចអនុវត្តក្នុងករណីនៃអំពើ ពេស្យាចារកុមារ ដែរ ។ មាត្រា ២៤ ( អំពើអូសទាញ ) មិនអនុវត្តក្នុងករណីនៃអំពើ ពេស្យាចារកុមារ ទេ ។

**អំពើពេស្យាចារនីតិជន**

និយមន័យនៃអំពើ ពេស្យាចារនីតិជន ដែលមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ មានធាតុផ្សំសំខាន់ៗជាច្រើន :

១) អ្នកប្រព្រឹត្ត ( ជនដែលប្រព្រឹត្តអំពើពេស្យាចារ )

២) មានសកម្មភាពផ្លូវភេទ ( អំពើរួមភេទ ឬ អំពើផ្លូវភេទផ្សេងទៀត )

៣) ជាមួយជនម្នាក់ទៀត ( ជនណាម្នាក់ ដែលមិនកំណត់ )

៤) ដើម្បីផ្លោះប្តូរទៅនឹងវត្ថុមានតម្លៃ អ្វីមួយ ។

និយមន័យនៃពាក្យគន្លឹះ ដែលត្រូវប្រើក្នុងកថាខ័ណ្ឌទី ១ មានដូចខាងក្រោម :

## អ្នកប្រព្រឹត្ត (ជានីតិជន)

កថាខ័ណ្ឌទី ១ នៃមាត្រានេះ មិនបានលើកឡើងឱ្យច្បាស់ ចំពោះអ្នកប្រព្រឹត្ត ប៉ុន្តែតាមការអនុវត្ត ដោយសមហេតុផល នៃកថាខ័ណ្ឌទី ២ (ដែលមានការកំណត់និយមន័យអំពើពេស្យាចារកុមារ ) គេយល់ថា កថាខ័ណ្ឌ ទី ១ នេះសំដៅ ទៅលើអំពើពេស្យាចារដែលប្រព្រឹត្តដោយនីតិជន ។

## " អំពើរួមភេទ "

ពាក្យថា " អំពើរួមភេទ " មានន័យថា ជាការស៊កបញ្ចូល កេរភេទរបស់ជនណាម្នាក់ ទៅក្នុងកេរភេទ មាត់ ឬ រន្ធគូទ របស់ជនម្នាក់ផ្សេងទៀត ឬ ជាការស៊កបញ្ចូល សម្ភារៈ ឬ ឧបករណ៍ណាមួយ ទៅក្នុង កេរភេទ របស់ជនម្នាក់ ទៀត ។[១៨] អំពើរួមភេទអាចកើតឡើង រវាងមនុស្ស ពីរនាក់ ឬ ច្រើននាក់ ជាងនេះអាចដែលមានភេទដូចគ្នា ឬ ខុស គ្នា ។

ពាក្យថា " សម្ភារៈ ឬ ឧបករណ៍ " គួរត្រូវបានគេបកស្រាយយ៉ាងទូលំទូលាយថា រួមមានដូចជា : ឈើ ប៊ិច លិង្គសប្បនិម្មិត ប្រដាប់រំញ័រ ដប ឬ ផ្នែកដទៃទៀត នៃរាងកាយមនុស្ស ដូចជា ម្រាមដៃ អណ្តាត ដៃ ។ល។

ជាទូទៅពាក្យថា " កេរភេទ " ត្រូវបានកំណត់ថា ជាលិង្គ ឬ រន្ធយោនី ។ ប៉ុន្តែដើម្បីពង្រឹងការការពារដល់ជនរងគ្រោះ នៅក្នុងច្បាប់នេះ ពាក្យថា កេរភេទ ត្រូវបានគេយល់ថា ជាលិង្គ ឬ រន្ធយោនី ឬ រន្ធគូទ ។

ពាក្យថា " អំពើរួមភេទ " មានរាប់បញ្ចូល ការរួមភេទតាមរន្ធយោនី ការរួមភេទតាមរន្ធគូទ និងការរួមភេទតាមមាត់ មិនថាឡើយ រវាងបុរស និងស្ត្រី បុរស និង បុរស ឬ ស្ត្រី និងស្ត្រី ។

## " ឬ អំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទ "

ពាក្យថា " អំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទ " មានន័យថា ជាប្រភេទ នៃអំពើផ្សេងទៀត ដែលនាំឱ្យរំជួល ឬ រំភើបដល់ចំណង់ផ្លូវភេទរបស់អ្នកប្រព្រឹត្ត ។[១៩]

អំពើបែបនេះ រួមមាន ការប៉ះពាល់រូបកាយ រវាងបុគ្គលពេស្យា និងបុគ្គលម្នាក់ទៀត និង ក៏អាចរាប់បញ្ចូលករណីដែលមិនមានការប៉ះពាល់រូបកាយ រវាងបុគ្គលពេស្យា និងបុគ្គលម្នាក់ទៀត ។ ឧទាហរណ៍ : ប្រសិនបើជនណាម្នាក់ឱ្យប្រាក់ដើម្បីមើលកេរភេទរបស់កុមារ ឬ មើលកុមារសម្រេចកាមដោយខ្លួនឯង ជននោះអាចត្រូវចោទប្រកាន់

---

[១៨] និយមន័យនេះ ស្របទៅនឹងសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌លេខ ០១ កយសណន (០៩ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩) ដែលកំណត់និយមន័យ អំពើរួមភេទ ដែលទាក់ទង នឹងមាត្រា ៤២ និង មាត្រា ៤៣ នៃច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។

[១៩] និយមន័យនៃពាក្យនេះ ផ្អែកទៅលើនិយមន័យ ដែលទាក់ទងនឹងពាក្យ " អំពើអាសគ្រាម " ដែលមានប្រើនៅមាត្រា ៤៣ នៃ ច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមានការកំណត់និយមន័យ ក្នុងសេចក្តីណែនាំរបស់ ក្រសួងយុត្តិធម៌ លេខ ០១ កយសណន (០៩ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩) ។

យោងតាមមាត្រា ៣៤ ( ការទិញពេស្យាចារកុមារ ) ទោះបីជាមិនមាន ការស្ទាប ឬ ការប៉ះពាល់រូបកាយផ្សេងទៀត រវាងអតិថិជន និងកុមារក៏ដោយ ។

ដើម្បីឱ្យទៅជា " អំពើផ្លូវភេទផ្សេងទៀត " អំពើនោះ ត្រូវតែធ្វើឡើងក្នុងគោលដៅ ធ្វើឱ្យរំជួល ឬ រំភើប ដល់ចំណង់ផ្លូវភេទរបស់អតិថិជន ។ មិនជាការសំខាន់ទេថាតើ អតិថិជននោះព្យាយាមដោយរបៀបណា ដើម្បីធ្វើឱ្យរំជួល ឬ រំភើបដល់ចំណង់ផ្លូវភេទ ។ អតិថិជនអាចចាប់ផ្ដើមរួមភេទជាមួយ បុគ្គលពេស្យា ឬ ឱ្យបុគ្គលពេស្យា ចាប់ផ្ដើមរួមភេទ ឬ បង្ហាញកេរភេទដល់អតិថិជន ឬ តតិយជន ឬ ឱ្យតតិយជនចាប់ផ្ដើមរួមភេទជាមួយបុគ្គលពេស្យា ។

### " ជាមួយជនណាម្នាក់ ដែលមិនកំណត់ "

ពាក្យនេះ សំដៅទៅលើជនណាម្នាក់ ដែលមិនមែនជាបុគ្គលពេស្យា ។ ជាធម្មតា ( មិនមែនតែងតែ ) ជនណាម្នាក់ ដែលមិនកំណត់ គឺជាអតិថិជន នោះទេ ពោលគឺ ជនដែលចូលរួមក្នុងសកម្មភាពផ្លូវភេទជាមួយ បុគ្គលពេស្យា គឺក៏អាចជាជនដែលផ្ដល់ ឬ សន្យាផ្ដល់វត្ថុមានតម្លៃអ្វីមួយ ទៅឱ្យបុគ្គលពេស្យា ដើម្បីផ្ដោះប្ដូរទៅនឹង ការរួមភេទ ឬ អំពើផ្សេងទៀត ដែលទាក់ទងនឹងផ្លូវភេទ ។ ក្នុងកាលៈទេសៈខ្លះ ទោះជាយ៉ាងណាក៏ដោយ ជនណាម្នាក់ដែលឱ្យប្រាក់ អាចផ្សេងគ្នា ពីជនណាម្នាក់ដែលមានសកម្មភាពផ្លូវភេទជាមួយ បុគ្គលពេស្យា ។

### " ដើម្បីផ្ដោះប្ដូរទៅនឹងវត្ថុមានតម្លៃ អ្វីមួយ "

ពាក្យថា " វត្ថុមានតម្លៃអ្វីមួយ " រួមមានដូចជា លាភការ ជាប្រាក់ ឬ វត្ថុមានតម្លៃ ( ឧទាហរណ៍ : គ្រឿងអលង្ការ សំលៀកបំពាក់ ។ល។ ) ទ្រព្យសម្បត្តិ ដែលមានរូបរាង (ឧទាហរណ៍ : ផ្ទះ ដី អាគារ ។ល។ ) ទ្រព្យសម្បត្តិដែលគ្មានរូបរាង ឬ សិទ្ធប្រត្យក្ស ( ឧទាហរណ៍ : សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ សិទ្ធិលក់ ឬ សិទ្ធិជួល ប្រភេទណាមួយ នៃចលនទ្រព្យ ឬ អចលនទ្រព្យ ) សេវាកម្ម ការបង់ប្រាក់ដោយផ្ទាល់ ឬ ដោយប្រយោល ឬ ថ្លៃឈ្នួល ( ថ្លៃឈ្នួលដែលបង់ទៅឱ្យតាមរយៈ ឬ ក្នុងនាមជនផ្សេងទៀត ) ព័ត៌មានដែលមានតម្លៃ ឬ ការគ្រប់គ្រង លើមនុស្ស ។

### <u>ពេស្យាចារកុមារ</u>

និយមន័យនៃពាក្យ ពេស្យាចារកុមារ ដែលមានចែងក្នុងកថាខ័ណ្ឌទី ២ នៃមាត្រានេះ ប្រើនិយមន័យដូចគ្នានឹងនិយមន័យ នៃពេស្យាចារនីតិជន ( ដែលមានការកំណត់និយមន័យ ក្នុងកថាខ័ណ្ឌទី ១ ) ដោយខុសគ្នាជាសំខាន់ថា ការរួមភេទ ឬ អំពើផ្សេងទៀត ដែលទាក់ទងនឹងផ្លូវភេទ ត្រូវតែកើតឡើងជាមួយអនីតិជន ។

ហេតុដូច្នេះ និយមន័យនៃពាក្យ ពេស្យាចារកុមារ ដែលមានចែងក្នុងមាត្រានេះ អនុវត្តនៅពេលដែលកើតមានធាតុផ្សំដូចខាងក្រោម :

១) អ្នកប្រព្រឹត្ត ( នីតិជន ឬ អនីតិជន )

២) មានសកម្មភាពផ្លូវភេទ ( អំពើរួមភេទ ឬ អំពើផ្សេងទៀត ដែលទាក់ទងនឹងផ្លូវភេទ )

៣) ជាមួយអនីតិជន ( ជនដែលមានអាយុក្រោម ១៨ ឆ្នាំ )

៤) ដើម្បីផ្តោះប្តូរ ទៅនឹងវត្ថុមានតម្លៃ អ្វីមួយ ។

ដូចនៅក្នុងមាត្រា ៧ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អនីតិជន គឺជនដែលមានអាយុក្រោម ១៨ ឆ្នាំ ។ គួរកត់សំគាល់ថា ជំពូកទី ៦ ( មាត្រា ៤២ ដល់ មាត្រា ៤៤ ) នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់ឱ្យអនីតិជនដែលមានអាយុ ១៥ ឆ្នាំ ឬ លើស ១៥ ឆ្នាំ ( ពោលគឺ ជន ដែលមានអាយុចាប់ពី ១៥ ឆ្នាំ និង តិចជាង ១៨ ឆ្នាំ ) នូវសមត្ថភាពក្នុងការយល់ព្រម រួមភេទ ប៉ុន្តែ ច្បាប់នេះ **មិន**បានផ្តល់ឱ្យអនីតិជនបែបនេះ មានសមត្ថភាពប្រព្រឹត្តអំពើពេស្យាចារ ទេ ។ រាល់អំពើ ពេស្យាចារ ទាំងអស់ ដែលទាក់ទិននឹងអនីតិជន ( ណាមួយដែលមានអាយុក្រោម ១៨ ឆ្នាំ ) ត្រូវចាត់ទុកថា ជាពេស្យាចារកុមារ និងខុសច្បាប់ យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

មាននិយមន័យ នៃធាតុផ្សំផ្សេងទៀត យោងតាមការពន្យល់ដែលមាន ក្នុងកថាខ័ណ្ឌទី ១ ( ស្តីពី ពេស្យាចារ នីតិជន ) នៃមាត្រានេះ ។

**មាត្រា ២៤.- អំពើអូសទាញ**

**ជនណាអូសទាញដោយចេតនានូវជនដទៃក្នុងទីសាធារណៈ ក្នុងគោលដៅប្រព្រឹត្តអំពើ ពេស្យាចារផ្ទាល់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ ( មួយ) ថ្ងៃ ដល់ ៦ ( ប្រាំមួយ ) ថ្ងៃ និងពិន័យជាប្រាក់ ពី ៣.០០០ ( បីពាន់) រៀល ដល់ ១០.០០០ ( មួយម៉ឺន) រៀល ។**

**អនីតិជនត្រូវលើកលែងពីការផ្តន្ទាទោស ចំពោះបទល្មើស ដូចមានចែងនៅក្នុងមាត្រានេះ ។**

មាត្រានេះ បង្កើតឱ្យមានបទល្មើសអំពើ អូសទាញ ដែលមានការកំណត់និយមន័យថាជា ការអូសទាញដោយចេតនា ដើម្បីប្រព្រឹត្តអំពើ ពេស្យាចារ ក្នុងទីសាធារណៈ ។ នេះមានន័យថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានចាត់ទុកថាជា បទល្មើសអំពើ អូសទាញ ដើម្បីប្រព្រឹត្តអំពើ ពេស្យាចារណាមួយ កើតឡើង ក) ដោយអចេតនា ឬ ខ) មិននៅក្នុងទីសាធារណៈឡើយ ។ ហេតុដូច្នេះ ជាទូទៅ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានធ្វើការផ្តន្ទាទោសជនរងគ្រោះ ដោយអំពើជួញដូរ ពីបទល្មើសអូសទាញទេ ដោយសារតែ ក្នុងករណីភាគច្រើនបំផុត ជនរងគ្រោះដោយអំពើ ជួញដូរ មិនមែនជាអ្នកចូលរួមដោយមានចេតនា ។ ដូចគ្នានេះដែរ ច្បាប់ក៏មិនបានធ្វើការផ្តន្ទាទោសអំពើ អូសទាញ ដែលធ្វើឡើងនៅទីកន្លែងឯកជន ដែរ ។

មាត្រានេះ ផ្អែកលើមាត្រា ប្រហាក់ប្រហែលគ្នា ក្នុងក្រមព្រហ្មទណ្ឌ ( សូមមើល គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៦ " ការប៉ះពាល់ផ្សេងទៀតដល់សេចក្តីថ្លៃថ្នូរ " ) ។

ក្នុងការចាត់ថ្នាក់បទល្មើស ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ អំពើអូសទាញ ត្រូវចាត់ថាជា បទល្មើសលហុ និងមិនមែនជាបទល្មើស ឧក្រិដ្ឋ ឬ មជ្ឈិម ។ ហេតុដូច្នេះ មាត្រាខាងក្រោមនេះ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនអនុវត្តចំពោះករណីអំពើអូសទាញទេ :

- មាត្រា ៣ ( ការអនុវត្តច្បាប់នេះនៅក្រៅដែនដី ) អនុវត្តចំពោះតែ បទល្មើសឧក្រិដ្ឋ និងមជ្ឈិម និង មិនអនុវត្តចំពោះអំពើអូសទាញ ទេ ។ ហេតុដូច្នេះ នគរបាល និងតុលាការ មិនមានអំណាចធ្វើការ ស៊ើបអង្កេត ចោទប្រកាន់ ឬ ផ្តន្ទាទោស អំពើអូសទាញណាមួយ ដែលកើតឡើងទាំងស្រុង នៅខាង ក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។
- មាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ១ ដល់ ទី៣ អនុវត្តចំពោះតែ បទល្មើស ឧក្រិដ្ឋ និង មជ្ឈិម និងមិនអនុវត្តចំពោះអំពើអូសទាញ ទេ ។ ហេតុដូច្នេះ នគរបាល និងតុលាការ មិនមានអំណាចធ្វើការ ស៊ើបអង្កេត ចោទប្រកាន់ ឬ ផ្តន្ទាទោស ទៅលើការប៉ុនប៉ងប្រព្រឹត្តអំពើ អូសទាញណាមួយ ឬ ទៅលើអ្នកសមគំនិត ឬ អ្នកផ្តើមគំនិត ឱ្យមានអំពើអូសទាញណាមួយឡើយ ។

មាត្រានេះ ចែងពីធាតុផ្សំនៃបទល្មើសដូចខាងក្រោម :

**" ដោយចេតនា "**

ការប្រើពាក្យថា " ដោយចេតនា " មានន័យថា អ្នកប្រព្រឹត្ត អូសទាញជនដទៃ ដោយស្ម័គ្រចិត្ត និងដោយ ចេញពីឆន្ទៈរបស់ខ្លួន ។

ប្រសិនបើ ជនណាម្នាក់អូសទាញជនម្នាក់ទៀត ដោយសារតែ ការសំឡុតគំរាម ការបង្ខិតបង្ខំ ការគំរាម កំហែង ឬ ត្រូវជនដទៃធ្វើការបង្ខំឱ្យប្រព្រឹត្តអំពើអូសទាញ ហេតុដូច្នេះ អំពើនោះ មិនត្រូវប្រព្រឹត្តឡើងដោយមាន ចេតនាទេ ។ ឧទាហរណ៍ : ប្រសិនបើ អ្នកប្រព្រឹត្ត ត្រូវបង្ខំ ឬ ត្រូវបង្ខិតបង្ខំ ឱ្យអូសទាញជនដទៃ ក្នុងគោលដៅ ប្រព្រឹត្តអំពើពេស្យាចារ អ្នកប្រព្រឹត្តនោះ មិនត្រូវចាត់ទុកថា បានអូសទាញដោយចេតនា និងហេតុដូច្នេះ មិនអាចត្រូវ បានចោទប្រកាន់ ឬ ផ្តន្ទាទោស យោងតាមមាត្រានេះទេ ។

ជាទូទៅ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រួចផុតពីការចោទប្រកាន់ និងការផ្តន្ទាទោស យោងតាម មាត្រានេះ ដោយសារតែ ក្នុងករណីភាគច្រើនបំផុត អំពើជួញដូរមនុស្ស គឺជាអំពើដែលជនណាម្នាក់ផ្សេងទៀត បង្ខំឱ្យ ជនរងគ្រោះប្រព្រឹត្តអំពើនោះ ដែលជនរងគ្រោះមិនមានឆន្ទៈប្រព្រឹត្ត ។

**" អូសទាញ "**

មាត្រានេះ ផ្តន្ទាទោសអំពើអូសទាញ ក្នុងគោលដៅប្រព្រឹត្តអំពើពេស្យាចារ ។ ពាក្យថា " អូសទាញ " មាន ន័យថា ត្រូវតែជាទំនាក់ទំនងច្បាស់លាស់ ឬ អាកប្បកិរិយារបស់ជនល្មើស ដែលជ្រៀតជ្រែក សាធារណៈជន និងនាំឱ្យ មានភាពឥតសណ្តាប់ធ្នាប់សាធារណៈ និងដែលបង្ហាញឱ្យឃើញថា ជនល្មើសមានចេតនា ធ្វើសកម្មភាពរួមភេទ ក្នុងការ ផ្តោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ ។

ជាការសំខាន់គួរកត់សំគាល់ថា ទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌណាមួយ ត្រូវតែមានភស្តុតាងនៃចេតនារបស់ជនល្មើសក្នុងការប្រព្រឹត្តអំពើ ពេស្យាចារផ្ទាល់ខ្លួន ។ ជាទូទៅ ខាងក្រោមនេះ មិនត្រូវចាត់ទុកថា ជាអំពើអូសទាញ ឬ ភស្តុតាងនៃចេតនាក្នុងការប្រព្រឹត្តអំពើ អូសទាញ ទេ :

- ការឈររងចាំ ក្នុងទីសាធារណៈ
- ការស្លៀកសំលៀកបំពាក់ ធ្វើឱ្យឃើញ ធ្វើឱ្យស្រើប ឬ ស៊ិចស៊ី
- ការញញឹម ឬ ការបក់ដៃហៅមនុស្ស
- ការមាន ឬ កាន់ស្រោមអនាម័យ ទឹករំអិល ឬ សម្ភារៈផ្សេងទៀត ដែលទាក់ទងនឹងការផ្សព្វផ្សាយពីសុវត្ថិភាពផ្លូវភេទ និងការកាត់បន្ថយជម្ងឺហ៊ីវ/អេដស៍[២០]
- ការធ្វើការនៅកន្លែងណាមួយ (ដូចជាបៀហ្គាឌិន ក្លឹបខារ៉ាអូខេ កន្លែងម៉ាស្សា ។ល។ និង ។ល។)

សូម្បីតែ នៅក្នុងករណីដែលមានការប្រព្រឹត្តឡើងនូវអំពើខាងលើ នៅតែមានអង្គហេតុផ្សេងទៀត ដែលអាចបម្រើជា ភស្តុតាង ដែលជនជាប់ចោទមានចេតនាដោយឆន្ទៈ ក្នុងការប្រព្រឹត្តអំពើពេស្យាចារ ដោយខ្លួនឯង នៅទីសាធារណៈ ។

## " ក្នុងទីសាធារណៈ "

មាត្រានេះ គ្រាន់តែផ្តន្ទាទោសអំពើ អូសទាញ ដែលធ្វើឡើងក្នុងទីសាធារណៈ ។ អំពើ អូសទាញ ដែលធ្វើឡើងនៅទីកន្លែងឯកជន មិនត្រូវបានផ្តន្ទាទោស យោងតាម ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ (ចូរកត់សំគាល់ថា មាត្រា ៣២ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តន្ទាទោសជនណា ដូចជាម្ចាស់ទ្រព្យសម្បត្តិ ដែលមានចេតនាផ្តល់ទីកន្លែងឯកជនឱ្យប្រើប្រាស់ ដើម្បីប្រព្រឹត្តអំពើ ពេស្យាចារ ប៉ុន្តែមិនបានផ្តន្ទាទោស បុគ្គលពេស្យា ដែលគឺជាជនធ្វើការអូសទាញដើម្បីប្រព្រឹត្តអំពើពេស្យាចារទេ) ។

ពាក្យថា " ទីសាធារណៈ " មានន័យថា ដី អគារ ផ្ទះ និងមធ្យោបាយដឹកជញ្ជូនណាមួយ ដែលគ្រប់គ្រងដោយរដ្ឋ ជាសាធារណៈ ឬ ជាឯកជន ដែលបើកឱ្យ និងផ្តល់សេវាឱ្យសាធារណៈជនទាំងអស់ ។ និយមន័យនេះស្រប ទៅនឹង និយមន័យដែលមានឃើញនៅក្នុង មាត្រា ៤ នៃច្បាប់ ស្តីពី ការការពារ និងលើកស្ទួយសិទ្ធិរបស់ជនពិការ (២០០៩) ។

---

[20] ជាក់ស្តែងសកម្មភាពអប់រំស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ដែលរួមទាំងការជម្រុញ និងការប្រើប្រាស់ស្រោមអនាម័យ ត្រូវបានលើកទឹកចិត្តដោយច្បាប់ និងគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជាដែលរួមទាំង បទបញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រី ស្តីពីកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ឱ្យបាន ១០០ភាគរយ ច្បាប់ស្តីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ឆ្នាំ ២០០២ និងគោលការណ៍អនុវត្តរបស់ច្បាប់នោះ (សូមមើលការពិភាក្សាបន្ថែមទៀត ស្តីពីបទប្បញ្ញត្តិ នៃច្បាប់ស្តីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ គោលការណ៍អនុវត្តរបស់ច្បាប់នោះ និងគោលនយោបាយស្តីពីការប្រើប្រាស់ស្រោមអនាម័យ នៅក្នុងកំណត់ពន្យល់នេះ នៅមាត្រា ២៥ មាត្រា ៣១ និងមាត្រា ៣២ ខាងក្រោមនេះ។

គោលបំណងនៃច្បាប់នេះ ពាក្យថា " ទីសាធារណៈ " ក៏មានន័យថា អំពើអូសទាញ ក៏អាចត្រូវផ្តន្ទាទោស ប្រសិនបើ អំពើនោះធ្វើឡើងនៅទីកន្លែងឯកជន ប៉ុន្តែជនណាម្នាក់ដែលស្ថិតក្នុងទីសាធារណៈ អាចមើលឃើញ ឬ ស្តាប់ឮ ។ ឧទាហរណ៍ : ប្រសិនបើ បុគ្គលពេស្យា ឈរអូសទាញ ដោយនៅតែខាងក្នុងទ្វារ នៃទីកន្លែងឯកជនណាមួយ ដើម្បីឱ្យមនុស្សនៅតាមផ្លូវ អាចមើលឃើញ ឬ ស្តាប់ឮ ដោយស្រួល ហេតុដូច្នេះអំពើនេះអាចត្រូវផ្តន្ទាទោស ។

គួរកត់សំគាល់អាចជាបានការថា បទប្បញ្ញត្តិស្តីពី អំពើហៅអ្នកដទៃនៅទីសាធារណៈ ក្នុងក្រមព្រហ្មទណ្ឌ មិនស្ថិតនៅក្នុងជំពូក ស្តីពី សញ្ចារកម្ម នៃអំពើពេស្យាចារទេ ប៉ុន្តែស្ថិតនៅក្នុងជំពូក ខាងក្រោយទៀត ដែលមានចំណងជើងថា " ការប៉ះពាល់ផ្សេងទៀតដល់សេចក្តីថ្លៃថ្នូរ " ដែលស្ថិតនៅខាងក្រោយ មាត្រាដែលដាក់ទោស ជនណាដែលស្រវឹងជាក់ស្តែង ( សូមមើល គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៦ នៃក្រមព្រហ្មទណ្ឌ ) ។ ការដាក់ឱ្យស្ថិតនៅក្នុងជំពូកខាងក្រោយបែបនេះ ផ្តល់យោបល់ថា មាត្រានេះមិនមានគោលបំណង ធ្វើការផ្តន្ទាទោស បុគ្គលពេស្យាទេ ( ដោយសារតែអំពើពេស្យាចារជាអំពើមិនខុសច្បាប់ ) ប៉ុន្តែតាមការពិត ដើម្បីការពារសិទ្ធិរបស់សាធារណៈជនទូទៅ ក្នុងការប្រើប្រាស់ និងចូលរួមសប្បាយនៅទីវាលសាធារណៈ និង ស្របទៅនឹងគោលបំណងរបស់ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដូចមានចែងក្នុងមាត្រា ១ ដើម្បីរក្សាការពារ និងលើកកម្ពស់ទំនៀមទំលាប់ដ៏ល្អរបស់ជាតិ ។ មានន័យថា មាត្រា ២៤ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គួរត្រូវអនុវត្ត តែនៅពេលណាដែលអំពើ អូសទាញ ធ្វើឡើងក្នុងលក្ខណៈមួយដែល ជ្រៀតជ្រែក ការប្រើប្រាស់ និងការសប្បាយ លើទីវាលសាធារណៈ របស់សាធារណៈជនប៉ុណ្ណោះ ។

ការយល់បែបនេះ ( បទល្មើសប្រព្រឹត្តអំពើ អូសទាញ ទាក់ទងនឹងការព្រួយបារម្ភ អំពីសិទ្ធិការប្រើប្រាស់ និងការសប្បាយនៅទីកន្លែងសាធារណៈ ) ត្រូវពង្រឹង ដោយគោលការណ៍ណែនាំ ឆ្នាំ ២០០៨ ស្តីពី ការអនុវត្តច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ( នៅទីនេះមានឈ្មោះថា " គោលការណ៍ណែនាំ ស្តីពីការអនុវត្ត " ) ដែលត្រូវប្រកាសឱ្យប្រើ ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៨ ដោយក្រសួងមហាផ្ទៃ តំណាងឱ្យក្រុមការងារថ្នាក់ខ្ពស់ ។ គោលការណ៍ណែនាំ ស្តីពី ការអនុវត្តបញ្ជាក់យ៉ាងច្បាស់ថា សកម្មភាពរបស់អាជ្ញាធរ ដែលទាក់ទងនឹង អំពើ ពេស្យាចារ គួរតែត្រូវធ្វើឡើង តែក្នុងករណី បួន ដូចខាងក្រោមនេះ :

- ប្រសិនបើ មានបណ្តឹងពីអ្នកជិតខាង ទៅលើសកម្មភាពអំពើ ពេស្យាចារ ដែលធ្វើឱ្យប៉ះពាល់ដល់ការរស់នៅប្រចាំថ្ងៃ
- ប្រសិនបើ មានបណ្តឹងពីជនរងគ្រោះ ដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើ ពេស្យាចារ នៅតំបន់នោះ
- ប្រសិនបើ មានអំពើ ពេស្យាចារកុមារ
- ប្រសិនបើ អំពើពេស្យាចារនាំឱ្យមានភាពឥតសណ្តាប់ធ្នាប់ និងអសន្តិសុខសាធារណៈ ។

**" ក្នុងគោលដៅប្រព្រឹត្តអំពើ ពេស្យាចារផ្ទាល់ខ្លួន "**

មាត្រានេះ ផ្តន្ទាទោស អំពើអូសទាញ នៅពេលដែលត្រូវប្រព្រឹត្តឡើងក្នុងគោលដៅប្រព្រឹត្តអំពើពេស្យាចារ ។ "

អំពើពេស្យាចារ " មាននិយមន័យ ដូចមានចែងក្នុងមាត្រា ២៣ ។

### " ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ថ្ងៃ ដល់ ៦ (ប្រាំមួយ) ថ្ងៃ "

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះ ជនល្មើស ត្រូវទទួលការជាប់ពន្ធនាគារ ពី ១ (មួយ) ថ្ងៃ ដល់ ៦ (ប្រាំមួយ) ថ្ងៃ ។ ការដាក់ពន្ធនាគារនេះ តម្រូវឱ្យមានបញ្ជារបស់តុលាការ នគរបាលមិនអាចចាប់ដាក់ពន្ធនាគារ ដោយគ្មានសាលក្រមរបស់តុលាការទេ នៅពេលដែល ជនល្មើសត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ ។

គួរកត់សំគាល់ថា យោងតាមមាត្រា ៥ នៃច្បាប់នេះ តុលាការអាចជ្រើសរើសធ្វើការផ្ដន្ទាទោសជនល្មើសដោយ :

១- ពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ឬ

២- ទោសជាប់ពន្ធនាគារ និងទោសពិន័យត្រួតគ្នា ឬ

៣- ទោសដាក់ពន្ធនាគារតែមួយប៉ុណ្ណោះ ។

បទប្បញ្ញត្តិស្ដីពី អំពើ ហៅអ្នកដទៃទៅទីសាធារណៈ ក្នុងក្រមព្រហ្មទណ្ឌ បច្ចុប្បន្នមិនបានចែងពីទោសជាប់ពន្ធនាគារណាមួយ ទៅលើជនល្មើសទេ (សូមមើល គន្លឹះទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៦ " ការប៉ះពាល់ផ្សេងទៀត ដល់សេចក្ដីថ្លៃថ្នូរ " ) ។

ទោះបីយ៉ាងណាក៏ដោយ នៅក្នុងមាត្រា ២៩៨ នៃក្រមព្រហ្មទណ្ឌ គ្រាន់តែផ្ដន្ទាទោសបុគ្គលណាដែលហៅអ្នកដទៃទៅទីសាធារណៈ ដើម្បីញុំាងឱ្យមានទំនាក់ទំនងផ្លូវភេទ ប៉ុន្តែគ្មានគោលបំណង ដើម្បីប្រកបរបរពេស្យាចារខ្លួនឯងទេ ។

ប្រសិនបើ បុគ្គលណាដែលហៅអ្នកដទៃទៅទីសាធារណៈ ដើម្បីញុំាងឱ្យមានទំនាក់ទំនងផ្លូវភេទ ក្នុងគោលបំណង ដើម្បីប្រកបរបរពេស្យាចារខ្លួនឯង នោះមាត្រា ២៤ នៃច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវយកមកអនុវត្ត ។ មាត្រា ២៤ នេះ តម្រូវឱ្យជនល្មើសទទួល ឬ យល់ព្រមទទួលវត្ថុមានតម្លៃអ្វីមួយ ដើម្បីជាការផ្ដោះប្ដូរក្នុងការរួមភេទជាមួយជនដទៃ ដោយមិនកំណត់ ។

### " ពិន័យជាប្រាក់ ពី ៣.០០០ (បីពាន់) រៀល ដល់ ១០.០០០ (មួយម៉ឺន) រៀល "

ប្រសិនបើ ជនល្មើសត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើសដែលមានចែងក្នុងមាត្រានេះ តុលាការអាចបញ្ជាឱ្យជនល្មើស បង់ប្រាក់ពិន័យ ពី ៣.០០០ (បីពាន់) រៀល ដល់ ១០.០០០ (មួយម៉ឺន) រៀល ។ ប្រាក់ពិន័យនេះ តម្រូវឱ្យមានបញ្ជារបស់តុលាការ នគរបាលមិនអាចពិន័យជាប្រាក់ ដោយគ្មានសាលក្រមរបស់តុលាការទេ នៅពេលដែលជនល្មើសត្រូវរកឃើញថា ប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ ។

### "អនីតិជនត្រូវលើកលែងពីការផ្ដន្ទាទោស ចំពោះបទល្មើស ដូចមានចែងនៅក្នុងមាត្រានេះ"

បទប្បញ្ញត្តិនេះ បញ្ជាក់យ៉ាងច្បាស់ថា អនីតិជន ត្រូវលើកលែងការផ្ដន្ទាទោសចំពោះអំពើ អូសទាញ ។

យោងតាមមាត្រា ៧ ( សូមមើលខាងលើ ) អនីតិជន គឺជាជនដែលមានអាយុតិចជាង ១៨ ឆ្នាំ ។

គួរកត់សំគាល់ថា ជំពូកទី ៦ ( មាត្រា ៤២ ដល់ មាត្រា ៤៤ ) នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់ឱ្យអនីតិជនដែលមានអាយុ ១៥ ឆ្នាំ និងលើសពី ១៥ ឆ្នាំ ( ពោលគឺ ជនដែលមានអាយុយ៉ាងហោច ១៥ ឆ្នាំ ប៉ុន្តែអាយុក្រោម ១៨ ឆ្នាំ ) នូវសមត្ថភាពយល់ព្រមរួមភេទ ប៉ុន្តែច្បាប់នេះ មិនបានផ្តល់ឱ្យអនីតិជនបែបនេះ នូវសមត្ថភាពក្នុងការយល់ព្រមក្នុងការប្រព្រឹត្តអំពើ ពេស្យាចារ ទេ ដែលរួមមាន អំពើអូសទាញ នៅទីសាធារណៈដើម្បីប្រព្រឹត្តអំពើ ពេស្យាចារ ។ រាល់អំពើពេស្យាចារទាំងអស់ ដែលទាក់ទិននឹងអនីតិជន (ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) ត្រូវចាត់ទុកថាជាអំពើ ពេស្យាចារកុមារ និងខុសច្បាប់ យោងតាម ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

យោងតាម ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អនិតិជនមិនមានសមត្ថភាពផ្លូវច្បាប់ក្នុងការយល់ព្រមធ្វើអំពើពេស្យាទេ ហេតុដូច្នេះអនីតិជនមិនអាចត្រូវបានចោទប្រកាន់ទេ ។

ប្រសិនបើ អនីតិជនត្រូវបានរកឃើញថា បានប្រព្រឹត្តអំពើអូសទាញ ក្នុងគោលដៅប្រព្រឹត្តអំពើ ពេស្យាចារ នគរបាល និងតុលាការ តែគួរចាប់ខ្លួន ចោទប្រកាន់ និងកាត់ទោស សព្វារិក សព្វារិកា ឬ មេពេស្យាចារ ដែលបានដឹកនាំឱ្យ អនីតិជនប្រព្រឹត្តអំពើនេះ ។ អនីតិជនត្រូវចាត់ទុកថា ជាជនរងគ្រោះដោយអំពើ ពេស្យាចារកុមារ និងហេតុដូច្នេះមាន សិទ្ធិទទួលបានការការពារ ។[២១]

**មាត្រា ២៥.. និយមន័យនៃសព្វារកម្ម**

អំពើសព្វារកម្ម នៅក្នុងច្បាប់នេះ មានន័យថា :

១- ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ

២- ជួយ ឬ ការពារអំពើពេស្យាចាររបស់ជនដទៃ

៣- ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយឱ្យ ធ្វើអំពើពេស្យាចារ

៤- ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ ។

អំពើដូចខាងក្រោមនេះ ត្រូវចាត់ទុកថា ដូចគ្នាទៅនឹងសព្វារកម្ម:

១- អំពើធ្វើជាអន្តរការី រវាងបុគ្គលដែលធ្វើពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬ ឱ្យលាភការដល់ពេស្យាចារជនដទៃ ។

២- អំពើរបស់ជនណាដែលបានជួយសម្រួល ឬ បិទបាំងនូវធនធាន ដែលខ្លួនបានដឹងថាបានមកពី អំពើសព្វារកម្ម ។

---

២១ កត់សំគាល់ថា ការការពារបែបណាមួយផ្អែកទៅលើការយល់ព្រម ពីកុមារ ឬ ឳពុកម្តាយ ឬ អ្នកអាណាព្យាបាលរបស់កុមារ នោះ ។

**៣- អំពើរារាំងដល់ការបង្ការ ការជួយ ឬ ការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬ ដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬ កំពុងមានគ្រោះ ដោយការធ្វើពេស្យាចារ ។**

មាត្រានេះ កំណត់និយមន័យពាក្យថា " សញ្ចារកម្ម " ដែលត្រូវប្រើយ៉ាងច្រើនទៅទូទាំងជំពូកនេះ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ មាត្រា ២៥ នេះ ប្រហាក់ប្រហែលគ្នា ក្នុងក្រមព្រហ្មទណ្ឌថ្មី ( សូមពិនិត្យមើលគន្ថីទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៥ " សញ្ចារកម្ម " ដែលរួមមាន មាត្រា ២៨៤ (បទសញ្ចារកម្ម) មាត្រា ២៨៥ (បទអន្តរការរវាងបុរស ឬស្ត្រីពេស្យា និងសញ្ចារិក ឬសញ្ចារិកា) មាត្រា ២៨៦ (ធនធានដែលបានមកពីសញ្ចារកម្ម) និងមាត្រា ២៨៧ (បទរារាំងដល់ការបង្ការ អំពើពេស្យាចារ) ។ មាត្រា ២៦ ដល់មាត្រា ២៩ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងពីបទល្មើស និងការផ្តន្ទាទោស ដែលទាក់ទងនឹងសញ្ចារកម្មពេស្យាចារ ។

សញ្ចារកម្ម គឺជាគំនិតដ៏ស្មុគ្រស្មាញមួយ ដែលអាចត្រូវគេយល់តាមរបៀបផ្សេងៗគ្នា និងមាត្រានេះ រួមមាននិយមន័យផ្សេងៗគ្នាជាច្រើន នៃសញ្ចារកម្ម ។ ទោះជាយ៉ាងណាក៏ដោយ និយមន័យទាំងអស់នេះ មានគោលបំណងធ្វើការផ្តន្ទាទោសជនណា ដែលទទួល ឬ រំពឹងថា នឹងទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីអំពើពេស្យាចាររបស់ជនដទៃ ឬ អ្នកដែលមានចេតនាធ្វើឱ្យរីកចម្រើនដល់សកម្មភាពអាជីវកម្មពេស្យាចារ ។ គំនិតជាមូលដ្ឋាននេះ គួរត្រូវចាត់ទុកថាជាផ្នែកនៃ និយមន័យទាំងអស់ ដែលមានចែងក្នុងមាត្រានេះ ។ ហេតុដូច្នេះ ប្រសិនបើ អ្នកប្រព្រឹត្តមិនបានទទួល ឬ រំពឹងថា ទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីអំពើពេស្យាចាររបស់អ្នកដទៃ ឬ មិនមានចេតនា ធ្វើឱ្យរីកចម្រើន ដល់សកម្មភាពអាជីវកម្មពេស្យាចារ អ្នកប្រព្រឹត្តនោះ មិនគួរទទួលខុសត្រូវចំពោះបទល្មើសសញ្ចារកម្ម ឡើយ ។

ជាការសំខាន់គួរកត់សំគាល់ថា មាត្រានេះ មិនបានផ្តន្ទាទោសជនណាដែលប្រព្រឹត្តសកម្មភាពពេស្យាចារដោយផ្ទាល់ខ្លួន និងមាត្រានេះ ក៏មិនបានធ្វើការផ្តន្ទាទោសបុគ្គលពេស្យាដែរ ។ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានផ្តន្ទាទោសបុគ្គលពេស្យា (ជាឯកត្តបុគ្គល ឬ ជាក្រុម ) ពីបទប្រព្រឹត្តអំពើពេស្យាចារ ឡើយ ។ ដូចគ្នានេះដែរ ច្បាប់នេះ មិនបានផ្តន្ទាទោសអតិថិជន នៃអំពើពេស្យាចារទេ ។

មាត្រានេះ កំណត់និយមន័យ សញ្ចារកម្មដូចខាងក្រោម :

### " ១. ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពី អំពើពេស្យាចាររបស់ជនដទៃ "[22]

ផ្នែកទី ១ ចែងពីករណីដែលអ្នកប្រព្រឹត្ត ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើ ពេស្យាចាររបស់ជនដទៃ ។

" ផលប្រយោជន៍ហិរញ្ញវត្ថុ " មានន័យថា ជាវត្ថុមានតម្លៃអ្វីមួយដែលអ្នកប្រព្រឹត្តទាញយកផលប្រយោជន៍ពីវត្ថុនោះ ។ ជាទូទៅ វត្ថុនេះ មានទម្រង់ជា ប្រាក់ ក៏ប៉ុន្តែវត្ថុផ្សេងទៀត ក៏អាចចាត់ទុកថាជា " វត្ថុមានតម្លៃអ្វីមួយ " ដែរ រួមមានដូចជា : លាភការ ជាប្រាក់ ឬ វត្ថុមានតម្លៃ ( ឧទាហរណ៍ : គ្រឿងអលង្ការ សំលៀកបំពាក់ ។ល។ )

---

[22] បទប្បញ្ញត្តិនេះ ដូចគ្នានឹងបទប្បញ្ញតិនៃ មាត្រា ២៨៤ ចំនុចទី ១ ស្តីពី សញ្ចារកម្ម នៃក្រមព្រហ្មទណ្ឌ ។

ទ្រព្យសម្បត្តិ ដែលមានរូបរាង (ឧទាហរណ៍ : ផ្ទះ ដី អាគារ ។ល។) ទ្រព្យសម្បត្តិដែលគ្មានរូបរាង ឬ សិទ្ធប្រត្យក្ស (ឧទាហរណ៍ : សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ សិទ្ធិលក់ ឬ សិទ្ធិជួល ប្រភេទណាមួយនៃចលនទ្រព្យ ឬអចលនទ្រព្យ) សេវាកម្ម ការបង់ប្រាក់ដោយផ្ទាល់ ឬ ដោយប្រយោល ឬ ថ្លៃឈ្នួល (ថ្លៃឈ្នួលដែលបង់ទៅឱ្យតាមរយៈ ឬ ក្នុងនាមជនផ្សេងទៀត) ព័ត៌មានដែលមានតម្លៃ ឬ ការគ្រប់គ្រង លើមនុស្ស ។

ពាក្យទាំងមូល " ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពី អំពើពេស្យាចាររបស់ជនដទៃ " សំដៅទៅលើសកម្មភាពអាជីវកម្មពីអំពើ ពេស្យាចារ (ដែលមិនមែនជាការជួយបុគ្គលពេស្យាទេ) ។

ឃ្លានេះ មានន័យថា អ្នកប្រព្រឹត្តទទួលយកអត្ថប្រយោជន៍ដោយផ្ទាល់ ពីសេវកម្មពេស្យាចាររបស់ជនដទៃ គឺមានន័យថា មិនមែនជាសេវាកម្មពេស្យាចារណាមួយ ដែលប្រព្រឹត្តដោយខ្លួនឯងនោះទេ ។ ឧទាហរណ៍ : ម្ចាស់ផ្ទះបនទាញយក អត្ថប្រយោជន៍ពី អំពើពេស្យាចាររបស់ បុគ្គលពេស្យានៅផ្ទះបននោះ ។ ដូចគ្នានេះដែរ ភ្នាក់ងារកណ្តាលដែល ទទួលយកកំរៃជើងសារ ពីសេវាកម្មពេស្យាចាររបស់បុគ្គលពេស្យា កំពុងតែទាញយក អត្ថប្រយោជន៍ពីអំពើពេស្យាចារ របស់ជនដទៃ។ ប៉ុន្តែបុគ្គលពេស្យា ដែលអតិថិជន ឱ្យប្រាក់មិនទទួលការផ្តន្ទាទោសក្នុងផ្នែកនេះទេ ដោយសារតែបុគ្គលពេស្យា កំពុងតែទាញយកអត្ថប្រយោជន៍ ពីអំពើពេស្យាចាររបស់ខ្លួន និងមិនមែនជារបស់ជនដទៃ ។

ដើម្បីឱ្យអ្នកប្រព្រឹត្ត ទទួលខុសត្រូវក្នុងផ្នែកនេះ ជននោះត្រូវតែបានដឹង និងមានចេតនាផង ។ អ្នកប្រព្រឹត្តត្រូវតែបានដឹងថា អត្ថប្រយោជន៍ហិរញ្ញវត្ថុដែលគាត់បានទទួល បានមកពីអំពើពេស្យាចាររបស់ជនដទៃ និងត្រូវមានចេតនាទាញយកអត្ថប្រយោជន៍ពី អំពើពេស្យាចាររបស់ជនដទៃផង ។ ក្នុងន័យផ្សេងទៀត ផ្នែកនេះមិនបានចែងក្នុងករណីដែលជនណាម្នាក់ ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុ ដែលគាត់មិនបានដឹងថា អត្ថប្រយោជន៍នោះបានមកពីអំពើពេស្យាចាររបស់ជនដទៃ គាត់ដឹងថាអត្ថប្រយោជន៍នោះ បានមកពីអំពើពេស្យាចារ តែគាត់មិនមានចេតនាឱ្យជនដទៃ ប្រព្រឹត្តអំពើពេស្យាចារ ។ ឧទាហរណ៍ : ម្ចាស់ដីដែលជួលអគារឱ្យមេបន ប៉ុន្តែមិនបានដឹងថា អគារនោះត្រូវប្រើ ប្រាស់ដើម្បីអំពើពេស្យាចារទេ យោងតាមផ្នែកនេះ ម្ចាស់ដីមិនទទួលខុសត្រូវ ចំពោះការបង់ប្រាក់ជួលដែលគាត់បានទទួលនោះទេ ។ ប្រហាក់ប្រហែលគ្នានេះដែរ បុគ្គលិកបម្រើការងារ (អ្នកគិតលុយ ចុងភៅ អ្នកសំអាត អ្នកយាម រថយន្ត។ល។) ដែលជួលដោយផ្ទះបន ទទួលប្រាក់ខែ (អត្ថប្រយោជន៍ហិរញ្ញវត្ថុ) ពីផ្ទះបន ប៉ុន្តែដោយសារតែបុគ្គលិកទាំងនេះ មិនមានចេតនាឱ្យបុគ្គលពេស្យាក្នុងផ្ទះបននោះ ប្រព្រឹត្តអំពើពេស្យាចារទេ ហេតុនេះពួកគាត់មិនគួរទទួលការផ្តន្ទាទោសយោងតាមផ្នែកនេះទេ ។

## "២. ជួយ ឬ ការពារអំពើពេស្យាចាររបស់ជនដទៃ"[២៣]

ផ្នែកទី ២ ចែងក្នុងករណីដែលអ្នកប្រព្រឹត្ត បានជួយសម្រួល ឬ បិទបាំងអំពើពេស្យាចាររបស់ជនដទៃ ។ " ការជួយសម្រួល ឬ បិទបាំង " មានន័យថា ជាទម្រង់ណាមួយនៃការជួយ ការការពារ ការជំរុញ ឬ សម្រួល ។

---

[23] បទប្បញ្ញត្តិនេះប្រហាក់ប្រហែលគ្នា នឹងបទប្បញ្ញត្តិ នៃមាត្រា ២៨៤ ចំនុចទី ២ ស្តីពី សញ្ចារកម្ម នៃក្រមព្រហ្មទណ្ឌ ។

[24] បទប្បញ្ញត្តិនេះប្រហាក់ប្រហែលគ្នា នឹងបទប្បញ្ញត្តិ នៃមាត្រា ២៨៤ ចំនុចទី ៣ ស្តីពី សញ្ចារកម្ម នៃក្រមព្រហ្មទណ្ឌ ។

" អំពើពេស្យាចាររបស់ជនដទៃ " មានន័យថាជា សកម្មភាពអាជីវកម្មពីអំពើ ពេស្យាចារ ( មិនមែនជាការជួយ ។ល។ បុគ្គលពេស្យាទេ ) ។

ឧទាហរណ៍ : ប្រសិនបើ អ្នកគ្រប់គ្រងផ្ទះបន ជួលសន្តិសុខឱ្យការពារបុគ្គលពេស្យានៅក្នុងផ្ទះបន ពីការយាយី និងដើម្បីឱ្យបុគ្គលពេស្យាអាចធ្វើការងាររបស់ខ្លួន អ្នកគ្រប់គ្រងនោះនឹងកំពុងតែការពារអំពើពេស្យាចារ របស់ជនដទៃ ។ ប្រសិនបើ អ្នកប្រព្រឹត្តជូនដំណឹងឱ្យម្ចាស់ផ្ទះបន ពីការវាយឆ្មក់របស់នគរបាល ដើម្បីឱ្យម្ចាស់ផ្ទះបនអាចលាក់បាំងអំពើ ពេស្យាចារនៅក្នុងផ្ទះបន អ្នកប្រព្រឹត្តនឹងកំពុងតែការពារអំពើពេស្យាចាររបស់ជនដទៃ។

ដើម្បីឱ្យអ្នកប្រព្រឹត្តទទួលខុសត្រូវក្នុងផ្នែកនេះ ជននោះត្រូវតែបានដឹង និងមានចេតនាផងដែរ ។ អ្នកប្រព្រឹត្តត្រូវតែដឹងថា ការជួយសម្រួល និងការបិទបាំង គឺដើម្បីផលប្រយោជន៍ អំពើពេស្យាចាររបស់ជនដទៃ និងមានចេតនា ជួយសម្រួល ឬ បិទបាំងអំពើពេស្យាចារនោះផង ។ ហេតុដូច្នេះ ជនណាដែលមិនបានដឹងថា បានជួយសម្រួល ឬ បិទបាំងអំពើពេស្យាចាររបស់ជនដទៃទេ មិនត្រូវទទួលខុសត្រូវយោងតាមផ្នែកនេះទេ ។

ប្រហាក់ប្រហែលគ្នានេះដែរ ជនណា ដែលជួយសម្រួល ឬ បិទបាំងបុគ្គលពេស្យា ប៉ុន្តែមិនមានចេតនា ជួយសម្រួល ឬ បិទបាំងបែបនេះ ដើម្បីឱ្យមានសកម្មភាពពេស្យាចារបន្តទៀត ជននោះមិនទទួលខុសឡើយ ត្រូវយោងតាមផ្នែកនេះ ។ ឧទាហរណ៍ : គ្រូពេទ្យ ដែលព្យាបាលបុគ្គលពេស្យាដែលមានជម្ងឺ មិនទទួលខុសត្រូវយោងតាម ផ្នែកនេះ ដោយសារតែ គ្រូពេទ្យនោះ មិនបានផ្តល់សេវកម្មដោយចេតនា ដើម្បីជួយសម្រួល ឬ បិទបាំង សកម្មភាពពេស្យាចារ ។ ដូចគ្នានេះដែរ អង្គការមិនមែនរដ្ឋាភិបាល ឬ ភ្នាក់ងារផ្សេងទៀត ដែលផ្តល់សេវាកម្មឱ្យបុគ្គលពេស្យា មិនទទួលខុសត្រូវ យោងតាមផ្នែកនេះ.. ។ ប្រហាក់ប្រហែលគ្នានេះដែរ ហេតុការដែលថា មន្ត្រីនគរបាលបានបញ្ឈប់អតិថិជន ពីការវាយដំលើបុគ្គលពេស្យា មិនមានន័យថា មន្ត្រីនគរបាលនោះ បានការពារ អំពើពេស្យាចារ របស់បុគ្គលពេស្យានោះទេ ។

### "៣. ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ "[២៤]

ផ្នែកទី ៣ ចែងពីករណីដែលអ្នកប្រព្រឹត្ត ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ ។ ឧទាហរណ៍ : ប្រសិនបើ ម្ចាស់ផ្ទះបន ឬ អ្នកធ្វើការនៅផ្ទះបន បានសុំឱ្យជនណាម្នាក់ធ្វើការឱ្យផ្ទះ បន ដោយឱ្យប្រាក់ ៣០០ ដុល្លា ក្នុងមួយខែ អំពើនោះបង្កើតឱ្យមានការជ្រើសរើសឱ្យធ្វើអំពើពេស្យាចារ ។ ប្រសិនបើអ្នកប្រព្រឹត្តបានបង្រៀនជនណាម្នាក់ឱ្យធ្វើការក្នុងផ្ទះបន និងដោះស្រាយជាមួយមេបន អំពើនោះនឹងបង្កើតឱ្យមានការបណ្តុះបណ្តាល ការបណ្តុះបណ្តាល ឱ្យធ្វើអំពើពេស្យាចារ ។ ប្រសិនបើ ម្ចាស់ផ្ទះបន ឬ អ្នកធ្វើការនៅផ្ទះបនអូសទាញជនណាម្នាក់ឱ្យធ្វើការនៅផ្ទះបន ជាបុគ្គលពេស្យា ដោយផ្តល់ ឬ សន្យាឱ្យប្រាក់ អំពើអូសទាញនោះ គឺជាសញ្ចារកម្ម ។

ដើម្បីឱ្យអ្នកប្រព្រឹត្តទទួលខុសត្រូវក្នុងផ្នែកនេះ អ្នកប្រព្រឹត្តត្រូវតែមានគោលបំណងឱ្យជនដទៃទៀត ប្រព្រឹត្តអំពើពេស្យាចារ ក្នុងការជ្រើសរើស ការអូសទាញ ឬ បណ្ដុះបណ្ដាលរបស់ខ្លួន ។ ហេតុដូច្នេះ ជនណាដែលមិនបាន ដឹងថាបានជ្រើសរើស អូសទាញ ឬ បណ្ដុះបណ្ដាល នរណាម្នាក់ មិនទទួលខុសត្រូវ យោងតាមផ្នែកនេះទេ ។ ដូចគ្នានេះ ដែរ ប្រសិនបើ ការជ្រើសរើស ការអូសទាញ ឬ ការបណ្ដុះបណ្ដាល មិនត្រូវបានប្រព្រឹត្តឡើងដោយមានចេតនា ដើម្បីធ្វើឱ្យចម្រើនដល់អំពើពេស្យាចារ ហេតុដូច្នេះ អំពើនោះមិនទទួលខុសត្រូវយោងតាមមាត្រានេះទេ ។

ឧទាហរណ៍ ៖ អង្គការសុខភាពសាធារណៈ ដែលធ្វើសកម្មភាពតាមផ្ទះ ឬ អប់រំ ដើម្បីប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជម្ងឺអេដស៍ ( ស្របទៅតាម ច្បាប់ស្ដីពី ការបង្ការ និងការប្រយុទ្ធ ទប់ស្កាត់ការរីករាលដាល មេរោគអេដស៍/ជម្ងឺអេដស៍ ឆ្នាំ ២០០២[25] និងគោលការណ៍ណែនាំអនុវត្ត នៃច្បាប់នេះ[26] និង បទបញ្ជារបស់ សម្ដេចនាយករដ្ឋមន្ត្រី ស្ដីពី កម្មវិធីប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០%) អាចធ្វើការផ្សព្វផ្សាយឱ្យយល់ពីការប្រើប្រាស់ស្រោមអនាម័យ ឬយល់ពីបច្ចេកទេសសុវត្ថិភាពផ្លូវភេទ។ យ៉ាងណាមិញ គោលបំណងនៅពីខាង ក្រោយ សកម្មភាពខាងលើនេះ គឺដើម្បីបង្ការការរីករាលដាល មេរោគអេដស៍/ជម្ងឺអេដស៍ និងកុំឱ្យប្រព្រឹត្តអំពើពេស្យាចារតទៅទៀត ។ ហេតុដូច្នេះសកម្មភាពបែបនេះមិនត្រូវទទួលខុសត្រូវយោងតាមផ្នែកនេះទេ ។ ប្រហាក់ប្រហែលគ្នានេះដែរ ផ្នែកនេះមិនបានហាមឃាត់ អង្គការដែលគាំពារសិទ្ធិរបស់បុគ្គលពេស្យា ឬ សកម្មភាពណាមួយ ដែលធ្វើឡើងដោយអង្គការនោះ ដោយសារតែចេតនា គឺដើម្បីការពារបុគ្គលពេស្យា និងការពារសិទ្ធិរបស់ពួកគេ មិនមែនដើម្បីធ្វើឱ្យរីកចម្រើនដល់សកម្មភាពអាជីវកម្មរបស់បុគ្គលពេស្យាទេ ។ ជាក់ស្ដែងយោងតាមច្បាប់ស្ដីពីការបង្ការ និងការ ប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ឆ្នាំ ២០០២ និងគោលការណ៍ណែនាំអនុវត្តរបស់ច្បាប់ នេះ អង្គការសុខភាពឯកជន មានអាណត្តិធ្វើសកម្មភាពអប់រំ ដើម្បីជម្រុញ ឱ្យមានការគោរពសិទ្ធិមនុស្សរបស់ ប្រជាពលរដ្ឋដែលមានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និងប្រជាពលរដ្ឋ ដែលងាយ ទទួលរងគ្រោះដោយមេរោគអេដស៍ ដូចជាអ្នករកស៊ីផ្លូវភេទជាដើម ។[27]

---

[25] មាត្រា ៣ នៃ ច្បាប់ស្ដីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ឆ្នាំ ២០០២ អំពាវនាវសុំឱ្យមាន ការប្រមូលមនុស្សនៅក្នុងសហគមន៍ ព្រមទាំងអង្គការ និងសមាគម ចូលរួមក្នុងគម្រោង និងការអនុវត្តកម្មវិធីអប់រំ និងពត៌មានស្ដីពី មេរោគអេដស៍/ជម្ងឺអេដស៍ ដែលរួមមានទាំងវិធានការណ៍បង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលនៃជម្ងឺអេដស៍ ។ មាត្រា ៤ នៃច្បាប់នេះចែងថា "ការអប់រំផ្សព្វផ្សាយ ស្ដីពីមេរោគអេស៍/ជម្ងឺអេដស៍ ព្រមទាំងការបំពាក់បំប៉នបន្ថែម ជាការភារកិច្ចរបស់អ្នកផ្ដល់សេវា ការថែទាំសុខភាព នៅក្នុងផ្នែកឯកជន ដើម្បីចូលរួមចំណែក ក្នុងការបង្ការ និងប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺឆ្លងអេដស៍" មាត្រា ១១ នៃ ច្បាប់ស្ដីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ ការរីករាលដាល មេរោគអេដស៍/ជម្ងឺអេដស៍ តម្រូវថាសម្ភារៈសម្រាប់បង្ការ ការចម្លងមេរោគអេដស៍ទាំងនេះ មានដូចជាស្រោមអនាម័យ ត្រូវមានភ្ជាប់មកជាមួយនូវពត៌មាន ដែលពន្យល់អំពីវិធីប្រើប្រាស់ដោយត្រឹមត្រូវនូវវត្ថុធាតុទាំងនេះ ។

[26] ជំពូកទី ៥ នៃគោលការណ៍ណែនាំអនុវត្ត នៃ ច្បាប់ស្ដីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ចែងថា "យោងតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល....... សេវាកម្មព្យាបាលជម្ងឺកាមរោគ គួរតែមានបញ្ចូលការផ្ដល់ពត៌មាន និងការអប់រំ ដូចជាការជម្រុញ និងការចែកចាយស្រោមអនាម័យ" ។

[27] មាត្រា ៤ នៃ ច្បាប់ស្ដីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ផ្ដល់អណត្តិដល់ អ្នកផ្ដល់ការថែទាំ សុខភាពឯកជនធ្វើការបំពាក់បំប៉នបន្ថែម ត្រូវរួមបញ្ចូលការពិភាក្សា អំពីបញ្ហាក្រមសីលធម៌ដែលទាក់ទងនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ ជាពិសេសរក្សារភាពសម្ងាត់ និងការគោរពសិទ្ធិបុគ្គល" ជំពូកទី ២ នៃគោលការណ៍ណែនាំអនុវត្ត នៃច្បាប់ស្ដីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ តម្រូវថា "ពត៌មាន និងឯកសារអប់រំទាំងអស់ គួរតែជម្រុញឱ្យមានការគោរពសិទ្ធិបុគ្គល ដែលមានផ្ទុកមេរោគអេដស៍ និងបុគ្គលដែលងាយទទួលរងនូវមេរោគអេដស៍.... និងអំពីរបៀបគោរពសិទ្ធិបុគ្គល......ជាពិសេសប្រយុទ្ធ ប្រឆាំងនឹងមេរោគអេដស៍/ជម្ងឺអេដស៍ ឱ្យបានជោគជ័យ" ។

### "៤. ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ"[២៨]

ផ្នែកនេះ ផ្តន្ទាទោសជនណាដែលធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ ។

ពាក្យថា " គាបសង្កត់ " ក្នុងមាត្រានេះ រួមមានជាអាទិ៍ : ការបង្ខំ ការគាបសង្កត់ ឬ ការដាក់កំហិតលើរាងកាយ ព្រមទាំងប្រភេទនៃការគាបសង្កត់ផ្សេងទៀត ដែលរួមមាន : ការគាបសង្កត់ហិរញ្ញវត្ថុ ឬ ផ្លូវចិត្ត ។ ឧទាហរណ៍ : ប្រសិនបើ អ្នកប្រព្រឹត្ត បានគំរាមកំហែង ដកការគាំទ្រ ពីកូនស្រីរបស់គាត់ ប្រសិនបើ កូនស្រីរបស់គាត់មិនបានប្រព្រឹត្ត អំពើពេស្យាចារដោយផ្ទាល់ខ្លួន ហេតុដូច្នេះ អ្នកប្រព្រឹត្តនេះបានធ្វើការគាបសង្កត់ ទៅលើកូនស្រីរបស់ខ្លួនឱ្យធ្វើជាស្រីពេស្យា ។

ផ្នែកខាងក្រោមនេះ តម្រូវឱ្យអ្នកប្រព្រឹត្តមានចេតនា ពោលគឺ អ្នកប្រព្រឹត្តបានធ្វើការគាបសង្កត់ ដោយចេតនា ឱ្យបុគ្គលម្នាក់ផ្សេងទៀត ធ្វើពេស្យាចារ ។ ទោះបីជា បុគ្គលដែលទទួលរងនូវការគាបសង្កត់នោះ កាលពីមុនជាបុគ្គលពេស្យាចារ ឬ មិនមែនជាបុគ្គលពេស្យាចារក៏ដោយ ។ វាមិនសំខាន់ទេថា ទោះបីជាជនដែលទទួលរង នូវការគាបសង្កត់នោះ បានចុះចាញ់ទទួលយកនូវការគាបសង្កត់នោះក៏ដោយ ។ បានន័យថា អ្នកប្រព្រឹត្តមិនអាចទាមទារឱ្យមានការការពារ ដែលថាជនទទួលរងនូវការគាបសង្កត់នោះ បានយល់ព្រមធ្វើពេស្យាចារ ប្រសិនបើការយល់ព្រមនោះមានវិការៈ ។

ក្នុងករណី មានការប្រើប្រាស់អំពើហិង្សា ក្នុងដំណើរប្រព្រឹត្តអំពើសញ្ចារកម្មប្រឆាំងនឹងជនណាម្នាក់ ដែលជាបុគ្គលពេស្យារួចជាស្រេចហើយ ( មិនមែនជាទម្រង់នៃការគាបសង្កត់ ដើម្បីអូសទាញជននោះ ឱ្យក្លាយជាបុគ្គលពេស្យា) ហេតុដូច្នេះ ជនល្មើសអាចទទួលទោសយោងតាមមាត្រា ២៧ ចំណុចទី ៣ ( ស្ថានទម្ងន់នៃសញ្ចារកម្ម ) ។

កត់សំគាល់ផងដែរថាក្នុងករណី " ការបោកបញ្ឆោត ការបំពានដោយអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគម្រាមកំហែង ឬ មធ្យោបាយបង្ខិតបង្ខំផ្សេងទៀត " ត្រូវបានប្រើប្រាស់ដើម្បីជ្រើសរើស ឬ អូសទាញឱ្យជនណាម្នាក់ធ្វើពេស្យាចារ ហេតុដូច្នេះជនល្មើសនោះ ក៏អាចទទួលទោសយោងតាមមាត្រា ១២ " ការជ្រើសរើស ដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចនី " នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

កថាខ័ណ្ឌទី ២ នៃមាត្រានេះ ចែកអំពើជា បី ប្រភេទ ដែលអំពើទាំង បី នោះ ដូចគ្នានឹងអំពើសញ្ចារកម្មដែរ ។

### "១. អំពើធ្វើជាអន្តរការី រវាងបុគ្គលដែលធ្វើពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬ ឱ្យលាភការ ដល់ពេស្យាចារជនដទៃ"[២៩]

---

[28] បទប្បញ្ញត្តិនេះដូចគ្នា នឹងបទប្បញ្ញត្តិ នៃមាត្រា ២៨៤ ចំនុចទី ៤ ស្តីពី សញ្ចារកម្ម នៃក្រមព្រហ្មទណ្ឌ ។

[29] បទប្បញ្ញត្តិនេះប្រហាក់ប្រហែលគ្នា នឹងបទប្បញ្ញត្តិ នៃមាត្រា ២៨៥ "បទអន្តរការរវាងបុរស ឬស្ត្រីពេស្យា និងសញ្ចារិក ឬសញ្ចារិកា" នៃក្រមព្រហ្មទណ្ឌ ។

ផ្នែកទី ១ ខាងក្រោមនេះ ចែងពីករណីដែល អ្នកប្រព្រឹត្តធ្វើជាអន្តរការី រវាងបុគ្គល ពីរ នាក់ : (ក) បុគ្គលពេស្យា និង (ខ) បុគ្គលដែលប្រកបអាជីវកម្ម ឬ ឱ្យលាភការដល់ពេស្យាចារ ។

" ប្រកបអាជីវកម្ម " ក្នុងផ្នែកនេះ មានន័យថា បុគ្គលដែលទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីសកម្មភាពពេស្យាចារ ។ (សូមពិនិត្យមើលការពិភាក្សាខាងលើទាក់ទងនឹង " ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពី អំពើពេស្យាចារ របស់ជនដទៃ " ) ។

" ឱ្យលាភការ " ក្នុងផ្នែកនេះ មានន័យថា បុគ្គលនោះផ្តល់ប្រាក់ឱ្យបុគ្គលពេស្យា ចំពោះសកម្មភាពពេស្យាចាររបស់ខ្លួន ។

ដើម្បីឱ្យអ្នកប្រព្រឹត្តទទួលខុសត្រូវក្នុងផ្នែកនេះ បុគ្គលដែលធ្វើជាអន្តរការី ត្រូវតែមានចេតនាចំពោះ សកម្មភាពរបស់ខ្លួនជាអន្តរការី ដើម្បីជម្រុញ ឬ សម្រួលអំពើពេស្យាចារ ។ ឧទាហរណ៍ : ប្រសិនបើ ជនណាម្នាក់ណែនាំបុគ្គលពេស្យាទៅឱ្យម្ចាស់ ឬ អ្នកគ្រប់គ្រងផ្ទះបន ដោយសង្ឃឹមថា បុគ្គលពេស្យានោះអាចធ្វើការនៅផ្ទះបន ហេតុដូច្នេះ អំពើណែនាំនេះ អាចត្រូវផ្តន្ទាទោស យោងតាមផ្នែកនេះ ដោយសារតែម្ចាស់ និងអ្នកគ្រប់គ្រងផ្ទះបន គឺជាជនដែលស្វែងរកប្រយោជន៍ ឬ ឱ្យលាភការដល់អំពើពេស្យាចាររបស់ជនដទៃ ។ យ៉ាងណាមិញ ប្រសិនបើ ជនណាម្នាក់ណែនាំបុគ្គលពេស្យាឱ្យទៅម្ចាស់ ឬ អ្នកគ្រប់គ្រងផ្ទះបន ដោយសង្ឃឹមថា បុគ្គលពេស្យានោះអាចធ្វើការងារនៅផ្ទះបន នោះ ជាអ្នកដាំស្ល ហេតុដូច្នេះ អំពើនេះមិនស្ថិតនៅក្នុងផ្នែកនេះទេ ។

ស្របនឹងគំនិត ជាអន្តរការីនៃសញ្ចារកម្ម អ្នកប្រព្រឹត្តជាអន្តរការីនោះ ត្រូវតែទទួល ឬ រំពឹងថា នឹងទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុខ្លះ ពីអំពើរបស់គាត់ ។ ឧទាហរណ៍ : អ្នកបើកតាក់ស៊ី ដែលដឹកអតិថិជន ទៅកាន់ផ្ទះបន និងទទួលបានកំរៃជើងសារពីផ្ទះបន ត្រូវទទួលការផ្តន្ទាទោស យោងតាមផ្នែកនេះ ។ ប៉ុន្តែ ពួកម៉ាក ដែលដឹកពួកម៉ាកម្នាក់ទៀត ទៅកាន់ផ្ទះបន និងមិនបានទទួលកំរៃជើងសារ ពីផ្ទះបន មិនត្រូវទទួលការផ្តន្ទាទោស យោងតាមផ្នែកនេះ ។

## "២. អំពើរបស់ជនណាដែលបានជួយសម្រួល ឬ បិទបាំងនូវធនធាន ដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ចារកម្ម"[៣០]

ផ្នែកទី (២) ចែងពីករណី ដែលអ្នកប្រព្រឹត្តបានជួយសម្រួល ឬ បិទបាំងនូវធនធាន ដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ចារកម្ម ។

បទប្បញ្ញត្តិនេះ ធ្វើឱ្យនឹកឃើញដល់មាត្រា ៦ នៃអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលដាក់ឱ្យទៅជាទោសព្រហ្មទណ្ឌ ចំពោះអំពើលាងប្រាក់ចំណូលដែលបានពីការប្រព្រឹត្តបទល្មើស និង ការលាក់បាំង និងការក្លែងបន្លំ ប្រាក់ចំណូលបានពីបទល្មើស ។

[30] បទប្បញ្ញត្តិនេះប្រហាក់ប្រហែលគ្នា នឹងបទប្បញ្ញត្តិ នៃមាត្រា ២៨៦ "ធនធានដែលបានមកពីសញ្ចារកម្ម" នៃក្រមព្រហ្មទណ្ឌ ។

" **សម្រួល....ធនធាន** " មានន័យថា ទាក់ទងនឹងការជួញដូរ (រួមមាន : ការដឹកជញ្ជូន ការផ្ទេរ ការបង់ ឬ ការទទួលប្រាក់ ) ដែលទាក់ទងនឹង ធនធានដែលបានទទួលមកពីអំពើសញ្ញារកម្ម ។

ពាក្យថា " ធនធាន " ដូចត្រូវបានប្រើនៅទីនេះ រួមមានជាអាទិ៍ លាភការដែលទទួលជាប្រាក់ ឬ ជាវត្ថុ ឧបករណ៍រូបិយវត្ថុ (ដែលរួមាន ប្រាក់ មូលលប្បទានប័ត្រ លិខិតបញ្ជាប្រាក់ ការផ្ទេរប្រាក់តាមអេឡិចត្រូនិក ) វត្ថុមានតម្លៃ ( ឧទាហរណ៍ : គ្រឿងអលង្ការ សំលៀកបំពាក់ ។ល។ ) ទ្រព្យសម្បត្តិ ដែលមានរូបរាង (ឧទាហរណ៍ : ផ្ទះ ដី អាគារ ។ល។ ) ទ្រព្យសម្បត្តិដែលគ្មានរូបរាង ឬ សិទ្ធប្រត្យក្ស (ឧទាហរណ៍ : សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ សិទ្ធិលក់ ឬ សិទ្ធិជួល ប្រភេទណាមួយនៃចលនទ្រព្យ ឬអចលនទ្រព្យ ) សេវាកម្ម ការបង់ប្រាក់ដោយផ្ទាល់ ឬ ដោយប្រយោល ឬ ថ្លៃឈ្នួល ( ថ្លៃឈ្នួលដែលបង់ទៅឱ្យតាមរយៈ ឬ ក្នុង នាមជនផ្សេងទៀត ) ព័ត៌មានដែលមានតម្លៃ ឬ ការគ្រប់គ្រង លើមនុស្ស ។

" **បិទបាំងឬ...ធនធាន** " មានន័យថា ជាការក្លែងបន្លំ ឬ លាក់បាំង ចំនួន ប្រភេទ ប្រភព ទីកន្លែង កម្មសិទ្ធិ ឬ ការគ្រប់គ្រងលើធនធាន ។

ដើម្បីឱ្យអ្នកប្រព្រឹត្តទទួលខុសត្រូវក្នុងផ្នែកនេះ អ្នកប្រព្រឹត្តនោះត្រូវតែ មានការដឹង និងមានចេតនា ។ អ្នកប្រព្រឹត្តត្រូវដឹងថា ធនធានបានទទួលមកពីអំពើ សញ្ញារកម្ម និង មានចេតនា សម្រួល ឬ បិទបាំងធនធានទាំងនេះ ដើម្បីជម្រុញឱ្យមានអំពើសញ្ញារកម្ម ។

ហេតុដូច្នេះ បុគ្គលណាដែលមិនបានដឹង ឬ មិនមានចេតនា សម្រួល ឬ បិទបាំងធនធាន ដែលបានមកពីអំពើសញ្ញារកម្ម មិនត្រូវទទួលខុសត្រូវ យោងតាមផ្នែកនេះ ។ ឧទាហរណ៍ : ប្រសិនបើ ម្ចាស់ផ្ទះបន ដាក់ប្រាក់ដែលគាត់ទទួលបានពីអំពើសញ្ញារកម្ម នៅក្នុងគណនីធនាគារ ឬ ផ្ទេរប្រាក់នោះ ពីគណនីធនាគារ ធនាគារនោះ មិនទទួលខុសត្រូវចំពោះអំពើសញ្ញារកម្ម យោងតាមផ្នែកនេះ ដោយសារតែត្រូវសន្មត់ថា ធនាគារមិនបានដឹងថា លុយនោះបានមកពីអំពើសញ្ញារកម្ម ។ ប៉ុន្តែប្រសិនបើ អ្នកគ្រប់គ្រងផ្ទះបន យកលុយដែលទទួលបានមកពីអំពើសញ្ញារកម្ម និងបានដាក់លុយនោះនៅក្នុងគណនីធនាគារ (ឬ លាក់លុយនោះ នៅទីកន្លែងផ្សេងទៀត ឬ ក្លែងបន្លំ ថាលុយនោះហាក់បីដូចជាបានទទួលពីប្រភពផ្សេងទៀត ) ហេតុដូច្នេះ អ្នកគ្រប់គ្រងផ្ទះបន អាចត្រូវទទួលការផ្តន្ទាទោស យោងតាមផ្នែកនេះ ។

**" ៣. អំពើរារាំងដល់ការបង្ការ ការជួយ ឬ ការអប់រំជាថ្មី ដោយនីត្តាក់ងារសាធារណៈ ឬ ដោយអង្គការឯកជន ដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ដល់បុគ្គល ដែលប្រព្រឹត្តពេស្យាចារ ឬ កំពុងមានគ្រោះ ដោយការធ្វើពេស្យាចារ "**[៣១]

[31] បទប្បញ្ញត្តិនេះដូចគ្នា នឹងបទប្បញ្ញត្តិ នៃមាត្រា ២៨៧ "បទរារាំងដល់ការបង្ការអំពើពេស្យាចារ" នៃក្រមព្រហ្មទណ្ឌ ។

ផ្នែកទី ៣ ចែងពីករណីដែលអ្នកប្រព្រឹត្ត រារាំងដល់កិច្ចខិតខំប្រឹងប្រែងរបស់ទីភ្នាក់ងារសាធារណៈ ឬ អង្គការឯកជន ដែលទីភ្នាក់ងារ ឬ អង្គការនោះធ្វើឡើង ដើម្បីជួយ ឬ អប់រំជាថ្មី លើបុគ្គលដែលប្រព្រឹត្តអំពើពេស្យាចារ ឬ ដើម្បីទប់ស្កាត់ពួកគេ កុំឱ្យស្ថិតក្នុងគ្រោះថ្នាក់នៃអំពើ ពេស្យាចារ ។

ដើម្បីឱ្យអ្នកប្រព្រឹត្តទទួលខុសត្រូវក្នុងផ្នែកនេះ បុគ្គលដែលរារាំងកិច្ចខិតខំប្រឹងប្រែងរបស់ទីភ្នាក់ងារសាធារណៈ ឬ អង្គការឯកជន ត្រូវមានចេតនាសម្រួល ឬ ជម្រុញឱ្យមានអំពើពេស្យាចារ ។ អំពើណាមួយ ដែលរារាំងដោយចៃដន្យ នូវអំពើទប់ស្កាត់ ការជួយ ឬ ការអប់រំជាថ្មី ដើម្បីជាគុណប្រយោជន៍ដល់បុគ្គលដែលប្រព្រឹត្ត អំពើពេស្យាចារ ឬ ស្ថិតក្នុងគ្រោះថ្នាក់ដោយអំពើពេស្យាចារ មិនបង្កើតឱ្យមានអំពើសញ្ជារកម្មទេ យោងតាមផ្នែកនេះ ។ ជាពិសេស បទប្បញ្ញត្តិនេះ មិនអនុវត្តចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬ នីតិបុគ្គលផ្សេងទៀត ដែលធ្វើការងារដើម្បីការពារ ឬ ជាគុណប្រយោជន៍ដល់បុគ្គលពេស្យា ទោះបីជាក្នុងករណី ដែលអំពើទាំងនោះ មិនមានចេតនាបិទបាំង ការជួយរបស់នីតិបុគ្គលផ្សេងទៀត ។

ឧទាហរណ៍ ៖ កន្លែងផ្តល់ជម្រកដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាលមួយ ធ្វើការថែរក្សាបុគ្គលពេស្យាដែលទទួលបានពីនគរបាល និងលើកទឹកចិត្តឱ្យពួកគេចូលក្នុងកម្មវិធីអប់រំសារជាថ្មី ដែលតម្រូវឱ្យពួកគេមិនឱ្យចាកចេញពីកន្លែងផ្តល់ជម្រកនោះ ។ មេធាវីជំនួយផ្នែកច្បាប់បានមកដល់ និងចង់ឱ្យអតិថិជនរបស់ខ្លួន ដែលជាបុគ្គលពេស្យាត្រូវដោះលែង ដោយសារតែមេធាវីអះអាងថា នេះជាការរឹតបន្តឹងមិនស្របច្បាប់ ទៅលើសេរីភាពរបស់អតិថិជនគាត់ ( ការបង្ខាំងខុសច្បាប់ ) ។ ទោះបីជាកន្លែងផ្តល់ជម្រក ដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល និងមេធាវីកំពុងតែព្យាយាមរារាំងផ្នែកផ្សេងទៀតក៏ដោយ ទាំងអង្គការ និងមេធាវីនោះ មិនអាចទទួលទោស យោងតាមបទប្បញ្ញត្តិនេះ ដោយសារតែមិនមានភាគីណាមួយប្រព្រឹត្ត ដោយមានចេតនាសម្រួល ឬ ជម្រុញឱ្យមានអំពើពេស្យាចារទេ ។

## មាត្រា ២៦.  សញ្ជារកម្ម

ជនណាដែលប្រព្រឹត្តសញ្ជារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ ( ពីរ ) ឆ្នាំ ដល់ ៥ ( ប្រាំ ) ឆ្នាំ .

មាត្រានេះ កំណត់ការផ្តន្ទាទោសចំពោះ អំពើសញ្ជារកម្ម នៃអំពើពេស្យាចារ ដែលមានការកំណត់និយមន័យក្នុងមាត្រា ២៥ ខាងលើ ។ ជនល្មើស ត្រូវតែទទួលការផ្តន្ទាទោស យោងតាមមាត្រានេះ មិនមែនយោងតាមមាត្រា ២៥ ទេ ។

មាត្រានេះ ផ្តន្ទាទោសបទល្មើសសញ្ជារកម្ម នៃអំពើពេស្យាចារ ដែលមានថិរវេលានៃទោសជាប់ពន្ធនាគារពី ២ ( ពីរ ) ឆ្នាំ ដល់ ៥ ( ប្រាំ ) ឆ្នាំ ។ ទោសបន្ថែម ក៏អាចត្រូវអនុវត្តបាន តាមអំណាចឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានក្នុងមាត្រា ៤៨ នៃច្បាប់នេះ ។

គួរកត់កត់សំគាល់ថា អាចមានថិរវេលានៃទោសជាប់ពន្ធនាគារយូរជាងនេះ ក្នុងករណីដែលអំពើសញ្ជារកម្មត្រូវគេយល់ថាជាស្ថានទម្ងន់ ( មាត្រា ២៧ ) ឬ ប្រព្រឹត្តឡើងទាក់ទងនឹងអំពើ ពេស្យាចារកុមារ ( មាត្រា ២៨ ) ឬ សម្រេចបានតាមមធ្យោបាយ ធ្វើទារុណកម្ម ឬ អំពើឃោរឃៅ ( មាត្រា ២៩ ) ។

ដូចចែងក្នុងមាត្រា ៤ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតនៃនីតិបុគ្គល ឬ ភារប្បទាយី ត្រូវគេរកឃើញថា មានទោសប្រព្រឹត្តបទល្មើសនេះ តុលាការអាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយី នោះ ដោយមានទោសបន្ថែមដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់ រួមមានដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ (មាត្រា៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣) ឬ ការបិទការផលិត (មាត្រា ៤៨ កថាខ័ណ្ឌទី ៤)។ (សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត) ។

គួរកត់សំគាល់ មាត្រា ២៨៤ មាត្រា ២៨៥ មាត្រា ២៨៦ និងមាត្រា ២៨៧ នៃក្រមព្រហ្មទណ្ឌដែលទាក់ទង នឹងអំពើដូចគ្នានៃសញ្ចារកម្ម ដែលមានកំណត់និយមន័យនៅមាត្រា ២៥ និងមាត្រា ២៦ នៃ ច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចែងពីទោសជាប់ពន្ធនាគារដូចគ្នា ពី ២ឆ្នាំ ទៅ ៥ឆ្នាំ ។ យ៉ាងណាមិញ មាត្រា ក្នុងក្រមព្រហ្មទណ្ឌ ដាក់បញ្ចូលទោសពិន័យជាប្រាក់បន្ថែម ពី ៤លានរៀល ទៅ ១០លានរៀល ។ ដោយសារតែមានវិធាន ដែលបានចែងក្នុង មាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌដែលចែងថា ក្នុងគ្រប់ករណីដែលបទល្មើស ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស ១) ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ២) ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ ៣) ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ហេតុដូច្នេះ យោងតាមក្រមព្រហ្មទណ្ឌ ពេលខ្លះចៅក្រមអាចដាក់ទោសត្រឹមពិន័យជាប្រាក់សម្រាប់បទសញ្ចារកម្មពេស្យាចារ ។

ចំពោះការផ្តន្ទាទោសមិនស្របគ្នា រវាងបទប្បញ្ញត្តិ ស្តីពីបទសញ្ចារកម្ម នៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរ មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ អាចត្រូវបានដោះស្រាយ យោងតាមគោលការណ៍ នៃការបកស្រាយច្បាប់ និងវិធានដែលមានចែង នៅក្នុងមាត្រា ៦៧១ និង មាត្រា ៦៦៨ នៃក្រម ព្រហ្មទណ្ឌ (សូមមើលការការពិភាក្សា ស្តីពី "គោលការណ៍ នៃការបកស្រាយច្បាប់"នៅក្នុងសេចក្តីផ្តើម និងនៅក្នុង មាត្រា ៥០ ខាងក្រោម) ។ ដោយផ្អែកទៅលើទៅលើគោលការណ៍នៃការបកស្រាយច្បាប់ ការផ្តន្ទាទោសចំពោះ បទសញ្ចារកម្ម យោងតាមក្រមព្រហ្មទណ្ឌថ្មី ជាទូទៅ នឹងត្រូវយកមកប្រើជំនួស ការផ្តន្ទាទោស ចំពោះបទសញ្ចារកម្ម ដែលមានចែង ក្នុងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ទោះបីជាយ៉ាងណាក៏ដោយ យោងទៅតាម "គោលការណ៍ឯកត្តកម្មនៃទោស" ក្នុងមាត្រា ៩៦ នៃក្រម ព្រហ្មទណ្ឌ ចំពោះករណីធ្ងន់ធ្ងរ នៃបទសញ្ចារកម្ម គួរតែត្រូវធ្វើការផ្តន្ទាទោសដាក់ពន្ធនាគារ មិនមែនដាក់តែទោស ពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះទេ ដោយសារផ្អែកទៅលើកត្តាជាច្រើន ដូចជា ទំហំនៃប្រតិបត្តិការ ឬ ចំនួនពេស្យាចារ ដែលពាក់ព័ន្ធ ចំនួននៃប្រាក់ដែលទទួលបាន ដោយសញ្ចារិក/សញ្ចារិកា រយៈពេលដែលជនល្មើសប្រព្រឹត្ត សកម្មភាព និង ករណីមិនរាងចាលជាដើម ។

ប៉ុន្តែ បើបទសញ្ចារកម្មធ្វើឡើងក្នុងបរិបទជួញដូរមនុស្ស ជនល្មើស គប្បីតែត្រូវចោទប្រកាន់ និងផ្តន្ទាទោស ដាក់ពន្ធនាគារឱ្យធ្ងន់ តាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលជាច្បាប់ពិសេស មានអាទិភាពលើច្បាប់ព្រហ្មទណ្ឌ ទាក់ទងនឹងបទល្មើសជួញដូរ) ។

**មាត្រា ២៧.- ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម**

ជនណាប្រព្រឹត្តសញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចខាងក្រោមនេះ :

១- កាលបើសញ្ចារិក សញ្ចារិកា ឬ ជនជាមេពេស្យាជាបុព្វញាតិ ឬ បច្ឆាញាតិ មានខាន់ស្លា អត់ខាន់ស្លា ឬ សាច់បង្កើត ឬ ចិញ្ចឹម របស់បុគ្គលដែលធ្វើពេស្យាចារ ។

២- កាលបើសញ្ចារិក សញ្ចារិកា ឬ ជនជាមេពេស្យា រំលោភអំណាច ដែលមុខងាររបស់ខ្លួនផ្តល់ឱ្យទៅលើបុគ្គលដែលធ្វើពេស្យាចារ ។

៣- កាលបើសញ្ចារិក សញ្ចារិកា ឬ ជនជាមេពេស្យាប្រើហឹង្សា ឬ ការបង្ខិតបង្ខំ ចំពោះបុគ្គលដែលធ្វើពេស្យាចារ ។

៤- កាលបើសញ្ចារកម្មត្រូវបានប្រព្រឹត្តជាក្រុមមានការចាត់តាំង ។

៥- កាលបើសញ្ចារកម្មត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ ។

មាត្រានេះ ចែងពីបទល្មើស និងធ្វើការផ្តន្ទាទោស ចំពោះស្ថានទម្ងន់ទោសនៃអំពើសញ្ចារកម្មទាំង ប្រាំ ប្រភេទ ។ ជនណាដែលប្រព្រឹត្តប្រភេទណាមួយ ក្នុងចំណោមប្រភេទទាំង ប្រាំ នៃស្ថានទម្ងន់ទោសខាងលើ ត្រូវផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរជាងនេះ ដោយត្រូវជាប់ពន្ធនាគារ ពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។ មិនមែនពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ដូចមានចែងក្នុងមាត្រា ២៦ ឡើយ ។

កត់សំគាល់ថាមាត្រានេះ ប្រហាក់ប្រហែលគ្នានឹងបទប្បញ្ញត្តិ នៃក្រមព្រហ្មទណ្ឌថ្មី (សូមមើល គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៥ "សញ្ចារកម្ម" មាត្រា ២៨៨ "ស្ថានទម្ងន់ទោសទាក់ទងនឹងចារី" ដែលចែងពីការផ្តន្ទាទោស ដាក់ពន្ធនាគារ ពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។

ដើម្បីផ្តន្ទាទោស យោងតាមមាត្រានេះ ជនល្មើសត្រូវតែ :

ក) មានទោសពីបទសញ្ចារកម្មនៃអំពើពេស្យាចារ ដូចមានការកំណត់និយមន័យក្នុងមាត្រា ២៥ ខាងលើ និង

ខ) ប្រព្រឹត្តប្រភេទណាមួយ ក្នុងចំណោមប្រភេទនៃស្ថានទម្ងន់ទោស ខាងក្រោម

ក្នុងករណីបែបនេះ ជនល្មើសគួរត្រូវចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រានេះ មិនមែនយោងតាមមាត្រា ២៥ និង មាត្រា ២៦ ។

ជាការសំខាន់គួរកត់សំគាល់ថា ត្រូវតែអានមាត្រានេះ ជាមួយគ្នានឹងមាត្រា ២៥ (និយមន័យសញ្ចារកម្ម ) និង មាត្រា ២៦ ( សញ្ចារកម្ម )។ ឧទាហរណ៍ : ក្នុងករណីដែលបទប្បញ្ញត្តិយោងតាមមាត្រានេះ សំដៅទៅលើ " បុគ្គលពេស្យា " វាមិនគ្រាន់តែសំដៅទៅលើ ជនណាម្នាក់ដែលជាបុគ្គលពេស្យារួចជាស្រេចទេ តាមរយៈអនុវត្ត នៃមាត្រា ២៥ បទប្បញ្ញត្តិក្នុងមាត្រានេះ ក៏អនុវត្តក្នុងករណីដែលទាក់ទិននឹងជនណាម្នាក់ អាចមិនទាន់ជាបុគ្គលពេស្យា

នៅឡើយ ប៉ុន្តែត្រូវបានជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលដើម្បីប្រព្រឹត្តអំពើពេស្យាចារ ( មាត្រា ២៥ កថាខ័ណ្ឌទី ៣) ឬ ជនណាម្នាក់ដែលទទួលរង ការគាបសង្កត់ឱ្យក្លាយជាបុគ្គលពេស្យា ( មាត្រា ២៥ កថាខ័ណ្ឌទី ៤ ) ។

ស្ថានទម្ងន់ទោសសញ្ចារកម្មស្ថិតនៅក្នុងករណី ដូចខាងក្រោមនេះ :

**" ១. កាលបើ សញ្ចារិក សញ្ចារិកា ឬ ជនជាមេពេស្យាជាបុព្វញ្ញាតិ ឬ បច្ឆាញ្ញាតិ មានខាន់ស្លា អត់ខាន់ស្លា ឬ សាច់បង្កើត ឬ ចិញ្ចឹម របស់បុគ្គលដែលធ្វើពេស្យាចារ "**

ស្ថិតក្នុងស្ថានទម្ងន់ទោសនៃសញ្ចារកម្ម ប្រសិនបើ ជនល្មើសជាប់ទាក់ទងនឹងបុគ្គលពេស្យា តាមខ្សែលោហិត ការរៀបអាពាហ៍ពិពាហ៍ ឬ ការយកមកចិញ្ចឹម ។ បទប្បញ្ញត្តិនេះ សង្កត់ធ្ងន់ថា បទល្មើសដែលត្រូវបានប្រព្រឹត្តដោយសមាជិកគ្រួសារណាម្នាក់ ទៅលើសមាជិកម្នាក់ទៀត ត្រូវចាត់ទុកថាជាស្ថានទម្ងន់ ហេតុដូច្នេះ សមតែទទួលទោសឱ្យធ្ងន់ធ្ងរ ។ សាច់ញាតិអាចជាសាច់ញាតិចាស់ជាង ឬ ក្មេងជាង របស់បុគ្គលពេស្យា ឬ អាចជាសាច់ញាតិ មានខាន់ស្លា ឬ អត់ខាន់ស្លា របស់បុគ្គលពេស្យា ។

កត់សំគាល់ថា ប្រសិនបើ បទល្មើសសញ្ចារកម្មត្រូវបានប្រព្រឹត្តទៅលើ សាច់ញាតិជាអនីតិជន ហេតុដូច្នេះ ជនល្មើសគួរតែត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសយោងតាមមាត្រា ២៨ ( សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ ) ។

**" ២. កាលបើសញ្ចារិក សញ្ចារិកា ឬ ជនជាមេពេស្យា រំលោភអំណាចដែលមុខងាររបស់ខ្លួន ផ្តល់ឱ្យទៅលើ បុគ្គលដែលធ្វើពេស្យាចារ "**

ស្ថិតក្នុងស្ថានទម្ងន់ទោសនៃសញ្ចារកម្ម កាលបើជនល្មើស រំលោភសិទ្ធិអំណាចរបស់ខ្លួនជាមន្ត្រីសាធារណៈ ក្នុងការប្រព្រឹត្តអំពើសញ្ចារកម្ម ។

**" ៣. កាលបើសញ្ចារិក សញ្ចារិកា ឬ ជនជាមេពេស្យា ប្រើហិង្សា ឬ ការបង្ខិតបង្ខំ ចំពោះបុគ្គលដែលធ្វើពេស្យាចារ "**

ស្ថិតក្នុងស្ថានទម្ងន់ទោសនៃសញ្ចារកម្ម ប្រសិនបើ ជនល្មើសប្រើអំពើហិង្សា ឬ ការបង្ខិតបង្ខំ (ការគម្រាមកំហែង ) ទៅលើបុគ្គលពេស្យា ។ ឧទាហរណ៍ : ប្រសិនបើម្ចាស់ ឬ អ្នកគ្រប់គ្រងផ្ទះបន វាយដំ បុគ្គលពេស្យា ដែលបម្រើការងារនៅផ្ទះបនរបស់គាត់ ដោយសារតែបុគ្គលពេស្យានោះ មិនមានបំណងបម្រើអតិថិជន ការប្រើ អំពើហិង្សានេះនឹងត្រូវស្ថិតក្នុងផ្នែកនេះ ។ ប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើ ម្ចាស់ ឬ អ្នកគ្រប់គ្រងផ្ទះបន គម្រាមកំហែងចាប់រំលោភសេពសន្ថវៈ គម្រាមកំហែងធ្វើឱ្យរបួស ឬ គម្រាមកំហែងសំលាប់បុគ្គលពេស្យា ដែលធ្វើការនៅផ្ទះបនរបស់គាត់ ប្រសិនបើ បុគ្គលពេស្យានោះ មិនស្តាប់តាមបញ្ជា នេះត្រូវចាត់ទុកថា ជាការបង្ខិតបង្ខំ ទៅលើបុគ្គលពេស្យា ហើយត្រូវទទួលការផ្តន្ទាទោសយោងតាមផ្នែកនេះ ។

**" អំពើហិង្សា "** មានន័យថា ការប្រើប្រាស់កំលាំងរាងកាយដើម្បីបណ្តាលឱ្យស្លាប់ ឈឺចាប់ ឬ របួសរូបកាយ មិនថា រយៈពេលវែង ឬ រយៈពេលខ្លី ( ដែលរួមមាន ការរំលោភសេពសន្ថវៈ និងទម្រង់ផ្សេងទៀតនៃការឈ្លានពាន

ផ្លូវភេទ ឬ ការប្រើថ្នាំញៀនដោយបង្ខំទៅលើជនរងគ្រោះ ។ល។ ) ព្រមទាំង ការបំពាបំពានផ្នែកស្មារតី ។ អំពើហឹង្សាក្នុងន័យនេះ គឺជាអំពើដែលធ្វើឡើង ប្រឆាំងនឹង រូបកាយ ឬ សុខភាពរូបកាយ ឬ ផ្លូវចិត្តរបស់ជនណាម្នាក់ ។ អំពើហឹង្សា ដែលអាចឈានដល់ ការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ គួរតែទទួលការចោទប្រកាន់ និងផ្តន្ទាទោសយោងតាមមាត្រា ២៩ ( សញ្ជួរកម្មដោយមានការធ្វើ ទារុណកម្ម ) ។

" **ការបង្ខិតបង្ខំ** " នៅទីនេះ មានន័យថា ជាការប្រើប្រាស់កំលាំង ឬ ការប្រើប្រាស់ការគម្រាមកំហែងដោយផ្ទាល់ ឬ ដោយប្រយោល ដែលរួមមានទម្រង់ខ្លះៗនៃការប្រើប្រាស់កំលាំង ឬ ការគម្រាមកំហែងដោយអហិង្សា ឬ ចិត្តសាស្ត្រ ។ ទាំងនេះ រួមមានដូចជា :

ក) ការប្រើប្រាស់កំលាំង ឬ ការគម្រាមកំហែងបង្កឱ្យមានគ្រោះថ្នាក់ (រួមមានបណ្តាលឱ្យស្លាប់ រងរបួសរូបកាយ ឬ រំលោភសេពសន្ធវៈ និងការឈ្លានពានផ្លូវភេទ ) ឬ បង្ខាំងរូបកាយដល់ជនណាម្នាក់ ។

ខ) គ្រោងការណ៍ ផែនការ ឬ គំរូ ដែលមានចេតនាបណ្តាលឱ្យជនណាម្នាក់ជឿថា ការខកខានមិនបានប្រព្រឹត្តអំពើណាមួយ នឹងនាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬ បង្ខាំងរូបកាយដល់ជនណាម្នាក់ ។

គ) ការបំពាន ឬ ការគម្រាមកំហែងណាមួយ ដែលជាប់ទាក់ទងនឹងឋានៈនៃជនណាម្នាក់ ។

ឃ) ការគាបសង្កត់ផ្លូវចិត្ត ដែលរួមមានបណ្តាលឱ្យជនណាម្នាក់ជឿថា គាត់ ឬ បុគ្គលផ្សេងទៀត នឹងត្រូវគេនាំយកចេញ លក់ ឬ បង្ខាំង ដោយខុសច្បាប់ ។

ការបង្ខិតបង្ខំក្នុងន័យនេះ គឺជាអំពើដែលធ្វើឡើងប្រឆាំងនឹងជនម្នាក់ផ្សេងទៀត ដើម្បីឱ្យជននោះមិនអាចបញ្ចេញឆន្ទៈដោយសេរីរបស់ខ្លួនបាន ។

ក្នុងករណីគ្មានស្ថានទម្ងន់ទោសទាំងនេះ ការគំរាមកំហែងតិចតួចដើម្បីគាបសង្កត់លើបុគ្គលណាម្នាក់ ដើម្បីឱ្យធ្វើជាពេស្យាចារ អាចនៅតែចាត់ទុកថាជា " ការគាបសង្កត់ " ដូចដែលមានចែងក្នុងមាត្រា ២៥ (៤) ( " ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ " ) ហេតុដូច្នេះ ត្រូវផ្តន្ទាទោសតាមមាត្រា ២៦ ។

## " ៤. កាលបើ សញ្ជួរកម្ម ត្រូវបានប្រព្រឹត្តជាក្រុមមានការចាត់តាំង "

ស្ថិតក្នុងស្ថានទម្ងន់ទោសនៃសញ្ជួរកម្ម ប្រសិនបើ សញ្ជួរកម្មនោះត្រូវបានប្រព្រឹត្តដោយ " ក្រុមមានការចាត់តាំង " ។

នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៧៧ " ក្រុមមានការចាត់តាំង " មានន័យថា គឺជាការប្រមូលផ្តុំ ដែលបានបង្កើតឡើង ឬ ជាសន្ទិដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

ក្នុងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ មាននិយមន័យ ប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែតម្រូវបន្ថែមឱ្យក្រុមមានការចាត់តាំង ត្រូវតែបញ្ចូលមនុស្សពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ។ ឧទាហរណ៍ : អនុសញ្ញា អង្គការសហប្រជាជាតិ ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័ន ឱ្យនិយម-

ន័យ " ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង " ក្នុងមាត្រា ២ (ក) ថាជា " ក្រុមដែលមានរចនាសម្ព័ន្ធ ដែលមានគ្នា ពី ៣ នាក់ ឬ ច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណង បទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មួយ ឬ ច្រើន ដែលត្រូវធ្វើឡើងស្របទៅនឹង អនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ សម្ភារៈផ្សេងទៀត " ។

ដូច្នេះហើយ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានឱ្យនិយមន័យ " ក្រុមមានការចាត់តាំង " មានន័យថា ជាក្រុម ផ្លូវការ ឬ មិនផ្លូវការ ដែលមានគ្នាបីនាក់ ឬ ច្រើននាក់ជាងនេះ ដែលត្រូវបានបង្កើតឡើងដើម្បីរៀបចំផែនការ ឬដើម្បីប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

### " ៥. កាលបើ សញ្ចារកម្ម ត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ "

ស្ថិតក្នុងស្ថានទម្ងន់ទោសនៃសញ្ចារកម្ម ប្រសិនបើ សញ្ចារកម្មត្រូវបានប្រព្រឹត្តលើ " បុគ្គលច្រើននាក់ " ។

នេះមានន័យថា ជនល្មើសដែលរកឃើញថា មានទោសពីបទល្មើសសញ្ចារកម្ម ដែលប្រព្រឹត្តមកលើបុគ្គលច្រើននាក់ត្រូវទទួលទោសធ្ងន់ធ្ងរជាងនេះ ។ ស្ថានទម្ងន់ទោសនេះ មានន័យថា មិនចាំបាច់មានការចោទប្រកាន់ច្រើនដង ដូចជាបទល្មើសត្រួតគ្នានោះទេ ។ យោងតាមបទប្បញ្ញត្តិនេះ អាចធ្វើការចោទប្រកាន់តែម្តង ដែលនាំឱ្យមានស្ថានទម្ងន់ទោស នៅពេលដែលរកឃើញថា ជនល្មើសមានទោស ។

## មាត្រា ២៨.- សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ

សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបុគ្គលដែលធ្វើពេស្យាចារនោះ ជាអនីតិជន ។

ពាក្យថា " ពេស្យាចារ " នៅក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនានានៃជំពូកនេះ ត្រូវជំនួសដោយពាក្យ " ពេស្យាចារកុមារ " នៅពេលដែលបទល្មើសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវអនុវត្ត ។

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោសអំពើ សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ ។ បុគ្គលណា ដែលប្រព្រឹត្តសញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ ត្រូវផ្តន្ទាទោសឱ្យធ្ងន់ធ្ងរជាងនេះ ដោយដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ មិនមែនពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ដូចមានចែងក្នុងមាត្រា ២៦ ឡើយ ។

កត់សំគាល់ថា កថាខណ្ឌទី ១ នៃមាត្រានេះ ដូចគ្នានឹងបទប្បញ្ញត្តិ នៃក្រមព្រហ្មទណ្ឌថ្មី (សូមមើល គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៥ "សញ្ចារកម្ម" មាត្រា ២៨៩ "ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ" ដែលចែងពីស្ថានទម្ងន់ទោសដាក់ពន្ធនាគារដូចគ្នា ពី ៧ ឆ្នាំ ដល់ ១៥ ឆ្នាំ ចំពោះសញ្ចារកម្ម កាលបើបុគ្គល ដែលធ្វើពេស្យាចារជាអនីតិជន។

ដើម្បីផ្តន្ទាទោសយោងតាមមាត្រានេះ ជនល្មើសត្រូវតែ :

ក) មានទោសពីបទសញ្ចារកម្ម ដូចមានការកំណត់និយមន័យក្នុងមាត្រា ២៥ ខាងលើ

ខ) ក្នុងករណីដែល បុគ្គលធ្វើពេស្យាចារជាអនីតិជន (អាយុក្រោម ១៨ ឆ្នាំ)

ក្នុងករណីបែបនេះ ជនល្មើសគួរតែត្រូវចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រានេះ មិនមែនយោងតាមមាត្រា ២៦ ។

អនីតិជន គឺជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ដូចមានក្នុងមាត្រា ៧ ។ គួរកត់សំគាល់ថា ជំពូកទី ៦ ( មាត្រា ៤២ ដល់ មាត្រា ៤៤ ) នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់ឱ្យអនីតិជនដែលមានអាយុ ១៥ ឆ្នាំ និងលើសពី ១៥ ឆ្នាំ ( ជនដែលមានអាយុពី ១៥ ឆ្នាំ ដល់ ក្រោម ១៨ ឆ្នាំ ) នូវសមត្ថភាពផ្លូវច្បាប់ ក្នុងការយល់ព្រមរួមភេទ ប៉ុន្តែច្បាប់នេះមិនបានផ្តល់ឱ្យអនីតិជនបែបនេះ នូវសមត្ថភាពក្នុងការយល់ព្រមប្រព្រឹត្តអំពើ ពេស្យាចារទេ ។ រាល់អំពើពេស្យាចារទាំងអស់ ដែលទាក់ទិននឹងអនីតិជនណាមួយ ( ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) ត្រូវចាត់ទុកថា ជាអំពើពេស្យាចារកុមារ និងមិនស្របច្បាប់យោងតាម ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ក្នុងករណីដែលអនុវត្តបទល្មើសសញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ នៅក្នុងជំពូកនេះ មាត្រានេះក៏ធ្វើការជំនួសពាក្យ " អំពើពេស្យាចារ " ទៅនឹងពាក្យ " ពេស្យាចារកុមារ " ចំពោះមាត្រាទាំងអស់ ។

**មាត្រា ២៩.- សញ្ចារកម្មដោយមានការធ្វើទារុណកម្ម**

សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០(ម្ភៃ) ឆ្នាំ កាលបើ សញ្ចារិក សញ្ចារិកា ឬ មេពេស្យាបានប្រើប្រាស់ទារុណកម្ម ឬ អំពើឃោរឃៅចំពោះបុគ្គលដែលធ្វើពេស្យាចារ ។

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះអំពើសញ្ចារកម្មដោយមានការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ ទៅលើបុគ្គលពេស្យា ។ ជនណាដែលប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរជាងនេះ ដោយដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ មិនមែនពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ដូចមានចែងក្នុងមាត្រា ២៦ ឡើយ ។

កត់សំគាល់ថា មាត្រានេះប្រហាក់ប្រហែលគ្នា នឹងបទប្បញ្ញត្តិ នៃក្រមព្រហ្មទណ្ឌថ្មី (សូមមើល គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៥ "សញ្ចារកម្ម" មាត្រា ២៩០ "ស្ថានទម្ងន់ទោសទាក់ទងដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ" ដែលចែងពីស្ថានទម្ងន់ទោសដាក់ពន្ធនាគារដូចគ្នា ពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ចំពោះសញ្ចារកម្ម កាលបើ សញ្ចារិក សញ្ចារិកា ឬជនជាមេពេស្យាបានប្រើទារុណកម្ម ឬអំពើឃោរឃៅចំពោះបុគ្គលដែលធ្វើពេស្យាចារ ។

ប្រសិនបើ ជនល្មើសមានចេតនាធ្វើឱ្យមានការឈឺចុកចាប់ធ្ងន់ធ្ងរ ឬ ការឈឺចាប់ ទៅលើបុគ្គលពេស្យា ក្នុងគោលបំណងដាក់ទណ្ឌកម្ម បំភិតបំភ័យ ឬ បង្ខិតបង្ខំបុគ្គលពេស្យា ជនល្មើសគួរតែត្រូវផ្តន្ទាទោសយោងតាមមាត្រានេះ ។ ក្នុងករណីដែលអំពើហឹង្សា ដែលប្រព្រឹត្តឡើង មិននាំឱ្យឈានដល់កំរិតនៃការធ្វើទារុណកម្ម ជនល្មើសអាចនៅតែទទួលការចោទប្រកាន់ យោងតាមមាត្រា ២៧ កថាខ័ណ្ឌទី ៣ ។

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានឱ្យនិយមន័យ "ទារុណកម្ម" ឬ " អំពើឃោរឃៅ " ទេ ។ ទោះជាយ៉ាងណា ពាក្យថា " ទារុណកម្ម " ត្រូវប្រើក្នុង ច្បាប់ព្រហ្មទណ្ឌកម្ពុជាដែលរួម

មានច្បាប់ដែលចូលជាធរមាន នៅពេលដែល ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានប្រកាសឱ្យប្រើ (សូមពិនិត្យមើល មាត្រា ១២ នៃច្បាប់អ៊ុនតាក់ និងមាត្រា ៧ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស) ព្រមទាំងក្រមព្រហ្មទណ្ឌ (សូមពិនិត្យមើល ឧទាហរណ៍ : គន្លឹទី ២ មាតិកាទី ២ ជំពូកទី ២ ផ្នែកទី ១ " ទារុណកម្ម និង អំពើឃោរឃៅ ") ។ ទោះបីជាច្បាប់ទាំងនេះ មិនបានឱ្យនិយមន័យពាក្យ " ទារុណកម្ម " ច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវយល់ថាបានបញ្ចូល (តាមរយៈឯកសារយោងក្នុងមាត្រា ១ នៃ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តសន្ធិសញ្ញា អន្តរជាតិ ផ្សេងទៀត) និយមន័យដូចមានចែងក្នុងអនុសញ្ញា ស្តីពី ការប្រឆាំងការធ្វើទារុណកម្ម ។ ប្រទេសកម្ពុជា បានឱ្យសច្ចាប័ន លើអនុសញ្ញា ស្តីពី ការប្រឆាំងការធ្វើទារុណកម្ម នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ។ មាត្រា ១ នៃអនុសញ្ញា ស្តីពី ការប្រឆាំង ការធ្វើទារុណកម្មឱ្យនិយមន័យ ពាក្យថា " ទារុណកម្ម " ដូចខាងក្រោម :

*"...អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬ រងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬ ផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនម្នាក់ទៀត ក្នុងគោលបំណងទាំងឡាយដូចជា ទាញយកព័ត៌មានពីជននោះ ឬ តតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយ ដែលជននោះ ឬ តតិយជនណាម្នាក់ បានប្រព្រឹត្ត ឬ សង្ស័យថាបានប្រព្រឹត្ត ឬ បំភិតបំភ័យ ឬ បង្ខិតបង្ខំជននោះ ឬ តតិយជនណាម្នាក់ ឬ ដើម្បីមូលហេតុណាផ្សេងទៀត ដោយផ្អែកលើការរើសអើងណាមួយ "*

ចំពោះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពាក្យថា " ទារុណកម្ម " កំណត់ដោយធាតុផ្សំសំខាន់ៗ ពីរ :

១) នាំឱ្យមានការឈឺចាប់ ឬ រងទុក្ខខ្លាំង ទោះជាផ្លូវកាយក្តី ឬ ផ្លូវចិត្តក្តី

២) បង្កឡើងដោយចេតនា ។

កត់សំគាល់ថា ចំពេលដែលច្បាប់អន្តរជាតិចាត់ទុកថា ទារុណកម្មអាចគ្រាន់តែប្រព្រឹត្តឡើងជាប់ទាក់ទងនឹង មន្ត្រីសាធារណៈ ឬ ជនណាម្នាក់ដែលបម្រើការនៅក្នុងមុខតំណែងផ្លូវការ នៅក្នុងច្បាប់ប្រទេសកម្ពុជាវិញ បទល្មើស ប្រព្រឹត្តអំពើ ទារុណកម្ម ក៏អាចអនុវត្តចំពោះអំពើមួយចំនួន ដែលប្រព្រឹត្តឡើងដោយបុគ្គលឯកជនដែរ ។ នេះស្របទៅ នឹងវិធីសាស្ត្រ ដែលមានចែងនៅក្នុងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌដែលពាក់ព័ន្ធ (សូមពិនិត្យមើល គន្លឹទី ២ មាតិកាទី ២ ជំពូកទី ២ ផ្នែកទី ១ " ទារុណកម្ម និងអំពើឃោរឃៅ ") ។

ពាក្យថា " អំពើឃោរឃៅ " មិនមានឱ្យនិយមន័យ ក្នុងច្បាប់កម្ពុជា ឬ ច្បាប់អន្តរជាតិទេ ប៉ុន្តែពាក្យនេះ សន្មត់ថា សំដៅទៅលើ ការប្រព្រឹត្តដោយសាហាវ ដែលមានកំរិតធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងទារុណកម្មដែរ ។ ក្នុងន័យ នេះ ពាក្យនេះ ប្រហាក់ប្រហែលនឹងពាក្យ " ការប្រព្រឹត្តដ៏ឃោរឃៅ អមនុស្សធម៌ និង បន្ថោកបន្ទាប " ដែលពាក្យនេះ ក៏ត្រូវបានប្រើ (ប៉ុន្តែ មិនមានកំណត់និយមន័យ) នៅក្នុងអនុសញ្ញា ស្តីពី ការប្រឆាំងនឹងការធ្វើទារុណកម្ម ។

## មាត្រា ៣០.. ការដឹកនាំពេស្យាចារ

**ជនណាដឹកនាំ ធ្វើអាជីវកម្ម ធ្វើប្រតិបត្តិការ ឬ ចេញប្រាក់ឱ្យគ្រឹះស្ថានពេស្យាចារ ដោយផ្ទាល់ ឬ តាមរយៈអន្តរការី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។**

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះការដឹកនាំ ការធ្វើអាជីវកម្ម ការធ្វើប្រតិបត្តិការ ឬ ការចេញប្រាក់ឱ្យគ្រឹះស្ថានពេស្យាចារ ។ មាត្រានេះ ផ្អែកទៅលើនិយមន័យ ប្រហាក់ប្រហែលគ្នា ក្នុងក្រមព្រហ្មទណ្ឌ មាត្រា ២៩១ ដែលទាក់ទងនឹងបទ ដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ (សូមពិនិត្យមើល ក្រមព្រហ្មទណ្ឌ គន្ថី ទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៥ " សញ្ចារកម្ម " ។

ជនល្មើស អាចត្រូវរកឃើញមានទោសប្រព្រឹត្តបទល្មើសនេះ ដោយផ្ទាល់ ឬ តាមរយៈអន្តរការី ។

### " ការដឹកនាំ "

" ការដឹកនាំ " មានន័យថា ជាការអនុវត្តការគ្រប់គ្រង ឬ សិទ្ធិអំណាច ទៅលើគ្រឹះស្ថាននោះ ។

អ្នកប្រព្រឹត្តអាចត្រូវចាត់ទុកថា ដឹកនាំដោយផ្ទាល់ ឬ តាមរយៈអន្តរការី ។

ឧទាហរណ៍ : ប្រសិនបើ បុគ្គលម្នាក់ ឈ្មោះ "ក" អនុញ្ញាតឱ្យប្អូនប្រុសរបស់ខ្លួន ឈ្មោះ "ខ" ធ្វើការគ្រប់គ្រងផ្ទះបន ដើម្បីឈ្មោះ "ក" ទាំងឈ្មោះ "ក" និង "ខ" មានការទាក់ទិននឹងការដឹកនាំគ្រឹះស្ថានពេស្យាចារ ។

### " ការធ្វើអាជីវកម្ម "

" ការធ្វើអាជីវកម្ម " មានន័យថា ជាការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីគ្រឹះស្ថាននោះ ដើម្បីប្រើប្រាស់អត្ថប្រយោជន៍នោះ ក្នុងគោលបំណងផ្សេងទៀត ។

ឧទាហរណ៍ : ប្រសិនបើ អ្នកប្រព្រឹត្ត ប្រើប្រាស់ប្រាក់ចំណូលបាន មកពីផ្ទះបន ដើម្បីផ្តល់មូលនិធិដល់ក្រុមហ៊ុនអចលនវត្ថុរបស់គាត់ គាត់នឹងកំពុងតែធ្វើអាជីវកម្មទៅលើគ្រឹះស្ថាន ពេស្យាចារ នោះ ។

### " ការធ្វើប្រតិបត្តិការ "

" ការធ្វើប្រតិបត្តិការ " មានន័យថា ជាការថែរក្សាជាទៀងទាត់នូវគ្រឹះស្ថាន ធ្វើជាអាជីវកម្មតទៅមុខ ដើម្បីអត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកប្រព្រឹត្តនោះ ( នៅពេលដែលគាត់ជាម្ចាស់ជាអាជីវកម្មផ្ទាល់ ) ឬ ក្នុងនាមជនផ្សេងទៀត ដែលជាម្ចាស់របស់គ្រឹះស្ថាន ។

### " ការចេញប្រាក់ "

" ការចេញប្រាក់ " មានន័យថា ជាការផ្គត់ផ្គង់ប្រាក់ ឬ ធនធានផ្សេងទៀត ដើម្បីអាចឱ្យមានការប្រតិបត្តិការលើគ្រឹះស្ថាន ។

ឧទាហរណ៍ ៖ ប្រសិនបើ អ្នកប្រព្រឹត្តផ្ដល់ប្រាក់ ឬ ឱ្យប្រាក់ខ្ចី ទៅដល់ផ្ទះបន អ្នកប្រព្រឹត្តនឹងកំពុងតែចេញប្រាក់ឱ្យគ្រឹះស្ថានពេស្យាចារនោះ ។

## " គ្រឹះស្ថានពេស្យាចារ "

" គ្រឹះស្ថានពេស្យាចារ " មានន័យថា ជាទីតាំងមានរូបរាង ( ផ្ទះ អគារ ក្រុមហ៊ុន ទីកន្លែង ។ល។ ) ដែលធ្វើប្រតិបត្តិការក្នុងគោលបំណងប្រព្រឹត្តអំពើ ពេស្យាចារ ។ ពាក្យ ពេស្យាចារ មានការកំណត់និយមន័យ ក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

ទីកន្លែងបែបនេះ ជាទូទៅមានឈ្មោះថា ផ្ទះបន ។

ចំពោះគ្រឹះស្ថានដែលធ្វើប្រតិបត្តិការដើម្បីគោលបំណងផ្សេងទៀត ( ដែលថាអំពើ ពេស្យាចារ មិនមែនជាគោលបំណងសំខាន់របស់គ្រឹះស្ថាន ) ហើយក្នុងករណី ទោះបីជាកើតមានអំពើ ពេស្យាចារ កើតឡើង មិនគួរប្រើមាត្រានេះទេ ។ យ៉ាងណាមិញ អាចអនុវត្តបានចំពោះបទល្មើស យោងតាមមាត្រា ៣១ ។

## " ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ "

បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ ( ពីរ ) ឆ្នាំ ទៅ ៥ ( ប្រាំ ) ឆ្នាំ ។ ទោសបន្ថែមអាចត្រូវអនុវត្តដោយអំណាចឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុង មាត្រា ៤៨ នៃច្បាប់នេះ ។

ប្រសិនបើ មានការប្រព្រឹត្តបទល្មើសទាក់ទងនឹងពេស្យាចារកុមារ ជនល្មើសគួរតែចោទប្រកាន់ និងផ្តន្ទាទោសឱ្យធ្ងន់ធ្ងរជាងនេះ ( ជាប់ពន្ធនាគារពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ ) ឆ្នាំ ) ដូចមានចែងក្នុងមាត្រា ៣៣ ( បទល្មើសទាក់ទងនឹងពេស្យាចារកុមារ ) ។

ដូចចែងក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតនៃនីតិបុគ្គល ឬ ភារប្បទាយី ត្រូវគេរកឃើញថា មានទោសប្រព្រឹត្តបទល្មើសនេះ តុលាការអាចផ្តន្ទាទោសនីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែមដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ដូចជាការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

គួរកត់សំគាល់ថា មាត្រា ២៩១ (បទដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ) នៃក្រមព្រហ្មទណ្ឌ ដែលទាក់ទងនឹងបទល្មើសដូចគ្នានឹងមាត្រា ៣០ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចែងពីការផ្តន្ទាទោសដាក់ពន្ធនាគារដូចគ្នាពី ២ឆ្នាំ ទៅ ៥ឆ្នាំ ។ យ៉ាងណាមិញ ក្រមព្រហ្មទណ្ឌបានដាក់បញ្ចូលទោសបន្ថែមពិន័យជាប្រាក់ ពី ៤ លានរៀល ដល់ ១០ លានរៀល ដែលទោសនេះអាចត្រូវបានដាក់តែឯង ឬ រួមជាមួយគ្នានឹងទោសជាប់ពន្ធនាគារ ។

ចំពោះការផ្តន្ទាទោសមិនស្របគ្នា រវាង ច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ អាចត្រូវបានដោះស្រាយ យោងតាមគោលការណ៍នៃការបកស្រាយច្បាប់ និងវិធាន ដែលមានចែង នៅក្នុង មាត្រា ៦៧១ និង មាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌ (សូមមើលការការពិភាក្សា ស្តីពី "គោលការណ៍នៃការបកស្រាយច្បាប់" នៅក្នុងសេចក្តីផ្តើម និងនៅក្នុងមាត្រា ៥០ ខាងក្រោម) ។ ដោយផ្អែកទៅ លើវិធានទាំងនេះ ការផ្តន្ទាទោសចំពោះ បទដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ យោងតាម ក្រមព្រហ្មទណ្ឌថ្មី ជាទូទៅនឹងត្រូវយកមកប្រើជំនួស ការផ្តន្ទាទោសចំពោះអំពើដូចគ្នា ដែលមានចែងក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។

ទោះបីជាយ៉ាងណាក៏ដោយ យោងទៅតាម " គោលការណ៍ឯកត្តកម្មនៃទោស " ក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ចំពោះករណីធ្ងន់ធ្ងរ នៃបទសញ្ចារកម្ម គួរតែត្រូវធ្វើការផ្តន្ទាទោសដាក់ពន្ធនាគារ មិនមែនដាក់តែទោសពិន័យ ជាប្រាក់តែមួយមុខប៉ុណ្ណោះទេ ដោយសារផ្អែកទៅលើកត្តាជាច្រើន ដូចជា ទំហំនៃប្រតិបត្តិការ ឬចំនួនពេស្យាចារដែលពាក់ព័ន្ធ ចំនួននៃប្រាក់ដែលទទួលបាន ដោយសញ្ចារិក/សញ្ចារិកា រយៈពេលដែលជនល្មើសប្រព្រឹត្តសកម្មភាព និងករណីមិនរាងចាលជាដើម ។

ប៉ុន្តែ បើបទល្មើសត្រូវធ្វើឡើងក្នុងបរិបទជួញដូរមនុស្ស ជនល្មើស គប្បីតែត្រូវចោទប្រកាន់ និងផ្តន្ទាទោសដាក់ពន្ធនាគារតាម ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលជាច្បាប់ពិសេសមានអាទិភាពលើក្រមព្រហ្មទណ្ឌទាក់ទងនឹងបទល្មើសជួញដូរ) ។

## មាត្រា ៣១.- ការដឹកនាំគ្រឹះស្ថានពេស្យាចារ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើបានយល់ព្រម ឬ បានអនុគ្រោះ :

១- ឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬ នៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន ឬ

២-ឱ្យបុគ្គលណាម្នាក់រកភ្ញៀវ ដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬ នៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាននេះ ។

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោសចំពោះជនណា (ម្ចាស់ ឬ អ្នកគ្រប់គ្រង) ដែលយល់ព្រម ឬ អនុគ្រោះទៅលើអំពើ ពេស្យាចារ ដែលបានប្រព្រឹត្តឡើងនៅក្នុងគ្រឹះស្ថាន ឬ នៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថានណាមួយ ។ មាត្រានេះ ផ្អែកទៅលើនិយមន័យ ប្រហាក់ប្រហែលគ្នា ក្នុងក្រមព្រហ្មទណ្ឌ មាត្រា ២៩២ ដែលទាក់ទងនឹងបទយល់ព្រមឱ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថានមួយ (សូមពិនិត្យមើល ក្រមព្រហ្មទណ្ឌ គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៥ " សញ្ចារកម្ម ") ។

បុគ្គលណាដែលត្រូវរកឃើញមានទោសពីបទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

បទល្មើសក្នុងមាត្រានេះ មានធាតុផ្សំជាច្រើន :

**" បុគ្គលណាម្នាក់ "**

ពាក្យថា " បុគ្គលណាម្នាក់ " ដូចត្រូវប្រើក្នុងមាត្រានេះ មានន័យថា ជានរណាម្នាក់ដែលដឹកនាំធ្វើអាជីវកម្មធ្វើប្រតិបត្តិការ ឬ ចេញប្រាក់ដោយផ្ទាល់ ឬ ដោយប្រយោល ទៅដល់គ្រឹះស្ថាន និងហេតុដូច្នេះ បុគ្គលនោះមានការគ្រប់គ្រង ឬ សិទ្ធិអំណាចលើគ្រឹះស្ថាននោះ។ ផ្ទុយទៅវិញម្ចាស់ដី ឬម្ចាស់ទ្រព្យសម្បត្តិដែលមិនបានដឹកនាំធ្វើអាជីវកម្មធ្វើប្រតិបត្តិការ ឬ ចេញប្រាក់ដល់គ្រឹះស្ថាន មិនគួរត្រូវផ្តន្ទាទោសយោងតាមមាត្រានេះទេ ប៉ុន្តែអាចទទួលទោសយោងតាមមាត្រា ៣២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ) ។

**" យល់ព្រម ឬ បានអនុគ្រោះ "**

ត្រូវទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ បើអ្នកប្រព្រឹត្ត :

ក) ដឹងអំពីសកម្មភាពពេស្យាចារកើតឡើងនៅក្នុងគ្រឹះស្ថាន និង

ខ) យល់ព្រម ឬ អនុគ្រោះ ចំពោះសកម្មភាពពេស្យាចារនោះ ។

ដើម្បីទទួលទោសយោងតាមមាត្រានេះ អ្នកប្រព្រឹត្តត្រូវតែ ក) បានដឹង និង ខ) អនុគ្រោះដល់សកម្មភាពពេស្យាចារ ។

ឧទាហរណ៍ : ប្រសិនបើ ម្ចាស់បារ មិនបានដឹងថា បុគ្គលិករបស់ខ្លួនប្រព្រឹត្តអំពើពេស្យាចារ នៅក្នុងបារ នោះហេតុដូច្នេះ ម្ចាស់បារមិនត្រូវទទួល ការផ្តន្ទាទោស យោងតាមមាត្រានេះទេ ។ ប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើម្ចាស់បារដឹងថា បុគ្គលិករបស់ខ្លួនបានប្រព្រឹត្តអំពើ ពេស្យាចារ ប៉ុន្តែមិនបានអនុគ្រោះ (ឧទាហរណ៍ : ម្ចាស់បារបានព្រមានបុគ្គលិកនោះឱ្យឈប់ប្រព្រឹត្ត បើមិនដូច្នេះទេ នឹងត្រូវបណ្តេញចេញ) ហេតុដូច្នេះ ម្ចាស់បារមិនមានការទទួលខុសត្រូវយោងតាមមាត្រានេះ ទោះបីជាបុគ្គលិនោះបន្តប្រព្រឹត្តអំពើ ពេស្យាចារ ដោយគ្មានការយល់ព្រមពីម្ចាស់បារក៏ដោយ ។

មាត្រានេះ តម្រូវឱ្យមានភស្តុតាងថា អ្នកប្រព្រឹត្ត ពិតជាបានដឹង និងអនុគ្រោះដល់សកម្មភាពពេស្យាចារ ។ ក្នុងករណី បើគ្រាន់តែមានស្រោមអនាម័យ ឬ សម្ភារៈផ្សេងទៀត ដែលគេប្រើប្រាស់ ដើម្បីលើកកម្ពស់ឱ្យមានការយល់ដឹងពីជម្ងឺឆ្លងតាមការរួមភេទ នេះមិនមែនជាភស្តុតាង ដែលថាមានអំពើពេស្យាចារ កើតមានឡើងនៅក្នុងគ្រឹះស្ថាននោះ។[៣២] ប្រហាក់ប្រហែលគ្នានេះដែរ ការខ្វះស្រោមអនាម័យ ឬ សម្ភារៈ ប្រហាក់ប្រហែលផ្សេងទៀត មិនបង្ហាញការពិតថាមិនមានអំពើពេស្យាចារនៅក្នុងគ្រឹះស្ថានទេ ។ ការផ្សព្វផ្សាយ និងការប្រើប្រាស់ស្រោមអនាម័យ ត្រូវបានលើកទឹកចិត្តដោយគោលនយោបាយរបស់រាជរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា យោងតាមច្បាប់ ស្តីពី ការបង្ការ និង ការប្រយុទ្ធ

[៣២] តាមការពិត គ្រឹះស្ថានកំសាន្តសប្បាយ អាចច្បាប់តម្រូវឱ្យមាន និងតាំងបង្ហាញស្រោមអនាម័យ ឬ សម្ភារៈផ្សេងទៀត ។ តម្រូវការបែបនេះ អាចកើតមានស្របទៅតាមបទបញ្ជា ដូចជា បទបញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រី ស្តីពី កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ឱ្យបាន ១០០ ភាគរយ បទបញ្ជារបស់សាលាក្រុងភ្នំពេញ លេខ ០១/០៨ ស្តីពី ការប្រើប្រាស់ស្រោមអនាម័យ ១០០ ភាគរយ ឬ សេចក្តីប្រកាសលេខ ៨៦ របស់ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការគ្រប់គ្រងជម្ងឺអេដស៍ នៅកន្លែងការងារ ។

ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ឆ្នាំ២០០២[៣៣] និងគោលការណ៍ណែនាំអនុវត្ត នៃច្បាប់នេះ[៣៤] និងហេតុដូច្នេះ ការចោទប្រកាន់ និងការផ្តន្ទាទោស យោងតាមបទប្បញ្ញត្តិនេះ តម្រូវឱ្យមានអង្គហេតុភស្តុតាងផ្សេងទៀត ដែលថាជនល្មើសបានទទួលយក និងអនុគ្រោះដល់អំពើពេស្យាចារ ។

**" ឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តពេស្យាចារ "**

**" ឱ្យបុគ្គលណាម្នាក់រកភ្ញៀវ ដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថាន "**

" បុគ្គលណាម្នាក់ " មានន័យថា ជាបុគ្គលពេស្យាជាអ្នកផ្តល់ស្រីឱ្យភ្ញៀវ ជាសញ្ចារិក ឬ សញ្ចារិកា ជាអន្តរការី និងជាអ្នកដែលប្រព្រឹត្តអំពើពេស្យាចារ ឬ ស្វែងរកភ្ញៀវពេស្យាចារ នៅក្នុងគ្រឹះស្ថាន ឬ ឧបសម្ព័ន្ធគ្រឹះស្ថាន ។

" ពេស្យាចារ " មាននិយមន័យដូចមានចែងក្នុងមាត្រា ២៣ ខាងលើ ។

ជាការសំខាន់គួរកត់សំគាល់ថា មាត្រានេះ មិនដាក់ឱ្យទៅជាទោសព្រហ្មទណ្ឌនូវសកម្មភាពពេស្យាចារដោយខ្លួនឯង និងមាត្រានេះមិនបានផ្តន្ទាទោសបុគ្គលពេស្យាផ្ទាល់ខ្លួនទេ ។ អំពើពេស្យាចារ យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានផ្តន្ទាទោសបុគ្គលពេស្យា ( ផ្ទាល់ខ្លួន ឬ ក្រុម ) ពីបទប្រព្រឹត្តអំពើពេស្យាចារទេ ។

**" នៅក្នុង "**

មាត្រានេះ ផ្តន្ទាទោសទៅលើបុគ្គលណាដែល**យល់ព្រម** និង**អនុគ្រោះ**អំពើពេស្យាចារ ដែលកើតឡើងនៅក្នុងគ្រឹះស្ថានរបស់ខ្លួន ។ ប្រសិនបើអំពើពេស្យាចារកើតឡើងនៅខាងក្រៅ ហេតុដូច្នេះ អ្នកប្រព្រឹត្តមិនត្រូវផ្តន្ទាទោសទេ ។

**ឧទាហរណ៍ : ប្រសិនបើ បុគ្គលិកផ្សព្វផ្សាយស្រាបៀបញ្ចប់វេណការងាររបស់ខ្លួននៅឯបារ បានចាកចេញពីបារ និងចំពេលដែលនៅខាងក្រៅតាមដងផ្លូវ អូសទាញ ជនណាម្នាក់ដោយមានគោលដៅប្រព្រឹត្តអំពើ ពេស្យាចារដោយ ខ្លួនឯង ម្ចាស់បារនោះមិនទទួលខុសត្រូវចំពោះ អំពើរបស់បុគ្គលិកនោះទេ ។**

---

[33] មាត្រា ២៩ នៃច្បាប់ស្តីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស តម្រូវឱ្យរដ្ឋត្រូវយកចិត្តទុកដាក់បន្តជម្រុញការទប់ស្កាត់ និងការគ្រប់គ្រងជម្ងឺកាមរោគ នៃមេរោគអេដស៍/ជម្ងឺអេដស៍ ។ មាត្រា ១១ នៃច្បាប់ស្តីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស តម្រូវឱ្យសម្ភារៈ ឬ វត្ថុធាតុសម្រាប់បង្ការការចម្លងមេរោគអេដស៍ទាំងអស់ ដូចជា ស្រោមអនាម័យ ត្រូវភ្ជាប់នូវពត៌មានដែលពន្យល់ ពីវិធីប្រើប្រាស់ត្រឹមត្រូវ សម្រាប់ប្រើប្រាស់វត្ថុធាតុទាំងនោះ ។

[34] ជំពូកទី ៥ នៃគោលការណ៍ណែនាំអនុវត្ត នៃ ច្បាប់ស្តីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ចែងថា "យោងតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល....... សេវាកម្មព្យាបាលជម្ងឺកាមរោគ គួរតែមានបញ្ចូលការផ្តល់ពត៌មាន និងការអប់រំ ដូចជាការជម្រុញ និងការចែកចាយស្រោមអនាម័យ" ។ ជំពូកទី ៥ ក៏បានចែងទៀតថា ដើម្បីទប់ស្កាត់ជម្ងឺឆ្លង មេរោគអេដស៍ តាមរយៈអ្នករកស៊ីផ្លូវភេទ ប្រទេសកម្ពុជាបានអនុវត្ត "កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០ភាគរយ" ដាក់បញ្ជាឱ្យប្រើប្រាស់ស្រោមអនាម័យ រាល់ពេលប្រកបរបរផ្លូវភេទទាំងអស់ ហើយធ្វើការផ្តន្ទាទោស ទៅលើម្ចាស់ និងអ្នកបើក គ្រឹះស្ថានកំសាន្តយុវជន ( ដូចជាព្រមានបិទ) ចំពោះការមិនអនុវត្តតាមតម្រូវការរបស់កម្មវិធីនេះ ។

### " គ្រឹះស្ថាន "

" គ្រឹះស្ថាន " មានន័យថា ជាទីតាំងមានរូបរាង ( ផ្ទះ អគារ ក្រុមហ៊ុន ទីកន្លែង ។ល។ ) ដែលធ្វើប្រតិបត្តិការក្នុងគោលបំណងផ្សេងទៀត ( ដែលថាអំពើពេស្យាចារ មិនមែនជាគោលបំណងសំខាន់របស់គ្រឹះស្ថានទេ ) ។ ប៉ុន្តែ ជាទីកន្លែងដែលកើតមានអំពើពេស្យាចារនៅក្នុងបរិវេណនោះ ។

**ឧទាហរណ៍ : ក្លឹបខារ៉ាអូខេ កន្លែងម៉ាស្សា ផ្ទះសំណាក់ បារ ឬ សណ្ឋាគារ នៅពេលដែលមានអំពើពេស្យាចារកើតមានឡើងអាចស្ថិតនៅក្នុងមាត្រានេះ ។**

មិនគួរប្រើមាត្រានេះទេ ចំពោះគ្រឹះស្ថាន ដែលធ្វើប្រតិបត្តិការក្នុងគោលបំណងអំពើពេស្យាចារ ( ផ្ទះបន ) ។ ករណីនេះ អាចអនុវត្តបទល្មើសដែលមានចែងក្នុងមាត្រា ៣០ វិញ ។

### " ឬ ឧបសម្ព័ន្ធគ្រឹះស្ថាន "

" ឧបសម្ព័ន្ធ " មានន័យថា ជាអគារ ឬ ក្រុមនៃអគារផ្សេងទៀត ដែលជាកម្មសិទ្ធ និងគ្រប់គ្រងដោយបុគ្គល ឬ នីតិបុគ្គលដែលមានម្ចាស់ជាមួយគ្នានឹងម្ចាស់គ្រឹះស្ថានធំ និងដែល :

ក. ជាម្ចាស់ ឬ គ្រប់គ្រង ដោយបុគ្គល ឬ នីតិបុគ្គលតែមួយជាមួយគ្នានឹងម្ចាស់គ្រឹះស្ថានធំ

ខ. មានបរិវេណជាប់គ្នាទៅនឹងគ្រឹះស្ថានធំ

**ឧទាហរណ៍ : ប្រសិនបើ ម្ចាស់ក្លឹបខារ៉ាអូខេ ក៏ជាម្ចាស់របស់សណ្ឋាគារ ដែលស្ថិតនៅលើដីឡូត៍ជាមួយគ្នា សណ្ឋាគារត្រូវចាត់ទុកថាជាឧបសម្ព័ន្ធ ចំពោះគោលបំណងរបស់មាត្រានេះ ។**

### " ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ "

ជនណាដែលបានប្រព្រឹត្តបទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ទោសបន្ថែមអាចត្រូវអនុវត្តដោយអំណាចឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ នៃច្បាប់នេះ ។

ប្រសិនបើ មានការប្រព្រឹត្តបទល្មើសទាក់ទងនឹងពេស្យាចារកុមារ ជនល្មើសគួរតែចោទប្រកាន់ និងផ្តន្ទាទោសឱ្យធ្ងន់ធ្ងរជាងនេះ ( ជាប់ពន្ធនាគារពី ៧ ( ប្រាំពីរ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ) ឆ្នាំ ) ដូចមានចែងក្នុងមាត្រា ៣៣ ( បទល្មើសទាក់ទងនឹងពេស្យាចារកុមារ ) ។

ដូចចែងក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតនៃនីតិបុគ្គល ឬ ភារប្បទាយី ត្រូវគេរកឃើញថា មានទោសប្រព្រឹត្តបទល្មើសនេះ តុលាការអាចផ្តន្ទាទោសនីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែមដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ដូចជាការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

គួរកត់សំគាល់ថា មាត្រា ២៩២ (បទយល់ព្រមឱ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ដែលទាក់ទងនឹងអំពើដូចគ្នានឹងមាត្រានេះ បានចែងពីការផ្តន្ទាទោសដាក់ពន្ធនាគារដូចគ្នាពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ ។ យ៉ាងណាមិញ ក្រមព្រហ្មទណ្ឌដាក់បញ្ចូលទោសបន្ថែមពិន័យជាប្រាក់ ពី ៤ លានរៀល ដល់ ១០ លានរៀល ដែលទោសនេះអាចត្រូវបានដាក់តែឯង ឬ រួមជាមួយគ្នានឹងទោសជាប់ពន្ធនាគារ ។

ចំពោះភាពមិនស្របគ្នាក្នុងការផ្តន្ទាទោស រវាង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ អាចត្រូវបានដោះស្រាយ យោងតាមគោលការណ៍នៃការបកស្រាយច្បាប់ និងវិធានដែលមានចែង នៅក្នុង មាត្រា ៦៧១ និង មាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌ (សូមមើលការការពិភាក្សា ស្តីពី "គោលការណ៍ នៃការបកស្រាយច្បាប់ "នៅក្នុងសេចក្តីផ្តើម និងនៅក្នុងមាត្រា ៥០ ខាងក្រោម) ។ ដោយផ្អែកទៅលើវិធានទាំងនេះ ការផ្តន្ទាទោសចំពោះ "បទយល់ព្រមឱ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន" យោងតាមក្រមព្រហ្មទណ្ឌថ្មី ជាទូទៅ នឹងត្រូវយកមកប្រើជំនួស ការផ្តន្ទាទោសចំពោះអំពើដូចគ្នា ដែលមានចែងក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ទោះបីជាយ៉ាងណាក៏ដោយ យោងទៅតាម " គោលការណ៍ឯកត្តកម្មនៃទោស " ក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ចំពោះករណីធ្ងន់ធ្ងរ នៃបទសញ្ចារកម្ម គួរតែត្រូវធ្វើការផ្តន្ទាទោសដាក់ពន្ធនាគារ មិនមែនដាក់តែទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះទេ ដោយសារផ្អែកទៅលើកត្តាជាច្រើន ដូចជា ទំហំនៃប្រតិបត្តិការ ឬចំនួនពេស្យាចារដែលពាក់ព័ន្ធ ចំនួននៃប្រាក់ដែលទទួលបាន ដោយសញ្ចារិក/សញ្ចារិកា រយៈពេលដែលជនល្មើសប្រព្រឹត្តសកម្មភាព និងករណីមិនរាងចាលជាដើម ។

ប៉ុន្តែ បើបទល្មើសត្រូវធ្វើឡើងក្នុងបរិបទជួញដូរមនុស្ស ជនល្មើស គប្បីត្រូវចោទប្រកាន់ និងផ្តន្ទាទោសដាក់ពន្ធនាគារ តាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលជាច្បាប់ពិសេសមានអាទិភាពលើក្រមព្រហ្មទណ្ឌទាក់ទងនឹងបទល្មើសជួញដូរ) ។

## មាត្រា ៣២.. ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ

ជនណាលក់ ឬ ដាក់ឱ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែង ដែលមិនមែនប្រើប្រាស់ដោយសាធារណជន ដោយដឹងថាបុគ្គលនោះនឹងប្រើប្រាស់ទីន្លែងនោះ សម្រាប់ធ្វើសកម្មភាពពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះជនណា (ម្ចាស់ដី ម្ចាស់ទ្រព្យសម្បត្តិ ឬ អ្នកជួល ) ដែលលក់ ជួល ឬ ផ្តល់ទីកន្លែងឯកជន ទៅឱ្យបុគ្គលម្នាក់ផ្សេងទៀត ដោយដឹងថា បុគ្គលផ្សេងទៀតនោះ នឹងប្រើប្រាស់បរិវេណនោះ ដើម្បីប្រព្រឹត្តអំពើពេស្យាចារ ។ មាត្រានេះ ផ្អែកទៅលើនិយមន័យ ប្រហាក់ប្រហែលគ្នា ក្នុងក្រមព្រហ្មទណ្ឌ មាត្រា ២៩៣ ដែលទាក់ទងនឹងបទដាក់ឱ្យប្រើប្រាស់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ ( សូមពិនិត្យមើលក្រមព្រហ្មទណ្ឌ គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៥ ផ្នែកទី ៥ " សញ្ចារកម្ម " ។

ជនណាម្នាក់ ប្រសិនបើរកឃើញថា មានទោសពីបទល្មើសនេះ ត្រូវផ្តន្ទាទោសដោយដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

បទល្មើសដែលមានចែងក្នុងមាត្រានេះ មានធាតុផ្សំជាច្រើន :

" **ជនណា** "

ពាក្យថា " ជនណា " ដូចត្រូវប្រើក្នុងមាត្រានេះ មានន័យថា ជាម្ចាស់ដី ម្ចាស់ទ្រព្យសម្បត្តិ ឬ អ្នកជួលទៅលើទ្រព្យសម្បត្តិ ។

ដើម្បីឱ្យមានការទទួលខុសត្រូវយោងតាមមាត្រានេះ ជនណាម្នាក់ ត្រូវតែមានសិទ្ធិទ្រព្យសម្បត្តិ ទៅលើកន្លែងណាមួយ ដែលរួមមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិនោះ ។

" **ដែលលក់ ឬ ដាក់ឱ្យប្រើប្រាស់** " នេះមានន័យថា លក់ ជួល ឱ្យគេខ្ចី ឬ ផ្តល់ទ្រព្យសម្បត្តិឱ្យបុគ្គលណាម្នាក់ផ្សេងទៀតប្រើប្រាស់ ។

" **ទីកន្លែងដែលមិនមែនប្រើប្រាស់ដោយ សាធារណៈជន** "

មាត្រានេះ អនុវត្តចំពោះការប្រើប្រាស់ទ្រព្យសម្បត្តិឯកជន ដែលរួមមាន ដី ឬ អគារ ដូចជា ផ្ទះ កន្លែងអាជីវកម្ម ឬ កន្លែងផ្សេងទៀត ដែលកាន់កាប់ និងគ្រប់គ្រងដោយឯកជន ។

មាត្រានេះ មិនអនុវត្តទៅលើករណីដែលទាក់ទងនឹង ការលក់ ការជួល ឬ ការផ្តល់ទ្រព្យសម្បត្តិសា- ធារណៈ ។ ចំពោះច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពាក្យថា " ទីសាធារណៈ " ( ដែលមានការកំណត់និយមន័យក្នុងការពិភាក្សា លើមាត្រា ២៤ ខាងលើ ) មានន័យថា ដី អគារ ផ្ទះ និងមធ្យោបាយដឹកជញ្ជូនណាមួយ ដែលគ្រប់គ្រងដោយរដ្ឋ ជាសាធារណៈ ឬ ជាឯកជន ដែលបើកឱ្យ និងផ្តល់សេវាឱ្យសាធារណៈជនទាំងអស់ ។ និយមន័យនេះ ស្របទៅនឹងមាត្រា ៤ នៃច្បាប់ ស្តីពី ការការពារ និងលើកស្ទួយសិទ្ធិរបស់ជនពិការ (២០០៩) ។ ហេតុដូច្នេះ ទ្រព្យសម្បត្តិ " ឯកជន " គឺជាទ្រព្យសម្បត្តិណាមួយ ដែលមិនបើកចំហឱ្យសាធារណៈជន ឬ មិនផ្តល់សេវាកម្មដល់សាធារណៈជន ។

" **ដោយដឹងថា បុគ្គលនោះនឹងប្រើប្រាស់ទីកន្លែងនោះ សម្រាប់ធ្វើសកម្មភាពពេស្យាចារ** "

បទល្មើសដែលមានចែងក្នុងមាត្រានេះ តម្រូវឱ្យអ្នកប្រព្រឹត្ត**បានដឹងដោយពិតប្រាកដ**ថា ទីកន្លែងនោះនឹងត្រូវប្រើប្រាស់ដើម្បីអំពើពេស្យាចារ ។ ឧទាហរណ៍ : ប្រសិនបើ ម្ចាស់ផ្ទះលក់ ឬ ជួលផ្ទះល្វែង ទៅឱ្យជនណាម្នាក់ដែលម្ចាស់ផ្ទះនោះដឹងថាជា បុគ្គលពេស្យា និងម្ចាស់បានដឹងថា បុគ្គលនោះ នឹងប្រព្រឹត្តអំពើពេស្យាចារនៅក្នុងផ្ទះល្វែងនោះ យោងតាមមាត្រានេះ ម្ចាស់ផ្ទះនឹងត្រូវផ្តន្ទាទោស ដោយជាប់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

" **អំពើពេស្យាចារ** "

មានន័យថា ជាសកម្មភាពដូចមាននិយមន័យក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

មាត្រានេះ តម្រូវឱ្យមានភស្តុតាងថា អ្នកប្រព្រឹត្តពិតជា**បានដឹងថា** បរិវេណនេះនឹងត្រូវប្រើប្រាស់ដើម្បីអំពើពេស្យាចារ ។ ទោះជាយ៉ាងណាក៏ដោយ ដូចបានពិភាក្សាក្នុងមាត្រា ៣១ បើគ្រាន់តែមានស្រោមអនាម័យ ឬ

សម្ភារៈផ្សេងទៀត ដែលគេប្រើប្រាស់ដើម្បីលើកកម្ពស់ឱ្យមានការយល់ដឹងពីជម្ងឺឆ្លងតាមការរួមភេទ នេះមិនមែនជាភស្តុតាង ដែលថាមានអំពើពេស្យាចារ កើតមានឡើងនៅក្នុងបរិវេណនោះទេ ។[៣៥] ប្រហាក់ប្រហែលគ្នានេះដែរ ការមិនមានស្រោមអនាម័យ ឬ សម្ភារៈប្រហាក់ប្រហែលផ្សេងទៀត មិនបង្ហាញជាការពិតថា មិនមានអំពើពេស្យាចារនៅក្នុងបរិវេណនោះទេ ។ ការផ្សព្វផ្សាយ និងការប្រើប្រាស់ស្រោមអនាម័យត្រូវបានលើកទឹកចិត្ត ដោយគោលនយោបាយរបស់រាជរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា យោងតាមច្បាប់ ស្តីពី ការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ឆ្នាំ២០០២[៣៦] និងគោលការណ៍ណែនាំអនុវត្តនៃច្បាប់នេះ[៣៧] និងហេតុដូច្នេះ ការចោទប្រកាន់ និងការផ្តន្ទាទោស យោងតាមបទប្បញ្ញត្តិនេះ តម្រូវឱ្យមានអង្គហេតុភស្តុតាងផ្សេងទៀត ដែលថាជនល្មើសបានដឹងពី សកម្មភាព អំពើពេស្យាចារ ។

គួរកត់សំគាល់ថា តម្រូវការឱ្យមានការដឹង ខុសគ្នាបន្តិចចំពោះការលក់ ទៅនឹងការជួលទ្រព្យសម្បត្តិ ។

ក) ការលក់

យោងតាមមាត្រានេះ ត្រូវទទួលការផ្តន្ទាទោស ក្នុងករណីដែលទ្រព្យសម្បត្តិដែលត្រូវលក់ អ្នកលក់ត្រូវដឹងថា នៅពេលដែលលក់នោះ ទ្រព្យសម្បត្តិនឹងត្រូវប្រើប្រាស់សម្រាប់អំពើពេស្យាចារ ។ ប្រសិនបើ នៅពេលលក់នោះ អ្នកលក់មិនបានដឹង ប៉ុន្តែក្រោយពីលក់ហើយបានដឹង ហេតុដូច្នេះអ្នកលក់មិនត្រូវទទួលទោស យោងតាមមាត្រានេះទេ ដោយសារតែអ្នកលក់លែងជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិនោះទៀតហើយ ។

ខ) ការជួល

យោងតាមមាត្រានេះ ត្រូវទទួលការផ្តន្ទាទោស ក្នុងករណីដែលទ្រព្យសម្បត្តិដែលត្រូវជួល ម្ចាស់ដីត្រូវទទួលការផ្តន្ទាទោស ប្រសិនបើគាត់ដឹងថា នៅពេលណាមួយនៅពេលជួល ទ្រព្យសម្បត្តិនោះត្រូវកំពុងប្រើប្រាស់សម្រាប់អំពើពេស្យាចារ ។ ក្នុងករណីនៃការជួល ម្ចាស់ដីមានការទទួលខុសត្រូវបន្ត ដោយសារតែគាត់នៅតែបន្តជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិនោះ ។

---

[៣៥] គ្រឹះស្ថានកំសាន្តសប្បាយ អាចច្បាប់តម្រូវឱ្យមាន និងតាំងបង្ហាញស្រោមអនាម័យ ឬ សម្ភារៈផ្សេងទៀត ។ តម្រូវការបែប នេះ អាចកើតមានស្របទៅតាមបទបញ្ជា ដូចជា បទបញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រី ស្តីពី កម្មវិធីប្រើប្រាស់ស្រោមអនាម័យឱ្យ បាន ១០០ ភាគរយ បទបញ្ជារបស់សាលាក្រុងភ្នំពេញ លេខ ០១/០៨ ស្តីពី ការប្រើប្រាស់ស្រោមអនាម័យ ១០០ ភាគរយ ឬ សេចក្តីប្រកាសលេខ ៨៦ របស់ក្រសួងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការគ្រប់គ្រងជម្ងឺអេដស៍នៅកន្លែងការងារ ។

[36] មាត្រា ២៩ នៃច្បាប់ស្តីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ តម្រូវឱ្យរដ្ឋត្រូវយកចិត្តទុកដាក់បន្តជម្រុញការ បង្ការទប់ស្កាត់ និងការគ្រប់គ្រងជម្ងឺកាមរោគ ក្នុងគោលដៅជួយទប់ស្កាត់ការឆ្លងរាលដាល មេរោគអេដស៍/ជម្ងឺអេដស៍ ។ មាត្រា ១១ នៃ ច្បាប់ស្តីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ តម្រូវឱ្យសម្ភារៈ ឬ វត្ថុធាតុសម្រាប់បង្ការការចម្លងមេរោគអេដស៍ទាំងអស់ ដូចជាស្រោមអនាម័យ ត្រូវភ្ជាប់នូវពតិមានដែលពន្យល់ពីវិធីប្រើប្រាស់ត្រឹមត្រូវសម្រាប់ប្រើប្រាស់វត្ថុធាតុទាំងនោះ ។

[37] ជំពូកទី ៥ នៃគោលការណ៍ណែនាំអនុវត្ត នៃច្បាប់ស្តីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ចែងថា "យោងតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល....... សេវាកម្មព្យាបាលជម្ងឺកាមរោគ គួរតែមានបញ្ចូលការផ្តល់ពតិមាន និងការអប់រំ ដូចជាការជម្រុញ និងការចែកចាយ ស្រោមអនាម័យ" ។ ជំពូកទី ៥ ក៏បានចែងទៀតថា ដើម្បីទប់ស្កាត់ជម្ងឺឆ្លង មេរោគអេដស៍ តាមរយៈអ្នករកស៊ីផ្លូវភេទ ប្រទេសកម្ពុជាបានអនុវត្ត "កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០ភាគរយ" ដាក់បញ្ជាឱ្យប្រើប្រាស់ស្រោមអនាម័យរាល់ពេល ប្រកបរបរផ្លូវភេទទាំងអស់ ហើយធ្វើការផ្តន្ទាទោសទៅលើម្ចាស់ និងអ្នកបើកគ្រឹះស្ថានកំសាន្តយុវជន (ដូចជាព្រមានបិទ) ចំពោះការមិនអនុវត្តតាមតម្រូវការរបស់កម្មវិធីនេះ ។

ជាចុងក្រោយ ជាការសំខាន់គួរកត់សំគាល់ថា មាត្រានេះមិនផ្តន្ទាទោសជនណាដែល លក់ ជួល ឬ ផ្តល់ទ្រព្យសម្បត្តិទៅឱ្យបុគ្គលពេស្យាដែលនឹងមិនប្រើប្រាស់ បរិវេណនោះដើម្បីប្រព្រឹត្តអំពើពេស្យាចារទេ ។

**ឧទាហរណ៍ : ក្នុងករណីដែលបុគ្គលពេស្យាស្នាក់នៅក្នុងផ្ទះជួល ឬ ផ្ទះល្វែងជួល ប៉ុន្តែមិនបានប្រព្រឹត្តអំពើពេស្យាចារ នៅក្នុងបរិវេណ ក្នុងផ្ទះនោះ ក្នុងករណីបែបនេះ ម្ចាស់ផ្ទះនោះមិនទទួល ការផ្តន្ទាទោសយោងតាមមាត្រានេះទេ ។**

## " ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ "

ជនណាដែលបានប្រព្រឹត្តបទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ទោសបន្ថែមអាចត្រូវអនុវត្តដោយអំណាចឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុង មាត្រា ៤៨ នៃច្បាប់នេះ ។

ប្រសិនបើ មានការប្រព្រឹត្តបទល្មើសទាក់ទងនឹងពេស្យាចារកុមារ ជនល្មើសគួរតែចោទប្រកាន់ និងផ្តន្ទាទោសឱ្យធ្ងន់ធ្ងរជាងនេះ ( ជាប់ពន្ធនាគារពី ៧ ( ប្រាំពីរ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ) ឆ្នាំ ) ដូចមានចែងក្នុងមាត្រា ៣៣ ( បទល្មើសទាក់ទងនឹងពេស្យាចារកុមារ ) ។

ដូចចែងក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតនៃនីតិបុគ្គល ឬ ភារប្បទាយី ត្រូវគេរកឃើញថាមានទោសប្រព្រឹត្តបទល្មើសនេះ តុលាការអាចផ្តន្ទាទោស នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែមដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមានដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា ៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

គួរកត់សំគាល់ថា មាត្រា ២៩៣ (បទដាក់ឱ្យប្រើប្រាស់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ) នៃក្រមព្រហ្មទណ្ឌ ដែលទាក់ទងនឹងអំពើដូចគ្នានឹងមាត្រា នេះបានចែងពីការផ្តន្ទាទោសដាក់ពន្ធនាគារដូចគ្នាពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ ។ យ៉ាងណាមិញ ក្រមព្រហ្មទណ្ឌដាក់បញ្ចូលទោសបន្ថែមពិន័យជាប្រាក់ ពី ៤ លានរៀល ដល់ ១០ លានរៀល ដែលទោសនេះអាចត្រូវបានដាក់តែឯង ឬរួមជាមួយគ្នានឹងទោសជាប់ពន្ធនាគារ ។

**ចំពោះភាពមិនស្របគ្នាក្នុងការផ្តន្ទាទោស រវាង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ អាចត្រូវបានដោះស្រាយ យោងតាមគោលការណ៍នៃការបកស្រាយច្បាប់ និងវិធានដែលមានចែង នៅក្នុង មាត្រា ៦៧១ និង មាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌ (សូមមើលការការពិភាក្សា ស្តីពី "គោលការណ៍ នៃការបកស្រាយច្បាប់" នៅក្នុងសេចក្តីផ្តើម និងនៅក្នុងមាត្រា ៥០ ខាងក្រោម) ។ ដោយផ្អែកទៅលើវិធានទាំងនេះ ការផ្តន្ទាទោសចំពោះ "បទដាក់ឱ្យប្រើប្រាស់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ" យោងតាមក្រមព្រហ្មទណ្ឌថ្មី ជាទូទៅ នឹងត្រូវយកមកប្រើជំនួស ការផ្តន្ទាទោសចំពោះអំពើដូចគ្នា ដែលមានចែងក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។**

ទោះបីជាយ៉ាងណាក៏ដោយ យោងទៅតាម " គោលការណ៍ឯកត្តកម្មនៃទោស " ក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ចំពោះករណីធ្ងន់ធ្ងរ នៃបទសញ្ចារកម្ម គួរតែធ្វើការផ្តន្ទាទោសដាក់ពន្ធនាគារ មិនមែនដាក់តែទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះទេ ដោយសារផ្អែកទៅលើកត្តាជាច្រើន ដូចជា ទំហំនៃប្រតិបត្តិការ ឬ ចំនួនពេស្យាចារដែលពាក់ព័ន្ធ ចំនួននៃប្រាក់ដែលទទួលបាន ដោយសញ្ចារិក/សញ្ចារិកា រយៈពេលដែលជនល្មើសប្រព្រឹត្តសកម្មភាព និងករណីមិនរាងចាលជាដើម ។

ប៉ុន្តែ បើបទល្មើសត្រូវធ្វើឡើងក្នុងបរិបទជួញដូរមនុស្ស ជនល្មើស គប្បីត្រូវចោទប្រកាន់ និងផ្តន្ទាទោសដាក់ពន្ធនាគារ តាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលជាច្បាប់ពិសេស មានអាទិភាពលើក្រមព្រហ្មទណ្ឌទាក់ទងនឹងបទល្មើសជួញដូរមនុស្ស) ។

## មាត្រា ៣៣.- បទល្មើសទាក់ទងនឹងពេស្យាចារកុមារ

ជនណាប្រព្រឹត្តបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣០ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ ប្រាំ) ឆ្នាំ បើបទល្មើសដែលបានប្រព្រឹត្តនោះទាក់ទងនឹងពេស្យាចារកុមារ ។

ពាក្យថា " ពេស្យាចារ " នៅក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនានានៃជំពូកនេះ ត្រូវជំនួសដោយពាក្យ " ពេស្យាចារកុមារ " នៅពេលដែលបទល្មើសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះត្រូវអនុវត្ត ។

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោសចំពោះ ការដឹកនាំ ការអនុគ្រោះ ឬ ផ្តល់ទីកន្លែងសម្រាប់ប្រើប្រាស់ប្រព្រឹត្តអំពើពេស្យាចារ ។ ជនណាប្រព្រឹត្តបទល្មើសនេះ ត្រូវផ្តន្ទាទោសឱ្យធ្ងន់ធ្ងរជាងនេះ ដោយដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ ឆ្នាំ មិនមែនពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ដូចមានចែងក្នុងមាត្រា ៣០ មាត្រា ៣១ និងមាត្រា ៣២ ឡើយ ។

ដើម្បីផ្តន្ទាទោសយោងតាមមាត្រានេះ ជនល្មើសត្រូវតែ :

ក ) មានទោសពីបទល្មើស ដូចមានការកំណត់និយមន័យក្នុងមាត្រា ៣០ ៣១ និង៣២ ខាងលើ

ខ ) ក្នុងករណីដែលបទល្មើសទាំងនេះ ទាក់ទិននឹងពេស្យាចារកុមារ

ក្នុងករណីបែបនេះ ជនល្មើសគួរតែត្រូវចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រានេះ មិនមែនយោងតាមមាត្រា ៣០ ៣១ ឬ ៣២ ទេ ។

" អំពើពេស្យចារកុមារ " មាននិយមន័យដូចមានចែងក្នុងមាត្រា ២៣ ខាងលើ ក្នុងករណីដែលសកម្មភាពទាក់ទិននឹងអនីតិជន (ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) ។

គួរកត់សំគាល់ថា ជំពូកទី ៦ (មាត្រា ៤២ ដល់ មាត្រា ៤៤) នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់ឱ្យអនីតិជនដែលមានអាយុ ១៥ ឆ្នាំ និងលើសពី ១៥ ឆ្នាំ (ពោលគឺ ជនដែលមាន

អាយុ ពី ១៥ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ) នូវសមត្ថភាពផ្លូវច្បាប់ ក្នុងការយល់ព្រមរួមភេទ ប៉ុន្តែច្បាប់នេះមិនបានផ្តល់ឱ្យអនីតិជន បែបនេះ នូវសមត្ថភាពក្នុងការយល់ព្រមប្រព្រឹត្តអំពើពេស្យាចារទេ ។ រាល់អំពើពេស្យាចារទាំងអស់ ដែលទាក់ទិននឹងអនីតិជនណាមួយ ( ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) ត្រូវចាត់ទុកថា ជាអំពើពេស្យចារកុមារ និងមិនស្របច្បាប់យោងតាម ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ក្នុងករណីដែលអនុវត្តបទល្មើស ការដឹកនាំ ការអនុគ្រោះ ការផ្តល់ទីកន្លែងដើម្បីប្រើប្រាស់សម្រាប់អំពើពេស្យាចារកុមារ នៅក្នុងជំពូកនេះ មាត្រានេះ ក៏ធ្វើការជំនួសពាក្យ " អំពើពេស្យាចារ " ទៅនឹងពាក្យ " ពេស្យាចារកុមារ " ចំពោះមាត្រាទាំងអស់ ។

**មាត្រា ៣៤.. ការទិញពេស្យាចារកុមារ**

**ជនណារួមភេទ ឬ ធ្វើអំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទជាមួយអនីតិជន ដែលមានអាយុចាប់ពី ១៥ ឆ្នាំ ឡើងទៅ ដោយផ្តល់ ឬ សន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយទៅឱ្យអនីតិជននោះ ឬ ទៅឱ្យអន្តរការី ឪពុកម្តាយ អ្នកអាណាព្យាបាល ឬ ជនដទៃទៀតដែលគ្រប់គ្រង ឬ ត្រួតពិនិត្យលើអនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ ( ពីរ ) ឆ្នាំ ដល់ ៥ ( ប្រាំ) ឆ្នាំ ។**

**ជនណាដែលប្រព្រឹត្តបទល្មើសខាងលើ ជាមួយអនីតិជនដែលមានអាយុតិចជាង ១៥ ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ ប្រាំ) ឆ្នាំ ។**

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោសទៅលើបទល្មើសការទិញពេស្យាចារកុមារ ។

មាត្រានេះ ចែងរយៈពេលនៃការផ្តន្ទាទោសពីរផ្សេងគ្នា ដោយពឹងផ្អែកទៅលើអាយុរបស់បុគ្គលពេស្យាកុមារ នៅពេលដែលប្រព្រឹត្តបទល្មើសនោះ :

- ប្រសិនបើ បុគ្គលពេស្យាមានអាយុ ពី ១៥ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើសអតិថិជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ( ពីរ ) ឆ្នាំ ដល់ ៥ ( ប្រាំ) ឆ្នាំ ។
- ប្រសិនបើ បុគ្គលពេស្យាកុមារមានអាយុក្រោម ១៥ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើសអតិថិជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ( ប្រាំពីរ ) ឆ្នាំ ដល់ ១៥ ( ដប់ប្រាំ) ឆ្នាំ ។

ទោសបន្ថែមអាចអនុវត្តដោយឆន្ទានុសិទ្ធិរបស់តុលាការ តាមមាត្រា ៤៨ នៃច្បាប់នេះ ។

ការបែងចែកអាយុជាពីរដូចនេះ ឆ្លុះបញ្ចាំងពីការពិតថា ទោះបីជា ជំពូកទី ៦ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់ឱ្យអនីតិជនដែលមានអាយុពី ១៥ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ នូវសមត្ថភាពក្នុងការយល់ព្រមរួមភេទក៏ដោយ ច្បាប់នេះមិនបានផ្តល់ឱ្យអនីតិជនដែលមានអាយុពី ១៥ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ នូវសមត្ថភាពប្រព្រឹត្តអំពើពេស្យាចារកុមារទេ។ យ៉ាងណាមិញ ដោយសារតែអនីតិជនដែលមានអាយុក្រោម

១៥ ឆ្នាំ ត្រូវបានចាត់ទុកថាងាយរងគ្រោះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តន្ទាទោសធ្ងន់ធ្ងរទៅលើបុគ្គលណាដែលទិញពេស្យាចារ ដែលទាក់ទិននឹងអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ ។

ជាការសំខាន់គួរកត់សំគាល់ថា មិនជាបញ្ហាថា តើអនីតិជនដែលទាក់ទិននឹងអំពើនោះ ពីមុនបានប្រព្រឹត្តអំពើពេស្យាចារកុមារដែរ ឬ អត់ ឬ ថាតើវាជាលើកដំបូង ដែលអនីតិជននោះស្ថិតក្នុងស្ថានភាពបែបនេះ ។ ប្រហាក់ប្រហែលគ្នានេះដែរ ជនល្មើសមិនអាចទាមទារឱ្យមានការការពារថា អនីតិជនបានអូសទាញ និងយល់ព្រមចំពោះ អំពើពេស្យាចារ ដោយសារតែច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចាត់ទុកថា តាមច្បាប់ អនីតិជន មិនអាចយល់ព្រមចំពោះ អំពើពេស្យាចារនោះទេ ។

បទល្មើស ការទិញពេស្យាចារកុមារ មានធាតុផ្សំជាច្រើន :

## " ជនណា "

មាត្រានេះ ផ្តន្ទាទោសជនណាដែល ទិញ ឬ (តាមរយៈការអនុវត្តមាត្រា ៤ ) ប៉ុនប៉ងទិញ សេវាកម្មភេទ ពីអនីតិជន (ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) ។ អញ្ចឹងហើយ ពាក្យ " ជនណា " នៅទីនេះ មានន័យថា ជាអតិថិជនពេស្យាចារ ។

ជនល្មើសអាចជា នីតិជន ឬ អនីតិជន ។ ឧទាហរណ៍ : អ្នកប្រព្រឹត្តអាយុ ១៧ ឆ្នាំ ដែលទិញពេស្យាចារកុមារ ពីអនីតិជន អាចទទួលទោសយោងតាមមាត្រានេះ ។ ជាការសំខាន់ ក្នុងការបែងចែកការផ្តល់ឱ្យអាយុ នៃមាត្រានេះ ឱ្យច្បាស់ពីការផ្តល់ឱ្យអាយុ ក្នុងជំពូកទី ៦ (អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ ) ។ ក្នុងជំពូកនោះ មាត្រា ៤២ និង មាត្រា ៤៣ ផ្តល់ឱ្យអនីតិជនដែលមានអាយុ ១៥ ឆ្នាំ ឬ លើសពី ១៥ ឆ្នាំ នូវសមត្ថភាពក្នុងការរួមភេទ ។ ប៉ុន្តែនេះមិនមានន័យថា អនីតិជនបែបនេះ ច្បាប់អនុញ្ញាតឱ្យទិញពេស្យាចារ ពីអនីតិជនដែលមានអាយុ ១៥ ឆ្នាំ ឬ លើសពី ១៥ ឆ្នាំ ទេ ។ ក្នុងន័យផ្សេងទៀត អនីតិជនដែលមានអាយុ ១៥ ឆ្នាំ ឬ លើសពី ១៥ ឆ្នាំ អាចធ្វើការរួមភេទជាមួយអនីតិជនម្នាក់ទៀត ដែលមានអាយុ ១៥ ឆ្នាំ ឬ លើសពី ១៥ ឆ្នាំ ប៉ុន្តែមាត្រានេះ ដាក់ទោសអំពើនោះ ប្រសិនបើ ការរួមភេទប្រព្រឹត្តឡើងតាមរយៈការផ្តល់ ឬ សន្យាឱ្យវត្ថុមានតម្លៃអ្វីមួយ ។

យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គួរកត់សំគាល់មាត្រានេះ គឺជាបទប្បញ្ញត្តិតែមួយគត់ ដែលផ្តន្ទាទោសជនណា (អតិថិជន) ដែលទិញពេស្យាចារកុមារ ។

## " ដែលរួមភេទ ឬ ធ្វើអំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទ "

មាត្រានេះ ផ្តន្ទាទោសជនណា ដែលបានរួមភេទបានសម្រេច ឬ ដែលប៉ុនប៉ងរួមភេទ ឬ ធ្វើអំពើគ្រប់រូបភាព ផ្សេងទៀត ដែលទាក់ទងនឹងផ្លូវភេទជាមួយអនីតិជនតាមរយៈការផ្តល់ ឬ សន្យាឱ្យវត្ថុមានតម្លៃអ្វីមួយ ។

យោងតាម បទប្បញ្ញត្តិនៃមាត្រា ៤ កថាខណ្ឌទី ១ ) " ការប៉ុនប៉ង " មាត្រានេះ ក៏អាចត្រូវប្រើប្រាស់ដើម្បី ផ្តន្ទាទោស ជនណាដែលបានប៉ុនប៉ងទិញពេស្យាចារ (ទោះបីការរួមភេទមិនទាន់កើតឡើងនៅឡើយ ) ។

" **ការរួមភេទ** " មានន័យថា ជាការបញ្ចូលកេរភេទទៅក្នុងកេរភេទ មាត់ ឬ រន្ធគូទ របស់ជនម្នាក់ទៀត ឬ ការបញ្ចូលសម្ភារៈ ឬ ឧបករណ៍ទៅក្នុងកេរភេទរបស់ជនម្នាក់ទៀត[៣៨] ។ ការរួមភេទអាចកើតឡើងរវាងមនុស្សពីរនាក់ ឬ ច្រើនជាងពីរនាក់ ដែលមានភេទដូចគ្នា ឬ ខុសគ្នា ។

ពាក្យថា "ឧបករណ៍" ត្រូវគេយល់ថារាប់បញ្ចូលទាំងម្រាមដៃ ឬផ្នែកដទៃទៀតនៃរាងកាយមនុស្ស។

ជាទូទៅពាក្យថា " កេរភេទ " ត្រូវបានកំណត់ថា ជាលិង្គ ឬ រន្ធយោនី ។ ប៉ុន្តែដើម្បីពង្រឹងការការពារដល់ជនរងគ្រោះ នៅក្នុងច្បាប់នេះ ពាក្យថា កេរភេទ ត្រូវបានគេយល់ថា ជាលិង្គ ឬ រន្ធយោនី ឬ រន្ធគូទ ។

ពាក្យថា "អំពើរួមភេទ" មានរាប់បញ្ចូល ការរួមភេទតាមរន្ធយោនី ការរួមភេទតាមរន្ធគូទ និងការរួមភេទតាមមាត់[៣៩] មិនថាឡើយរវាងបុរស និងស្ត្រី បុរស និង បុរស ឬស្ត្រី និងស្ត្រី។

**"អំពើផ្លូវភេទគ្រប់ប្រភេទផ្សេងទៀត"** មានន័យថាជាអំពើដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទរបស់អ្នកប្រព្រឹត្ត។

អំពើបែបនេះរួមមាន ការប៉ះរូបកាយរវាងបុគ្គលពេស្យា និងជនដទៃ និងក៏អាចរាប់បញ្ចូលករណីដែលមិនមានការប៉ះរូបកាយរវាងបុគ្គលពេស្យា និងជនដទៃ ដែរ។ ឧទាហរណ៍ ប្រសិនបើជនណាម្នាក់ ឱ្យលុយដើម្បីមើលឃើញកេរភេទរបស់កុមារ ឬដើម្បីមើលកុមារសម្រេចកាមដោយខ្លួនឯង ជននោះអាចត្រូវចោទប្រកាន់យោងតាមមាត្រានេះ ទោះបីជាមិនមានការប៉ះពាល់រូបកាយរវាង អតិថិជន និងកុមារនោះក៏ដោយ ។

ដើម្បីឱ្យក្លាយជា " អំពើផ្លូវភេទផ្សេងទៀត " អំពើនោះត្រូវតែធ្វើឡើងដោយមានគោលដៅធ្វើឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទរបស់អតិថិជន ។ មិនសំខាន់ថា តើអតិថិជននោះព្យាយាមធ្វើឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទដោយវិធីណាទេ ។ អតិថិជនអាចចាប់ផ្តើមរួមភេទជាមួយ បុគ្គលពេស្យា ឬ ឱ្យបុគ្គលពេស្យារួមភេទជាមួយ ឬ បង្ហាញឱ្យអតិថិជន ឬ តតិយជនឃើញ ឬ ឱ្យតតិយជនរួមភេទជាមួយបុគ្គលពេស្យា ។

## " ជាមួយអនីតិជនដែលមានអាយុចាប់ពី ១៥ ឆ្នាំ ឡើងទៅ "

" អនីតិជន " មានន័យថា ជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ដូចមាននិយមន័យក្នុងមាត្រា ៧ ។ ប្រសិនបើ នៅពេលប្រព្រឹត្តបទល្មើសអនីតិជនមានអាយុ ពី ១៥ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ អតិថិជនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ( ពីរ ) ឆ្នាំ ដល់ ៥ ( ប្រាំ) ឆ្នាំ ។

ជំពូកទី ៦ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់ឱ្យអនីតិជនដែលមានអាយុ ១៥ ឆ្នាំ និងលើសពី ១៥ ឆ្នាំ ( ជនដែលមានអាយុចាប់ពី ១៥ ដល់ក្រោម ១៨ ឆ្នាំ ) នូវសមត្ថភាពផ្លូវច្បាប់

---

[៣៨] និយមន័យនេះ ស្របទៅនឹងសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ លេខ ០១ កយ.សណន/០៩ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដែលកំណត់និយមន័យការរួមភេទ ទាក់ទងនឹងមាត្រា ៤២ និងមាត្រា ៤៣ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

[៣៩] និយមន័យនៃពាក្យនេះ ផ្អែកទៅលើនិយមន័យនៃ " អំពើអាស " ដែលមានប្រើនៅក្នុងមាត្រា ៤៣ នៃច្បាប់នេះ និងមានកំណត់និយមន័យក្នុងសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ លេខ ០១ កយ.សណន/០៩ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។

ក្នុងការយល់ព្រមរួមភេទ ។ ប៉ុន្តែច្បាប់នេះ មិនបានផ្តល់ឱ្យអនីតិជនបែបនេះ នូវសមត្ថភាពក្នុងការយល់ព្រមប្រព្រឹត្ត អំពើពេស្យាចារទេ ។ រាល់អំពើពេស្យាចារទាំងអស់ ដែលទាក់ទិននឹងអនីតិជនណាមួយ (ជនដែលមានអាយុក្រោម ១៨ ឆ្នាំ) ត្រូវចាត់ទុកថា ជាអំពើពេស្យាចារកុមារ និងមិនស្របច្បាប់យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

### " ដោយផ្តល់ ឬ សន្យាផ្តល់ "

មាត្រានេះ ផ្តន្ទាទោសអតិថិជនដែលមានការរួមភេទជាមួយអនីតិជន ដោយផ្តល់ ឬ សន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយ ។

ជាការសំខាន់គួរកត់សំគាល់ថា មាត្រានេះមិនតម្រូវថា អតិថិជនពិតជាផ្តល់វត្ថុមានតម្លៃអ្វីមួយ ។ ប្រសិនបើអតិថិជនគ្រាន់តែសន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយ និងបានរួមភេទជាមួយអនីតិជនដោយសន្យាថា ផ្តល់វត្ថុនោះ ហេតុដូច្នេះ អតិថិជនត្រូវទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ។

**ឧទាហរណ៍ : អ្នកប្រព្រឹត្តសន្យាបង់ប្រាក់ថ្លៃសាលាឱ្យអនីតិជន ដើម្បីជាការផ្លោះប្តូរការរួមភេទ និងបានរួមភេទជាមួយអនីតិជន ប៉ុន្តែការផ្តន្ទាទោសមកមិនបានបង់ថ្លៃសាលាឱ្យអនីតិជនទេ អ្នកប្រព្រឹត្តទទួលការផ្តន្ទាទោសយោងតាមមាត្រានេះ ។**

### " វត្ថុមានតម្លៃអ្វីមួយ "

ដូចបានពិភាក្សា យោងតាមមាត្រា ២៣ ខាងលើ ពាក្យថា " វត្ថុមានតម្លៃអ្វីមួយ " រួមមានដូចជា លាភការជាប្រាក់ ឬ វត្ថុមានតម្លៃ ( ឧទាហរណ៍ : គ្រឿងអលង្ការ សំលៀកបំពាក់ ។ល។ ) ទ្រព្យសម្បត្តិ ដែលមានរូបរាង (ឧទាហរណ៍ : ផ្ទះ ដី អាគារ ។ល។ ) ទ្រព្យសម្បត្តិដែលគ្មានរូបរាង ឬ សិទ្ធប្រត្យក្ស ( ឧទាហរណ៍ : សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ សិទ្ធិលក់ ឬ សិទ្ធិជួល ប្រភេទណាមួយ នៃចលនទ្រព្យ ឬ អចលនទ្រព្យ ) សេវាកម្ម ការបង់ប្រាក់ដោយផ្ទាល់ ឬ ដោយប្រយោល ឬ ថ្លៃឈ្នួល ( ថ្លៃឈ្នួលដែលបង់ទៅឱ្យតាមរយៈ ឬ ក្នុងនាមជន ផ្សេងទៀត ) ព័ត៌មានដែលមានតម្លៃ ឬ ការគ្រប់គ្រងលើមនុស្ស ។

### " ទៅឱ្យអនីតិជននោះ ឬ ទៅឱ្យអន្តរការី ឪពុក-ម្តាយ អាណាព្យាបាល ឬ ជនដទៃទៀតដែលគ្រប់គ្រង ឬ ត្រួតពិនិត្យលើអនីតិជននោះ "

បទប្បញ្ញត្តិនេះ ឆ្លុះបញ្ចាំងពីការពិតថា ក្នុងករណីដែលមានអំពើពេស្យាចារកុមារ ជាញឹកញាប់អនីតិជនមិនបានទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុដោយផ្ទាល់ណាមួយទេ ។ បែរជា អត្ថប្រយោជន៍ហិរញ្ញវត្ថុនោះ បានទៅលើឪពុក-ម្តាយ អាណាព្យាបាល ឬ ជនដទៃដែលគ្រប់គ្រង ឬ ត្រួតពិនិត្យលើអនីតិជននោះ ។ ហេតុដូច្នេះ មាត្រានេះ ផ្តន្ទាទោសចំពោះការទិញពេស្យាចារកុមារ ក្នុងស្ថានការណ៍បែបនេះ ។

ឧទាហរណ៍ ៖ ប្រសិនបើ "ក" បានរួមភេទជាមួយអនីតិជន ដោយផ្ដល់ប្រាក់ទៅឱ្យអន្តរការី "ក" នឹងបានប្រព្រឹត្តបទទិញពេស្យាចារកុមារ ។ ប្រសិនបើ "ក" បានប្រព្រឹត្តអំពើអាសជាមួយអនីតិជន ដោយសន្យាធ្វើការឱ្យឪពុក-ម្ដាយរបស់អនីតិជននោះ រយៈពេលមួយខែ "ក" នឹងបានប្រព្រឹត្តបទទិញពេស្យាចារកុមារ ដោយសារតែគាត់បានសន្យាផ្ដល់វត្ថុមានតម្លៃអ្វីមួយ (សេវាកម្ម) ទៅឱ្យឪពុក-ម្ដាយរបស់អនីតិជន ។

គួរកត់សំគាល់ថា ឧទាហរណ៍ទាំងអស់ក្នុងកថាខ័ណ្ឌខាងលើ អន្តរការី ឪពុកម្ដាយ ឬ អ្នកអាណាព្យាបាល នឹងក៏ទទួលទោសយោងតាមមាត្រា ២៨ (សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ) ។

## " ការគ្រប់គ្រង ឬ ត្រួតពិនិត្យ "

" ការគ្រប់គ្រង ឬ ត្រួតពិនិត្យ " មានន័យថា ជាស្ថានការណ៍ ពីរ ៖

ក) អំណាចស្របច្បាប់ ដែលផ្ដល់ដោយច្បាប់ ទៅកាន់ឪពុក-ម្ដាយ អាណាព្យាបាល ឬ អ្នកថែរក្សាទូទៅរបស់អនីតិជន ឬ

ខ) ការគ្រប់គ្រង ឬ ការត្រួតពិនិត្យ ទៅលើអនីតិជននោះ ក្នុងករណីដែលនីតិជននោះ មិនមានសិទ្ធិអំណាចតាមផ្លូវច្បាប់ ទៅលើអនីតិជននោះ ដូចក្នុងចំនុចទី ១ ខាងលើនេះក៏ដោយ ។

ឧទាហរណ៍ ៖ ប្រសិនបើ ឪពុកម្ដាយ សុំឱ្យសាច់ញាតិរបស់ខ្លួន ឬ អ្នកជិតខាង ថែរក្សាកូនរបស់គាត់ដែលជាអនីតិជន ក្នុងអំឡុងពេលណាមួយ សាច់ញាតិ និងអ្នកជិតខាងនោះត្រូវបានចាត់ទុកថា មានការគ្រប់គ្រង ឬ ត្រួតពិនិត្យលើអនីតិជននោះ ។

ប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើអនីតិជនត្រូវគេជ្រើសរើសឱ្យបម្រើការងារ និយោជកត្រូវគេចាត់ទុកថា មានការគ្រប់គ្រង ឬ ត្រួតពិនិត្យទៅលើអនីតិជន នៅពេលម៉ោងការងារ ឬ ចំពេលដែលអនីតិជននោះ កំពុងធ្វើការងារ ។

ប្រសិនបើ អនីតិជននោះនៅឯសាលារៀនកំពុងសិក្សា លោកគ្រូ-អ្នកគ្រូ របស់អនីតិជន និងនាយកសាលាត្រូវចាត់ទុកថា មានការ គ្រប់គ្រង និងការត្រួតពិនិត្យលើអនីតិជននោះ ។

**មាត្រា ៣៥.. ការផ្សាយពាណិជ្ជកម្មពេស្យាចារកុមារ**

ជនណាចែកចាយឯកសារដែលសម្រាប់អំពើពេស្យាចារកុមារ ឬ ផ្សាយពាណិជ្ជកម្មនូវអំពើពេស្យាចារកុមារ ក្នុងគោលបំណងធ្វើជាអន្តរការីនៃអំពើពេស្យាចារកុមារនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

ជនណាប្រព្រឹត្តបទល្មើសខាងលើ ធ្វើជាមុខរបរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះជនណាដែលអូសទាញអតិថិជន ដែលមានសក្តានុពលឱ្យប្រព្រឹត្តអំពើពេស្យាចារកុមារ ឬ ដែលផ្សាយពាណិជ្ជកម្មនូវអំពើពេស្យាចារកុមារ ដើម្បីទទួលបានអត្ថ-ប្រយោជន៍ហិរញ្ញវត្ថុ ជាអន្តរការី ។

គួរកត់សំគាល់ថា មាត្រានេះមិនបានចែង និងមិនបានធ្វើការផ្តន្ទាទោស បុគ្គលធ្វើពេស្យាចារកុមារ ដែលអូសទាញជនដទៃ ( អតិថិជន) ក្នុងគោលបំណងធ្វើពេស្យាចារដោយខ្លួនឯង ។ អំពើអូសទាញដោយមានគោលដៅប្រព្រឹត្តអំពើពេស្យា មិនគ្របដណ្តប់ដោយមាត្រា ២៤ ទេ ។ យោងតាមមាត្រា ២៤ ( កថាខ័ណ្ឌទី ២ ) អនីតិជនរួចផុតពីការទទួលការផ្តន្ទាទោស នៃបទល្មើសអូសទាញ ។

## " អូសទាញ "

" អូសទាញ " មានន័យថា ជាសកម្មភាពដូចមាននិយមន័យ ក្នុងមាត្រា ២៤ ( អំពើអូសទាញ ) ។ មាត្រានេះផ្តន្ទាទោស ចំពោះអំពើអូសទាញក្នុងគោលបំណងប្រព្រឹត្តអំពើ ពេស្យាចារកុមារ ។

ពាក្យថា " អូសទាញ " មានន័យថា ត្រូវមានទំនាក់ទំនងច្បាស់លាស់ រវាងជនល្មើស និងជនម្នាក់ទៀត ឬ អាកប្បកិរិយាផ្សេងទៀត របស់ជនល្មើសដែលបង្ហាញឱ្យឃើញថា ជនល្មើសមានចេតនានាំបុគ្គលធ្វើពេស្យាចារកុមារឱ្យជនម្នាក់ផ្សេងទៀត ឬ កំពុងផ្សាយពាណិជ្ជកម្ម ពីសេវាកម្មរបស់បុគ្គលធ្វើពេស្យាចារកុមារ ក្នុងការផ្តោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ ។

## " ការផ្សាយពាណិជ្ជកម្ម "

ក្នុងបទប្បញ្ញត្តិនេះ " ការផ្សាយពាណិជ្ជកម្ម " មានន័យថា ជាការផ្សព្វផ្សាយឱ្យមានសេវាកម្មពេស្យាចារកុមារ ទៅឱ្យជនម្នាក់ផ្សេងទៀត ឬ ដើម្បីជូនដំណឹងដល់ជនម្នាក់ផ្សេងទៀត ពីសេវាកម្មពេស្យាចារកុមារ ។ ការផ្សាយពាណិជ្ជកម្ម ( ការផ្សព្វផ្សាយ ឬ ជូនដំណឹង ) អាចត្រូវធ្វើឡើងតាមរយៈមធ្យោបាយ ផ្សព្វផ្សាយ ដែលរួមមាន ការធ្វើឡើងដោយផ្ទាល់មាត់ ដោយបោះពុម្ព ឬ តាមអេឡិចត្រូនិក ។

## " ពេស្យាចារកុមារ "

" ពេស្យាចារកុមារ " មាននិយមន័យដូចមានចែង ក្នុងមាត្រា ២៣ ខាងលើ ក្នុងករណីដែលសកម្មភាពអំពើពេស្យាចារទាក់ទងនឹងអនីតិជន ( ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) ។

គួរកត់សំគាល់ថា ជំពូកទី ៦ ( មាត្រា ៤២ ដល់ មាត្រា ៤៤) នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់ឱ្យអនីតិជនដែលមានអាយុ ១៥ ឆ្នាំ និងលើសពី ១៥ ឆ្នាំ ( ជនដែលមានអាយុចាប់ពី ១៥ ដល់ក្រោម ១៨ ឆ្នាំ ) នូវសមត្ថភាពផ្លូវច្បាប់ ក្នុងការយល់ព្រមរួមភេទ ប៉ុន្តែច្បាប់នេះមិនបានផ្តល់ ឱ្យអនីតិជនបែបនេះ នូវសមត្ថភាពក្នុងការយល់ព្រមប្រព្រឹត្តអំពើពេស្យាចារទេ ។ រាល់អំពើពេស្យាចារទាំងអស់ ដែលទាក់ទិននឹង

អនីតិជនណាមួយ (ជនដែលមានអាយុក្រោម ១៨ ឆ្នាំ) ត្រូវចាត់ទុកថា ជាអំពើពេស្យាចារកុមារ និងមិនស្របច្បាប់ យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

### " ក្នុងគោលដៅធ្វើជាអន្តរការីនៃអំពើពេស្យាចារកុមារនោះ "

មាត្រានេះ មានគោលបំណងធ្វើការផ្តន្ទាទោសទៅលើជនណា ដែលធ្វើជាអន្តរការី ។ ក្នុងមាត្រានេះ " ការធ្វើ ជាអន្តរការី " មានន័យថា ជនល្មើសមានចេតនាចំពោះសកម្មភាពរបស់ក្នុងការធ្វើជាអន្តរការី ដើម្បីជម្រុញ ឬ សម្រួល ឱ្យមានអំពើពេស្យាចារកុមារ ។

### " ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល "

ជនណាដែលត្រូវរកឃើញថា មានទោសពីបទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន ) រៀល ។ ដូចមានចែងក្នុងមាត្រា ៥ " ការប្រកាសមូលទោស " គឺតុលាការអាចដាក់ទោស តែមួយមុខ ឬ ទាំងពីរមុខ ។ ទោសបន្ថែមអាចអនុវត្តបានដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ នៃច្បាប់នេះ ។

ដូចចែងក្នុងមាត្រា ៤ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតនៃនីតិបុគ្គល ឬ ភារប្បទាយី ត្រូវគេរកឃើញថាមានទោសប្រព្រឹត្តបទល្មើសនេះ តុលាការអាចផ្តន្ទាទោសនីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែមដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ (មាត្រា៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣) ឬ ការបិទការផលិត (មាត្រា ៤៨ កថាខ័ណ្ឌទី ៤) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

### " ជនណាប្រព្រឹត្តបទល្មើសខាងលើ ធ្វើជាមុខរបរ "

បទប្បញ្ញត្តិនេះ បង្កើតទោសចំពោះជនល្មើសដែលបានប្រព្រឹត្តបទល្មើសធ្វើជាមុខរបរ ។ ក្នុងករណីបែបនេះ ជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។ ទោសបន្ថែមអាចអនុវត្តបានដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ នៃច្បាប់នេះ ។

" ជាមុខរបរ " មានន័យថា អ្នកប្រព្រឹត្តអូសទាញ ឬ ផ្សាយពាណិជ្ជកម្ម ពីពេស្យាចារកុមារ ជាដដែលៗ និងជាទៀតទាត់ ក្នុងគោលបំណងទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុបច្ចុប្បន្ន ពីសកម្មភាពរបស់គាត់ ។

ដូចចែងក្នុងមាត្រា ៤ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតនៃនីតិបុគ្គល ឬ ភារប្បទាយី ត្រូវគេរកឃើញថាមានទោសប្រព្រឹត្តបទល្មើសនេះ តុលាការអាចផ្តន្ទាទោស

នីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែមដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

## មាត្រា ៣៦.. ការឱ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ

ជនណាឱ្យជនដទៃខ្ចីប្រាក់ ឬ វត្ថុមានតម្លៃអ្វីមួយ ដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឱ្យអនីតិជន ប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ( ប្រាំ) ឆ្នាំ ដល់ ១០ ( ដប់) ឆ្នាំ ។

ជនណាឱ្យអនីតិជនខ្ចីប្រាក់ ឬ វត្ថុមានតម្លៃអ្វីមួយ ដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឱ្យអនីតិជននោះប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ។

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោសចំពោះ ជនណាដែលឱ្យខ្ចីប្រាក់ ឬ វត្ថុមានតម្លៃអ្វីមួយទៅដល់តតិយជន ឬ អនីតិជន ដោយមានលក្ខខ័ណ្ឌឱ្យអនីតិជននោះ ប្រព្រឹត្តអំពើពេស្យាចារកុមារ ។

### " ការឱ្យខ្ចីប្រាក់ "

" ការឱ្យខ្ចីប្រាក់ " មានន័យថា ជាចំនួនប្រាក់ ( ជារូបិយប័ណ្ណ) ដែលប្រគល់ទៅឱ្យអ្នកខ្ចី ដើម្បីប្រើប្រាស់ក្នុងអំឡុងពេលណាមួយ ដោយរំពឹងថា/ឬសន្យាថា ប្រាក់នោះនឹងប្រគល់ទៅឱ្យអ្នកឱ្យខ្ចីវិញ ( ដោយមាន ឬ មិនមានការប្រាក់ ) ។

### " វត្ថុមានតម្លៃអ្វីមួយ "

ដូចបានពិភាក្សា យោងតាមមាត្រា ២៣ ខាងលើ ពាក្យថា " វត្ថុមានតម្លៃអ្វីមួយ " រួមមានដូចជា លាភការជាប្រាក់ ឬ វត្ថុមានតម្លៃ ( ឧទាហរណ៍ : គ្រឿងអលង្ការ សំលៀកបំពាក់ ។ល។ ) ទ្រព្យសម្បត្តិ ដែលមានរូបរាង ( ឧទាហរណ៍ : ផ្ទះ ដី អាគារ ។ល។ ) ទ្រព្យសម្បត្តិដែលគ្មានរូបរាង ឬ សិទ្ធប្រត្យក្ស ( ឧទាហរណ៍ : សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ សិទ្ធិលក់ ឬ សិទ្ធិជួល ប្រភេទណាមួយ នៃចលនទ្រព្យ ឬ អចលនទ្រព្យ ) សេវាកម្ម ការបង់ប្រាក់ដោយផ្ទាល់ ឬ ដោយប្រយោល ឬ ថ្លៃឈ្នួល ( ថ្លៃឈ្នួលដែលបង់ទៅឱ្យតាមរយៈ ឬ ក្នុងនាមជនផ្សេងទៀត ) ព័ត៌មានដែលមានតម្លៃ ឬ ការគ្រប់គ្រង លើមនុស្ស ។

" វត្ថុមានតម្លៃអ្វីមួយ " គួរត្រូវបកស្រាយឱ្យទូលំទូលាយ ដើម្បីរាប់បញ្ចូលគ្រប់ទម្រង់នៃការចំណាយ ដែលមានលក្ខខ័ណ្ឌទាំងអស់ ឬ ការឱ្យផ្តល់ឱ្យ ដែលទាក់ទងនឹងអំពើពេស្យាចារកុមារ ។

ឧទាហរណ៍ : ប្រសិនបើ អ្នកប្រព្រឹត្តផ្តល់ទូរទស្សន៍ ទៅឱ្យម្តាយដោយមានលក្ខខ័ណ្ឌថា កូនស្រីដែលជាអនីតិជន របស់គាត់ ត្រូវធ្វើពេស្យាចារដោយខ្លួនឯង អ្នកប្រព្រឹត្តនោះនឹងត្រូវផ្តន្ទាទោស យោងតាមមាត្រានេះ ។

ប្រសិនបើ និយោជក យល់ព្រមផ្ដល់ការងារឱ្យអ្នកសំអាតណាម្នាក់ ដោយមានល័ក្ខខ័ណ្ឌឱ្យកូនស្រីដែលជាអនីតិជនរបស់អ្នកសំអាតនោះ ធ្វើពេស្យាចាដោយខ្លួនឯង និយោជកនោះ នឹងត្រូវផ្ដន្ទាទោសយោងតាមមាត្រានេះ ។

ដូចគ្នានេះដែរ ប្រសិនបើអ្នកប្រព្រឹត្តផ្ដល់ស្ករគ្រាប់ ទៅឱ្យអនីតិជនដោយមានលក្ខខ័ណ្ឌថា ឱ្យអនីតិជននោះធ្វើពេស្យាចារដោយខ្លួនឯង អំពើនេះនឹងត្រូវស្ថិតក្នុងមាត្រានេះ ។

### " ដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឱ្យអនីតិជននោះ ប្រកបរបរពេស្យាចារ "

មាត្រានេះ មានគោលបំណងធ្វើការផ្ដន្ទាទោសជនដែល ជ្រើសរើស រកស្រើឱ្យ អូសទាញ ឬ ផ្សព្វផ្សាយ អំពើពេស្យាចារកុមារ តាមរយៈផ្ដល់ប្រាក់កម្ចី ឬ វត្ថុមានតម្លៃអ្វីមួយឱ្យទៅតតិយជន ឬ អនីតិជនដោយមានលក្ខខណ្ឌឱ្យអនីតិជននោះ ប្រកបរបរពេស្យាចារ ។ ជាការមិនសំខាន់ថាតើអនីតិជននោះ ពិតជាបានប្រព្រឹត្តអំពើពេស្យាចារ ដោយសារតែប្រាក់កម្ចីរបស់អ្នកប្រព្រឹត្ត ដែរឬអត់ ។

" ពេស្យាចារកុមារ " មាននិយមយ័យដូចមានចែង ក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

" របរពេស្យាចារកុមារ " រាប់បញ្ចូលស្ថានភាពដែលអនីតិជននោះ ត្រូវបង្ខំឱ្យប្រព្រឹត្តពេស្យាចារកុមារ មិនថាឡើយធ្វើតែម្ដង ឬ ជាទៀងទាត់ ។

គួរកត់សំគាល់ថា មាត្រានេះមិនព្យាយាមផ្ដន្ទាទោសជនណា ( អតិថិជន) ដែលឱ្យប្រាក់ដល់បុគ្គលធ្វើពេស្យាចារកុមារ ដើម្បីរួមភេទជាមួយបុគ្គលពេស្យាកុមារនោះ ។ អាកប្បកិរិយាបែបនេះ ត្រូវផ្ដន្ទាទោសយោងតាម បទល្មើសដែលមានចែងក្នុងមាត្រា ៣៤ " ការទិញពេស្យាចារកុមារ " ។ មាត្រានេះ ព្យាយាមផ្ដន្ទាទោសអ្នកដែលអូសទាញ ឬបង្ខំកុមារ ឱ្យប្រព្រឹត្តអំពើពេស្យចារ តាមរយៈការឱ្យខ្ចីប្រាក់ ឬ វត្ថុមានតម្លៃផ្សេងទៀត ។

### " ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ "

ជនណាដែលត្រូវរកឃើញថា មានទោសពីបទល្មើសនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ ( ប្រាំ) ឆ្នាំ ដល់ ១០ ( ដប់) ឆ្នាំ ។ ទោសបន្ថែមអាចអនុវត្តបានដោយឆន្ទានុសិទ្ធិរបស់តុលាការដូចមានចែងក្នុងមាត្រា ៤៨នៃច្បាប់នេះ ។

ដូចចែងក្នុងមាត្រា ៤ ( ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតនៃនីតិបុគ្គល ឬ ភារប្បទាយី ត្រូវគេរកឃើញថាមានទោសប្រព្រឹត្តបទល្មើសនេះ តុលាការអាចផ្ដន្ទាទោសនីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែមដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ ( មាត្រា៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣ ) ឬ ការបិទការផលិត ( មាត្រា ៤៨ កថាខ័ណ្ឌទី ៤ ) ។ ( សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត ) ។

**មាត្រា ៣៧.- កិច្ចសន្យានៃអំពើពេស្យាចារកុមារ**

ជនណាធ្វើកិច្ចសន្យាជាមួយជនដទៃ ដែលក្នុងកិច្ចសន្យានោះ តម្រូវឱ្យអនីតិជនប្រកបបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ( ប្រាំ ) ឆ្នាំ ដល់ ១០ ( ដប់ ) ឆ្នាំ ។

ជនណាធ្វើកិច្ចសន្យាជាមួយអនីតិជន ដែលក្នុងកិច្ចសន្យានោះ តម្រូវឱ្យអនីតិជនប្រកបបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ។

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោសចំពោះ ជនណាដែលធ្វើកិច្ចសន្យាជាមួយតតិយជន ឬ អនីតិជន ដោយមានលក្ខខណ្ឌឱ្យអនីតិជននោះ ប្រព្រឹត្តអំពើពេស្យាចារកុមារ ។ ជនល្មើសដែលត្រូវរកឃើញថា មានទោសពីមាត្រានេះ ត្រូវផ្តន្ទាទោស ពី ៥ ( ប្រាំ ) ឆ្នាំ ដល់ ១០ ( ដប់ ) ឆ្នាំ ។

" ពេស្យាចារកុមារ " មាននិយមន័យដូចមានចែង ក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

### " ជនណាធ្វើកិច្ចសន្យាជាមួយជនដទៃ "

ពាក្យថា " កិច្ចសន្យា " នៅទីនេះ ដែលមានការកំណត់និយមន័យក្នុង ច្បាប់កម្ពុជា មានន័យថា ជាឆន្ទៈព្រមព្រៀងរវាងបុគ្គល ពីរនាក់ ឬ ច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ចមួយ ឬ ច្រើន ដែលទាក់ទិននឹងខ្លួន ។

ការព្រមព្រៀងបែបនេះ អាចធ្វើដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ អនុវត្តទៅលើបុគ្គលជា រូបវន្តបុគ្គល ឬ ជានីតិបុគ្គល និងអាចធ្វើកិច្ចសន្យាតាមរយៈបុគ្គលដែលជាតំណាងរបស់ខ្លួន ។

តាមច្បាប់ប្រភេទនៃកិច្ចសន្យាបែបនេះ ត្រូវច្បាប់ចាត់ទុកជាមោឃៈ ។ កិច្ចសន្យាណាមួយដែលធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ដើម្បីប្រព្រឹត្តសកម្មភាពខុសច្បាប់ (ដែលរួមមាន ទម្រង់ណាមួយនៃការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ) ត្រូវទុកជាមោឃៈ និងមិនអាចអនុវត្តបាន ។

ស្របទៅនឹងវិធីសាស្ត្រ ក្នុងច្បាប់កិច្ចសន្យាដែលនៅជាធរមាន នៅពេលដែលច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានប្រកាសឱ្យប្រើ ។ មាត្រា ៥ នៃក្រឹត្យច្បាប់លេខ ៣៨ (ស្តីពី កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ) ចែងថាកិច្ចសន្យា :

> *" ....ត្រូវទុកជាមោឃៈដាច់ខាត*
>
> *-កិច្ចសន្យាទាំងឡាយណា ដែលមិនស្របនឹងច្បាប់ របៀបរៀបរយសាធារណៈ ឬ ទំនៀមទំលាប់ដ៏ប្រពៃ*
>
> *- កិច្ចសន្យាទាំងឡាយណាដែលមិនស្របនឹងផលប្រយោជន៍សង្គម ឬមិនស្របនឹងគោលការណ៍សីលធម៌ សង្គម*
>
> *-កិច្ចសន្យាទាំងឡាយណា ដែលមានតាវកាលិក ឬ កម្មវត្ថុនៃកិច្ចសន្យាមិនអាចធ្វើកើត ។"*

ប្រហាក់ប្រហែលគ្នានេះដែរ ក្រមរដ្ឋប្បវេណីក្នុងមាត្រា ៣៥៤ ចែងថា កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ " (ក) អត្ថន័យនៃកិច្ចសន្យានោះ ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ឬ (ខ) អត្ថន័យនៃកិច្ចសន្យានោះ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំម្លាប់ល្អ " ។

ភាសាក្នុងមាត្រាដែលដកស្រង់ខាងលើ មានចេតនាយ៉ាងទូលំទូលាយ និងមានបំណងទុកជាមោឃៈ នូវកិច្ចសន្យាដែលខុសច្បាប់ និងផ្ទុយសណ្តាប់ធ្នាប់សាធារណៈ ។ នេះរាប់បញ្ចូលទាំងកិច្ចសន្យាណាមួយ ដែលទាក់ទងនឹងពេស្យាចារកុមារ ក៏ត្រូវចាត់ទុកជាមោឃៈដែរ ។ កិច្ចសន្យាណាមួយដែលធ្វើឡើងក្នុងគោលដៅប្រព្រឹត្តបទល្មើសបែបនេះ គឺទុកជាមោឃៈ និងមិនអាចអនុវត្តបានទៅលើភាគីណាមួយនៃកិច្ចសន្យាឡើយ ។

## " លក្ខខណ្ឌដែលអនីតិជនប្រកបរបរពេស្យាចារ "

មាត្រានេះ មានគោលបំណងផ្តន្ទាទោសជនណាដែលបង្ខំ ឬ ប៉ុនប៉ង (តាមរយៈមាត្រា ៤ កថាខ័ណ្ឌទី ១) បង្ខំឱ្យអនីតិជនប្រកបរបរពេស្យាចារ ដោយប្រើកិច្ចសន្យាជាមួយតតិយជន ឬ ជាមួយអនីតិជន ។ មិនសំខាន់ថា តើអនីតិជននោះ ពិតជាប្រព្រឹត្តអំពើពេស្យាចារកុមារ ដោយសារតែកិច្ចសន្យានោះទេ ។

" ពេស្យាចារកុមារ " មាននិយមន័យដូចមានចែង ក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

" របរពេស្យាចារកុមារ " រាប់បញ្ចូលស្ថានភាពដែលអនីតិជននោះ ត្រូវបង្ខំឱ្យប្រព្រឹត្តពេស្យាចារកុមារ មិនថាឡើយធ្វើតែម្តង ឬ ជាទៀងទាត់ ។

គួរកត់សំគាល់ថា មាត្រានេះមិនព្យាយាមផ្តន្ទាទោសជនណា (អតិថិជន) ដែលឱ្យប្រាក់ដល់បុគ្គលធ្វើពេស្យាចារកុមារ ដើម្បីរួមភេទជាមួយបុគ្គលពេស្យាកុមារនោះ ។ អាកប្បកិរិយាបែបនេះ ត្រូវផ្តន្ទាទោសយោងតាមបទល្មើសដែលមានចែងក្នុងមាត្រា ៣៤ " ការទិញពេស្យាចារកុមារ " ។ មាត្រានេះ ព្យាយាមផ្តន្ទាទោសអ្នកដែលអូសទាញ ឬ បង្ខំកុមារឱ្យប្រព្រឹត្តអំពើពេស្យចារ តាមរយៈការឱ្យខ្ចីប្រាក់ ឬ វត្ថុមានតម្លៃផ្សេងទៀត ។

## " ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ "

ជនណាដែលត្រូវរកឃើញថា មានទោសពីបទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។ ទោសបន្ថែមអាចអនុវត្តបានដោយឆន្ទានុសិទ្ធិរបស់តុលាការ ដូចមានចែងក្នុងមាត្រា ៤៨ នៃច្បាប់នេះ ។

ដូចចែងក្នុងមាត្រា ៤ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ) កថាខ័ណ្ឌទី ៤ ប្រសិនបើ អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតនៃនីតិបុគ្គល ឬ ភារប្បទាយី ត្រូវគេរកឃើញថាមានទោសប្រព្រឹត្តបទល្មើសនេះ តុលាការអាចផ្តន្ទាទោសនីតិបុគ្គល ឬ ភារប្បទាយីនោះ ដោយមានទោសបន្ថែមដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ទោសបន្ថែមទាំងនេះ ប្រសិនបើចាំបាច់ត្រូវដាក់រួមមាន ដូចជា ការរឹបអូសសម្ភារៈ ឬ ទ្រព្យសម្បត្តិ (មាត្រា៤៨ កថាខ័ណ្ឌទី ១ ដល់ ទី ៣) ឬ ការបិទការផលិត (មាត្រា ៤៨ កថាខ័ណ្ឌទី ៤) ។ (សូមពិនិត្យមើលការពិភាក្សា យោងតាមមាត្រា ៤៨ សម្រាប់ព័ត៌មានលំអិត) ។

## ជំពូកទី ៥
## រូបភាព និង សម្ភារៈអាសអាភាស

ជំពូកនេះ កំណត់និយមន័យរូបភាព និងសម្ភារៈអាសអាភាស និងរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ និងមានចែងពីបទល្មើស និងការផ្តន្ទាទោសដែលទាក់ទងនឹងបទល្មើសនេះ ។

**មាត្រា ៣៨.- និយមន័យនៃរូបភាព និង សម្ភារៈអាសអាភាស**

រូបភាព និង សម្ភារៈអាសអាភាស នៅក្នុងច្បាប់នេះមានន័យថា ជាសម្ភារៈដែលអាចមើលឃើញនឹងភ្នែក ដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិច ដែលពិពណ៌នាអំពី កេរភេទ ឬ ភាពអាសអាភាស ប្រហាក់ប្រហែលផ្សេងទៀត ដែលធ្វើឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទ ។

មាត្រានេះ កំណត់និយមន័យ ពាក្យថា " រូបភាព និងសម្ភារៈអាសអាភាស " ។ មាត្រានេះ មិនមានចែងពីបទល្មើសណាមួយ ដែលទាក់ទងនឹង រូបភាព និងសម្ភារៈអាសអាភាស ទេ ប៉ុន្តែយោងតាមមាត្រា ៣៩ មានចែងពីបទល្មើសនេះ ។ ហេតុដូច្នេះ ប្រសិនបើត្រូវរកឃើញមានទោសជនជាប់ចោទ គួរតែត្រូវចោទប្រកាន់ និងផ្តន្ទាទោសពីបទល្មើសដែលមានចែង ក្នុងមាត្រា ៣៩ ។

### " សម្ភារៈដែលអាចមើលឃើញនឹងភ្នែក "

មាត្រានេះ កំណត់និយមន័យ រូបភាព និងសម្ភារៈអាសអាភាស ថាជាសម្ភារៈដែលអាចមើលឃើញនឹងភ្នែក ។ សម្ភារៈទាំងនេះ រួមមានជាអាទិ៍ រូបថត គំនូរ អត្ថបទ ខ្សែវីដេអូ និងខ្សែភាពយន្តក្នុងទម្រង់ជារូបរាង ឬ អេឡិចត្រូនិចណាមួយ ។ សម្ភារៈដែលអាចមើលឃើញនឹងភ្នែកបែបនេះ ក៏អាចមានជាសម្លេងដែលមានលក្ខណៈអាសអាភាសដែរ ។

### " ពិពណ៌នាអំពី កេរភេទ "

ត្រូវចាត់ទុកថាជា រូបភាព និងសម្ភារៈអាសអាភាស សម្ភារៈទាំងនេះត្រូវបង្ហាញ កេរភេទ របស់ជនណាម្នាក់ និង ( ដូចកត់សំគាល់ខាងក្រោម) មានចេតនាធ្វើឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទ ។

ជាទូទៅពាក្យថា " កេរភេទ " ត្រូវបានកំណត់ថា ជាលិង្គ ឬ រន្ធយោនី ។ ប៉ុន្តែដើម្បីពង្រឹងការការពារដល់ជនរងគ្រោះ នៅក្នុងច្បាប់នេះ ពាក្យថា កេរភេទ ត្រូវបានគេយល់ថា ជាលិង្គ ឬ រន្ធយោនី ឬ រន្ធគូទ ។

ចំពោះអត្ថបទដែលត្រូវចាត់ទុកថាជា រូបភាព និងសម្ភារៈអាសអាភាស អត្ថបទនោះត្រូវតែមានបញ្ចូលការពិពណ៌នាជាលាយលក្ខណ៍អក្សរ នៃកេរភេទរបស់ជនណាម្នាក់ ។

### " ភាពអាសអាភាស ប្រហាក់ប្រហែលផ្សេងទៀត "

គោលបំណងនៃច្បាប់នេះ ពាក្យថា " ទីសាធារណៈ " ក៏មានន័យថា ការដាក់តាំង ការបញ្ចាំង ឬ ការបង្ហាញ រូបភាព និងសម្ភារៈអាសអាភាស អាចត្រូវទទួលការផ្តន្ទាទោស ប្រសិនបើ ជនណាម្នាក់នៅទីសាធារណៈអាចមើលឃើញ ឬ ស្តាប់ឮ[៤០] នូវរូបភាព និងសម្ភារៈអាសអាភាសនោះ ។

ឧទាហរណ៍ : ប្រសិនបើ ការបង្ហាញរូបភាព និងសម្ភារៈអាសអាភាស គ្រាន់តែធ្វើឡើងនៅខាងក្នុងទ្វារនៃកន្លែងឯកជន ប៉ុន្តែមនុស្សនៅតាមដងផ្លូវ អាចមើលឃើញ ឬ ស្តាប់ឮដោយស្រួលនូវការបង្ហាញ រូបភាព និងសម្ភារៈអាសអាភាសទាំងនោះ ហេតុដូច្នេះ អំពើនោះអាចត្រូវផ្តន្ទាទោស ។

## " ជនណា កាន់កាប់ ដឹកជញ្ជូន នាំចូល ឬ នាំចេញនូវ រូបភាព និងសម្ភារៈអាសអាភាស ក្នុងគោលដៅ "

បទប្បញ្ញត្តិនេះ ដាក់ឱ្យទៅជាទោសព្រហ្មទណ្ឌ នូវការកាន់កាប់ ការដឹកជញ្ជូន ការនាំចូល ឬ ការនាំចេញនូវរូបភាព និងសម្ភារៈអាសអាភាស ក្នុងករណីដែលអំពើនេះត្រូវធ្វើឡើងក្នុងគោលដៅ ប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ។ ដោយសារតែសកម្មភាពកាន់កាប់ ដឹកជញ្ជូន នាំចូល ឬ នាំចេញ ត្រូវបានហាមឃាត់ តែនៅពេលដែលត្រូវធ្វើឡើងដោយមានចេតនាប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ការចោទប្រកាន់ត្រូវតែបង្ហាញពីភស្តុតាងខ្លះនៃចេតនារបស់ជនជាប់ចោទ ។

" ការកាន់កាប់ " មានរាប់បញ្ចូលការកាន់កាប់សម្ភារៈក្នុងទម្រង់ណាមួយ (ដែលរួមមាន ជាទម្រង់ ដែលមានរូប ឬ ជាអេឡិចត្រូនិក ) ។ គួរកត់សំគាល់ថា ប្រសិនបើការកាន់កាប់នេះ មិនធ្វើឡើង ដោយមានចេតនាប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ហេតុដូច្នេះ មិនត្រូវហាមឃាត់សកម្មភាពនេះទេ ។

**ឧទាហរណ៍ : មាត្រានេះ មិនបានហាមឃាត់ការកាន់កាប់រូបភាព និងសម្ភារៈអាសអាភាសសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនទេ ។**

" ដឹកជញ្ជូន " " នាំចូល " និង " នាំចេញ " ត្រូវគេយល់យ៉ាងទូលំទូលាយថា មានការរាប់បញ្ចូលអត្ថន័យជាធម្មតា ( ពោលគឺ ដំណើរការជាធម្មតានៃការដឹកជញ្ជូន ការនាំចូល ឬ ការនាំចេញ ) និងក៏រាប់បញ្ចូលអំពើណាមួយដែលទាក់ទងនឹងបច្ចេកទេសថ្មី ដូចជាអ៊ិនធឺណែត ទូរស័ព្ទដៃ ឬ បច្ចេកទេសថ្មីផ្សេងទៀត ។ ហេតុដូច្នេះ ពាក្យទាំងនេះក៏ហាមឃាត់ ការទាញយក ការបញ្ចូល ឬ ការបញ្ជូន រូបភាព និងសម្ភារៈអាសអាភាស តាមអ៊ីមែល ទូរស័ព្ទដៃ ឬ បច្ចេកទេសផ្សេងទៀត នៅពេលដែលធ្វើឡើងក្នុងគោលដៅប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខ័ណ្ឌ ដំបូង នៃមាត្រានេះ ។

---

[៤០] ទោះបី ជាមាត្រា ៣៨ កំណត់និយមន័យ " រូបភាព និងសម្ភារៈអាសអាភាស " ថា ជាសម្ភារៈដែលអាចមើលឃើញ សម្លេង ចេញពីសម្ភារៈបែបហ្នឹងក៏អាចមានលក្ខណៈអាសអាភាសដែរ ។ ប្រសិនបើ មានការបង្ហាញសម្ភារៈដែលអាចមើលឃើញ នៅទី កន្លែងឯកជន ប៉ុន្តែសម្លេងរបស់វាអាចឱ្យជនណាម្នាក់នៅទីសាធារណៈអាចស្តាប់ឮ ហេតុដូច្នេះនេះ អាចនៅតែត្រូវផ្តន្ទាទោស ។ ឧទាហរណ៍ : ប្រសិនបើ កុនអាសអាភាស ត្រូវបានបញ្ចាំងនៅក្នុងផ្ទះ ប៉ុន្តែសម្លេងរបស់វាឮខ្លាំង និងគេអាចស្តាប់ឮ នៅតាមផ្លូវ ហេតុដូច្នេះជនដែលបញ្ចាំងកុននោះ អាចត្រូវគេរកឃើញថាមានទោស យោងតាមមាត្រានេះ ។

" **ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាស ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី ១ និង ទី ២ នៃមាត្រានេះ** "

បទប្បញ្ញត្តិនេះ បន្ថែមការផ្ដន្ទាទោសចំពោះ ជនណាដែលផលិតរូបភាព និងសម្ភារៈអាសអាភាស ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី ១ និង ទី ២។

ដើម្បីឱ្យមានការទទួលខុសត្រូវយោងតាមកថាខ័ណ្ឌនេះ ជនល្មើសត្រូវតម្រូវឱ្យមានចេតនាពីរ : ១) ចេតនាផលិតរូបភាព និងសម្ភារៈអាសអាភាស (ដែលរួមមានការដឹងថាសម្ភារៈដែលផលិតនោះ គឺជា រូបភាព និងសម្ភារៈអាសអាភាស ) និង ២) មានចេតនា ប្រើប្រាស់ រូបភាព និងសម្ភារៈអាសអាភាស ដែលផលិតនោះ ក្នុងគោលដៅប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ ឬ ទី ២ ។

**មាត្រា ៤០.- និយមន័យនៃរូបភាព និង សម្ភារៈអាសអាភាសនៃកុមារ**

**រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ នៅក្នុងច្បាប់នេះមានន័យថា សម្ភារៈដែលអាចមើលឃើញនឹង ភ្នែក ដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈ អេឡិចត្រូនិច ដែលបង្ហាញពីរូបរាងអាក្រាតរបស់អនីតិជន ដែលធ្វើ ឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទ ។**

មាត្រានេះ កំណត់និយមន័យ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ។ មាត្រានេះ មិនបង្កើតឱ្យមានបទល្មើសណាមួយដែលទាក់ទងនឹង រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ប៉ុន្តែមាត្រា ៤១ មានចែងពីបទល្មើសនេះ ។ ហេតុដូច្នេះ ប្រសិនបើត្រូវរកឃើញមានទោស ជនជាប់ចោទគួរតែត្រូវ ចោទប្រកាន់ និងផ្ដន្ទាទោស យោងតាមមាត្រា ៤១ នៃច្បាប់នេះ ។

" **សម្ភារៈដែលអាចមើលឃើញនឹងភ្នែក** "

មាត្រានេះ កំណត់និយមន័យ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ថាជាសម្ភារៈដែលអាចមើលឃើញនឹងភ្នែក ។ សម្ភារៈទាំងនេះ រួមមានជាអាទិ៍ រូបថត គំនូរ អត្ថបទ ខ្សែវីដេអូ និងខ្សែភាពយន្ត ក្នុងទម្រង់មានរូបរាង ឬ អេឡិចត្រូនិច ណាមួយ ។ សម្ភារៈដែលអាចមើលឃើញនឹងភ្នែកបែបនេះ ក៏អាចមានជាសម្លេងដែលមានលក្ខណៈអាសអាភាសដែរ ។

គួរកត់សំគាល់ថា អំពើរបស់នីតិជនដែលរៀបចំការជួបជុំ ដែលរួមមានការបង្ហាញកេរភេទ ឬ មានទំនាក់ទំនងខាងផ្លូវភេទ ដោយមានអនីតិជនបានមើល ឬចូលរួមផងនោះ គឺជាបទល្មើស យោងតាមក្រមព្រហ្មទណ្ឌថ្មី មាត្រា ៣៤៦ (សូមពិនិត្យមើលក្រមព្រហ្មទណ្ឌ គន្ថីទី ២ មាតិកាទី ៣ ជំពូកទី ៥ ផ្នែកទី ២ " ការញុះញង់អនីតិជនឱ្យប្រព្រឹត្តអំពើខុសច្បាប់ ឬ អំពើគ្រោះថ្នាក់ " ) ។

### " ដែលបង្ហាញពីរូបរាងអាក្រាត របស់អនីតិជន "

ត្រូវចាត់ទុកថាជា រូបភាព និងសម្ភារៈអាសអាភាស សម្ភារៈនោះ ត្រូវបង្ហាញពីរូបរាងអាក្រាតទាំងអស់ ឬ ផ្នែកណាមួយ នៃរូបរាងអាក្រាតរបស់អនីតិជន ។ នេះមានន័យថា ជាការបង្ហាញ អនីតិជនដោះសំលៀកបំពាក់ចេញទាំងអស់ ឬ ភាគខ្លះ ។ នេះអាចរាប់បញ្ចូលទាំង ការបង្ហាញ កេរភេទរបស់អនីតិជន ឬ ផ្នែករូបកាយផ្សេងទៀត ផងដែរ ។ ការបង្ហាញបែបនេះ ត្រូវតែមានចេតនាធ្វើឱ្យរំជួល ឬ រំភើបដល់ចំណង់ផ្លូវភេទ ។

ចំពោះអត្ថបទដែលត្រូវចាត់ទុកថា ជារូបភាព និងសម្ភារៈអាសអាភាស អត្ថបទនោះត្រូវតែមានរាប់បញ្ចូលការបង្ហាញពីរូបរាងអាក្រាតរបស់អនីតិជន ។

### " ដែលធ្វើឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទ "

ត្រូវចាត់ទុកថាជា រូបភាព និងសម្ភារៈអាសអាភាស សម្ភារៈនោះ ត្រូវតែមានចេតនាធ្វើឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទដល់អ្នកមើល ។

តម្រូវការឱ្យមានចេតនានេះ គឺជាមូលដ្ឋានគ្រឹះ ដើម្បីមិនរាប់បញ្ចូលសម្ភារៈ ដែលបង្ហាញពីកេរភេទរបស់ជនណាម្នាក់ ក្នុងគោលដៅជាធម្មានរូប (ដែលមិនមានចេតនាជាចំបងធ្វើឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទ)។ សម្ភារៈដែលមានបំណងប្រើប្រាស់ក្នុងវិស័យបែបនេះ មានដូចជា ថ្នាំពេទ្យ សុខភាពសាធារណៈ ការអប់រំ ឬ សិល្បៈ មិនត្រូវចាត់ទុកថាជា រូបភាព និងសម្ភារៈអាសអាភាសទេ ។

**មាត្រា ៤១.. រូបភាព និង សម្ភារៈអាសអាភាសនៃកុមារ**

**ជនណា ចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬ បង្ហាញនៅទីសាធារណៈ នូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ ) ឆ្នាំ ដល់ ៥ ( ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.000.000 (បួនលាន)រៀល ដល់ ១០.000.000 (ដប់លាន )រៀល ។**

**ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬ នាំចេញនូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសដូចគ្នា ។**

**ជនណាផលិតរូបភាព និង សម្ភារៈអាសអាភាសកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ( ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។**

**ជនណាផលិត រូបភាព និង សម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់ នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី ១ និង ទី ២ ខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ។**

មាត្រានេះ ចែងពីបទល្មើស និងកំណត់ការផ្តន្ទាទោសចំពោះ ជនណាដែលចែកចាយ លក់ ឬ ជួល រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ឬ ផ្តល់ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ក្នុងទីសាធារណៈ ឬ ជនណាដែល

ផលិតរូបភាពអាសអាភាសនៃកុមារ ឬ ជនណាដែល កាន់កាប់ ដឹកជញ្ជូន ឬ ផលិត រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅ ចែកចាយ ដាក់តាំង ឬ បង្ហាញ រូបភាពនេះ ។

ទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌណាមួយ ជនល្មើសត្រូវតែ មានការដឹង និងមានចេតនា ។ ក្នុងមាត្រានេះ ជនណាម្នាក់ត្រូវដាក់ឱ្យទទួលទោស ជននោះត្រូវដឹងថា សម្ភារៈនោះមាន រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ និងត្រូវមានចេតនាប្រព្រឹត្តអំពើហាមឃាត់នោះ ។

**ឧទាហរណ៍ : ប្រសិនបើ បុគ្គលណាម្នាក់មិនមានចេតនាបញ្ចូល រូបភាព ឬ សម្ភារៈអាសអាភាសនៃកុមារ នៅក្នុងសៀវភៅ ឬ ទស្សនាវដ្ដី ។ល។ ទេ បុគ្គលនោះក៏មិនត្រូវទទួលទោស យោងតាមមាត្រានេះដែរ ។ ជាការពិត ប្រសិនបើជនណាម្នាក់មានចេតនា ចែកចាយ ឬ ផលិតសៀវភៅ ឬ ទស្សនាវដ្ដី ដែលមានរូបភាព និងសម្ភារៈអាសអាភាស នៃនីតិជន ក្នុងករណីបែបនេះ ប្រសិនបើជននោះ មិនមានចេតនាផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ គាត់គួរតែត្រូវចោទប្រកាន់ និងផ្ដន្ទាទោសយោង តាមមាត្រា ៣៩ នៃច្បាប់នេះ ។**

ទោះជាយ៉ាងណាក៏ដោយ យោងតាមមាត្រា ៧ អ្នកផលិតរូបភាព និងសម្ភារៈអាសអាភាស អាចត្រូវគេចាត់ទុកថា មានការគ្រប់គ្រង និងការត្រួតពិនិត្យលើអនីតិជន និងហេតុដូច្នេះ ត្រូវចាត់ទុកថា បានដឹងពីអាយុរបស់អនីតិជននោះ ។ ប្រសិនបើ អ្នកផលិតចង់ទាមទារឱ្យមានការការពារថា គាត់មានចេតនាផលិតតែរូបភាព និងសម្ភារៈអាសអាភាសនីតិជន គាត់ត្រូវតែបង្ហាញការពិតថា គាត់មានជំនឿសមហេតុផលដែលថា អនីតិជនដែលត្រូវគាត់បង្ហាញក្នុងរូបភាព និងសម្ភារៈអាសអាភាសនោះ មានអាយុ ១៨ ឆ្នាំ ឬ លើសពី ១៨ ឆ្នាំ ។ ក្នុងការពិចារណាថា តើជំនឿនេះសមហេតុផលដែរ ឬ ទេ តុលាការអាចមើលកត្តាជាច្រើន ដែលរួមមានជាអាទិ៍ អាយុពិតរបស់ជនរងគ្រោះការបង្ហាញពីអាយុតាមរយៈការផ្ដល់ឯកសារ ( ឧទាហរណ៍ : ក្នុងករណី ដែលអនីតិជនផ្ដល់សំបុត្រកំណើត ឬ អត្តសញ្ញាណប័ណ្ណ ក្លែងក្លាយ ដែលបញ្ជាក់ថា អនីតិជននោះ មានអាយុ ១៨ ឆ្នាំ ឬ លើសពី ១៨ ឆ្នាំ ) ។ល។ ( សម្រាប់ព័ត៌មានលំអិតជាងនេះ សូមមើលការពិភាក្សាទាក់ទងនឹងមាត្រា ៧ ខាងលើ ) ។

មាត្រានេះ ហាមឃាត់អំពើមួយចំនួន ដូចខាងក្រោម :

### " ចែកចាយ លក់ ជួល "

បទប្បញ្ញត្តិនេះ ហាមឃាត់ ការចែកចាយជាពាណិជ្ជកម្ម និងមិនមែនជាពាណិជ្ជកម្ម ( ទោះដោយមិនយកប្រាក់ ឬ ផ្ដោះប្ដូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ ) ព្រមទាំង ការលក់ ឬ ការជួល រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ។

### " ដាក់តាំង បញ្ចាំង ឬ ការបង្ហាញនៅទីសាធារណៈ "

បទប្បញ្ញត្តិនេះ ហាមឃាត់ ការដាក់តាំង បញ្ចាំង ឬ បង្ហាញ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ នៅទីសាធារណៈ ។

" ដាក់តាំង " មានន័យថា ជនណាម្នាក់មានចេតនាធ្វើឱ្យ ឬ អនុញ្ញាតឱ្យជនម្នាក់ទៀត មើលឃើញ រូបភាព និងសម្ភារៈអាសអាភាស ប៉ុន្តែមិនអនុវត្តក្នុងករណីដែលជននោះមើលឃើញ រូបភាព និងសម្ភារៈអាសអាភាស ដោយខ្លួនឯងទេ ។ យ៉ាងណាមិញ ដោយសារតែបទប្បញ្ញត្តិនេះ មានគោលបំណងដើម្បីទប់ស្កាត់សាធារណៈជន កុំឱ្យឃើញ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ប្រឆាំងនឹងឆន្ទៈរបស់ខ្លួន អ្នកប្រព្រឹត្តក៏អាចត្រូវគេរកឃើញថា មានទោស ប្រសិនបើ គាត់ដាក់តាំង រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ នៅទីកន្លែងឯកជន ប៉ុន្តែរូបភាពនោះ មនុស្សដែលនៅទីសាធារណៈ អាចមើលឃើញ ។

ពាក្យថា " ទីសាធារណៈ " មានន័យថា ដី អគារ ផ្ទះ និងមធ្យោបាយដឹកជញ្ជូនណាមួយ ដែលគ្រប់គ្រងដោយរដ្ឋ ជាសាធារណៈ ឬ ជាឯកជន ដែលបើកឱ្យ និងផ្តល់សេវាឱ្យសាធារណៈជនទាំងអស់ ។ និយមន័យនេះស្របទៅនឹងមាត្រា ៤ នៃច្បាប់ ស្តីពី ការការពារ និងលើកស្ទួយសិទ្ធិរបស់ជនពិការ (២០០៩) ។

គោលបំណងនៃច្បាប់នេះ ពាក្យថា " ទីសាធារណៈ " ក៏មានន័យថា ការដាក់តាំង ការបញ្ចាំង ឬ ការបង្ហាញ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ អាចត្រូវទទួលការផ្តន្ទាទោស ប្រសិនបើ ជនណាម្នាក់នៅទីសាធារណៈ អាចមើលឃើញ ឬ ស្តាប់ឮ[៤១] នូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារនោះ ។

ឧទាហរណ៍ : ប្រសិនបើ ការបង្ហាញ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ គ្រាន់តែធ្វើឡើងនៅខាងក្នុងទ្វារនៃកន្លែងឯកជន ប៉ុន្តែមនុស្សនៅតាមដងផ្លូវ អាចមើលឃើញ ឬ ស្តាប់ឮ ដោយស្រួលនូវការបង្ហាញនូវ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ទាំងនោះ ហេតុដូច្នេះ អំពើនោះអាចត្រូវផ្តន្ទាទោស ។

## " ជនណា កាន់កាប់ ដឹកជញ្ជូន នាំចូល ឬ នាំចេញនូវ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅ "

បទប្បញ្ញត្តិនេះ ដាក់ឱ្យទៅជាទោសព្រហ្មទណ្ឌ នូវការកាន់កាប់ ការដឹកជញ្ជូន ការនាំចូល ឬ ការនាំចេញ នូវ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ក្នុងករណីដែលអំពើនេះ ត្រូវធ្វើឡើងក្នុងគោលដៅប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។ ដោយសារតែសកម្មភាព កាន់កាប់ ដឹកជញ្ជូន នាំចូល ឬ នាំចេញ ត្រូវបានហាមឃាត់ តែនៅពេលដែលត្រូវធ្វើឡើងដោយមានចេតនាប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ការចោទប្រកាន់ត្រូវតែបង្ហាញពីភស្តុតាងខ្លះនៃចេតនារបស់ជនជាប់ចោទ ។

---

[៤១] ទោះបីជាមាត្រា ៤០ កំណត់និយមន័យ " រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ " ថាជា សម្ភារៈ ដែលអាចមើលឃើញ សម្លេងចេញពីសម្ភារៈបែបហ្នឹងក៏អាចមានលក្ខណៈអាសអាភាសដែរ ។ ប្រសិនបើមានការបង្ហាញសម្ភារៈ ដែលអាចមើលឃើញ នៅទីកន្លែងឯកជន ប៉ុន្តែសម្លេងរបស់វាអាចឱ្យជនណាម្នាក់នៅទីសាធារណៈ អាចស្តាប់ឮ ហេតុដូច្នេះ នេះអាចទៅតែត្រូវផ្តន្ទាទោស ។ ឧទាហរណ៍ : ប្រសិនបើកុនអាសអាភាស ត្រូវបានបញ្ចាំងនៅក្នុងផ្ទះ ប៉ុន្តែសម្លេងរបស់វាឮខ្លាំង និងគេអាចស្តាប់ឮ នៅតាមផ្លូវ ហេតុដូច្នេះ ជនដែលបញ្ចាំងកុននោះ អាចត្រូវគេរកឃើញថា មានទោសយោងតាមមាត្រានេះ ។

" ការកាន់កាប់ " មានរាប់បញ្ចូល ការកាន់កាប់សម្ភារៈក្នុងទម្រង់ណាមួយ (ដែលរួមមានជាទម្រង់ ដែលមាន រូប ឬ ជាអេឡិចត្រូនិក ) ។ គួរកត់សំគាល់ថា ប្រសិនបើ ការកាន់កាប់នេះមិនធ្វើឡើង ដោយមានចេតនាប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ហេតុដូច្នេះ មិនត្រូវហាមឃាត់សកម្មភាពនេះទេ ។

" ដឹកជញ្ជូន " " នាំចូល " និង " នាំចេញ " ត្រូវគេយល់យ៉ាងទូលំទូលាយ ថាមានការរាប់បញ្ចូលអត្ថន័យជាធម្មតា (ពោលគឺ ដំណើរការជាធម្មតានៃការដឹកជញ្ជូន ការនាំចូល ឬ ការនាំចេញ ) និងក៏រាប់បញ្ចូលអំពើណាមួយដែលទាក់ទងនឹងបច្ចេកទេសថ្មី ដូចជាអ៊ិនធឺណែត ទូរស័ព្ទដៃ ឬ បច្ចេកទេសថ្មីផ្សេងទៀត ។ ហេតុដូច្នេះ ពាក្យទាំងនេះក៏ហាមឃាត់ ការទាញយក ការបញ្ចូល ឬ បញ្ជូន រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ តាមអ៊ីមែល ទូរស័ព្ទដៃ ឬ បច្ចេកទេសផ្សេងទៀត នៅពេលដែលធ្វើឡើងក្នុងគោលដៅប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ។

### " ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាស កុមារ "

បទប្បញ្ញត្តិនេះ ដាក់ទោសដល់ជនណាដែលផលិតរូបភាពអាសអាភាសនៃកុមារ ទោះបីជាពុំមានគោលដៅយក ទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយក៏ដោយ ។

ដើម្បីឱ្យមានការទទួលខុសត្រូវយោងតាមកថាខ័ណ្ឌនេះ ជនល្មើសត្រូវតម្រូវឱ្យមានចេតនា ផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ( ដែលរួមមានការដឹងថា សម្ភារៈដែលផលិតនោះ មានរូបភាព និង សម្ភារៈអាសអាភាសនៃកុមារ ) ។

យោងតាមមាត្រា ៧ អ្នកផលិតរូបភាព និងសម្ភារៈអាសអាភាស អាចត្រូវគេចាត់ទុកថា មានការគ្រប់គ្រង និងការត្រួតពិនិត្យលើអនីតិជន និងហេតុដូច្នេះត្រូវចាត់ទុកថា បានដឹងពីអាយុរបស់អនីតិជននោះ ។ ប្រសិនបើ អ្នកផលិតចង់ទាមទារឱ្យមានការការពារថា គាត់មានចេតនាផលិតតែ រូបភាព និងសម្ភារៈអាសអាភាសនីតិជន គាត់ត្រូវតែបង្ហាញការពិតថា គាត់មានជំនឿសមហេតុផលដែលថា អនីតិជនដែលត្រូវគាត់បង្ហាញក្នុងរូបភាព និងសម្ភារៈអាស-អាភាសនោះ មានអាយុ ១៨ ឆ្នាំ ឬ លើសពី ១៨ ឆ្នាំ ។ ក្នុងការពិចារណាថា តើជំនឿនេះ សមហេតុផលដែរ ឬ ទេ តុលាការអាចមើលកត្តាជាច្រើន ដែលរួមមានជាអាទិ៍ អាយុពិតរបស់ជនរងគ្រោះ ការបង្ហាញពីអាយុតាមរយៈការផ្តល់ឯកសារ ( ឧទាហរណ៍ : ក្នុងករណីដែល អនីតិជនផ្តល់សំបុត្រកំណើត ឬ អត្តសញ្ញាណប័ណ្ណ ក្លែងក្លាយ ដែលបញ្ជាក់ថា អនីតិជននោះ មានអាយុ ១៨ ឆ្នាំ ឬ លើសពី ១៨ ឆ្នាំ ) ។ល។ (សម្រាប់ព័ត៌មានលំអិតជាងនេះ សូមមើលការពិភាក្សាមាត្រា ៧ ខាងលើ ) ។

### " ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាស នៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់ នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី ១ និង ទី ២ នៃមាត្រានេះ "

បទប្បញ្ញត្តិនេះ បន្ថែមការផ្តន្ទាទោសចំពោះជនណាដែល ផលិត រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់ នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី ១ និង ទី ២ ។

ដើម្បីឱ្យមានការទទួលខុសត្រូវយោងតាមកថាខ័ណ្ឌនេះ ជនល្មើសត្រូវតម្រូវឱ្យមានចេតនាពីរ : ១) ចេតនាផលិត រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ( ដែលរួមមានការដឹងថា សម្ភារៈដែលផលិតនោះ មានរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ) និង ២) មានចេតនាប្រើប្រាស់ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ដែលផលិតនោះ ក្នុងគោលដៅប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ និង ទី ២ ។

# ជំពូកទី ៦

## អំពើអាសអាភាសនិងអនីតិជនអាយុក្រោម ១៥ ឆ្នាំ

ជំពូកនេះ កំណត់និយមន័យនៃបទល្មើស និងកំណត់ការផ្តន្ទាទោស ចំពោះជនណាដែលមានទំនាក់ទំនងផ្លូវភេទ នៃប្រភេទណាមួយ ជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ ។

តាមរយៈការកំណត់និយមន័យបទល្មើសទាំងនេះ ជំពូកនេះ ក៏កំណត់អាយុនៃការព្រមព្រៀងរួមភេទ នៅត្រឹមអាយុ ១៥ ឆ្នាំ ហេតុដូច្នេះ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់អាយុ ១៥ ឆ្នាំ នូវសមត្ថភាពស្របច្បាប់ ក្នុងការមានទំនាក់ទំនងផ្លូវភេទដោយស្ម័គ្រចិត្ត ។ នេះស្របទៅនឹងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា "អាយុនៃការរួមភេទត្រូវបានកំណត់ចាប់ពី អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ" ។

គួរកត់សំគាល់ថា គ្រប់អនីតិជន ( ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) ត្រូវហាមឃាត់ ពីការប្រព្រឹត្តអំពើពេស្យាចារ ។ ជាការពិតណាស់ ចំពោះអនីតិជនដែលមានអាយុ ១៥ ឆ្នាំ ឬ លើស ១៥ ឆ្នាំ អាចឈានដល់អាយុព្រមព្រៀងរួមភេទ ។ ក្នុងន័យផ្សេងទៀត ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់ឱ្យអនីតិជន ដែលមានអាយុ ពី ១៥ ឆ្នាំ ដល់អាយុក្រោម ១៨ ឆ្នាំ នូវសមត្ថភាព ដើម្បីយល់ព្រមរួមភេទ ប៉ុន្តែមិនមានសមត្ថភាពយល់ព្រមប្រព្រឹត្តអំពើពេស្យាចារដោយខ្លួនឯងទេ ។ ហេតុដូច្នេះ ប្រសិនបើជនណាម្នាក់មានទំនាក់ទំនងផ្លូវភេទណាមួយ ជាមួយអនីតិជន ( ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ) តាមរយៈ ផ្តល់ ឬ សន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយ ជននោះគួរតែត្រូវទទួលការចោទប្រកាន់ និងកាត់ទោស ពីបទល្មើសទិញពេស្យាចារកុមារ យោងតាមមាត្រា ៣៤ បន្ថែមទៅនឹង ការចោទប្រកាន់ និងការកាត់ទោសណាមួយ យោងតាមជំពូកនេះ ។

គួរកត់សំគាល់ថា ក្រសួងយុត្តិធម៌ បានចេញសេចក្តីណែនាំ ( នៅខែ កុម្ភៈ ឆ្នាំ ២០០៩ ) ដោយបញ្ជាក់យ៉ាងច្បាស់ ពីការអនុវត្តដ៏ត្រឹមត្រូវនៃជំពូកនេះ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

### មាត្រា ៤២.. អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ

**ជនណារួមភេទជាមួយជនដទៃ ដែលមានអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។**

មាត្រានេះ ផ្តន្ទាទោសជនណា ( បុរស ឬ ស្ត្រី ) ដែលរួមផ្លូវភេទជាមួយ អនីតិជនអាយុក្រោម ១៥ ឆ្នាំ ។

មាត្រានេះ ក៏ត្រូវអនុវត្តសូម្បីតែក្នុងករណី ដែលអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ បានយល់ព្រមយ៉ាងពេញលេញ ក្នុងការរួមភេទបែបនេះ ឬ មិនបានតទល់ក្នុងវិធីណាមួយក៏ដោយ ។ ដោយសារតែ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានផ្តល់ឱ្យអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ នូវសមត្ថភាពក្នុងការយល់ព្រមរួមភេទ ក្នុងន័យច្បាប់ ការព្រមព្រៀងបែបណាមួយក៏ដោយ មិនមែនជា " ការយល់ព្រម " ទេ ។

ប្រសិនបើ ជនល្មើសបានរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ តាមមធ្យោបាយ ប្រើកំលាំង អំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ បំភ័យ ជននោះគួរត្រូវ ចោទប្រកាន់ និងផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ យោងតាមមាត្រា ២៤១ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ)នៃក្រមព្រហ្មទណ្ឌជាជាងត្រូវចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រានេះ។ (សូមមើលក្រមព្រហ្មទណ្ឌ គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៣ ផ្នែកទី ១ " រំលោភសេពសន្ថវៈ " [៤២] ) ។

ប្រសិនបើ ជនល្មើសមានទំនាក់ទំនងផ្លូវភេទជាមួយអនីតិជន ដែលមានអាយុក្រោម ១៥ ឆ្នាំ តាមរយៈផ្តល់ ឬ សន្យាផ្តល់វត្ថុមានតំលៃអ្វីមួយ ទៅដល់អនីតិជន ឬ តតិយជន ជននោះគួរតែត្រូវចោទប្រកាន់ និងផ្តន្ទាទោស ពីបទល្មើសទិញពេស្យាចារកុមារ យោងតាមមាត្រា ៣៤ បន្ថែមទៅនឹងការចោទប្រកាន់ និងផ្តន្ទាទោស ដែលអាចមានយោងតាមមាត្រានេះ ។

ដូចមានចែងក្នុងមាត្រា ៧ ( និយមន័យនៃអនីតិជន ) ជនណាដែលរក្សាទុកអនីតិជននៅក្រោមការគ្រប់គ្រង ឬ ត្រួតពិនិត្យរបស់ខ្លួន នឹងត្រូវចាត់ទុកថា បានដឹងពីអាយុរបស់អនីតិជននោះ លើកលែងតែជននោះ បង្ហាញឱ្យឃើញថា ខ្លួនមានការជឿជាក់ដោយសមហេតុផលថា អនីតិជននោះមានអាយុ ១៨ ឆ្នាំ ឬ ច្រើនជាង ១៨ ឆ្នាំ ។ ការសន្មត់ថា បានដឹង នេះក៏អនុវត្តចំពោះសំនួរដែលទាក់ទងនឹងអាយុនៃការយល់ព្រមរួមភេទ ។

**ឧទាហរណ៍ : ក្នុងករណីដែលជនណាម្នាក់ មានការគ្រប់គ្រង ឬ ត្រួតពិនិត្យទៅលើអនីតិជនមានទំនាក់ទំនងផ្លូវភេទជាមួយអនីតិជននោះ មាត្រា ៧ ចាត់ទុកថា ជននោះបានដឹងពីអាយុរបស់អនីតិជន និងដូច្នេះហើយ ជននោះមិនអាចងាយស្រួល ទាមទារការការពារដែលថា គាត់មិនបានដឹងពីអាយុរបស់អនីតិជន ថាមានអាយុក្រោម ១៥ ឆ្នាំទេ ។**

(សម្រាប់ព័ត៌មានបន្ថែម ដែលរួមមានការពិភាក្សានៃ " ការត្រួតពិនិត្យ និងការគ្រប់គ្រង " សូមមើល អត្ថបទស្តីពីមាត្រា ៧ ខាងលើ) ។

ស្របតាមមាត្រា ៤៤ ចំពោះតែជនណាដែលមានអាយុ ១៥ ឆ្នាំ ឬ លើសពី ១៥ ឆ្នាំ អាចត្រូវផ្តន្ទាទោស យោងតាមមាត្រានេះ ។

ជាគោលការណ៍យោងតាមមាត្រា ៣៨ និង ៣៩ នៃក្រមព្រហ្មទណ្ឌ អនីតិជនដែលមានអាយុ ១៤ ឆ្នាំ អាចទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែករណីនៅក្នុងមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺមានតែកុមារដែលមានអាយុយ៉ាងតិច ១៥ឆ្នាំ ប៉ុណ្ណោះដែលអាចទទួលទោសព្រហ្មទណ្ឌ យោងតាម មាត្រានេះបាន។

ក្នុងការអនុវត្តនីជាក់ស្តែង អនីតិជនខ្លះដែលមានអាយុប្រហាក់ប្រហែលគ្នា រឺអាយុខុសគ្នាបន្តិចបន្តួច ដែលបានស្ម័គ្រចិត្តមានទំនាក់ទំនងផ្លូវភេទជាមួយគ្នាដោយពុំមានប្រើអំពើហឹង្សា ឬ ការបង្ខិតបង្ខំ ឬ គម្រាម កំហែង ឬ

[42] យោងតាមមាត្រា ២៣៩ និង មាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ "បទរំលោភសេពសន្ថវៈ" ត្រូវកំណត់និយមន័យថា គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ ណាមួយនៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើប្រាស់ហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្នក់ឱកាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៧ ( ប្រាំពីរ ) ឆ្នាំ ទៅ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសប្រព្រឹត្តឡើងទៅលើបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

ឆ្នក់ឱកាស ឬ បោកបញ្ឆោត ។ ឧទាហរណ៍ កុមារាម្នាក់អាយុ ១៦ ឆ្នាំ និងកុមារីម្នាក់អាយុ ១៤ ឆ្នាំ មានទំនាក់ទំនងស្នេហាជាមួយគ្នា ហើយបានព្រមព្រៀងរួមភេទជាមួយគ្នាដោយគ្មានការប្រើកម្លាំងបង្ខិតបង្ខំ ឬ បង្ករបួសស្នាម ឬ បំពារ បំពានដោយអាងអំណាច ។

ដូចឧទាហរណ៍ខាងលើនេះ សេចក្ដីសម្រេចរបស់តុលាការជាន់ខ្ពស់ក្នុងប្រទេសមួយចំនួនចាត់ទុកទំនាក់ទំនងផ្លូវភេទដែលមានការព្រមព្រៀងគ្នារវាងកុមារនិងកុមារដែលមានអាយុប្រហាក់ប្រហែលគ្នា ជាទំនាក់ទំនងគ្មានការទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ជាបទល្មើសតូចតាច ពីព្រោះប្រទេសទាំងនោះជឿជាក់ថា ការផ្តន្ទាទោសកុមារចំពោះ ទំនាក់ទំនងផ្លូវភេទដែលមានការព្រមព្រៀងគ្នា គឺពុំបានផ្តល់ជាឧត្តមប្រយោជន៍ដល់កុមារឡើយ ។[៤៣] ដូច្នេះនៅក្នុងករណីឧទាហរណ៍ខាងលើ ដោយពិចារណាទៅលើកាលៈទេសៈនៃបទល្មើសនិងបុគ្គលិកលក្ខណៈរបស់អនីតិជនដូចដែលមានចែងនៅក្នុងមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌព្រះរាជអាជ្ញា ឬ តុលាការអាចធ្វើការចោទ ប្រកាន់ ឬ មិនចោទប្រកាន់ ឬ អនុវត្តនីវិធានការផ្សេងៗទៅលើអនីតិជន ។ ក្នុងករណីមានការសម្រេចធ្វើការចោទប្រកាន់ទៅលើកុមារ តុលាការគប្បីពិចារណាអនុវត្តនីវិធានការផ្សេងៗដើម្បីជៀសវាងការឃុំខ្លួនបណ្តោះអា សន្ន និងការផ្តន្ទាទោសដាក់ពន្ធនាគារ រីយ៉ាងហោចណាស់ត្រូវពិចារណាអំពីស្ថានសម្រាលទោស ដូចមានចែងនៅ ក្នុងមាត្រា ៩៦នៃក្រម ព្រហ្មទណ្ឌ។

## " ការរួមភេទ "

ពាក្យថា " ការរួមភេទ " មានន័យថា ជាការដាក់បញ្ចូលកេរភេទ ទៅក្នុង កេរភេទ មាត់ ឬ រន្ធគូទ របស់ជនម្នាក់ទៀត ឬ ការដាក់បញ្ចូល សម្ភារៈ ឬ ឧបករណ៍ ទៅក្នុង កេរភេទ របស់ជនម្នាក់ទៀត ។ ការរួមភេទអាចកើតឡើង រវាងមនុស្ស ពីរនាក់ ឬ ច្រើនជាងពីរនាក់ ដែលមានភេទដូចគ្នា ឬ ខុសគ្នា ។ និយមន័យនេះ ស្របទៅនឹងសេចក្ដីណែនាំរបស់ក្រសួងយុត្តិធម៌ លេខ ០១ កយ.សណន/ ០៩ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។

ពាក្យថា " ឧបករណ៍ " ត្រូវគេយល់ថា រាប់បញ្ចូលទាំងម្រាមដៃ ឬ ផ្នែកដទៃទៀត នៃរាងកាយមនុស្ស ។

ជាទូទៅពាក្យថា " កេរភេទ " ត្រូវបានកំណត់ថា ជាលិង្គ ឬ រន្ធយោនី ។ ប៉ុន្តែដើម្បីពង្រឹងការការពារដល់ជនរងគ្រោះ នៅក្នុងច្បាប់នេះ ពាក្យថា កេរភេទ ត្រូវបានគេយល់ថា ជាលិង្គ ឬ រន្ធយោនី ឬ រន្ធគូទ ។

---

[៤៣] បណ្តាប្រទេសជាច្រើនដូចជា ប្រទេសអង់គ្លេសជាដើម គេនៅតែរក្សាច្បាប់ស្តីពីការរំលោភសេពសន្ថវៈលើអនីតិជនដដែល ។ ប៉ុន្តែគេក៏រក្សាទម្លាប់មិនចោទប្រកាន់លើជនល្មើសដែលជាអនីតិជននោះទេ ។

ដូចគ្នានេះដែរ យើងឃើញមានកំណើននិន្នាការឆ្ពោះទៅរកការរៀបចំការអនុវត្តច្បាប់ ដែលសហរដ្ឋអាមេរិក យោងទៅរកច្បាប់ រ៉ូមីអូ និងយូលាត ក្នុងករណីមានទំនាក់ទំនងផ្លូវភេទដែលមានការព្រម.ព្រៀងគ្នា រវាងបុគ្គល និងបុគ្គល ដែលមានអាយុប្រហាក់ប្រហែលគ្នា ត្រូវបានពិចារណា ចាត់ទុកថាជាទំនាក់ទំនងគ្មានការទទួលខុសត្រូវព្រហ្មទណ្ឌ ឬ នៅតែចាត់ទុកជាបទល្មើស ប៉ុន្តែមានការកម្រិត ទោសស្រាលជាងការកម្រិត ទោសដែលមានចែងនៅក្នុងច្បាប់ស្តីពីការរំលោភសេពសន្ថវៈលើអនីតិជន ។ ដកស្រង់ចេញពីឯកសារ (ស្ទីវ ចេមស៍-រ៉ូមីអូ និងយូលាត : ការធ្វើវិភាគទៅលើអាយុនីតិភាពអាចព្រមព្រៀង និងការអំពាវនាវឱ្យមានកំណែទម្រង់-៧៨ UMKC L.Rev. ២៤១ ២៤៨ (២០០៩ ) ។

ពាក្យថា " អំពើរួមភេទ " មានរាប់បញ្ចូល ការរួមភេទតាមរន្ធយោនី ការរួមភេទតាមរន្ធគូទ និងការរួមភេទតាមមាត់[៤៤] ។

ជនល្មើសអាចត្រូវផ្តន្ទាទោសយោងតាមមាត្រានេះ ដោយមិនគិតថា តើជនល្មើសគឺជាជនដែលស៊កបញ្ចូលមកលើជនរងគ្រោះ ឬ ជនដែលត្រូវជនរងគ្រោះស៊កបញ្ចូល ។

**មាត្រា ៤៣.- អំពើអាសចំពោះអនីតិជនអាយុក្រោម ១៥ ឆ្នាំ**

**អំពើអាសនៅក្នុងច្បាប់នេះ មានន័យថា ជាអំពើនៃការប៉ះពាល់ ឬ ការបង្ហាញកេរភេទ ឬ ផ្នែកភេទផ្សេងទៀត របស់ជនដទៃ ឬ ការឱ្យជនដទៃប៉ះពាល់កេរភេទ ឬ ផ្នែកភេទផ្សេងទៀត របស់ជនល្មើសខ្លួនឯង ឬ របស់តតិយជនក្នុងចេតនាធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។**

**ជនណាដែលប្រព្រឹត្តអំពើអាសទៅលើជនដទៃ ដែលមានអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.000.000 (ពីរលាន) រៀល ដល់ ៦.000.000 (ប្រាំមួយលាន) រៀល ។**

**ជនណាដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៤២ ឬ មាត្រានេះ បើមិនរាងចាលទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ទ្វេដង ។**

មាត្រានេះ កំណត់និយមន័យ អំពើអាស ( ការប៉ះពាល់កេរភេទ ដែលមិនឈានដល់ការរួមភេទ ដូចមានការកំណត់និយមន័យ ក្នុងមាត្រា ៤២ ) និងផ្តន្ទាទោស ជនណា ( បុរស ឬ ស្ត្រី ) ដែលចូលរួមប្រព្រឹត្តអំពើអាសទៅលើ អនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ ។

យោងតាមមាត្រា ៤៣ នៃច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការផ្តន្ទាទោសជាប់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ និងពិន័យ ជាប្រាក់ ពី ២ លានរៀល ដល់ ៦ លានរៀល នឹងមានស្ថាន់ទម្ងន់ទោសទ្វេដង កាលបើជនល្មើសប្រព្រឹត្តបទល្មើសនោះ ម្តងទៀត ។

កត់សំគាល់ថាមាត្រា ៤៣ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ ដូចគ្នានឹងបទប្បញ្ញត្តិនៃមាត្រា ៣៤១ នៃក្រមព្រហ្មទណ្ឌ (សូមមើលគន្ថីទី ២ មាតិកាទី ៣ ជំពូកទី ៥ "ការដាក់ អនីតិជនឱ្យស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់" ផ្នែកទី ១ "ការប៉ះពាល់ដល់សុខភាព និងចិត្តសាស្ត្រ" ។

មាត្រា ៣៤១ "បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ ឆ្នាំ" នៃក្រមព្រហ្មទណ្ឌ ដែលចែងពីផ្តន្ទាទោស ដាក់ពន្ធនាគារដូចគ្នាពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យ ជាប្រាក់ពី ២.000.000 (ពីរលាន) រៀល ទៅ ៦.000.000 (ប្រាំមួយលាន) រៀល ។

---

[៤៤] ការរួមភេទតាមមាត់ ត្រូវចាត់ទុកថាជា " ការរួមភេទ " ដែរ សូម្បីតែនៅពេលដែលធ្វើឡើងទៅលើស្ត្រី និងមិនមានការស៊កបញ្ចូល ទៅក្នុងរន្ធយោនី ឬ រន្ធគូទក៏ដោយ ។ ការបកស្រាយនេះ ចាំបាច់ណាស់ដើម្បីធានាថា កុំឱ្យមានការរើសអើងមកលើអនីតិជនភេទស្រី និងផ្តល់សិទ្ធិ និងការការពារឱ្យអនីតិជនភេទស្រី ដូចគ្នានឹងបុរសដែរ យោងតាមច្បាប់នេះ ។

ទោសនេះនឹងត្រូវកើនពី ពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងករណីមានស្ថានទម្ងន់ទោសដូចមាន រៀបរាប់នៅក្នុងមាត្រា ៣៤២ (ស្ថានទម្ងន់ទោស) នៃក្រមព្រហ្មទណ្ឌ ។

មាត្រានេះ ត្រូវអនុវត្តសូម្បីតែក្នុងករណី ដែលអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ បានយល់ព្រមយ៉ាងពេញលេញចំពោះការប៉ះពាល់បែបនេះ ឬ មិនបានទប់ទល់ ក្នុងវិធីណាមួយក៏ដោយ ។ ដោយសារតែ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានផ្តល់ឱ្យអនីតិជន ដែលមានអាយុក្រោម ១៥ ឆ្នាំ នូវសមត្ថភាពក្នុងការយល់ព្រមរួមភេទ ក្នុងន័យច្បាប់ ការព្រមព្រៀងបែបណាមួយក៏ដោយ មិនមែនជា " ការយល់ព្រម " ទេ ។

ប្រសិនបើ ជនល្មើសប្រព្រឹត្តអំពើអាស ទៅលើអនីតិជន (អាយុក្រោម ១៥ឆ្នាំ) តាមមធ្យោបាយប្រើកំលាំង អំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ការបំភិតបំភ័យ ជនល្មើស គួរតែត្រូវចោទប្រកាន់ និងផ្តន្ទាទោសពីបទប្រទូស្តកេរខ្មាសដោយមានស្ថានទម្ងន់ តាមមាត្រា ២៤៧ ឬមាត្រា ២៤៨ ដែលមានទំនាក់ទំនងនឹងមាត្រា ២៤៦ "បទប្រទូស្តកេរខ្មាស"[៤៥] នៃក្រមព្រហ្មទណ្ឌ ជាជាងត្រូវចោទប្រកាន់ ឬ ផ្តន្ទាទោស យោងតាមមាត្រា ៤៣ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ ។ (សូមមើលក្រមព្រហ្មទណ្ឌគន្ថីទី ២ មាតិកាទី ២ ជំពូកទី ៣ ផ្នែកទី ២ " ការបំពានផ្លូវភេទ ដទៃទៀត" ) ។ មាត្រា ២៤៧ និង មាត្រា ២៤៨ នៃក្រព្រហ្មទណ្ឌ ផ្តន្ទាទោសដោយមានស្ថានទម្ងន់ ដោយដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើមានស្ថានទម្ងន់ទោសដែលរួមបញ្ចូល ទាំងក្នុងករណីដែលជនរងគ្រោះ ជាបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។[៤៦]

ប្រសិនបើ ជនល្មើសបានរួមភេទ ជាមួយជនរងគ្រោះ (ដែលជា អនីតិជនអាយុក្រោម ១៥ ឆ្នាំ) ជនល្មើស គួរតែត្រូវចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រា ៤២ ។

ប្រសិនបើ ជនល្មើសបានប្រព្រឹត្តអំពើអាសទៅលើអនីតិជន ដែលមានអាយុក្រោម ១៥ ឆ្នាំ តាមរយៈ ផ្តល់ ឬ សន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយ ទៅឱ្យអនីតិជន ឬ តតិយជន ជននោះគួរតែត្រូវចោទប្រកាន់ និងផ្តន្ទាទោស ពីបទល្មើសទិញពេស្យាចារកុមារ យោងតាមមាត្រា ៣៤ បន្ថែមទៅនឹងការចោទប្រកាន់ និងផ្តន្ទាទោសដែលអាចយោង

[45] មាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌឱ្យនិយមន័យបទប្រទូស្តកេរខ្មាស ថាជា "អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រផងទេ ឬបង្ខំបុគ្គលដទៃទៀតឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬទៅលើតតិយបុគ្គល ក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាលដល់ចំណង់ផ្លូវភេទរបស់ជនល្មើស"

[46] យោងតាមមាត្រា ២៤៧ (ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងចារី) នៃក្រមព្រហ្មទណ្ឌ បទប្រទូស្តកេរខ្មាសមានស្ថានទម្ងន់ទោស កាលបើអំពើនោះប្រព្រឹត្តឡើងដោយ ការប្រើប្រាស់អាវុធ ឬការគំរាមកំហែងនឹងអាវុធ ការប្រើគ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់ ការរំលោភអំណាច ។ល។ ....យោងតាមមាត្រា ២៤៨ (ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ) នៃក្រមព្រហ្មទណ្ឌ បទប្រទូស្តកេរខ្មាសមានស្ថានទម្ងន់ទោស កាលបើអំពើនោះប្រព្រឹត្តទៅលើ បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

ផ្លូវភេទរបស់ខ្លួន ។ វិធីទាំងនេះ អាចមានដូចជា ប្រើសកម្មភាពផ្ទាល់ខ្លួនទៅលើជនរងគ្រោះ ឱ្យជនរងគ្រោះធ្វើអំពើមកលើខ្លួន ឬ ទៅលើតតិយជន ឬ ឱ្យតតិយជនធ្វើអំពើមកលើជនរងគ្រោះ ។

**មាត្រា ៤៤.. ការលើកលែងពីការផ្តន្ទាទោស**

**ជនណាដែលមានអាយុក្រោម ១៥ ឆ្នាំ នឹងត្រូវលើកលែងពីការផ្តន្ទាទោស ចំពោះបទល្មើសដូចមានចែងនៅក្នុងមាត្រា ៤២ និងមាត្រា ៤៣ នៃច្បាប់នេះ ។**

មាត្រានេះ ចែងថា ជនណាមានអាយុក្រោម ១៥ ឆ្នាំ មិនត្រូវធ្វើការផ្តន្ទាទោស ពីបទល្មើសដែលមានចែងក្នុងមាត្រា ៤២ ( ការរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ ) និងមាត្រា ៤៣ ( អំពើអាសគ្រាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ ) ។ ទោះជាយ៉ាងណាក៏ដោយ ការលើកលែងពីទោសនេះ អនុវត្តបានតែទៅលើការចោទប្រកាន់ដែលធ្វើឡើង យោងតាមមាត្រា ៤២ មាត្រា ៤៣ ។ ការលើកលែងពីទោសនេះ មិនរាប់បញ្ចូលបុគ្គលដែលមានអាយុ ១៤ ឆ្នាំ ដែលទទួលទោសពីបទរំលោភសេពសន្ថវៈ ឬ ការឈ្លានពានផ្លូវភេទ យោងតាមច្បាប់ព្រហ្មទណ្ឌ ដែលកំពុងអនុវត្ត ។

គួរកត់សំគាល់ថា ការលើកលែងពីការផ្តន្ទាទោស អនុវត្តតែការចោទប្រកាន់ដែលធ្វើឡើង យោងតាមមាត្រា ៤២ និង មាត្រា ៤៣ ក្នុងករណីដែលអំពើផ្លូវភេទ ត្រូវប្រព្រឹត្តឡើងដោយមានការយល់ព្រមដោយស្ម័គ្រចិត្ត ពីអ្នកចូលរួមទាំងអស់ ។

ប្រសិនបើ អ្នកចូលរួម មិនយល់ព្រមចូលរួមក្នុងអំពើដែលមានចែងក្នុងមាត្រា ៤២ និង មាត្រា ៤៣ ទេ និងអ្នកប្រព្រឹត្តបានប្រើកំលាំង អំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ការបំភិតបំភ័យ ហេតុដូច្នេះអ្នកប្រព្រឹត្តគួរតែត្រូវចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ ឬ ទម្រង់នៃការឈ្លានពានផ្លូវភេទផ្សេងទៀត យោងតាមបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌដែលកំពុងអនុវត្ត ។ ( សូមមើលក្រមព្រហ្មទណ្ឌ គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៣ ផ្នែកទី ១ " រំលោភសេពសន្ថវៈ " និងផ្នែកទី ២ " ការបំពានខាងផ្លូវភេទដទៃទៀត " ) ។ ក្នុងករណីនេះ គួរកត់សំគាល់ថា ច្បាប់ព្រហ្មទណ្ឌ ចែងពីការផ្តន្ទាទោសស្រាលចំពោះជនល្មើសជាអនីតិជន ដែលមានអាយុយ៉ាងតិច ១៤ ឆ្នាំ ។ ( សូមមើល ឧទាហរណ៍ : ក្រមព្រហ្មទណ្ឌ គន្ថីទី ១ មាតិកាទី ២ ជំពូកទី ៣ " ការទទួលខុសត្រូវ ព្រហ្មទណ្ឌរបស់អនីតិជន " ) ។

**ឧទាហរណ៍ : ប្រសិនបើ ជនណាម្នាក់ដែលមានអាយុ ១៤ ឆ្នាំ បានរួមភេទ ជាមួយអនីតិជន ដែលមានអាយុតិចជាង ១៥ ឆ្នាំ ហើយការរួមភេទនោះ បានសម្រេចតាមមធ្យោបាយ ប្រើកំលាំង អំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ការបំភិតបំភ័យ ហេតុដូច្នេះ ជនល្មើសគួរតែត្រូវ ចោទប្រកាន់ និងផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ ក្នុងច្បាប់ ព្រហ្មទណ្ឌ ជាជាងត្រូវចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រា ៤២ ។**

## ជំពូកទី ៧

## សំណងរដ្ឋប្បវេណី

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សំខាន់គឺជាច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែជំពូកនេះ ចែងពីសំណងរដ្ឋប្បវេណីដែលមានតាមច្បាប់ ។

**មាត្រា ៤៥.- កិច្ចសន្យាសម្រាប់អំពើលក់-ដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ**

កិច្ចសន្យាមួយនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើកិច្ចសន្យានោះត្រូវបានធ្វើឡើង ដោយមានគោលដៅបំពេញនូវ អំពើលក់-ដូរមនុស្ស ឬ អំពើធ្វើអាជីវកម្មផ្លូវភេទ ។

កិច្ចសន្យាឱ្យខ្ចីនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើកិច្ចសន្យានោះ ត្រូវបានធ្វើឡើងដោយភ្ជាប់ទៅនឹង អំពើលក់-ដូរមនុស្ស ឬ អំពើធ្វើអាជីវកម្មផ្លូវភេទ ។

" អំពើលក់-ដូរមនុស្ស " ឬ " អំពើធ្វើអាជីវកម្មផ្លូវភេទ " នៅក្នុងមាត្រានេះ និងមាត្រាបន្តបន្ទាប់ មានន័យថា ជាអំពើខុសច្បាប់ដែលពាក់ព័ន្ធទៅនឹងបទល្មើសទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់នេះ ។

មាត្រានេះ ចែងថា កិច្ចសន្យា ឬ កិច្ចសន្យាឱ្យខ្ចីនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើ កិច្ចសន្យានោះធ្វើឡើង ភ្ជាប់នឹងបទល្មើសណាមួយ យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ការចែងដូច្នេះ ស្របនឹងវិធីសាស្ត្រក្នុងច្បាប់កិច្ចសន្យា ដែលនៅជាធរមាននៅពេល ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានប្រកាសឱ្យប្រើ ។ មាត្រា ៥ នៃក្រិត្យច្បាប់លេខ ៣៨ ( ស្តីពី កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ) ចែងថា កិច្ចសន្យា :

> *“...ត្រូវទុកជាមោឃៈដាច់ខាត*
>
> *- កិច្ចសន្យាទាំងឡាយណា ដែលមិនស្របនឹងច្បាប់ របៀបរៀបរយសាធារណៈ ឬ ទំនៀមទំលាប់ ដ៏ប្រពៃ*
>
> *- កិច្ចសន្យាទាំងឡាយណា ដែលមិនស្របនឹងផលប្រយោជន៍សង្គម ឬ មិនស្របនឹង គោលការណ៍សីលធម៌ សង្គម*
>
> *- កិច្ចសន្យាទាំងឡាយណា ដែលមានតាវកាលិក ឬ កម្មវត្ថុនៃកិច្ចសន្យាមិនអាចធ្វើកើត ។”*

ប្រហាក់ប្រហែលគ្នានេះដែរ ក្រមរដ្ឋប្បវេណី ក្នុងមាត្រា ៣៩៤ ចែងថា កិច្ចសន្យា ត្រូវបានចាត់ទុកជាមោឃៈ " (ក) អត្ថន័យនៃកិច្ចសន្យានោះ ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ឬ (ខ) អត្ថន័យនៃកិច្ចសន្យានោះ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ " ។

ភាសាក្នុងមាត្រាដែលលើកឡើងខាងលើនេះ មានចេតនាយ៉ាងទូលំទូលាយ និងមានបំណងធ្វើឱ្យទៅជាមោឃៈ នូវកិច្ចសន្យាណាមួយ ដែលខុសច្បាប់ និងផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ។ នេះរាប់បញ្ចូល នូវកិច្ចសន្យាណាមួយ ដែលធ្វើឡើងក្នុងគោលដៅប្រព្រឹត្តគ្រប់អំពើជួញដូរ ដែលរួមមានរាល់បទល្មើស ដែលមានចែងនៅក្នុងច្បាប់នេះ ទាំងមូល ។ កិច្ចសន្យាណាមួយ ដែលមានគោលដៅប្រព្រឹត្តបទល្មើសទាំងនេះ ត្រូវចាត់ទុកជាមោឃៈ និងមិនអាចអនុវត្តបានដោយភាគីនៃកិច្ចសន្យា ។

" **កិច្ចសន្យាឱ្យខ្ចី និងត្រូវចាត់ទុកជាមោឃៈ...** "

កថាខ័ណ្ឌនេះ មានន័យថា ការឱ្យខ្ចីដែលទាក់ទងនឹងអំពើជួញដូរ និងអំពើធ្វើអាជីវកម្ម គឺមិនអាចអនុវត្តបាន ។ ការឱ្យខ្ចីដែលធ្វើឡើង ជាប់ទាក់ទងនឹងបទល្មើសទាំងនេះ គឺត្រូវចាត់ទុកជាមោឃៈ ដោយមិនគិតថាអ្នកឱ្យខ្ចី គឺជាបុគ្គលឯកជន ឬ ស្ថាប័នហិរញ្ញវត្ថុ ។ គោលបំណងនៃបទប្បញ្ញត្តិនេះ គឺដើម្បីលើកទឹកចិត្តឱ្យអ្នកឱ្យខ្ចីបង្ហាញការពិតថា ប្រាក់ដែលពួកគេឱ្យខ្ចី មិនត្រូវប្រើដើម្បី ផ្តល់ហិរញ្ញវត្ថុដល់អំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ពាក្យថា " កិច្ចសន្យា " ដែលលើកឡើងនៅទីនេះ និងក្នុងមាត្រា ៣៧ គួរត្រូវធ្វើការបកស្រាយឱ្យទូលំទូលាយ ។ កិច្ចសន្យា ដែលធ្វើដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ ដើម្បីប្រព្រឹត្តសកម្មភាពមិនស្របច្បាប់ (រួមមានទម្រង់ណាមួយនៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ) ត្រូវចាត់ទុកជាមោឃៈ និងមិនអាចអនុវត្តបាន ។

" **អំពើខុសច្បាប់ដែលពាក់ព័ន្ធនៅនឹងបទល្មើសទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់នេះ** "

បទប្បញ្ញត្តិនេះ មានន័យថា កិច្ចសន្យា ឬ ការឱ្យខ្ចី ត្រូវចាត់ជាទុកមោឃៈ ប្រសិនការឱ្យខ្ចីនោះ ធ្វើឡើងក្នុងគោលបំណង ឬ ភ្ជាប់នឹងបទល្មើសណាមួយ នៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឬ បទល្មើសណាមួយផ្សេងទៀត ដែលមានការកំណត់និយមន័យនៅក្នុងច្បាប់កម្ពុជា ដែលត្រូវអនុវត្ត ទាក់ទងនឹងបទល្មើសណាមួយ នៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**មាត្រា ៤៦.- សំណងបដិទានលើការទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផល**

**ជនណាទទួលយកនូវផលប្រយោជន៍ ដោយគ្មានហេតុផលស្របច្បាប់ ដោយដឹងថាផលប្រយោជន៍នោះ បានមកពីអំពើលក់-ដូរមនុស្ស ឬ អំពើធ្វើអាជីវកម្មផ្លូវភេទ នឹងត្រូវទទួលខុសត្រូវលើសំណងបដិទានចំពោះ អំពើទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផល ព្រមទាំងការប្រាក់ដែលកើតឡើង ។**

**ជនដែលត្រូវគេកេងយកប្រយោជន៍ អាចប្តឹងទាមទារសំណងលើការខូចខាតជាបន្ថែម លើសំណងបដិទានចំពោះអំពើទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផល ។**

**ជនណាបានបង្កើតកិច្ចសន្យាឱ្យខ្ចី ឬ ការផ្តល់ផ្សេងទៀតទៅជនដទៃ ក្នុងគោលដៅធ្វើការលក់-ដូរមនុស្ស ឬ ធ្វើអាជីវកម្មផ្លូវភេទ មិនអាចប្តឹងទាមទារសំណងបដិទាន ចំពោះការផ្តល់នោះបានទេ ។**

មាត្រានេះ មានបំណងទប់ស្កាត់ជនណាមួយ ពីការកេងយកផលប្រយោជន៍ ពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ មាត្រានេះ តម្រូវឱ្យមានសំណងបដិទានទាំងមូលលើការទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផល ដែលកើតមកពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ នេះមានន័យថា ជនណាដែលដឹងជាមុន កេងយកផលប្រយោជន៍ពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ( ក្រៅតែពីជនរងគ្រោះនៃបទល្មើសទាំងនោះ ) ត្រូវសងសំណងទាំងអស់វិញ ទៅដល់ជនដែលទទួលការខាតបង់ ដោយសារជនល្មើសបានចំណេញ ។

**" ជនណាទទួលយកនូវផលប្រយោជន៍ ដោយគ្មានហេតុផលស្របច្បាប់..."**

បទប្បញ្ញត្តិនេះ អនុវត្តចំពោះបុគ្គលទាំងអស់ ដែលទទួលនូវផលប្រយោជន៍មិនស្របច្បាប់ ឬ ពីប្រភពមិនស្របច្បាប់ ។

**"...ដោយដឹងថា ផលប្រយោជន៍នោះ បានមកពីអំពើលក់-ដូរមនុស្ស ឬអំពើធ្វើអាជីវកម្មផ្លូវភេទ..."**

មាត្រានេះ តម្រូវឱ្យជនណាដែលទទួលផលប្រយោជន៍ ត្រូវដឹងថា ផលប្រយោជន៍នេះ បានមកពីអំពើ ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ នេះមិនរាប់បញ្ចូលក្នុងករណីដែល ជនម្នាក់ទទួលបានផលប្រយោជន៍ ប៉ុន្តែមិនបានដឹងថា ផលប្រយោជន៍នោះបានមកពីបទល្មើស យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**"....ត្រូវទទួលខុសត្រូវលើសំណងបដិទានចំពោះ អំពើទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផល ព្រមទាំង ការខ្ចាត់ដែលកើតឡើង "**

បទប្បញ្ញត្តិនេះ អនុញ្ញាតឱ្យជនរងគ្រោះដោយបទល្មើស យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឬ ជនណាមួយផ្សេងទៀត ដែលបាត់បង់ផលប្រយោជន៍ ដោយសារជនល្មើសបានចំណេញដោយមិនសមហេតុផល ធ្វើការទាមទារសំណងបដិទានលើការទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផលនេះមកវិញ ។

" ការទទួលបានផលប្រយោជន៍ដោយមិនសមហេតុផល " មានន័យថាជា ផលប្រយោជន៍ ឬ ប្រាក់ចំណេញដែលរកបានដោយខុសច្បាប់ ពីទ្រព្យសម្បត្តិ ឬ សេវាកម្មអ្នកដទៃ ហើយធ្វើឱ្យកើតមានការអន្តរាយ ឬ ការបាត់បង់ដល់អ្នកដទៃ ។ និយមន័យនេះស្របទៅនឹង គំនិតនៃការទទួលបានសេចក្តីចម្រើនដោយឥតហេតុ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ( សូមមើលគន្លីទី ៥ ជំពូកទី ១៥ " សេចក្តីចម្រើនដោយឥតហេតុ " ។

តុលាការ ត្រូវបញ្ជាឱ្យជនដែលទទួលបានផលប្រយោជន៍ដោយមិនសមហេតុផល ធ្វើការសងសំណងបដិទានទៅកាន់អ្នកទាមទារ ឱ្យគ្រប់ចំនួនទាំងអស់ ដែលរួមបញ្ចូលទាំងការប្រាក់កើនឡើង ដែលតុលាការជាអ្នកគណនា ។

**" ជនដែលត្រូវគេគេចយកប្រយោជន៍ អាចប្តឹងទាមទារសំណងលើការខូចខាតជាបន្ថែមលើសំណងបដិទាន ចំពោះអំពើទទួលបានផលប្រយោជន៍ ដោយមិនសមហេតុផល "**

បទប្បញ្ញត្តិនេះ អនុញ្ញាតឱ្យជនរងគ្រោះដោយបទល្មើស យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឬ ជនណាមួយផ្សេងទៀត ដែលបាត់បង់ផលប្រយោជន៍ ដោយសារជនល្មើស

បានទទួលដោយមិនសមហេតុផល ធ្វើការទាមទារសំណងខូចខាតបន្ថែម នឹងសំណងបដិទានលើការទទួលបានផល-ប្រយោជន៍ ដោយមិនសមហេតុផល ។

**" ជនណាបានបង្កើតកិច្ចសន្យាឱ្យខ្ចី ឬ ការផ្តល់ផ្សេងទៀតទៅជនដទៃ ក្នុងគោលដៅធ្វើការលក់-ដូរមនុស្ស ឬ ធ្វើអាជីវកម្មផ្លូវភេទ មិនអាចប្តឹងទាមទារសំណងបដិទាន ចំពោះការផ្តល់នោះបានទេ "**

កថាខ័ណ្ឌទី ៣ នៃមាត្រានេះ ពន្យល់ថា ប្រសិនបើជនណាម្នាក់ យល់ព្រមឱ្យប្រាក់គេខ្ចី ក្នុងគោលដៅពង្រីកអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមច្បាប់ អ្នកឱ្យខ្ចី មិនអាចទាមទារសំណងនោះវិញបានទេ ។

គោលបំណងនៃបទប្បញ្ញត្តិនេះ គឺដើម្បីទប់ស្កាត់ អ្នកឱ្យខ្ចី ពីការផ្តល់ប្រាក់ដល់ អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងផ្តន្ទាទោសអ្នកឱ្យខ្ចី ក្នុងករណីដែលអ្នកឱ្យខ្ចីនោះ មានប្រាក់កម្ចីសម្រាប់គោលដៅបែបនេះ ។

កថាខ័ណ្ឌនេះ មានមុខងារជាអញ្ញត្រកម្មចំពោះបទប្បញ្ញត្តិដែលមានចែងក្នុងកថាខ័ណ្ឌទី ១ និងទី ២ នៃមាត្រានេះ ។ ក្នុងន័យផ្សេងទៀត កថាខ័ណ្ឌទី ១ និងទី ២ ចែងថា ជនណាដែលទទួលផលប្រយោជន៍ដោយការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហើយផលប្រយោជន៍បែបនេះ ធ្វើឱ្យជនដទៃខាតបង់ ត្រូវទទួលខុសត្រូវចំពោះសំណងបដិទាន និងការខូចខាតនោះ ។ យ៉ាងណាមិញ កថាខ័ណ្ឌទី ៣ ចែងថា ក្នុងករណីដែលជនដទៃបានឱ្យប្រាក់ជនល្មើសខ្ចី ក្នុងគោលដៅប្រព្រឹត្តបទល្មើស ហេតុដូច្នេះ អ្នកឱ្យខ្ចីមិនអាចទាមទារឱ្យសងប្រាក់កម្ចីវិញ ឬ ទម្រង់ផ្សេងទៀតនៃសំណងបដិទាន បានទេ ។

នេះស្របទៅនឹងក្រមរដ្ឋប្បវេណី មាត្រា ៧៤១ ( ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់ ) ដែលចែងថា ការទាមទារឱ្យមានសំណងបដិទានលើ ការទទួលបានផលប្រយោជន៍ដោយមិនសមហេតុផល ត្រូវហាមឃាត់ ប្រសិនបើ ការទាមទារបែបនេះ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ច្បាប់ដែលទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ៤៧.. សិទ្ធិជាអាទិភាពក្នុងការទទួលបានទ្រព្យសម្បត្តិ ដែលត្រូវបានរឹបអូស**

**ជនរងគ្រោះ ត្រូវទទួលបានដោយអាទិភាពនូវទ្រព្យដែលត្រូវបានរឹបអូសដោយរដ្ឋ សម្រាប់ជាសំណងលើការខូចខាត និង សំណងបដិទាន ដល់ជនរងគ្រោះនោះ ។**

មាត្រានេះ ផ្តល់ឱ្យជនរងគ្រោះនូវសិទ្ធិទាមទារទ្រព្យសម្បត្តិ ដែលត្រូវបានរឹបអូស សម្រាប់ជាសំណងលើការខូចខាត និងសំណងបដិទាន ចំពោះភាពទទួលរងគ្រោះនោះ ។ បទប្បញ្ញត្តិនេះ មានគោលបំណងដើម្បីផ្តល់យន្តការសម្រាប់សងលើការខូតខាតដល់ជនរងគ្រោះ និងដើម្បីធានាថា ជនរងគ្រោះទទួលបានដោយអាទិភាពលើសំណង លើការខូចខាត បែបនេះ ។

**" អាទិភាព "**

ពាក្យថា " អាទិភាព " មានន័យថា ជនរងគ្រោះមាន ឯកសិទ្ធិ លើទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស ។ ឯកសិទ្ធិរបស់ជនរងគ្រោះ មានអាទិភាពលើសិទ្ធិដទៃទៀត លើទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសនោះ ដែលរួមមាន សិទ្ធិណាមួយរបស់ម្ចាស់បំណុល យោងតាមក្រមរដ្ឋប្បវេណី ( សូមមើល គន្លឹះទី ៦ ជំពូកទី ៣ " ឯកសិទ្ធិ " ) ។

ក្នុងន័យផ្សេងទៀត ការទាមទាររបស់ជនរងគ្រោះឱ្យសងសំណងលើការខូចខាត និងសំណងបដិទានមាន អាទិភាពលើការទាមទារណាមួយផ្សេងទៀត លើទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស ដែលរួមមានលើការទាមទាររបស់ រដ្ឋ ឬ របស់ម្ចាស់បំណុល ។ ប្រសិនបើ តម្លៃនៃទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស មិនអាចសងសំណងជនរងគ្រោះគ្រប់ គ្រាន់ ជនរងគ្រោះនោះ អាចធ្វើការទាមទារបន្តទៀត ។

**" ទ្រព្យសម្បត្តិ "**

ពាក្យថា " ទ្រព្យសម្បត្តិ " ត្រូវកំណត់និយមន័យយ៉ាងទូលំទូលាយ ។ យោងទៅតាមមាត្រា ២ (គ) នៃ អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពី ការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ពាក្យថា " ទ្រព្យសម្បត្តិ " មានន័យថា ជា ទ្រព្យសកម្មគ្រប់ប្រភេទ ថាតើមាន រូប ឬ អរូប ជាចលនទ្រព្យ ឬ អចលនទ្រព្យ ជារូបី ឬ អរូបី និងឯកសារ ឬ ប័ណ្ណកម្មសិទ្ធិ ឬ ការប្រាក់នៃទ្រព្យសកម្មនេះ ។

## ជំពូកទី ៨
## បទប្បញ្ញត្តិបន្ថែម

**មាត្រា ៤៨.- ទោសបន្ថែម**

**ចំពោះបទល្មើស ដែលមានចែងនៅក្នុងច្បាប់នេះ អាចត្រូវទទួលទោសបន្ថែមដូចតទៅ :**

**១-រឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុទាំងឡាយដែលត្រូវបានប្រើប្រាស់ ឬ នឹងត្រូវប្រើប្រាស់ ក្នុងការប្រព្រឹត្តបទល្មើស**

**២-រឹបអូសសម្ភារៈទាំងឡាយ ដែលជាកម្មវត្ថុ នៃបទល្មើស**

**៣-រឹបអូសប្រាក់ចំណូល ឬ ទ្រព្យដែលរកបាន ឬ ជាផលនៃបទល្មើស**

**៤-បិទការផលិត ដែលបម្រើដល់ការប្រព្រឹត្តបទល្មើស**

**៥-ការដាក់កំហិតលើសិទ្ធិពលរដ្ឋ និង**

**៦-ការហាមឃាត់ការស្នាក់នៅ ។**

មាត្រានេះ ចែងពីទោសបន្ថែម ដែលតុលាការអាចអនុវត្តទៅលើជនល្មើសដែលត្រូវគេរកឃើញថា មានទោស យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

មាត្រានេះ មានគោលបំណងផ្តល់ឱ្យតុលាការ នូវឧបករណ៍ជាច្រើនទៀត ដើម្បីធ្វើឱ្យរាំងស្ទះដល់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ មាត្រានេះ អនុញ្ញាតឱ្យមាន ការរឹបអូសទ្រព្យសម្បត្តិដែលទាក់ទងយ៉ាងជិតស្និទ្ធជាមួយបទល្មើស ដែលមានចែងក្នុងច្បាប់នេះ ការបិទដោយបង្ខំលើអាជីវកម្មដែលមានចំណែក ការដាក់កំហិតលើសិទ្ធិពលរដ្ឋ ការដាក់កំហិតការដើរហើរ ។ ទោសបន្ថែមទាំងនេះ គួរត្រូវប្រើដោយអំណាចឆន្ទានុសិទ្ធិរបស់តុលាការ និងគួរតែអនុវត្ត ចំពោះតែមកលើចារីនៃបទល្មើស និងមិនត្រូវអនុវត្តមកលើជនរងគ្រោះទេ ។

ក្នុងករណីដែល អ្នកតំណាង ភ្នាក់ងារ ឬ និយោជិតនៃនីតិបុគ្គល ឬ ភារប្បទាយី ត្រូវរកឃើញថា បានប្រព្រឹត្តបទល្មើស យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តុលាការអាចពិចារណាធ្វើការដាក់ទោសខ្លះ ដែលមានរៀបរាប់ក្នុងមាត្រានេះ ទៅលើនីតិបុគ្គលនោះ យោងតាមមាត្រា ៤ ខាងលើ ។ (សូមមើលការពិភាក្សាយោងតាមមាត្រា ៤ សម្រាប់ព័ត៌មានលំអិត ) ។

**" រឹបអូសឧបករណ៍ សម្ភារៈ វត្ថុទាំងឡាយដែលត្រូវបានប្រើប្រាស់ ឬ នឹងត្រូវប្រើប្រាស់ ក្នុងការប្រព្រឹត្តបទល្មើស "**

**" រឹបអូសសម្ភារៈទាំងឡាយ ដែលជាកម្មវត្ថុនៃបទល្មើស "**

**" រឹបអូសប្រាក់ចំណូល ឬ ទ្រព្យដែលរកបាន ឬ ជាផលនៃបទល្មើស "**

បទប្បញ្ញត្តិនេះ អនុញ្ញាតឱ្យតុលាការ រឹបអូសឧបករណ៍ សម្ភារៈ វត្ថុទាំងឡាយ ប្រាក់ចំណូល ឬ ទ្រព្យដែល

រកបាន ដែលទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងបទល្មើស និងដែលត្រូវបានប្រើប្រាស់ដោយជនល្មើស ក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលជនល្មើសបានទទួលដោយសារតែលទ្ធផលនៃការប្រព្រឹត្តបទល្មើស ។

មិនមានគោលបំណងក្នុងការប្រើបទប្បញ្ញត្តិទាំងនេះ ដើម្បីរឹបអូសទ្រព្យសម្បត្តិដែលមិនមែនជាកម្មសិទ្ធិរបស់ជនល្មើសទេ ។ យោងតាមមាត្រានេះ ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់តតិយជន ( ដែលរួមមានជនរងគ្រោះ ) មិនអាចត្រូវរឹបអូសបានឡើយ ។ នេះស្របនឹងក្រមព្រហ្មទណ្ឌ ដែលហាមឃាត់ការរឹបអូសណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។ (សូមមើលក្រមព្រហ្មទណ្ឌ គន្ថីទី ១ មាតិកាទី ៣ " ទោស " ជំពូកទី ១ ផ្នែកទី ១ " មូលទោស " ជំពូកទី ៧ " ទោសដែលអនុវត្តចំពោះនីតិបុគ្គល " ) ។

ក្នុងមាត្រានេះ វិសាលភាពនៃការរឹបអូស និងឆន្ទានុសិទ្ធិរបស់តុលាការធំជាង បទប្បញ្ញត្តិការរឹបអូស នៃច្បាប់ស្តីពី ការជួញដូរមនុស្ស ឆ្នាំ ១៩៩៦ ។ ច្បាប់ស្តីពី ការជួញដូរមនុស្ស ឆ្នាំ ១៩៩៦ បានចែងថា ទ្រព្យសម្បត្តិណាមួយ ដែលត្រូវប្រើទាក់ទងនឹងបទល្មើស នឹងត្រូវរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។ យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការរឹបអូសទ្រព្យសម្បត្តិ អាចជ្រើសរើសធ្វើបាន ដែលជាឧបករណ៍ដែលតុលាការប្រើឆន្ទានុសិទ្ធិ ដើម្បីធ្វើឱ្យប្រសើរឡើងដល់យុត្តិធម៌ និងសមធម៌ ។

ដូចមានចែងក្នុងមាត្រា ៤៧ ( សិទ្ធិជាអាទិភាពក្នុងការទទួលបានទ្រព្យសម្បត្តិ ដែលត្រូវគេរឹបអូស ) នៃច្បាប់នេះ សម្ភារៈ ប្រាក់ចំណូល ឬ ទ្រព្យដែលត្រូវបានរឹបអូស ត្រូវតែប្រើជាដំបូង ដើម្បីសងសំណងដល់ជនរងគ្រោះ ដែលយោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជនរងគ្រោះមានសិទ្ធិទាមទារជាអទិភាព ទៅលើទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស សម្រាប់ជាសំណងលើការខូចខាត និងសំណងបដិទាន ។ ប្រសិនបើ ជនរងគ្រោះទទួលបានសំណងហើយ ហេតុដូច្នេះទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសនឹងក្លាយជា ទ្រព្យសម្បត្តិរដ្ឋ ដែលស្របនឹងក្រមព្រហ្មទណ្ឌ (សូមមើល គន្ថីទី ១ មាតិកាទី ៣ " ទោស " ជំពូកទី ១ ផ្នែកទី ១ " មូលទោស " ជំពូកទី ៧ " ទោសដែលអនុវត្តចំពោះនីតិបុគ្គល " ) ។

### " ការបិទអាជីវកម្ម ដែលបម្រើដល់ការប្រព្រឹត្តបទល្មើស "

បទប្បញ្ញត្តិនេះ មានន័យថា ប្រសិនបើអាជីវកម្មត្រូវគេប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស តុលាការអាចបញ្ជាឱ្យបិទអាជីវកម្មនោះ ។ តុលាការអាចអនុវត្តទោសនេះ ក្នុងករណីដែល អ្នកតំណាង ភ្នាក់ងារ ឬ និយោជិត នៃអាជីវកម្ម ត្រូវគេរកឃើញថា ប្រព្រឹត្តបទល្មើស និងតុលាការបានរកឃើញថា បានប្រើអាជីវកម្មនោះ ដើម្បីប្រព្រឹត្តបទល្មើស។ ស្របទៅនឹងក្រមព្រហ្មទណ្ឌ (គន្ថីទី ១ មាតិកាទី ៣ ជំពូកទី ៧ " ទោសដែលអនុវត្តចំពោះនីតិបុគ្គល " ) ។

ទោសនៃការបិទ អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន សម្រាប់ថិរវេលា ៥ ( ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ (ក៏សូមមើលការពិភាក្សា ពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះនីតិបុគ្គលយោងតាមមាត្រា ៤ ខាងលើ ) ។

## " ការដាក់កំហិតលើសិទ្ធិពលរដ្ឋ "

យោងតាមបទប្បញ្ញត្តិនេះ តុលាការអាចផ្តន្ទាទោសជនល្មើសតាមរយៈដាក់កំហិតលើសិទ្ធិពលរដ្ឋ ។ ទណ្ឌកម្មទាំងនេះ មានការកំណត់និយមន័យក្នុងក្រមព្រហ្មទណ្ឌ ( គន្ថីទី ១ មាតិកាទី ៣ " ទោស " ជំពូកទី ១ ផ្នែកទី ២ " ទោសបន្ថែម " ) ដែលចែងថា :

*សិទ្ធិពលរដ្ឋដែលអាចដកបាន ដូចមានចែងក្នុងចំណុច ១ នៃ ( ប្រភេទនៃទោសបន្ថែម ) រួមមាន :*

*១- សិទ្ធិបោះឆ្នោត ។*

*២- សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។*

*៣- សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ។*

*៤- សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬ ជាអណត្តិគាហក របស់តុលាការ ។*

*៥- សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ ។*

*៦- សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ ។*

*ទោសនេះ អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ ( ប្រាំ) ឆ្នាំ យ៉ាងច្រើន ។*

## " ការហាមឃាត់ការស្នាក់នៅ "

យោងតាមបទប្បញ្ញត្តិនេះ តុលាការអាចផ្តន្ទាទោសជនល្មើស ដោយហាមឃាត់ ឬ ដាក់កំហិតពីការតាំងទីលំនៅក្នុងកន្លែងណាមួយ ដោយហាមឃាត់ជនល្មើសពីការចាកចេញពីព្រះរាជាណាចក្រកម្ពុជា ឬ (ទណ្ឌិតជាជនបរទេស) ពីការចូល ឬ តាំងទីលំនៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ជាការសំខាន់ គួរកត់សំគាល់ថា ការផ្តន្ទាទោសទាំងនេះ គឺត្រូវអនុវត្តផ្សេងៗគ្នាទៅលើជនល្មើសដែល គឺជាពលរដ្ឋកម្ពុជា និងជនល្មើសដែលជាជនបរទេស ។

នៅពេលអនុវត្តទៅលើជនល្មើសដែលជាជនជាតិកម្ពុជា ឬ ជាជនបរទេសនេះ មានន័យថា តុលាការអាចហាមឃាត់ជនល្មើស ពីការស្នាក់នៅទីកន្លែងណាមួយ ឬ កន្លែងកំណត់មួយចំនួន ។ តុលាការអាចធ្វើការហាមឃាត់ ក្នុងលក្ខណៈដែលប្រហាក់ប្រហែល នឹងការហាមឃាត់ដែលមានកំណត់និយមន័យ ក្នុង មាត្រា ៥៩ នៃក្រមព្រហ្មទណ្ឌ ( គន្ថីទី ១ មាតិកាទី ៣ " ទោស " ជំពូកទី ១ ផ្នែកទី ២ " ទោសបន្ថែម " ដែលចែងថា :

*ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិត ចំពោះការមានមុខនៅទីកន្លែងខ្លះ លើដែនដី នៃព្រះរាជាណាចក្រកម្ពុជា ។ ទោសនេះមិនអាច លើសពី ១០ (ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ ( ប្រាំ) ឆ្នាំ ចំពោះ បទមជ្ឈិម ។*

*តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់ និងកំណត់ថិរវេលានៃការហាមឃាត់ ។*

*ការហាមឃាត់ការស្នាក់នៅ រួមមានវិធានការតាមដាន ។*

*ទណ្ឌិតត្រូវតែ :*

*១-ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬ រដ្ឋបាល ដែលតុលាការបានចាត់តាំង ។*

*២-ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬ កងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ ។*

*តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន ។*

*សេចក្តីសម្រេចរបស់តុលាការ ត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។*

ចំពោះជនល្មើសជាជនជាតិកម្ពុជា តុលាការក៏អាចហាមឃាត់ ពីការចាកចេញពីប្រទេសកម្ពុជា សម្រាប់រយៈពេលណាមួយ ។

តុលាការអាចអនុវត្តការហាមឃាត់ ក្នុងលក្ខណៈប្រហាក់ប្រហែលនឹងការហាមឃាត់ ដែលមានការកំណត់និយមន័យ ក្នុងមាត្រា ៦០ នៃក្រមព្រហ្មទណ្ឌថ្មី( គន្ថីទី ១ មាតិកាទី ៣ "ទោស" ជំពូកទី ១ ផ្នែកទី ២ "ទោសបន្ថែម" ) ដែលចែងថា :

*"ការហាមឃាត់ចំពោះ ការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវលើសពី ៥ ( ប្រាំ ) ឆ្នាំ ។*

*ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ ។ លិខិតឆ្លងដែននេះ ត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ។*

*ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេ ក្នុងរយៈពេលដែលកំពុងទទួលទោសនោះ ។"*

ចំពោះជនល្មើសជាជនបរទេស តុលាការក៏អាចហាមឃាត់ ពីការចូល ឬ តាំងទីលំនៅ ក្នុងប្រទេសកម្ពុជា ។ ចំពោះជនល្មើសដែលនៅក្នុងប្រទេសកម្ពុជារួចស្រេចហើយ មានន័យថា តុលាការអាចបញ្ជាឱ្យធ្វើការនិរទេសជនល្មើស ។ ប្រសិនបើ ការផ្តន្ទាទោស ត្រូវធ្វើឡើងដោយមានការជាប់ពន្ធនាគារ មានន័យថា ជនល្មើសនឹងត្រូវនិរទេសពីប្រទេសកម្ពុជា ក្រោយពេលបញ្ចប់ការជាប់ពន្ធនាគារជាមុនសិន ។

តុលាការ មិនអាចហាមឃាត់ជនបរទេសពីការចាកចេញពីប្រទេសកម្ពុជា លើកលែងតែក្នុងករណីដែលជនបរទេសនោះ ក៏ត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ឬ ក្នុងករណីដែលជនបរទេសនោះ ត្រូវបានចោទប្រកាន់ ប៉ុន្តែការជំនុំជម្រះក្តីមិនទាន់ចប់នៅឡើយ ។ ប្រសិនបើ ជនបរទេសត្រូវគេរកឃើញថា មានទោសនិងត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ជាទូទៅច្បាប់តម្រូវឱ្យមានការជាប់ពន្ធនាគារនៅក្នុងប្រទេសកម្ពុជាសិន ។

តុលាការអាចអនុវត្តការផ្តន្ទាទោសនេះ ក្នុងលក្ខណៈប្រហាក់ប្រហែលនឹងការផ្តន្ទាទោសដែលមានការកំណត់និយមន័យក្នុងមាត្រា ៦១ នៃក្រមព្រហ្មទណ្ឌថ្មី ( គន្ថីទី ១ មាតិកាទី ៣ " ទោស " ជំពូកទី ១ ផ្នែកទី ២ " ទោសបន្ថែម" ដែលចែងថា :

*"ការហាមឃាត់ដល់ទណ្ឌិតបរទេស ចំពោះការចូល និងការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន ដែលមានរយៈពេល ៥ ( ប្រាំ ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះ នាំឱ្យមានការបណ្តេញទណ្ឌិតឱ្យចេញដោយពេញច្បាប់ នៅពេលបញ្ចប់ទោស ដាក់ពន្ធនាគារ ។"*

គួរកត់សំគាល់ថា ច្បាប់មិនអនុញ្ញាតឱ្យតុលាការ និរទេស ឬ បណ្តេញចេញពលរដ្ឋកម្ពុជាពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ ។ រដ្ឋធម្មនុញ្ញ ក្នុងមាត្រា ៣៣ ចែងថា ពលរដ្ឋខ្មែរមិនអាចត្រូវ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានការព្រមព្រៀងជាមួយគ្នា ទៅវិញទៅមក ។

**មាត្រា ៤៩.. ការលាក់បាំងនូវអត្តសញ្ញាណរបស់ជនរងគ្រោះ**

**សារព័ត៌មាន និងគ្រប់មធ្យោបាយផ្សព្វផ្សាយដទៃទៀត ត្រូវហាមឃាត់មិនឱ្យធ្វើការបោះពុម្ពផ្សាយ ឬ ផ្សព្វផ្សាយនូវព័ត៌មាន ដែលធ្វើឱ្យសាធារណៈជនដឹងអំពីអត្តសញ្ញាណរបស់ជនរងគ្រោះ ក្នុងបទល្មើសទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ ។**

មាត្រានេះ ហាមឃាត់មធ្យោបាយផ្សព្វផ្សាយ ( ដែលរួមមាន សារព័ត៌មាន និងគ្រប់មធ្យោបាយផ្សព្វផ្សាយដទៃទៀត ) ពីការបោះពុម្ពផ្សាយ ឬ ផ្សព្វផ្សាយព័ត៌មានណាមួយ ដែលអាចឱ្យសាធារណៈជនដឹងអំពី អត្តសញ្ញាណរបស់ជនរងគ្រោះ យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

មាត្រានេះ គោលបំណងដើម្បីការពារជនរងគ្រោះដោយសារអំពើជួញដូរ និងអំពើធ្វើអាជីវកម្ម ពីការយាយីដោយមិនចាំបាច់ និងការធ្វើទុក្ខទោសពីសង្គម និងដើម្បីលើកទឹកចិត្តឱ្យពួកគេធ្វើសហប្រតិបត្តិការ ដល់ការស៊ើបអង្កេត និងការចោទប្រកាន់ ទៅលើចារីដែលប្រព្រឹត្តអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

### " ការបោះពុម្ពផ្សាយ ឬ ការផ្សព្វផ្សាយនូវព័ត៌មាន "

នៅទីនេះ ពាក្យ " ការបោះពុម្ពផ្សាយ " ឬ " ការផ្សព្វផ្សាយ " មានន័យថា ជាទម្រង់នៃការផ្តល់ព័ត៌មានមិនថាឡើយ តាមរយៈការបោះពុម្ព ( ដែលរួមមាន កាសែត និងទស្សនាវដ្តី ។ល។ ) ការបញ្ជូនតាមអេឡិចត្រូនិក ( រួមមាន ទូរទស្សន៍ វិទ្យុ ឧឃោសនសព្ទ ឬ អ៊ិនធឺណែត ) ការបិទផ្សាយនៅកន្លែងសាធារណៈ ឬ មធ្យោបាយផ្សេងទៀត នៃការចែកចាយព័ត៌មាន ទៅកាន់សាធារណៈជនទូទៅ ឬ តតិយជន ។

### " ត្រូវធ្វើការហាមឃាត់ "

គួរកត់សំគាល់ថា ទោះបីជាមាត្រានេះ ហាមឃាត់មធ្យោបាយផ្សព្វផ្សាយ ពីការបោះពុម្ពផ្សាយ ឬ ផ្សព្វផ្សាយនូវព័ត៌មានបែបនេះ មាត្រានេះ មិនមានការបញ្ជាក់ពីការផ្តន្ទាទោសឱ្យច្បាស់ទេ ។ ហេតុដូច្នេះ មាត្រានេះ មិនមានការកំណត់និយមន័យនៃបទល្មើសព្រហ្មទណ្ឌ ។ យ៉ាងណាមិញ ជនរងគ្រោះនៃបទល្មើស ក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលកេរ្តិ៍ឈ្មោះ និងកិត្តិយស ត្រូវបានខូចខាត ដោយសារការបោះពុម្ពផ្សាយ នៃព័ត៌មាន អាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងបុគ្គល ឬ ស្ថាប័នដែលបានបោះពុម្ពផ្សាយផ្សាយ ឬ ផ្សព្វផ្សាយនូវព័ត៌មានដែលហាមឃាត់ ដើម្បីឱ្យមានសំណង យោងតាមច្បាប់ អំពើនីត្យានុកូលភាព ។ (សូមមើល ក្រមរដ្ឋប្បវេណី គន្ថីទី ៥ ជំពូកទី ១៦ " អំពើនីត្យានុកូលភាព " និងជាពិសេស មាត្រា ៧៤៤ មាត្រា ៧៤៧ កថាខ័ណ្ឌទី ៣ និងមាត្រា ៧៦២ ) ។

ក្នុងន័យនេះ មាត្រានេះប្រហាក់ប្រហែលគ្នានឹង មាត្រា ១៥ នៃច្បាប់ ស្តីពី របបសារព័ត៌មាន ( ឆ្នាំ ១៩៩៥) ដែលចែងថា :

*" សារព័ត៌មាន " ពុំអាចផ្សាយដំណឹង រូបថត ឬ គំនូរ ដែលអាចឱ្យអ្នកអានស្គាល់ឈ្មោះ និងភិនភាគនៃ :*

*ស្ត្រីដែលទទួលរងគ្រោះដោយអំពើ រំលោភលើរាងកាយ ឬ អំពើចាប់បង្ខំសេពសន្ថវៈ*

*...បុគ្គលណាដែលត្រូវសារពត៌មានបំពានសិទ្ធិខាងលើនេះ មានសិទ្ធិប្តឹងទៅតុលាការដើម្បីទាមទារជម្ងឺចិត្ត ។"*

ទោះជាយ៉ាងណាក៏ដោយ ផ្ទុយនឹងមាត្រា ១៥ ក្នុង ច្បាប់ស្តីពី របបសាព័ត៌មាន ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានដាក់កំហិតការហាមឃាត់ ចំពោះករណីទាក់ទង នឹងអំពើរំលោភលើរាងកាយ ឬ អំពើរំលោភសេពសន្ថវៈ ហើយក៏មិនតម្រូវឱ្យជនរងគ្រោះ ត្រូវតែជាស្ត្រីដែរ ។ យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានការហាមឃាត់យ៉ាងខ្លាំង មកលើការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយនូវព័ត៌មានណាមួយ ដែលធ្វើឱ្យស្គាល់អត្តសញ្ញាណជនរងគ្រោះ ( បុរស ឬ ស្ត្រី នីតិជន ឬ អនីតិជន ) ដោយសារបទល្មើសនៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម យោងតាមច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ការហាមឃាត់នេះ មិនអនុវត្តក្នុងករណីដែល ជនរងគ្រោះផ្តល់ការយល់ព្រមដោយសេរី ពេញលេញ និងជូនដំណឹងជាមុន ចំពោះការបោះពុម្ពផ្សាយបង្ហាញឱ្យដឹងព័ត៌មាន ។ អញ្ញត្រកម្មនេះ សំខាន់ណាស់ នៅពេលដែលភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អាចទទួលការយល់ព្រមពីជនរងគ្រោះ ក្នុងការផ្សាយ បង្ហាញឱ្យដឹង ព័ត៌មាន (ឧទាហរណ៍ : ជាផ្នែកមួយនៃយុទ្ធនាការយល់ដឹងជាសាធារណៈ ) ដើម្បីលើកកម្ពស់ការយល់ដឹង អំពីគ្រោះថ្នាក់នៃការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ក្នុងករណីដែល ជនរងគ្រោះយល់ព្រមឱ្យប្រើចំពោះព័ត៌មានបែបនេះ " ការយល់ព្រម " មានន័យថា ជនរងគ្រោះត្រូវតែផ្តល់ការយល់ព្រមរបស់ខ្លួន ដោយសេរី ពេញលេញ និងត្រូវជូនដំណឹងដោយស្មោះ ពីការស្នើឱ្យមានការប្រើព័ត៌មាន មុនពេលការបោះពុម្ពផ្សាយនូវព័ត៌មានណាមួយ ។ ការយល់ព្រមនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

ទោះបីជា ជនរងគ្រោះមានការយល់ព្រម តុលាការអាចហាមឃាត់ការបោះពុម្ពផ្សាយ ឬ ការផ្សព្វផ្សាយនូវព័ត៌មាន ប្រសិនបើ ការផ្សាយទាំងនោះ ប៉ះពាល់ដល់ការស៊ើបអង្កេតដែលកំពុងដំណើរការរបស់តុលាការ ។

អញ្ញត្រកម្មទាំងនេះ ដែលទាក់ទងនឹងការយល់ព្រម គឺប្រហាក់ប្រហែលគ្នានឹងអញ្ញត្រកម្មដែលមានឃើញក្នុងមាត្រា ១៥ នៃច្បាប់ស្តីពី របបសារព័ត៌មាន ដែលចែងថា :

*" លើកលែងក្នុងករណី ដែលសាមីជន ឬ អ្នកអាណាព្យាបាល យល់ព្រមជាលាយលក្ខណ៍អក្សរ សារព័ត៌មានអាចផ្សព្វផ្សាយរឿងនេះបាន លើកលែងតែការផ្សាយនេះ នាំឱ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការ "* ។

ទោះជាយ៉ាងណាក៏ដោយ ស្របនឹងច្បាប់នេះ មានតែបុគ្គលដែលមានសមត្ថភាពផ្លូវច្បាប់ ក្នុងការធ្វើសកម្មភាពទេ ទើបអាចផ្តល់ការយល់ព្រម ឱ្យមានការបោះពុម្ពផ្សាយនូវព័ត៌មានដែលបង្ហាញពីអត្តសញ្ញាណ បែបនេះបាន ។ យោងតាមក្រមរដ្ឋប្បវេណី សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពី

លទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួនអាចលុបចោលបាន ។ ហេតុដូច្នេះអនីតិជន ដែលស្ថិតក្រោមអាណាព្យាបាល ឬ បុគ្គលដែលស្ថិតក្រោមហិតូបត្ថម្ភ មិនអាចផ្តល់ការយល់ព្រមរបស់ខ្លួនឡើយ ។ ( សូមមើល ក្រមរដ្ឋប្បវេណី គន្ថីទី ២ ជំពូកទី ១ ផ្នែកទី ៣ " សមត្ថភាព " ខាងឆន្ទះ និងផ្នែកទី ៤ " សមត្ថភាពក្នុងការធ្វើសកម្មភាព " ។

ការបោះពុម្ពផ្សាយ ឬ ផ្សព្វផ្សាយព័ត៌មាន ដែលអាចនាំឱ្យដឹងពីអត្តសញ្ញាណរបស់ជនរងគ្រោះជាអនីតិជន ឬ របស់សាក្សី គួរតែត្រូវហាមឃាត់ ទោះបីជាមានការយល់ព្រមពីឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ក៏ដោយ ។ នេះស្របទៅនឹងគោលការណ៍ណែនាំអង្គការសហប្រជាជាតិ ស្តីពី យុត្តិធម៌ក្នុងបញ្ហាដែលទាក់ទងនឹងជនរងគ្រោះជាអនីតិ-ជន និងសាក្សីនៃបទឧក្រិដ្ឋ ( ឆ្នាំ ២០០៥ ) ដែលចែងថា :

*" ជនរងគ្រោះជាកុមារ និងសាក្សី គួរតែទទួលបានការការពារការសម្ងាត់របស់ពួកគេ ជាបញ្ហាសំខាន់ " ហើយព័ត៌មានដែលទាក់ទងនឹង ការពាក់ព័ន្ធរបស់កុមារក្នុងដំណើរការយុត្តិធម៌ គួរតែទទួលបានការការពារ....តាមរយៈការរក្សាការសម្ងាត់ និងកំហិតការលាតត្រដាងព័ត៌មានដែលនាំ ឱ្យដឹងពីអត្តសញ្ញាណរបស់កុមារ ដែលគឺជាជនរងគ្រោះ ឬ សាក្សី នៅក្នុងដំណើការយុត្តិធម៌ " ។*

**" ព័ត៌មានណាមួយ ដែលនាំទៅដល់ការដឹងឮជាសាធារណៈ អំពីអត្តសញ្ញាណរបស់ជនរងគ្រោះ "**

បទប្បញ្ញត្តិនេះ ហាមឃាត់ការផ្តល់ប្រភេទព័ត៌មានណាមួយ ដែលអាចឱ្យសាធារណៈដឹងឮអំពីអត្តសញ្ញាណរបស់ជនរងគ្រោះ ដែលរួមមាន រូបថត គំនូរ ឈ្មោះ អាស័យដ្ឋាន ឬ ព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀត ។ នេះក៏ រាប់បញ្ចូលព័ត៌មានអំពីសមាជិកគ្រួសាររបស់ជនរងគ្រោះដែរ តាមរយៈនេះជនរងគ្រោះក៏អាចត្រូវបានស្គាល់ ប្រសិនបើអត្តសញ្ញាណសមាជិក គ្រួសារជនរងគ្រោះត្រូវគេបង្ហាញឱ្យដឹង ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៥០.- និរាករណ៍នៃច្បាប់ដែលផ្ទុយ**

ច្បាប់ស្តីពី " ការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស " ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៦/០១ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះ ត្រូវមានអាទិភាព ប្រសិនបើបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រានេះ ធ្វើនិរាករណ៍ច្បាប់ ឆ្នាំ ១៩៩៦ ដែលអនុវត្តពីមុនទាក់ទងនឹង អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ចាប់ពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលជាកាលបរិច្ឆេទប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហេតុដូច្នេះ ហើយច្បាប់ឆ្នាំ ១៩៩៦ ស្តីពី ការបង្ក្រាប អំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស (ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៦/០១) អស់សុពលភាពអនុវត្តតទៅទៀត ។

**" ច្បាប់នេះ ត្រូវមានអាទិភាព ប្រសិនបើបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិ នៃច្បាប់នេះ "**

កថាខ័ណ្ឌទី ២ នៃមាត្រានេះចែងថា ប្រសិនបើមានភាពមិនស្របគ្នាកើតមានឡើងរវាង បទប្បញ្ញត្តិនៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទៅនឹងបទប្បញ្ញត្តិនៃច្បាប់ណាមួយ ផ្សេងទៀត បទប្បញ្ញត្តិ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវតែអនុវត្ត ។ ទោះជាយ៉ាងណាក៏ដោយ ត្រូវតែយល់ពីកថាខ័ណ្ឌនេះ ក្នុងក្របខណ្ឌច្បាប់កម្ពុជា និងឋានានុក្រមនៃច្បាប់ និងឱ្យស្របតាមគោលការណ៍ដែលទទួលយកនៃការបកស្រាយច្បាប់ ។

នៅពេលដែលមានភាពមិនស្របគ្នាកើតឡើង រវាងបទប្បញ្ញត្តិនៃច្បាប់ផ្សេងៗគ្នា ដែលមានកំរិត ឋានានុក្រមខុសគ្នា ។ ក្នុងករណីនេះ បទប្បញ្ញត្តិច្បាប់ដែលមានឋានៈខ្ពស់ជាង មានអាទិភាពលើបទប្បញ្ញត្តិច្បាប់ដែលមានឋានៈទាបជាង ។ ច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើ អាជីវកម្មផ្លូវភេទ គឺជាច្បាប់ដែលត្រូវបានអនុម័តឡើងដោយរដ្ឋសភាជាតិ និងព្រឹទ្ធសភា ហើយត្រូវបានប្រកាសឱ្យ ប្រើដោយព្រះមហាក្សត្រ ដែលមានតួនាទីជាព្រះប្រមុខរដ្ឋ ។ ហេតុដូច្នេះ មាត្រានេះ មានន័យថា ក្នុងបរិបទនៃ ឋានានុក្រមច្បាប់កម្ពុជា ប្រសិនបើបទប្បញ្ញត្តិនៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានភាពមិនស្របគ្នា នឹងបទប្បញ្ញត្តិនៃឧបករណ៍ច្បាប់ដែលមានឋានៈទាបជាង នោះច្បាប់ ស្តីពី ការបង្ក្រាប អំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ

នឹងត្រូវមានអាទិភាព ។ ក្នុងករណីដែលមានបទប្បញ្ញត្តិដែលមិនស្របគ្នាកើតឡើង នៅក្នុងឧបករណ៍ច្បាប់ដែលមានកំរិតស្មើគ្នា ។ គោលការណ៍នៃការបកស្រាយច្បាប់ ( សូមមើលការពិភាក្សាក្នុងសេចក្តីផ្តើមខាងលើ ) ផ្តល់គោលការណ៍ខ្លះ ។

ជាពិសេសគួរតែចងចាំនូវវិធានពីរ :

១) ថ្មី និង ចាស់ ។ ច្បាប់ដែលថ្មីជាង នឹងមានអាទិភាពលើច្បាប់ដែលចាស់ជាង ។

២) ពិសេស និង ទូទៅ ។ ច្បាប់ពិសេស និងមានអាទិភាពលើច្បាប់ទូទៅ ។

ក្នុងករណីដែលច្បាប់ថ្មី ដែលជាច្បាប់ទូទៅមានបទប្បញ្ញត្តិមិនស្របគ្នា ដោយប្រយោលទៅ នឹងច្បាប់ចាស់ដែលជាច្បាប់ពិសេស ហេតុដូច្នេះ ច្បាប់ថ្មី នឹងមានអាទិភាព ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើច្បាប់ទូទៅថ្មី មានភាពស្ងប់ស្ងាត់ ដោយមិនបានចែង ទៅលើបញ្ហាជាក់លាក់ណាមួយ តែបញ្ហាទាំងនោះ មានចែងក្នុងច្បាប់ពិសេសចាស់ (ហេតុដូច្នេះច្បាប់ទូទៅថ្មី និងច្បាប់ពិសេសចាស់ មិនមានទំនាស់នឹងគ្នាទៅលើបញ្ហាទាំងនេះ ) ហេតុដូច្នេះ បទប្បញ្ញត្តិនៃច្បាប់ពិសេសចាស់ ដែលពាក់ព័ន្ធជាទូទៅ ត្រូវចាត់ទុកថានៅតែមានសុពលភាព ។យោងតាមមាត្រា ៥០ កថាខ័ណ្ឌទី ២ ច្បាប់ថ្មីស្តីពី " ការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ " ត្រូវមានអាទិភាព ប្រសិនបើ បទប្បញ្ញត្តិនៃច្បាប់ ចាស់ណាមួយ មានភាពមិនស្របគ្នា ជាមួយបទប្បញ្ញត្តិ នៃច្បាប់ថ្មី ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវ កម្មផ្លូវភេទ ។

គោលការណ៍នៃការបកស្រាយច្បាប់ទាំងនេះ ជួយដោះស្រាយភាពទំនាស់គ្នារវាង មាត្រា ២២ នៃច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលដាក់ទោស អស់មួយជីវិត ចំពោះការបង្ខាំងដែលមានស្ថានទម្ងន់ ) និងមាត្រា ៧ នៃច្បាប់ចាស់ ស្តីពីស្ថានទម្ងន់ទោស (ដែលអនុញ្ញាតឱ្យបទល្មើសដូចគ្នាត្រូវដាក់ទោសជាប់ពន្ធនាគាររយៈពេល ១៥ ឆ្នាំ )។ ដោយសារតែ ច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ នៅទីនេះជាច្បាប់ថ្មី ហើយអាចអះអាងថា មានលក្ខណៈជាច្បាប់ពិសេសជាង ច្បាប់ ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ បទប្បញ្ញត្តិអំពីទោសបញ្ញត្តិ ក្នុងមាត្រា ២២ នៃច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ មានអាទិភាពលើបទប្បញ្ញត្តិ ក្នុងមាត្រា ៧ នៃច្បាប់ ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

យ៉ាងណាមិញ ទោះបីជាមានខ្លឹមសារនៃបទប្បញ្ញត្តិ មាត្រា ៥០ កថាខ័ណ្ឌទី ២ នៃច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏ដោយ នោះច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញ ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងមិនមានអាទិភាពទេ ក្នុងករណីដែលច្បាប់ ស្តីពី ការបង្រ្កាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានភាពមិនស្របគ្នា ជាមួយនឹងបទប្បញ្ញត្តិនៃច្បាប់ ដែលមានឋានៈខ្ពស់ជាង ដូចជា រដ្ឋធម្មនុញ្ញជាដើម ឬ ក្នុងករណីប្រសិនបើច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានភាពមិនស្របគ្នាជាមួយនឹង បទប្បញ្ញត្តិនៃច្បាប់ថ្មី ដែលបានអនុម័ត និងប្រកាសឱ្យប្រើ ក្រោយៗទៀតនៃច្បាប់ ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ក្នុងករណីបែបនេះ ច្បាប់ដែលមានឋានៈខ្ពស់ជាង ឬ ច្បាប់អនុម័តក្រោយ នឹងមានអាទិភាព ជាងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ឧទាហរណ៍មួយទៀត ៖ ក្រមព្រហ្មទណ្ឌថ្មី ដែលបានចូលជាធរមាន យ៉ាងពេញលេញនៅខែ ធ្នូ ឆ្នាំ២០១០ គឺជាច្បាប់មួយដែលត្រូវបានអនុម័តក្រោយពីច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ហើយដែលច្បាប់ព្រហ្មទណ្ឌថ្មីនោះអាចមានបទប្បញ្ញត្តិដែលអាចចែងមានទំនាស់ទៅនឹង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។ យោងទៅតាមក្រមព្រហ្មទណ្ឌ (គន្ថីទី ៦ "អវសានប្បញ្ញត្តិ" មាត្រា ៦៧១ " និរាករណ៍ និងអានុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន ") បទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌដែលចូលជាធរមានពីមុន ដែលមិនស្របគ្នាទៅនឹងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មី ត្រូវចាត់ទុកថាមិនមានសុពលភាព ចំពោះតែបទប្បញ្ញត្តិណាដែលមិនស្របគ្នាតែប៉ុណ្ណោះ ។ យោងទៅតាមនោះដែរ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ នឹងនៅតែជាធរមានដដែល តែបើបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ មានទំនាស់គ្នាទៅនឹងបទប្បញ្ញត្តិដែលមានចែង នៅក្នុងក្រមព្រហ្មទណ្ឌ បទប្បញ្ញត្តិដែលមានចែងនៅក្នុង ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ នឹងត្រូវបានជំនួសតែពាក្យណាដែលផ្ទុយគ្នាប៉ុណ្ណោះ ។

យ៉ាងណាមិញ ចំពោះអំពើល្មើសដែលទាក់ទងនឹងបទល្មើសជួញដូរមនុស្ស ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ អាចត្រូវយកមកប្រើ ទោះបីជាមានទំនាស់គ្នាទៅនឹង បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ យោងតាមការទទួលស្គាល់ គោលការណ៍នៃការបកស្រាយច្បាប់ ដែលថាជាទូទៅ ច្បាប់ពិសេសមានអាទិភាពទៅលើច្បាប់ទូទៅ ។ គួរកត់សំគាល់ថា ក្រមព្រហ្មទណ្ឌដែលមិនមានចែងពីបទល្មើស " ជាក់លាក់ " ទាក់ទងនឹងការជួញដូរមនុស្ស ហេតុដូច្នេះហើយ ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ នៅតែជាច្បាប់គោល គ្រប់គ្រងទៅលើបទល្មើសដែលទាក់ទងទៅនឹងការជួញដូរមនុស្ស ។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌ ទទួលស្គាល់ឧត្តមភាព នៃច្បាប់ពិសេស ដែលមានទៅលើច្បាប់ទូទៅនៅក្នុងមាត្រា ៦៦៨ (ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក) គន្ថីទី ៥ "អន្តរប្បញ្ញត្តិ" ដែលចែងថា ៖

*"ចំពោះបទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសដោយច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌ ដោយឡែកផ្សេងទៀតដែលកំពុងនៅជាធរមាន ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះ ។*

*នៅក្នុងករណីដែលមានទំនាស់រវាងច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក និងបទប្បញ្ញត្តិ នៃក្រមនេះ ត្រូវអនុវត្តដោយអនុលោមតាមវិធានដែលមានចែងក្នុងគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ។*

*បទប្បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើ មិនត្រូវយកមកអនុវត្ត ចំពោះច្បាប់ព្រហ្មទណ្ឌ ដែលមានចរិតពិសេស ។ "*

ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ អាចត្រូវគេចាត់ទុកថាជាច្បាប់ព្រហ្មទណ្ឌពិសេសដោយផ្អែកទៅលើគោលបំណងរបស់ច្បាប់ដែលមានចែងនៅក្នុងមាត្រា ១ "បង្ក្រាបអំពើជួញដូរ

មនុស្ស " និងដើម្បី "អនុវត្តឱ្យបានសមស្របផងដែរ តាមពិធីសារអង្គការ សហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ" ។ យោងតាមនោះផងដែរ ក្នុងពេលមានទំនាស់គ្នាដោយផ្ទាល់យ៉ាងច្បាស់ រវាងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ និង បទប្បញ្ញត្តិ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ចំពោះករណីដែលទាក់ទងនឹងអំពើជួញដូរមនុស្ស នៅតែត្រូវអនុវត្ត បទប្បញ្ញត្តិច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។

លើសពីនេះទៀត ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គួរតែបកស្រាយមិនឱ្យផ្ទុយទៅនឹងបទប្បញ្ញត្តិ នៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាជារដ្ឋភាគី ។ វិធីសាស្ត្រនេះត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាធម្មនុញ្ញ របស់ប្រទេសកម្ពុជា ដែលនៅក្នុងសេចក្តីសម្រេច ខែ កក្កដា ឆ្នាំ ២០០៧ បានបកស្រាយច្បាប់កម្ពុជា ដើម្បីឱ្យស្របទៅនឹងបទប្បញ្ញត្តិ នៃសន្ធិសញ្ញាសិទ្ធិ មនុស្សអន្តរជាតិ ។

## មាត្រា ៥១.- ការជំនួសដោយច្បាប់ក្រមព្រហ្មទណ្ឌ

**មាត្រា ២ មាត្រា ៣ មាត្រា ៤ និងមាត្រា ៦ នៃច្បាប់នេះ ត្រូវជំនួសដោយបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ នៅពេលដែលក្រមនោះ ចូលជាធរមាន ។**

មាត្រានេះ ចែងយ៉ាងច្បាស់ថា មាត្រាជាក់លាក់មួយចំនួន ដូចជា ( មាត្រា ២ មាត្រា ៣ មាត្រា ៤ និងមាត្រា ៦ ) នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងត្រូវបានជំនួស ដោយបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មី នៅពេលដែលក្រមព្រហ្មទណ្ឌថ្មីចូលជាធរមាន ។

នៅពេលដែល ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានអនុម័តក្រមព្រហ្មទណ្ឌដែលកំពុងនៅជាសេចក្តីព្រាងនៅឡើយ ។ ក្រោយមកក្រមព្រហ្មទណ្ឌត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។ គន្ថីទី ១ នៃក្រមព្រហ្មទណ្ឌចូលជាធរមាននៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៩ សម្រាប់នៅទីក្រុងភ្នំពេញ រីឯនៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០០៩ ចូលជាធរមាន នៅទូទាំងប្រទេស ។ គន្ថទី ២ ដល់ គន្ថីទី ៦ នៃក្រមព្រហ្មទណ្ឌ ចូលជាធរមាន មួយឆ្នាំក្រោយមកទៀត ឬនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១០ សម្រាប់នៅទីក្រុងភ្នំពេញ និងនៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១០ ចូលជាធរមាន នៅទូទាំងប្រទេស ។

គួរកត់សំគាល់ថាមាត្រា ២ "ការអនុវត្តច្បាប់នេះនៅក្នុងដែនដី" មាត្រា ៣ "ការអនុវត្តច្បាប់នេះនៅក្រៅដែនដី" មាត្រា ៤ "ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ" និងមាត្រា ៦ "បទល្មើសត្រួតគ្នា" ជាបទប្បញ្ញត្តិទូទៅនៅក្នុងជំពូកទី ១ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ មាត្រាទាំងនេះ ឥឡូវនេះត្រូវបានជំនួស ដោយគន្ថីទី ១ នៃក្រមព្រហ្មទណ្ឌថ្មី ដែលចែងអំពីបទប្បញ្ញត្តិទូទៅ សម្រាប់ការអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ ។ នេះស្របទៅនឹងមាត្រា ៦៧០ ( ការពន្លាតការអនុវត្តគន្ថីទី ១ "បទប្បញ្ញត្តិទូទៅ" នៃក្រមនេះ) ដែលចែងថា *"គន្ថីទី ១*

*(បទប្បញ្ញត្តិទូទៅ) នៃក្រមនេះត្រូវយកទៅអនុវត្តចំពោះគ្រប់បទប្បញ្ញត្តិ ព្រហ្មទណ្ឌដោយឡែកដទៃទៀត លើកលែងតែមានបទប្បញ្ញត្តិផ្សេងចែងផ្ទុយពីនេះ"។*

ទោះបីយ៉ាងណាក៏ដោយ ក្រៅពីមាត្រា ២ មាត្រា ៣ មាត្រា ៤ មាត្រា ៦ នៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏នៅមានមាត្រាមួយចំនួនផ្សេងទៀត នៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ ក៏ត្រូវបានជំនួសដោយក្រមព្រហ្មទណ្ឌថ្មីផងដែរ តាមរយៈការអនុវត្តគោលការណ៍ ដែលទទួលយកអនុវត្តជាទូទៅ នៃការបកស្រាយច្បាប់ ។ ដោយយោងតាមគោលការណ៍នោះ ប្រសិនបើមានភាពមិនស្របគ្នា រវាងបទប្បញ្ញត្តិ នៃច្បាប់ពីរផ្សេងគ្នា គឺច្បាប់ដែលថ្មីជាង ជាទូទៅត្រូវអនុវត្តដោយមានអាទិភាព (សូមពិនិត្យមើល ការបកស្រាយពន្យល់ក្នុងមាត្រា ៥០ កថាខ័ណ្ឌទី ២ ខាងលើ ) ។

## មាត្រា ៥២.- ការអនុវត្តច្បាប់នេះ

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

មាត្រានេះ មានន័យថា ច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចូលជាធរមានភ្លាម នៅទូទាំងប្រទេស ក្រោយពីការប្រកាសឱ្យប្រើកាលពី ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។ នេះស្របទៅនឹងមាត្រា ៩៣ កថាខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ៤០ ក.យ.ប្រក/០៩

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩

**ប្រកាស**

**ស្តីពី**

**ការបង្កើតក្រុមការងារត្រួតពិនិត្យសេចក្តីអធិប្បាយពន្យល់លើច្បាប់ស្តីពី**

**ការបង្ក្រាបអំពើជួញដូរ និង អំពើធ្វើអាជីវកម្មផ្លូវភេទ**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលបានប្រកាសអោយប្រើដោយអនុក្រឹតលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ប្រកាសអោយប្រើច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតក្រុមការងារត្រួតពិនិត្យសេចក្តីអធិប្បាយពន្យល់លើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អង្គ វង្ស វឌ្ឍានា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| ២-ឯកឧត្តម | **ហ៊ី សោភា** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣-លោកជំទាវ | **ចាន់ សុខ្លាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន(ទទួលបន្ទុកផ្ទាល់) |
| ៤-ឯកឧត្តម | **យូ ប៊ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ | សមាជិក |
| ៥-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | | | សមាជិក |
| ៦-រដ្ឋលេខាធិការក្រសួងកិច្ចការនារី | | | សមាជិក |
| ៧-ឯកឧត្តម | **ជីវ កេង** | ប្រធានសាលាដំបូងក្រុងភ្នំពេញ | សមាជិក |
| ៨-លោក | **គី ខេមលីន** | អគ្គនាយករងក្រសួងយុត្តិធម៌ | សមាជិកអចិន្ត្រៃយ៍ |

**ប្រការ ២.**

ក្រុមការងារនេះ មានភារៈកិច្ចរៀបចំពិនិត្យសេចក្តីកំណត់ពន្យល់លើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីរៀបចំបោះពុម្ព និង ធ្វើការផ្សព្វផ្សាយ ។

**ប្រការ ៣.**

សមាជិកទាំងអស់នៃក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ ៤.**

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមក្នុងប្រការ ១ និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ៕/

រដ្ឋមន្ត្រី

អង្គ-វង្សវឌ្ឍានា

**ចម្លងជូន :**

-សាមីខ្លួន

-ឯកសារ-កាលប្បវត្តិ